ហ៊ុន សែន

# ១៣ ទសវត្ស
# នៃ
# ដំណើរកម្ពុជា

ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ
ផ្សព្វផ្សាយឡើងវិញ [illegible]
ការផ្សព្វផ្សាយតាមគេហទំព័រ www.cnv.org.kh
ខែ មិថុនា ឆ្នាំ ២០១១

ការផ្សាយរបស់កាសែត
រស្មីកម្ពុជា

# អារម្ភកថា

១៣ ទសវត្សមកនេះ បដិវត្តន៍កម្ពុជាត្រូវបានដំណើរការក្រោមរបបសង្គមខុសៗ គ្នា ក្រោមបរិយាកាសនៃសភាពការណ៍ទាំងក្នុង និងក្រៅប្រទេសខុសៗគ្នា។ ជំហាននីមួយៗ ត្រូវទៅមុខ និងថយក្រោយ ត្រូវដើរត្រង់ និងបត់បែនក្នុងយុទ្ធសាស្ត្រ យុទ្ធវិធីស្មុគស្មាញ រហូតដល់ "ការបដិវត្តន៍មួយដែលត្រូវធ្វើឡើងវិញ" ជាមួយនឹងជ័យជំនះមួយ ដែលមិនអាចប៉ាន់ស្មានបាន និងកម្រមានក្នុងប្រវត្តិសាស្ត្រ នៃបដិវត្តន៍នានាលើសកលលោក។

ជាមួយនឹងចរិតនៃក្រឹត្យក្រមរួម អាស្រ័យដោយ "កម្ពុជា" ក៏ជាចំណែកមួយនៅលើផែនទីសកលលោក ចរិតពិសេសដោយឡែកនៃបដិវត្តន៍របស់ប្រទេសនេះ មានលក្ខណៈស្មុគស្មាញពិបាកយល់ជាច្រើន ហើយត្រូវធ្វើដំណើរតាមរបៀបមួយមិនធម្មតា ព្រោះថា៖

- សាម៉ីខ្លួននៃសង្គមកម្ពុជា ប៉ុន្មានជំនាន់តៗ មកហើយ សុទ្ធតែមានលក្ខណៈស្មុគស្មាញ
- សភាពការណ៍អន្តរជាតិ មានការវិវត្តន៍ប្រែប្រួលស្មុគស្មាញ, ហើយ
- សាម៉ីបដិវត្តន៍កម្ពុជាខ្លួនឯងផ្ទាល់ ក៏មានលក្ខណៈស្មុគ្រស្មាញជាច្រើន

ចរិតពិសេសដោយឡែកនៃដំណើរកម្ពុជា ក៏ធ្លាប់ជាមូលបទនៃការស្រាវជ្រាវរបស់អ្នកនិពន្ធ អ្នកស្រាវជ្រាវនានា ក្នុង និងក្រៅប្រទេស។

នៅក្នុងប្រទេស ក្រៅពីសៀវភៅ "១០ ឆ្នាំនៃដំណើរកម្ពុជា" ដែលខ្លួនខ្ញុំផ្ទាល់បានសរសេរ ហើយបោះពុម្ពផ្សាយក្នុងឱកាសខួបទី ១០ ទិវាបុណ្យជាតិ ៧ មករា ក៏នៅមានការស្រាវជ្រាវខ្លះទៀត ដែលមានជាចង្កោមសរុបរបស់គណៈស្រាវជ្រាវប្រវត្តិសាស្ត្របក្សប្រជាជនបដិវត្តកម្ពុជា។

នៅក្រៅប្រទេស ការស្រាវជ្រាវដែលមានការលេចធ្លោ មានជាអាទិ៍ "ព្រឹត្តិការណ៍បន្ទាប់បដិវត្តន៍" របស់លោក វិល្យាម ស្អូវក្រុសស៍, "ពេលសង្គ្រាមចប់" របស់អ្នកស្រី អេលីហ្សាបែត បេឃ័រ, "បងប្អូនដែលជាសត្រូវនឹងគ្នា" របស់លោក ណាយ៉ាន់ ចាន់ដា, "តើ ប៉ុល ពត ឡើងកាន់អំណាចរបៀបណា" របស់លោក បែន គៀរណេន, "ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា" របស់លោក យ. យ. មីហេយ៉េរ។

ដោយឡែក ក្នុង "១៣ ទសវត្សនៃដំណើរកម្ពុជា" ដែលខ្ញុំបានស្រាវជ្រាវ និងសរសេរនាពេលនេះ អាចនិយាយបានថា ក៏មានលក្ខណៈដោយឡែករបស់ខ្លួន ឬថ្មីពីការស្រាវជ្រាវខាងលើ ដែលការស្រាវជ្រាវនិពន្ធខាងលើនេះដែរ ទោះបីមានខ្លះនិយាយត្រង់ចំបញ្ហាកម្ពុជា ឬខ្លះនិយាយដល់ឥណ្ឌូចិន ដែលក្នុងនោះមានមួយផ្នែកទាក់ទងដល់កម្ពុជា ក៏ច្រើនតែជា "ការរៀបរាប់ព្រឹត្តិការណ៍ វិភាគសភាពការណ៍" ប៉ុណ្ណោះ។ ជាធម្មតាទេ នៅពេលគេជាជនបរទេស ហើយសិក្សា និងសរសេរពីបញ្ហាកម្ពុជា ទោះបីយ៉ាងណាក៏មានលក្ខណៈមិនដូចជាជនកម្ពុជា ដែលសិក្សា និងសរសេរបញ្ហារបស់ប្រទេសខ្លួនផ្ទាល់ដែរ។

បញ្ហាផ្ទាល់ដោយឡែកនៃបដិវត្តន៍កម្ពុជាដែលបានស្រាវជ្រាវ និងលាតត្រដាងក្នុងសៀវភៅនេះ អាចមានចំណុចថ្មីប្លែកពីអ្នកស្រាវជ្រាវមុនៗ ហើយមានចំណុចខ្លះទៀត ទោះបីមិនថ្មីសុទ្ធសាធ និងទាំងស្រុងពីអ្នកស្រាជ្រាវមុនៗ តែវាក៏នៅតែជាចំណុចថ្មីលើការវិភាគបន្ថែម និងលើការវិភាគខ្លះ ដែលផ្សេងទាំងស្រុងពីការវិភាគមុនៗ។ ហេតុនេះ សូម្បីតែការវិភាគពីចរិតវណ្ណៈរបស់សីហនុ ឬធាតុពិតនៃរបប ប៉ុល ពត ដែលបានអនុវត្តនៅកម្ពុជាមកទល់នឹងពេលនេះ ក៏ជាបញ្ហាវិភាគដ៏ចម្រូងចម្រាស់ មិនទាន់ឯកភាពគ្នានៅឡើយ។

ទន្ទឹមនឹងនេះដែរ មិនគ្រាន់តែអ្នកស្រាវជ្រាវ អ្នកនិពន្ធ អ្នកវិទ្យាសាស្ត្រ

នយោបាយ ទស្សនវិទូ ប្រវត្តិវិទូ និងអ្នកនយោបាយបរទេស នៅមានការវិភាគខុសៗ គ្នា នៅក្នុងក្របខ័ណ្ឌអង្គការចាត់តាំងបដិវត្ត ក៏នៅមិនទាន់មានការវិភាគចុះសម្រុងគ្នានៅឡើយដែរ។

រួមចំណែកជាអ្នកវិភាគ ជាអ្នកទទួលខុសត្រូវម្នាក់ចំពោះមុខប្រវត្តិសាស្ត្រ និងជាតិកម្ពុជា ការស្រាវជ្រាវដែលបង្កើតឡើងបាននូវសៀវភៅ "១៣ ទសវត្សនៃដំណើរកម្ពុជា" នឹងបញ្ចាក់នៅពេលនេះ លើជំពូកពីរធំៈ ទី ១ - **ការបដិវត្តន៍ និងការក្បត់បដិវត្តន៍** និង ទី ២ - **ការបដិវត្តន៍មួយដែលត្រូវធ្វើឡើងវិញ**។

ក្នុង "*ការបដិវត្តន៍ និងការក្បត់បដិវត្តន៍*" ការស្រាវជ្រាវរបស់ខ្ញុំប្រមូលផ្តុំជាសំខាន់ទៅលើៈ

- ស្ថានភាពសង្គមមុនឆ្នាំ ១៩៥៥ និងការបដិវត្តន៍
- ស្ថានភាពសង្គមមុនឆ្នាំ ១៩៧០ និងការបដិវត្តន៍
- ការតស៊ូរំដោះជាតិ និងការក្បត់បដិវត្តន៍

រីឯក្នុង "*ការបដិវត្តន៍មួយដែលត្រូវធ្វើឡើងវិញ*" បញ្ហាដែលបានប្រមូលផ្តុំ សំខាន់គឺលើៈ

- ធាតុពិតនៃរបប ប៉ុល ពត
- ការរីកចំរើនឡើងនៃកម្លាំងស្នេហាជាតិ ក្រោមរបបប្រល័យពូជសាសន៍ ប៉ុល ពត និងការគួបផ្សំរវាងកម្លាំងបដិវត្តជាតិ និងកម្លាំងអន្តរជាតិ ក្នុងការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត
- ការរស់ឡើងវិញរបស់ជាតិ ក្នុងស្ថានភាពមានសន្តិភាពផង និងមានសង្គ្រាមផង

សៀវភៅដែលត្រូវបោះពុម្ពផ្សាយលើកនេះ ត្រូវបានដកស្រង់មួយផ្នែកពី

និក្ខេបបទ ដែលមានចំណងជើងថា "លក្ខណៈពិសេសដោយឡែក នៃដំណើរការបដិវត្តន៍កម្ពុជា" ជានិក្ខេបបទថ្នាក់បណ្ឌិតទស្សនវិជ្ជា។ អាស្រ័យដោយបានចេញផ្សាយរួចហើយនូវសៀវភៅ "១០ ឆ្នាំនៃដំណើរកម្ពុជា" ដូចនេះក្នុងសៀវភៅនេះ មិនបានរៀបរាប់លំអិតឡើងវិញអំពីរយៈពេល ១២ ឆ្នាំចុងក្រោយនេះ និងទិសសំរាប់ពេលខាងមុខឡើយ។

មុននឹងចាប់ផ្តើមអានសៀវភៅនេះ អ្នកនិពន្ធមានក្តីសង្ឃឹមថា មិត្តអ្នកអានទាំងអស់ពិតជាមានការយោគយល់ ចំពោះការខ្វះខាតខ្លះដែលអាចកើតមាន ហើយនេះក៏ជាប្រការមួយ ដែលអាស្រ័យដោយពេលវេលានៃការសរសេរមានរយៈពេលខ្លី ហើយពេលវេលាដ៏ខ្លីនោះ តែងតែត្រូវបែងចែកភាគធំបំផុតអោយភារទទួលខុសត្រូវធ្ងន់ធ្ងរ នៃការងាររបស់រដ្ឋាភិបាល។ ការព្យាយាមដ៏មុតមាំណាស់ត្រូវបានបំពេញ ជំនួសនូវពេលវេលាដែលត្រូវការចាំបាច់ទាំងឡាយ ដើម្បីសរសេរ និងស្រាវជ្រាវនេះ។

*ភ្នំពេញ ថ្ងៃទី ៧ មករា ឆ្នាំ ១៩៩១*

**ហ៊ុន សែន**

# មាតិការឿង


<u>ជំពូក ១</u>

**ការបដិវត្តន៍ និងការក្បត់បដិវត្តន៍** ទំព័រ ១

ស្ថានភាពសង្គមមុនឆ្នាំ ១៩៥៥ និងការបដិវត្តន៍ ......................៣

ស្ថានភាពសង្គមមុនឆ្នាំ ១៩៧០ និងការបដិវត្តន៍......................៤៦

ការតស៊ូរំដោះជាតិ និងការក្បត់បដិវត្តន៍..................................១០០

<u>ជំពូក ២</u>

**ការបដិវត្តន៍មួយ ត្រូវធ្វើឡើងវិញ** ទំព័រ ១១៨

ធាតុពិតនៃរបប ប៉ុល ពត.....................................................១២០

ការរីកចំរើនឡើងនៃកម្លាំងបដិវត្តន៍ និងកម្លាំងស្នេហាជាតិ ក្រោមរបប ប្រល័យពូជសាសន៍ ប៉ុល ពត និងការរួបផ្សំរវាងកម្លាំងបដិវត្ត ជាតិ និងកម្លាំងអន្តរជាតិ ក្នុងការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត .........................................................................១៥៧

ការរស់ឡើងវិញរបស់ជាតិ ក្នុងស្ថានភាពមានសន្តិភាពផង និង មានសង្គ្រាមផង ..................................................................១៨៤

**ឯកសារពិចារណា** ទំព័រ ១៩៨

**ជំពូក ១**

# ការបដិវត្តន៍
# និងការក្បត់បដិវត្តន៍

ផ្នែកទី ១

## ស្ថានភាពសង្គមមុនឆ្នាំ ១៩៥៥ និងការបដិវត្តន៍

ផ្នែកទី ២

## ស្ថានភាពសង្គមមុនឆ្នាំ ១៩៧០ និងការបដិវត្តន៍

ផ្នែកទី ៣

## ការតស៊ូរំដោះជាតិ និងការក្បត់បដិវត្តន៍

ផ្នែកទី ១

# ស្ថានភាពសង្គមមុនឆ្នាំ ១៩៥៥ និង ការបដិវត្តន៍

*បដិវត្តន៍របស់ប្រជាជនដែលត្រូវសង្កត់សង្កិន ពេលណាក៏មានមូលហេតុត្រឹមត្រូវ ដើម្បីធ្វើបដិវត្តន៍ មានគោលដៅច្បាស់លាស់ដើម្បីសំរេចការបដិវត្តន៍។ នៅកម្ពុជា ប្រសិនបើមិនទាន់និយាយដល់រយៈពេលដែលបារាំងចូលមកដាក់នឹមត្រួតត្រា ក៏ការតស៊ូបានមានជាបន្តបន្ទាប់ ដែលចាប់ផ្តើមពីការទាមទារសេរីភាព ប្រជាធិបតេយ្យ ប្រឆាំងការជិះជាន់ ទោះជាសង្គមកម្ពុជានាពេលនោះ គ្មានលក្ខណៈសម្បត្តិសំរាប់ការបដិវត្តន៍ ដើម្បីផ្លាស់ប្តូរបែបផែនផលិតកម្មក៏ដោយ ក៏ការតស៊ូសំខាន់ប្រមូលផ្តុំក្នុងទំនាក់ទំនងសង្គម ពិសេសរវាងកសិករ ជាមួយពួកសក្តិភូមិម្ចាស់ដី អាស្រ័យដោយស្ថានភាពសង្គមពេលនោះជារបបសក្តិភូមិ ដូច្នេះទំនាស់វាកើតមានស្រាប់តាំងពីយូរយារមកហើយ រវាងកសិករជាមួយសក្តិភូមិម្ចាស់ដី។ ម្យ៉ាងទៀត វាក៏មានការតស៊ូដើម្បីប្រឆាំងការកាន់កាប់និងទន្ទ្រានយកទឹកដីពីសំណាក់សក្តិភូមិសៀម និងសក្តិភូមិវៀតណាមផងដែរ។*

ឆ្នាំ ១៨៦៣ ស្តេច នរោត្តម ដែលជាតំណាងអោយវណ្ណៈសក្តិភូមិនៅកម្ពុជាពេលនោះ បានទទួលយកនូវការត្រួតត្រារបស់អាណានិគមនិយមបារាំង ក្រោមរូបភាពនៃរបបអាណាព្យាបាលជំនួសការគ្រប់គ្រងបែបសហព័ន្ធខ្មែរ-សៀម នៅបណ្តាខេត្តភាគខាងលិច និងការចំណុះសៀម លើការតែងតាំងមហាក្សត្រ និងកិច្ចការផ្សេងទៀត ដែលមានអង្គេសនៅពីខាងក្រោយសក្តិភូមិសៀម។ នេះ ជាការបន្តនយោបាយ ព្រះបាទអង្គឌួង មុនពេលសុគតទៅ។ ពិតមែនតែពេលនោះ បារាំងពុំទាន់ហ៊ានរឹបអូសយកកម្ពុជាទាំងស្រុង អាស្រ័យដោយម្យ៉ាងបារាំងត្រូវឆ្ងងកាត់ការលំបាកជាច្រើន ដើម្បីសំរេចនូវការឈ្លានពានរបស់ខ្លួននៅវៀតណាម ម្យ៉ាងទៀតត្រូវទប់ទល់នឹងការប៉ុនប៉ងរបស់របបសក្តិភូមិសៀម ដែលចង់កាន់កាប់ប្រទេសខ្មែរដែរ។ ទោះជាបារាំងមិនទាន់ត្រួតត្រាទាំងស្រុង ប៉ុន្តែក្រោមសន្ធិសញ្ញារវាងបារាំង ជាមួយសក្តិភូមិខ្មែរ ថ្ងៃ ១១ សីហា ១៨៦៣ ដែលកម្ពុជាត្រូវស្ថិតក្រោមរបបអាណាព្យាបាល គឺប្រទេសកម្ពុជាបានផ្ទេរពីរបបសក្តិភូមិមកកាន់របបអាណានិគមនិយម និងពាក់កណ្តាលសក្តិភូមិលើវិស័យប្រជាជាតិ ទំនាស់បានចាប់ផ្តើមឡើងភ្លាម គឺរវាងប្រជាជាតិកម្ពុជា ជាមួយអាណានិគមនិយមបារាំង។ ហើយនៅឆ្នាំ ១៨៦៤ ពេលបារាំងចុះហត្ថលេខាលើសន្ធិសញ្ញាបារាំង-សៀម ដែលមានលក្ខណៈជាការប្តូរគ្នា គឺសក្តិភូមិសៀមត្រូវទទួលស្គាល់នូវសិទ្ធិ និងផលប្រយោជន៍របស់បារាំងនៅកម្ពុជា ឯបារាំងក៏ត្រូវយល់ព្រមកាត់ខេត្តបាត់ដំបងសៀមរាប ឧត្តរមានជ័យ ព្រះវិហារ និងកោះកុងរបស់កម្ពុជាទៅអោយសៀម ដែលការសម្របសម្រួលនេះ ត្រូវបានចុះហត្ថលេខាលើសន្ធិសញ្ញាបារាំង-សៀម ក្នុងឆ្នាំ ១៨៦៧។ ដូច្នេះ កម្ពុជាពេលនោះត្រូវកាត់ជា

*ពីរ មួយក្រោមការត្រួតត្រារបស់បារាំង មួយទៀតក្លាយទៅជាចំណែកមួយនៃដែនដីរាជាណាចក្រសៀម។ អាស្រ័យហេតុនេះ ប្រជាជាតិកម្ពុជានាពេលនោះ មិនគ្រាន់តែប្រឈមមុខជាមួយអាណានិគមនិយមបារាំងមួយប៉ុណ្ណោះទេ ប៉ុន្តែត្រូវប្រឈមមុខនឹងការបាត់បង់ទឹកដីមួយផ្នែកទៀត ដែលវាបានកើតឡើងនូវទំនាស់មួយទៀត រវាងប្រជាជាតិកម្ពុជា ជាមួយសក្តិភូមិសៀម ដែលទំនាស់នេះបានអូសបន្លាយរហូតដល់ឆ្នាំ ១៩០៧ ពេលមានសន្ធិសញ្ញាបារាំង-សៀម ដែលសៀមបានប្រគល់ខេត្តទាំងប៉ុន្មាននេះមកអោយបារាំងវិញ។ ចាំបាច់ត្រូវវិភាគវែកញែកអោយច្បាស់ថា ការដែលបារាំងដាក់ការកៀបសង្កត់ចំពោះរាជាណាចក្រសៀម ដើម្បីចុះហត្ថលេខាលើសន្ធិសញ្ញាបារាំង-សៀម បង្ខំអោយសៀមប្រគល់ខេត្តទាំង ៥ មកបារាំងវិញ គឺមិនមែនជាផលប្រយោជន៍របស់កម្ពុជានោះឡើយ ទោះបីជាខេត្តទាំង ៥ នេះបានស្ថិតស្ថេររហូតសព្វថ្ងៃជារបស់កម្ពុជាក៏ដោយ ប៉ុន្តែផ្ទុយទៅវិញគឺជាផលប្រយោជន៍បារាំង ព្រោះសន្ធិសញ្ញាបារាំង-សៀម អំពីការប្រគល់ខេត្តទាំង ៥ នេះ ធ្វើឡើងក្រោយសន្ធិសញ្ញាថ្មីមួយទៀត រវាងបារាំងជាមួយស្តេចប្រទេសខ្មែរ នាថ្ងៃ ១៧ មិថុនា ១៨៨៤ ដែលសន្ធិសញ្ញានេះ បានបញ្ជាក់ច្បាស់ពីការដាក់កម្ពុជា ក្រោមការត្រួតត្រាទាំងស្រុងរបស់បារាំង ដូច្នេះ នេះជាផលប្រយោជន៍បារាំងទាំងស្រុង។*

*ទំនាស់មានការផ្លាស់ប្តូរជារូបភាព ប៉ុន្តែខ្លឹមសារគ្មានការផ្លាស់ប្តូរទេ។ ការផ្លាស់ប្តូរជារូបភាពនៅត្រង់ ពីឆ្នាំ ១៨៦៤ ដល់ឆ្នាំ ១៩០៧ ទំនាស់ប្រជាជាតិ ត្រូវចែកចេញជាពីរ មួយជាមួយអាណានិគមនិយមបារាំង មួយទៀតគឺជាមួយសក្តិភូមិសៀម។ ក្រោយឆ្នាំ ១៩០៧ ទំនាស់ប្រមូលផ្តុំ*

*រវាងប្រជាជាតិកម្ពុជា ជាមួយអាណានិគមនិយមបារាំង។ ក្នុងរយៈពេលជាមួយគ្នានោះ ទំនាស់រវាងកសិករ ប្រជាពលករ ជាមួយសក្តិភូមិម្ចាស់ដីដែលមានស្រាប់មកហើយ ក៏បានកើនឡើងយ៉ាងស្រួចស្រាល់ ព្រោះម្យ៉ាង ថ្វីត្បិតតែបារាំងបានដាក់នឹមត្រួតត្រាលើកម្ពុជា ប៉ុន្តែបារាំងនៅតែរក្សាទុករបបសក្តិភូមិឱនថយនេះ សំរាប់ធ្វើជាបរិវារដដែល ម្យ៉ាងទៀតអាស្រ័យដោយ បែបផែនផលិតកម្មនៃរបបសក្តិភូមិឱនថយនេះគ្មានការផ្លាស់ប្តូរ ថ្វីត្បិតតែរយៈពេលចុងក្រោយនៃរបបអាណានិគមនិយមបារាំងមានការកើនឡើងបន្តិចបន្តួចអំពីកម្លាំងផលិតកម្ម សំខាន់មានការលូតលាស់ក្នុងកំរិតមួយអំពីឧស្សាហកម្មតូច សិប្បកម្ម ការបង្កើតឡើងនូវកសិដ្ឋានដំណាំឧស្សាហកម្ម និងការកែទម្រង់លើការប្រើប្រាស់ និងកម្មសិទ្ធិលើដីធ្លី ដែលបានកែសម្រួលបន្តិចបន្តួចអំពីទំនាក់ទំនងផលិតកម្មដោយទំនាក់ទំនងផលិតកម្មមូលធនបានរីកចំរើនឡើង បើប្រៀបធៀបជាមួយរយៈកាលមុនបារាំង ចូលមកត្រួតត្រាប្រទេសកម្ពុជា ដែលប្រការនេះ បាននាំមកនូវការកើតឡើងនូវវណ្ណៈកម្មករនៅកម្ពុជាមួយភាគតូច។ ដូច្នេះធាតុពិតនៃសង្គមកម្ពុជានាសម័យកាលនោះ ជា "<u>សង្គមអាណានិគមនិយម និងពាក់កណ្តាលសក្តិភូមិ</u>"។ អាណានិគមនិយមគឺនៅត្រង់បារាំងត្រួតត្រាទាំងស្រុង ឯពាក់កណ្តាលសក្តិភូមិ នៅត្រង់បារាំងរក្សាទុកស្តេច និងរាជវង្សខ្មែរ តែគ្រាន់តែជានិមិត្តរូប និងជាបរិវារ។ ម្យ៉ាងទៀតទំនាក់ទំនងផលិតកម្ម ក៏ស្ថិតក្នុងទំនាក់ទំនងផលិតកម្មសក្តិភូមិក្រោមអាណានិគមនិយម។*

*អាស្រ័យដោយធាតុពិតនៃសង្គមកម្ពុជា ជាសង្គមអាណានិគម និងពាក់កណ្តាលសក្តិភូមិ ខ្លឹមសារនៃទំនាស់ គឺជាទំនាស់រវាងប្រជាជាតិកម្ពុ*

ជា ជាមួយអាណានិគមនិយមបារាំង និងរវាងកសិករ ប្រជាពលករ ជាមួយសក្តិភូមិម្ចាស់ដី ប៉ុន្តែ ទំនាស់រវាងប្រជាជាតិទាំងមូល ជាមួយអាណានិគមនិយមបារាំង គឺជាទំនាស់មូលដ្ឋានបំផុត។

លើមូលដ្ឋានទំនាស់ ប្រសិនបើនិយាយអំពីទ្រឹស្តី គេត្រូវដំណើការបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ដែលសំខាន់គឺបដិវត្តន៍ប្រជាជាតិតាំងពីដំបូង គ្រាដែលបារាំងចូលមកដល់ ហើយអាចនឹងដណ្តើមបានជោគជ័យ ឬហោចណាស់ក៏ជំរុញចលនាតស៊ូអោយរីកធំធាត់ក្នុងជំហានមួយវែង ហើយរក្សាបាននូវចលនានេះ ប្រសិនបើមានបក្សនយោបាយដឹកនាំត្រឹមត្រូវ និងលក្ខណៈសម្បត្តិអន្តរជាតិអនុគ្រោះ ព្រោះបារាំង មួយផ្នែកត្រូវប្រឈមមុខជាមួយប្រជាជាតិខ្មែរ រាប់ទាំងរាជវង្សានុវង្សដែលស្នេហាជាតិផង និងមួយផ្នែកទៀត បារាំងត្រូវមានទំនាស់ជាមួយសក្តិភូមិសៀម ដែលទំនាស់នេះ ក៏ជាទំនាស់រវាងបារាំងជាមួយអង់គ្លេសផងដែរ។ ម្យ៉ាងទៀត នៅក្នុងរាជវង្សានុវង្ស មន្ត្រីនៅក្នុងរាជវាំងពេលនោះក៏មានការបែកបាក់យ៉ាងធ្ងន់ធ្ងរ រវាងម្ខាងគាំទ្រអោយមានរបបអាណាព្យាបាលបារាំង ម្ខាងទៀតចង់បន្តដំណើរជាមួយរាជាណាចក្រសៀម បដិសេធចោលបារាំង។ ក្នុងនេះដែរ បារាំងក៏ត្រូវប្រឈមមុខជាមួយប្រជាជាតិវៀតណាម ប្រជាជាតិឡាវផងដែរ។ ប៉ុន្តែ ការជាក់ស្តែងនាពេលនោះ ពួកចក្រពត្តិកំពុងពង្រីកខ្លួនដណ្តើមប្រទេសនានាធ្វើជាអាណានិគម ក្នុងពេលដែលបក្សម៉ាក្ស-ឡេនីន មិនទាន់កើតមានជារូបរាង បដិវត្តន៍ខែតុលារុស្ស៊ី មិនទាន់មានកំណើត។ ការតស៊ូរបស់ប្រជាជាតិកម្ពុជាប្រឆាំងអាណានិគមនិយមបារាំង និងការជិះជាន់របស់សក្តិភូមិ បានកើតមានភ្លាមក្រោយពីបារាំងចូលដល់ គឺចលនាអាចារ្យស្វា (១៨៦៤-១៨៦៦) ចលនាពោរកំ

*ប៉ោរ (១៨៦៥-១៨៦៧) ចលនាក្រឡាហោមគង់ (១៨៨៤-១៨៨៦) ចលនាស៊ីវត្ថា (១៨៨៥-១៨៩៥) និងចលនាផ្សេងទៀតយ៉ាងច្រើន ប៉ុន្តែ ចលនាទាំងអស់សុទ្ធតែត្រូវបរាជ័យ អាស្រ័យដោយខ្វះមាគ៌ាយុទ្ធសាស្ត្រ យុទ្ធវិធីត្រឹមត្រូវ ក្នុងដំណាក់កាលតស៊ូនីមួយៗ។ និយាយយ៉ាងដូច្នេះ មានន័យថាបន្ទុះបង្អាប់ចលនាតស៊ូទាំងនោះឬ? មិនមែនទេ ចលនាទាំង នោះ គឺជាទុនធំសម្បើមនៃប្រជាជាតិកម្ពុជា ជាមរតកមិនអាចកាត់ថ្លៃ បានសំរាប់ចលនាតស៊ូក្រោយមកទៀត ហើយដែលសំខាន់បំផុតគឺជា មូលដ្ឋានសំរាប់ការបង្កើតបក្សនយោបាយរបស់វណ្ណកម្មករ នាពេល ក្រោយនេះឯង។ នោះគឺការគួបផ្សំរវាងទ្រឹស្តីនៃលទ្ធិម៉ាក្ស-ឡេនីន ជាមួយ ចលនាតស៊ូរបស់អ្នកស្នេហាជាតិនៅកម្ពុជា ដែលរួមមានកម្មករ កសិករ បញ្ញាជន និងស្រទាប់ផ្សេងទៀតដែលស្នេហាជាតិ ហើយការជួបគ្នានេះ បានធ្វើឡើងក្រោយពីប្រធាន ហូ ជីមិញ បានបង្កើតនូវបក្សកុម្មុយនិស្ត ឥណ្ឌូចិននាឆ្នាំ ១៩៣០ នាំលទ្ធិម៉ាក្ស-ឡេនីនផ្តល់អោយប្រជាជាតិកម្ពុជា វៀតណាម ឡាវ ធ្វើជាត្រីវិស័យសំរាប់ការតស៊ូរំដោះជាតិខ្លួន។ ដោយ ឡែកការគួបផ្សំរវាងទ្រឹស្តីនៃលទ្ធិម៉ាក្ស-ឡេនីន ជាមួយចលនាស្នេហា ជាតិកម្ពុជា ដែលជាវត្ថុធាតុគួបផ្សំ បង្កើតបក្សរបស់វណ្ណៈកម្មករសំរាប់ ដឹកនាំការបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យនៅកម្ពុជា គឺបានប្រព្រឹត្តិ ឡើង និងវិវត្តយ៉ាងឆាប់រហ័សក្រោយឆ្នាំ ១៩៤៥។*

*និយាយដល់បក្សកុម្មុយនិស្តឥណ្ឌូចិន ដែលជាប្រភពកំណើតរបស់ បក្សប្រជាជនបដិវត្តន៍ខ្មែរ និយាយដល់សម្ព័ន្ធភាពនៃការតស៊ូរវាងប្រជា ជាតិកម្ពុជា វៀតណាម ឡាវ ចាំបាច់ត្រូវវិភាគវែកញែកអោយច្បាស់ លាស់ប្រឆាំងឧបាយកលបំបែកបំបាក់របស់សត្រូវអំពីរបស់ដែលហៅថា*

សហព័ន្ធឥណ្ឌូចិន។ ត្រូវរំលឹកថា បារាំងពេលចូលមកកម្ពុជា បន្ទាប់ពីការត្រួតត្រាបានវៀតណាម រួចហើយទៅទន្ទ្រានយកឡាវ ថ្ងៃ ១៧ តុលា ១៨៨៧ បារាំងបានចេញក្រឹត្យបង្កើតសហព័ន្ធឥណ្ឌូចិន ដោយបែងចែកដីអាណានិគមនៅឥណ្ឌូចិនជា ៥ ភូមិភាគ មានវៀតណាមខាងជើង វៀតណាមកណ្តាល វៀតណាមខាងត្បូង (បាក់គី: វៀតណាមខាងជើង, ដុងគី: វៀតណាមកណ្តាល, ណាមគី: វៀតណាមខាងត្បូង) កម្ពុជា ឡាវ ដោយមានក្បាលម៉ាស៊ីនត្រួតត្រារួមគ្នា គឺអគ្គទេសាភិបាលរបស់បារាំង។ ដូច្នេះប្រទេសកម្ពុជា វៀតណាម ឡាវ ត្រូវស្ថិតក្នុងសហព័ន្ធឥណ្ឌូចិន ក្រោមការត្រួតត្រារបស់បារាំង ដែលផ្សារភ្ជាប់គ្នារហូតដល់រូបិយវត្ថុក៏ប្រើប្រាស់រួមគ្នា។ មិនមែនគ្រាន់តែបារាំងបញ្ចូលប្រទេសទាំងបី ទៅក្នុងសហព័ន្ធឥណ្ឌូចិន ក្រោមចំណុះបារាំងប៉ុណ្ណោះទេ គឺបារាំងថែមទាំងបានផ្សារភ្ជាប់ដែនដីឥណ្ឌូចិននេះជាមួយដែនដីអាណានិគមផ្សេងទៀត សំខាន់នៅទ្វីបអាហ្វ្រិក ដូច្នេះហើយបានជាបារាំងបានប្រើប្រាស់ជនជាតិអាហ្វ្រិកជាច្រើនដែលជាអាណានិគមខ្លួន ធ្វើជាទាហានរបស់បារាំងមកធ្វើការបង្ក្រាបប្រជាជាតិនៅឥណ្ឌូចិន។ និយាយដល់ជនជាតិអាហ្វ្រិកធ្វើជាទាហានបារាំងមកប្រយុទ្ធនៅឥណ្ឌូចិន មិនមានន័យថា ជនជាតិអាហ្វ្រិកទាំងនោះជាគូទំនាស់ជាមួយប្រជាជាតិនៅឥណ្ឌូចិនឡើយ ទំនាស់ពិតប្រាកដនៅតែជាទំនាស់រវាងប្រជាជាតិកម្ពុជា វៀតណាម ឡាវ ជាមួយអាណានិគមនិយមបារាំង ឯបណ្តាប្រទេសអាហ្វ្រិកក្រោមអាណានិគមនិយមបារាំងក៏ជាតួទំនាស់ ជាមួយអាណានិគមនិយមបារាំងដូចគ្នាដែរ។ ចំពោះពួកអាណានិគមនិយម ពិតមែនតែវាមានទំនាស់គ្នាក្នុងការដណ្តើមដែនដីប្រទេសផ្សេងទៀតធ្វើជាអាណានិគម ប៉ុន្តែជានិច្ចកាល ពួកវាតែងរួបរួមគ្នា

បង្ក្រាបចលនាតស៊ូរបស់បណ្តាប្រជាជាតិ ដែលក្រោកឡើងតស៊ូប្រឆាំងការឈ្លានពានប្រឆាំងអាណានិគមនិយម ឧទាហរណ៍នៅឥណ្ឌូចិន អាមេរិក និងអង់គ្លេស បានជួយដល់បារាំងដើម្បីពង្រឹងអាណានិគមខ្លួនឡើងវិញ បន្ទាប់ពីជប៉ុនចាញ់សង្គ្រាម។ ដោយឡែក នៅកម្ពុជាឆ្នាំ ១៩៥០ អាមេរិកបានចាប់ផ្តើមផ្តល់ជំនួយយោធាអោយរបបសក្តិភូមិ ជាបរិវារបារាំងតាមរយៈបារាំង។

អាស្រ័យដោយសភាពការណ៍ដូចបានពោលខាងលើ ការតស៊ូរបស់ប្រជាជាតិនិមួយៗ នៅឥណ្ឌូចិន មិនគ្រាន់តែតម្រូវអោយធ្វើសម្ព័ន្ធភាពជាមួយគ្នារវាងប្រជាជាតិនៅឥណ្ឌូចិនប៉ុណ្ណោះទេ តែតម្រូវអោយធ្វើសម្ព័ន្ធភាពជាមួយបណ្តាប្រជាជាតិផ្សេងទៀត ដែលតស៊ូប្រឆាំងអាណានិគមនិយមដូចគ្នា មិនគ្រាន់តែប្រឆាំងអាណានិគមនិយមបារាំងមួយប៉ុណ្ណោះទេ ប៉ុន្តែគ្រប់ប្រភេទអាណានិគមនិយម ទាំងចាស់ទាំងថ្មី តម្រូវអោយមានការរួបរួមជាមួយប្រជាពលករទាំងអស់ នៅក្នុងប្រទេសជាចក្រពត្តិអាណានិគមនិយម និងប្រទេសមូលធននិយមផ្សេងទៀត ដែលត្រូវទទួលការជិះជាន់ដែរ តម្រូវអោយធ្វើសម្ព័ន្ធភាព និងទទួលការគាំទ្រពីប្រទេសសង្គមនិយម មានន័យថាចលនាបដិវត្តន៍ទាំងបីលើសកលលោកធ្វើសម្ព័ន្ធភាពជាមួយគ្នា និងគាំទ្រគ្នាទៅវិញទៅមក។ ដោយឡែកតែនៅកម្ពុជា វៀតណាម ឡាវ ដែលស្ថិតក្នុងសហព័ន្ធឥណ្ឌូចិន ក្រោមចំណុះបារាំង ភាពចាំបាច់ខានមិនបាន គឺតម្រូវអោយធ្វើសម្ព័ន្ធភាពជាមួយគ្នាដើម្បីរំដោះជាតិរៀងៗ ខ្លួន។ សម្ព័ន្ធភាពនេះ មានលក្ខណៈជាក្រឹត្យក្រមសត្យានុម័ត <u>ដែលមានចរិតចាប់បង្ខំផង និងចរិតស្ម័គ្រចិត្តផង ហើយចរិតទាំងពីរនេះមានលក្ខណៈយុទ្ធសាស្ត្រយូរអង្វែង</u>។

**ចរិតចាប់បង្ខំ** គឺផ្តើមចេញពីនយោបាយ និងសកម្មភាពរបស់ចក្រពត្តិអាណានិគមនិយម ទោះជាចក្រពត្តិអាណានិគមនិយមណា ក៏សុទ្ធសឹងមានចរិតដូចគ្នា បង្ក្រាប និងបញ្ចូលប្រជាជាតិទាំងបីនៅក្រោមការត្រួតត្រាជាមួយគ្នា។ ទោះជាជប៉ុន អាមេរិក មិនមានចេញច្បាប់ដាក់ប្រទេសទាំងបីនៅឥណ្ឌូចិនក្នុងសហព័ន្ធដូចជាបារាំង ក៏ចក្រពត្តិទាំងពីរនេះចូលមកឥណ្ឌូចិន មាននយោបាយ និងសកម្មភាពដូចគ្នា។ ដូច្នេះ ប្រជាជាតិទាំងបីនៅឥណ្ឌូចិន មានសត្រូវរួមដូចគ្នា មានមុខសញ្ញាតស៊ូដូចគ្នា និងមានគោលដៅដូចគ្នា ហើយប្រជាជាតិទាំងបីនេះ មិនអាចដណ្តើមបានជោគជ័យទេ ប្រសិនបើមិនធ្វើសម្ព័ន្ធភាពជាមួយគ្នាក្នុងការតស៊ូ។ ម្យ៉ាងទៀត លក្ខណៈសម្បត្តិភូមិសាស្រ្តធម្មជាតិ ដែលប្រទេសទាំងបីនៅជាប់គ្នាតម្រូវអោយមានការសាមគ្គីសហការគ្នាជិតស្និទ្ធ មិនគ្រាន់តែក្នុងកាលៈទេសៈសង្គ្រាមប៉ុណ្ណោះទេ តែក៏ក្នុងកាលៈទេសៈសន្តិភាពផងដែរ ទើបអាចរក្សាបានរឹងមាំនូវសន្តិភាពរបស់ប្រទេសនីមួយៗ។ លក្ខណៈភូមិសាស្រ្តធម្មជាតិនេះ ប្រៀបដូចជាផ្ទះបីដែលសាងសង់ឡើងជាប់គ្នា ប្រសិនបើភ្លើងឆេះផ្ទះណាមួយ ផ្ទះពីរទៀត តិចឬច្រើនក៏ឆេះដូចគ្នា ឧទាហរណ៍ក្នុងពេលអាមេរិកឈ្លានពានវៀតណាម យើងឃើញថា កម្ពុជា ឡាវ ក៏គ្មានស្ថេរភាព ដំបូងនៅតាមព្រំដែនជាមួយវៀតណាម និងការបាត់ស្ថេរភាពខាងនយោបាយនៅផ្ទៃក្នុង ទីបំផុតទាំងកម្ពុជា ទាំងឡាវ ក៏សុទ្ធតែត្រូវអាមេរិកឈ្លានពានដូចគ្នា។

**ចរិតស្ម័គ្រចិត្ត** គឺផ្តើមចេញពីការតស៊ូ ពីសុច្ឆន្ទៈសន្តិភាព និងមិត្តភាព ប្រសិនបើត្រូវធ្វើការតស៊ូប្រឆាំងសត្រូវ ចាំបាច់ត្រូវស្វែងរកសម្ព័ន្ធមិត្ត។ ការស្វែងរកសម្ព័ន្ធមិត្ត គឺជាការស្ម័គ្រចិត្ត គ្មានអ្នកណាចាប់បង្ខំ បានឡើយ។ តើ

*អ្នកណាជាសម្ព័ន្ធមិត្ត? ច្បាស់លាស់ណាស់ គឺអ្នកដែលមានសត្រូវរួម ហើយវាកាន់តែងាយស្រួលទៅទៀតសំរាប់ការតស៊ូ នៅពេលមានសម្ព័ន្ធមិត្តនៅក្បែរខ្លួន។ ប្រសិនបើមិនទាន់និយាយដល់ការតស៊ូនៅក្រោយមានបក្សកុម្មុយនិស្តឥណ្ឌូចិននៅឡើយ គ្រាន់តែនិយាយដល់ចលនាតស៊ូក្រោយបារាំងចូលប្រទេសខ្មែរក្រោម ក៏កើតមានសម្ព័ន្ធភាពរវាងចលនាតស៊ូរបស់ប្រជាជនកម្ពុជា ជាមួយចលនាតស៊ូរបស់ប្រជាជនវៀតណាមក្រោម ដូចជាទំនាក់ទំនងរវាងអាចារ្យស្វាជាមួយ ង្វៀង ហ៊ីវហ្វីន រវាងចលនាពោធិ៍កំបោជាមួយ ទ្រឿង គៀន (ឯកសារព្រាងប្រវត្តិសាស្ត្របក្សប្រជាជនបដិវត្តកម្ពុជា ស្រាវជ្រាវដោយ គណៈស្រាវជ្រាវប្រវត្តិសាស្ត្របក្សប្រជាជនបដិវត្តកម្ពុជា)។ល។*

*សុច្ឆន្ទៈសន្តិភាព មិត្តភាព មានលក្ខណៈយុទ្ធសាស្ត្រយូរអង្វែង វាមិនគ្រាន់តែសំរាប់បំរើអោយការតស៊ូដើម្បីរំដោះជាតិប៉ុណ្ណោះទេ វាមានសារៈសំខាន់ខ្លាំងណាស់ សំរាប់កាលៈទេសៈការពារជាតិ និងកសាងជាតិ។ គ្មានពេលណាអាចកសាងប្រទេសបានឡើយ ប្រសិនបើប្រជាជាតិទាំងបីគ្មានឯករាជ្យរៀងខ្លួន គ្មានមិត្តភាព និងសហប្រតិបត្តិការជាមួយគ្នា តែបែរជាធ្វើសត្រូវនឹងគ្នាទៅវិញ។ លក្ខណៈសម្បត្តិដើម្បីកសាងប្រទេសអោយរីកចំរើន ដំបូងបំផុតត្រូវការនូវកត្តាពីរ៖ មួយគឺស្ថេរភាពផ្ទៃក្នុង ពីរគឺលក្ខណៈសម្បត្តិអន្តរជាតិអនុគ្រោះ ពិសេសមិត្តភាពជាមួយប្រទេសជិតខាងខ្លួន។*

*និយាយដល់ចំណុចនេះ ចាំបាច់ត្រូវរិះគន់ទ្រឹស្តីប្រតិកិរិយារបស់សត្រូវដែលខិតខំបំបែកបំបាក់ ដើម្បីត្រួតត្រាអំពីសហព័ន្ធឥណ្ឌូចិន ប្រជាជាតិមួយកងទ័ពមួយ ក្រោមការត្រួតត្រារបស់វៀតណាម និងទស្សនៈជាតិ*

និយមចង្អៀតចង្អល់ហួសហេតុ។

ដំបូងត្រូវមានទស្សនៈវណ្ណៈ ក្នុងការពិនិត្យបញ្ហាមានចរិតជាប្រវត្តិសាស្ត្រ។ ក្នុងសង្គមមានវណ្ណៈ និងតស៊ូវណ្ណៈ នាដំណាក់កាលពួកមូលធននិយម ក្លាយទៅជាចក្រពត្តិ ដើរទន្ទ្រានឈ្លានពានប្រទេសផ្សេងទៀត ធ្វើជាអាណានិគម ឬជារណប ការតស៊ូវណ្ណៈមិនស្ថិតនៅក្នុងក្របខ័ណ្ឌតែប្រទេសមួយៗ ដោយឡែកៗ ឡើយ វាក្លាយទៅជាការតស៊ូវណ្ណៈក្នុងក្របខ័ណ្ឌសកលលោក។ ពួកវណ្ណៈជិះជាន់ដែលត្រួតត្រាប្រទេសមួយ តែងរកសម្ព័ន្ធភាពជាមួយវណ្ណៈជិះជាន់ត្រួតត្រាប្រទេសផ្សេងទៀត ដើម្បី បង្ក្រាបចលនាតស៊ូរបស់ប្រជាពលករនៅក្នុងប្រទេស។ នៅកម្ពុជា ក្នុងពេលដែលសត្រូវលើកឡើងអំពីវៀតណាមជាសត្រូវសួពូជ ពេលនោះដៃអ្នកកាន់អំណាចនៅវៀតណាម ក្រោមអាណានិគមនិយមបារាំង បែរជាធ្វើសម្ព័ន្ធមិត្តជាមួយគ្នា ដើម្បីបង្ក្រាបចលនាតស៊ូរបស់ប្រជាពលករ ទាំងនៅកម្ពុជា ទាំងនៅវៀតណាម។

គួរលើកបញ្ជាក់នូវចំណុចតូចមួយ ស្តីពីវណ្ណៈត្រួតត្រានៅកម្ពុជា វៀតណាមខាងត្បូង ឡាវ ដែលធ្វើសម្ព័ន្ធភាពជាមួយគ្នា ដើម្បីបង្ក្រាបការតស៊ូរបស់ប្រជាជន នៃប្រទេសទាំងបីនៅឥណ្ឌូចិន។

ថ្ងៃ ២២ សីហា ១៩៥៥ សម សារី (សមាជិកឧត្តមប្រឹក្សានៃព្រះរាជាអតីតសមាជិកប្រតិភូនៃប្រទេសកម្ពុជា នាសន្និសីទហ្សឺណែវ) បានថ្លែងនៅមន្ទីសភាទីប្រឹក្សាជាតិ អំពីកិច្ចព្រមព្រៀងហ្សឺណែវថា៖ "គណៈប្រតិភូ ៦ ចង់បាច់គ្នា បំរុងនឹងជួយគ្នាទៅវិញទៅមក (គឺគណៈប្រតិភូអង់គ្លេស អាមេរិក បារាំង ខ្មែរ យួន លាវ) សន្យាថា ជំនុំលើកដំបូងនោះគ្រាន់តែជាឱកាសអោយគណៈប្រតិភូបារាំង ថ្លែងសេចក្តីបំណងចង់បំ

បាត់ចម្បាំងរាំងជល់ នៅប្រទេសឥណ្ឌូចិន ដើម្បីធ្វើអោយទ្វីបទាំងមូល ឃើញកស្តុតាងនូវគំនិតល្អរបស់បារាំងប៉ុណ្ណោះ ហើយបើគណៈប្រតិភូកុម្មុយនិស្តលើករឿងស្រុកខ្មែរមកនិយាយ មានរឿងសុំអោយពួកឧទ្ទាមខ្មែរចូលជំនុំជាដើមនោះ គណៈប្រតិភូណាមួយក្នុងចំណោមប្រទេសជាមិត្តទាំង ៦ នឹងតវ៉ាអោយលើកលែងជំនុំ ហើយបើគេមិនធ្វើតាម នឹងនាំគ្នាចេញពីកន្លែងជំនុំ" (*)។

ប្រតិភូខ្មែរ វៀតណាមខាងត្បូង ឡាវ ពេលនោះគឺជាអ្នកកាន់អំណាចក្រោមការត្រួតត្រារបស់បារាំង ដែលគេធ្វើសម្ព័ន្ធភាពជាមួយគ្នាប្រឆាំងការតស៊ូរបស់ប្រជាជននៃប្រទេសទាំងបី។ នេះជាសម្ព័ន្ធភាពខាងនយោបាយ និងការទូតក្នុងពេលផ្តាច់ព្រ័ត្រលើតុចរចា ក្រោយមួយរយៈពេលដ៏យូរ នៃការធ្វើសម្ព័ន្ធភាពខាងផ្លូវយោធាក្រោមអាណាព្យាបាលបារាំង។

មិនគ្រាន់តែមានសម្ព័ន្ធភាពជាមួយគ្នា ក្នុងពេលដែលគេនៅក្នុងសហព័ន្ធឥណ្ឌូចិន ក្រោមចំណុះបារាំងប៉ុណ្ណោះទេ សូម្បីតែមកដល់ទសវត្សឆ្នាំ ៧០ ដែលគេចាត់ទុកប្រទេសនីមួយៗ នៅដាច់ពីគ្នាហើយ ក៏វណ្ណៈត្រួតត្រាអំណាចនៅកម្ពុជា វៀតណាមខាងត្បូង ឡាវ ថែមទាំងស្វែងរកការធ្វើសម្ព័ន្ធភាពជាមួយគ្នាដែរ ហើយជាក់ស្តែងបំផុតពេលអាមេរិកនាំកងទ័ពចូលឈ្លានពានកម្ពុជា ក៏មានកងទ័ពរបស់រដ្ឋអំណាចអាយ៉ងនៅសាយហ្គន ចូលមកជាមួយយ៉ាងសន្ធឹកសន្ធាប់ មិនមែនជាកងទ័ពចម្រុះ

(*) សេចក្តីថ្លែងការណ៍របស់ សម សារី អំពីកិច្ចព្រមព្រៀងនៅទីក្រុងហ្សឺណែវ និងការបោះឆ្នោតនៅប្រទេសខ្មែរ ថ្ងៃច័ន្ទ ២២ សីហា ១៩៥៥ វេលាម៉ោង ១៨.៣០ នាទី ជាភាសាខ្មែរ នៅមន្ទីរសភាទីប្រឹក្សាជាតិ និងថ្ងៃ អង្គារ ២៣ សីហា ១៩៥៥ វេលាម៉ោង ២០.៣០ នាទី ជាភាសាបារាំង នៅសណ្ឋាគាររាជរដ្ឋាភិបាល (សណ្ឋាគារវត្តភ្នំ) បោះពុម្ពជាភាសាខ្មែរ និងបារាំង គ្មានឈ្មោះរោងពុម្ព និងថ្ងៃខែឆ្នាំ។

*អាមេរិក-វៀតណាមខាងត្បូងនោះទេ តែជាកងឯកភាពរបស់វៀតណាមខាងត្បូងចូលមកកម្ពុជា ដើម្បីជួយទ្រទ្រង់រដ្ឋាភិបាលស្និទ្ធអាមេរិកនៅភ្នំពេញ ប្រឆាំងប្រជាជនកម្ពុជាស្លូតត្រង់ ដែលតស៊ូដើម្បីរំដោះជាតិខ្លួន ហើយក្នុងពេលជាមួយគ្នានេះដែរ រដ្ឋការ លន់ នល់ ក៏បានធ្វើការបង្ក្រាបយ៉ាងព្រៃផ្សៃបំផុត ចំពោះអាណិកជនវៀតណាមស្លូតត្រង់នៅកម្ពុជា។ ជារឿងដ៏ចម្លែកដែលរដ្ឋការ សាយហ្គន មិនបានផ្តន្ទាទោសរដ្ឋការភ្នំពេញ ហើយរដ្ឋការភ្នំពេញក៏មិនបានផ្តន្ទាទោសរដ្ឋការសាយហ្គន ចំពោះវិនាសកម្មដែលកើតមានចំពោះប្រជាជនស្លូតត្រង់ទាំងនេះ។*

*តាមព្រឹត្តិការណ៍ដែលបានរៀបរាប់ខាងលើ អាចកំណត់បានច្បាស់ថា <u>សម្ព័ន្ធភាពរវាងប្រទេសទាំងបីនៅឥណ្ឌូចិន ក៏ដូចជាការឈ្លានពាន និងការបំផ្លិចបំផ្លាញរបស់ចក្រពត្តិ និងពួកបរិវារប្រតិកិរិយាចំពោះប្រទេសទាំងបី សុទ្ធតែមានចរិតវណ្ណៈទាំងអស់</u>។ គេធ្វើសម្ព័ន្ធភាពរវាងវណ្ណៈត្រួតត្រានៅប្រទេសនេះ ជាមួយវណ្ណៈត្រួតត្រានៅប្រទេសនោះបាន លើមូលដ្ឋានផលប្រយោជន៍វណ្ណៈស្របគ្នា ហើយគេបង្ក្រាបចំពោះចលនាតស៊ូជាតិនេះ ឬជាតិនោះ ក៏លើមូលដ្ឋាននៃផលប្រយោជន៍ខុសគ្នា ដូច្នេះពិតជាមិនមែនស្ថិតនៅត្រង់ជម្លោះជាតិសាសន៍ ដែលពួកគេចាត់ទុកថាដោះស្រាយមិនបាន ហើយមានចរិតតពូជតពង្សនោះឡើយ។ ពួកវណ្ណៈជិះជាន់ជានិច្ចកាលធ្វើសម្ព័ន្ធភាពជាមួយគ្នា ដើម្បីបង្ក្រាបការតស៊ូរបស់ប្រជាពលករ ក្នុងពេលជាមួយគ្នា គេចោទប្រកាន់ការធ្វើសម្ព័ន្ធភាពរវាងប្រជាពលករនៃបណ្តាប្រទេស ដែលបានធ្វើសម្ព័ន្ធភាពជាមួយគ្នា ដើម្បីប្រឆាំងពួកគេ ទាមទារឯករាជ្យ ប្រជាធិបតេយ្យ។*

និយាយពី ចរិតវណ្ណៈនៃសម្ព័ន្ធភាព រវាងវណ្ណៈត្រួតត្រាប្រទេសមួយជាមួយវណ្ណៈត្រួតត្រាប្រទេសមួយទៀត ដើម្បីបង្ក្រាបចលនាតស៊ូរបស់ប្រជាពលករ ត្រូវបែងចែកអោយដាច់ អំពីការសម្រុះសម្រួលរវាងកម្លាំងបដិបក្ខគ្នានៅក្នុងដំណាក់កាលណាមួយនោះ។ ការសម្រុះសម្រួលមានន័យថា កម្លាំងបដិបក្ខគ្មានគោលដៅចុងក្រោយដូចគ្នាទេ ប៉ុន្តែតម្រូវអោយមានការសម្រុះសម្រួលជាបណ្តោះអាសន្ន ដើម្បីដោះស្រាយបញ្ហាចំពោះមុខណាមួយនោះ។ នេះជាវិធីសាស្ត្រចំពោះបញ្ហាមិត្ត និងសត្រូវចំពោះមុខ និងយូរអង្វែង។

ការរៀបរាប់ និងវិភាគជាច្រើនដូចខាងលើសំដៅបង្ហាញអោយឃើញនូវភាពស្មុគស្មាញនៃចរិតផ្ទៃក្នុង និងចរិតអន្តរជាតិ នៃការតស៊ូបដិវត្តរបស់ប្រជាជនកម្ពុជា ដែលស្ថិតក្នុងបរិយាកាសរួមនៃការតស៊ូរបស់ប្រជាជនទាំងបីនៅឥណ្ឌូចិន ក្នុងនោះទាក់ទងសំខាន់ដល់សម្ព័ន្ធភាពនៃកម្លាំងប្រឆាំង សម្ព័ន្ធភាពនៃកម្លាំងតស៊ូ និងប្រភពកើតឡើងនៃបក្សប្រជាជនបដិវត្តខ្មែរ។ ក្នុងការកកើតឡើងនូវបក្សប្រជាជនបដិវត្តខ្មែរ មានចំណុចសំខាន់បីដែលត្រូវយកចិត្តទុកដាក់។

ទីមួយ គឺបក្សបានកើតឡើងដោយមានការគួបផ្សំរវាងទ្រឹស្តីនៃលទ្ធិម៉ាក្ស-ឡេនីន ជាមួយចលនាស្នេហាជាតិដែលមានយូរមកហើយ។ ពិតមែនតែលើទ្រឹស្តីនិយាយពី ការគួបផ្សំរវាងទ្រឹស្តីនៃលទ្ធិម៉ាក្ស-ឡេនីន ជាមួយចលនាកម្មករ ហើយពិតមែនតែបក្សដែលបានបង្កើតឡើងនេះ ជាបក្សនយោបាយរបស់វណ្ណៈកម្មករ ជាកងឈានមុខរបស់វណ្ណៈកម្មករ ប៉ុន្តែការជាក់ស្តែងមិនអាចនិយាយបានថា ជាការគួបផ្សំរវាងទ្រឹស្តីនៃលទ្ធិម៉ាក្ស-

ឡេនីន ជាមួយចលនាកម្មករតែមួយបានឡើយ ព្រោះថាលក្ខណៈសម្បត្តិនៅកម្ពុជាក្នុងពេលបក្សចាប់កំណើត វណ្ណៈកម្មករមានតិចតួចណាស់។ និយាយអោយត្រូវជាមួយការជាក់ស្តែង បក្សប្រជាជនបដិវត្តខ្មែរចាប់ប្រភពពីការគួបផ្សំរវាងទ្រឹស្តីនៃលទ្ធិម៉ាក្ស-ឡេនីន ជាមួយចលនាស្នេហាជាតិ ដែលមានស្រាប់។ **ចលនាស្នេហាជាតិ** រួមមានកម្មករ កសិករ បញ្ញាជន និងស្រទាប់ផ្សេងទៀតចូលរួម។ **មានស្រាប់** គឺចលនាតស៊ូរបស់ប្រជាជនកម្ពុជា បានកើតមានតាំងពីបារាំងចូលមកត្រួតត្រាកម្ពុជា ហើយចលនាទាំងនោះបានក្លាយទៅជាចលនាជាបន្តបន្ទាប់ រហូតបានមកគួបផ្សំជាមួយទ្រឹស្តីនៃលទ្ធិម៉ាក្ស-ឡេនីន ដែលបានក្លាយទៅជាប្រភពនៃកំណើតបក្ស ប៉ុន្តែទោះជាបានកើតឡើងក្នុងស្ថានភាពបែបនេះក៏ដោយ ក៏បក្សប្រជាជនបដិវត្តខ្មែរ នៅតែជាបក្សរបស់វណ្ណៈកម្មករ អាស្រ័យដោយបានយកនូវទ្រឹស្តីនៃលទ្ធិម៉ាក្ស-ឡេនីន ជាត្រីវិស័យនៅគ្រប់សកម្មភាពរបស់ខ្លួន។

ទីពីរ គឺអាស្រ័យដោយលក្ខណៈសម្បត្តិខាងនយោបាយ លក្ខណៈសម្បត្តិខាងភូមិសាស្ត្រធម្មជាតិ និងគោលការណ៍ស្មុគ្រចិត្ត បក្សប្រជាជនបដិវត្តកម្ពុជាបានកើតឡើងក្នុងសភាពជាកូនភ្លោះបីពីផ្ទៃតែមួយ ក្នុងពេលជាមួយគ្នា មានទឹកចិត្តដូចគ្នា តែមានរូបរាងខុសគ្នា។ នោះគឺបក្សកុម្មុយនិស្តឥណ្ឌូចិន ដែលមានជនជាតិបីចូលរួម។ កូនភ្លោះបីពីផ្ទៃតែមួយ គឺទ្រឹស្តីនៃលទ្ធិម៉ាក្ស-ឡេនីន ដែលបានមកជួបចលនាតស៊ូរបស់ប្រជាជាតិទាំងបីនៅឥណ្ឌូចិន។ ក្នុងពេលតែមួយ គឺបក្សនេះពេលបង្កើតមានឈ្មោះថា បក្សកុម្មុយនិស្តឥណ្ឌូចិន ហើយទោះជាបក្សនេះត្រូវបានប្រធាន ហូ ជីមិញ ដែលជាជនជាតិវៀតណាមបង្កើតឡើង ក៏គ្មានពេល

ណាជនកុម្មុយនិស្តវៀតណាមទាមទារធ្វើជារៀមច្បង ឬត្រួតត្រាកម្ពុជា ឬឡាវឡើយ។ បក្សទាំងបីមានឯករាជ្យរៀងៗខ្លួន និងជួយគ្នាទៅវិញទៅមកលើស្មារតីជាបងប្អូន និងសមភាព។ មានទឹកចិត្តដូចគ្នា គឺមានគោលដៅរួមដូចគ្នា។ មានរូបរាងខុសគ្នា នៅត្រង់ជនជាតិផ្សេងគ្នា លក្ខណៈសម្បត្តិនៃប្រទេសនីមួយៗ ខុសគ្នា ទោះជាមានគោលដៅរួមដូចគ្នា ប៉ុន្តែការអនុវត្តជាក់ស្តែងតម្រូវអោយមានយុទ្ធសាស្រ្ត យុទ្ធវិធីក្នុងដំណាក់កាលនីមួយៗ ខុសគ្នា ស្របទៅតាមចរិតនៃសភាពការណ៍ខុសគ្នា។

ទីបី គឺបក្សកុម្មុយនិស្តឥណ្ឌូចិន ត្រូវបានបំបែកជាបក្សបី សំរាប់ដឹកនាំចលនាតស៊ូបដិវត្តនៅប្រទេសទាំងបី បន្ទាប់ពីបានរីកធំធាត់ និងលក្ខណៈសម្បត្តិខាងនយោបាយអនុញ្ញាត លើគោលការណ៍ស្ម័គ្រចិត្ត។ ពេលវេលានៃការបំបែកបក្សកុម្មុយនិស្តឥណ្ឌូចិន ក៏ជាពេលវេលាបង្កើតបក្សប្រជាជនបដិវត្តខ្មែរ និងបក្សប្រជាជនបដិវត្តឡាវ។

មុនពេលចូលទៅបញ្ហាអំពីស្ថានភាពសង្គមមុនឆ្នាំ ១៩៥៥ និងការបដិវត្តន៍ សូមលើកឡើងវិភាគវែកញែកនូវព្រឹត្តិការណ៍មួយចំនួន ដែលលេចធ្លោ ក្នុងចន្លោះឆ្នាំ ១៩៤០ ដល់ ១៩៥៥។

ឆ្នាំ ១៩៤៥ ជាដំណាក់កាលមួយនៃការប្រែប្រួលខាងរូបភាពទំនាស់រវាងប្រជាជនកម្ពុជា និងពួកសត្រូវឈ្លានពាន ប៉ុន្តែខ្លឹមសារនៃទំនាស់គ្មានការផ្លាស់ប្តូរទេ។ ទំនាស់បានចាប់ផ្តើមប្រែប្រួលតាំងពីរដ្ឋាភិបាលបារាំងចុះចាញ់ពួកហ្វាស៊ីស្តអាល្លឺម៉ង់ នាខែ មិថុនា ១៩៤០។ ឆ្លៀតពេលដែលបារាំងត្រូវបាត់បង់ប្រទេស ពួកហ្វាស៊ីស្តជប៉ុនបានដាក់ចេញនូវគោលការណ៍ដណ្តើមដែនដីអាណានិគមនៅទ្វីបអាស៊ី ក្នុងនោះមាន

ដែនដីអាណានិគមបារាំងនៅឥណ្ឌូចិន។ បារាំងបានយល់ព្រមជាមួយជប៉ុន ដាក់ឥណ្ឌូចិនក្រោមការការពាររួមបារាំង និងជប៉ុន ដែលផ្តល់លទ្ធភាពអោយជប៉ុនដាក់កម្លាំងកងទ័ពនៅលើទឹកដីឥណ្ឌូចិន។ ថៃឆ្លៀតប្រើប្រាស់ឱកាសនេះ ដណ្តើមយកទៅវិញនូវខេត្តកម្ពុជាមួយចំនួន ដែលថៃបានប្រគល់អោយបារាំងតាមសន្ធិសញ្ញាបារាំង-សៀម ឆ្នាំ ១៩០៧។ ផ្អែកលើជប៉ុន ថៃបានប្រើប្រាស់កម្លាំងយោធាវាយចូលកម្ពុជានាខែ វិច្ឆិកា ១៩៤០។ ប៉ុន្តែទោះបីជាបារាំងបានឈ្នះក្នុងសង្គ្រាមជាមួយថៃ ប៉ុន្តែ អាស្រ័យដោយបារាំងខ្លាចជប៉ុន បារាំងត្រូវបង្ខំចិត្តកាត់ខេត្តមួយចំនួនទៅអោយថៃ តាមសន្ធិសញ្ញាស្តីពី សន្តិភាពរវាងថៃ-បារាំង នាខែឧសភា ១៩៤១ ដែលតាមសន្ធិសញ្ញា បារាំងត្រូវកាត់ខេត្តមួយចំនួនខាងជើងខ្សែស្របលេខ ១៥ ទៅអោយថៃ មាន ស៊ីសុផុន ខេត្តសៀមរាប កំពង់ធំ និងស្ទឹងត្រែង។ ដូច្នេះ ទំនាស់ពេលនោះ បានប្រែប្រួលពីទំនាស់តែជាមួយនឹងបារាំង មកកាន់ទំនាស់ជាមួយនឹងបារាំងផង ជាមួយជប៉ុនផង និងជាមួយថៃផង។

ថ្ងៃ ៩ មីនា ១៩៤៥ ទំនាស់បានប្រែប្រួលបន្ត គឺនៅពេលដែលជប៉ុនបើកការវាយប្រហារទៅលើបារាំងនៅទូទាំងឥណ្ឌូចិន និងនៅពេលដែលរាជរដ្ឋាភិបាលអាយ៉ងបារាំង ឱនក្បាលធ្វើបរិវារអោយជប៉ុននាថ្ងៃ ១០ មីនា ១៩៤៥។ នរោត្តម សីហនុ ក្រោយពេលឡើងសោយរាជ្យក្រោមចំណុះបារាំង ពីថ្ងៃ ២៣ ខែមេសា ១៩៤១ បន្ទាប់ពី មុនីវង្សសុគតទៅ ក៏ត្រូវបានជប៉ុនរក្សាអោយបន្តធ្វើស្តេច។ ជប៉ុន បានដាក់ការត្រួតត្រានៅកម្ពុជាជំនួសបារាំង ហើយបង្ខំអោយនរោត្តម សីហនុ តែងតាំង

សឹងផ្ទុកថាន់ ដែលជាបរិវាររបស់ជប៉ុន ធ្វើជានាយករដ្ឋមន្ត្រី។

ទំនាស់ប្រជាជាតិនៅពេលនេះគឺនៅដដែល តែជាមូលដ្ឋាន គឺជាមួយនឹងហ្វាស៊ីស្តជប៉ុន ដូច្នេះ ទោះជាមានការប្រែប្រួលអំពីរូបភាពទំនាស់ ប៉ុន្តែខ្លឹមសារបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ គឺស្ថិតនៅដូចពេលមុន គឺតស៊ូវាយបណ្តេញជប៉ុន ដណ្តើមឯករាជ្យ សេរីភាព ជូនមាតុភូមិ។

ក៏នៅក្នុងឆ្នាំ ១៩៤៥ នេះដែរ គឺប៉ុន្មានខែក្រោយហ្វាស៊ីស្តជប៉ុនត្រួតត្រាកម្ពុជា ក៏ដូចជា ឥណ្ឌូចិន សភាពការណ៍សកលលោកមានការប្រែប្រួលយ៉ាងឆាប់រហ័ស តាមរយៈនៃការដួលរលំរបស់ពួកហ្វាស៊ីស្តអាល្លឺម៉ង់នាខែឧសភា ១៩៤៥ ក្រោមការវាយលុករបស់សហភាពសូវៀត និងចលនាតស៊ូរបស់ប្រជាជនបណ្តាប្រទេស ដែលពួកហ៊ីត្លែរកាន់កាប់ និងមានការចូលរួមមួយផ្នែករបស់សហរដ្ឋអាមេរិក និងប្រទេសប៉ែកខាងលិចមួយចំនួន។ បីខែបន្ទាប់ពីនោះមក កងទ័ពសហភាពសូវៀតបានវាយទៅលើកងទ័ពដ៏ចំណានៗ របស់ជប៉ុន បន្ថែមដោយគ្រាប់បែកបរិមាណូរបស់អាមេរិកទម្លាក់ទៅលើប្រទេសជប៉ុន"ក្រុងហ៊ីរ៉ូហ្ស៊ីម៉ា" ហ្វាស៊ីស្តជប៉ុនចុះចាញ់ដោយឥតលក្ខខណ្ឌ។ ការចាញ់របស់ហ្វាស៊ីស្តអាល្លឺម៉ង់ និងហ្វាស៊ីស្តជប៉ុន បានបញ្ចប់នូវសង្គ្រាមលោកលើកទី ២។ ព្រឹត្តិការណ៍នេះ គឺជាឱកាសល្អសំរាប់ប្រទេសអាណានិគម និងពាក់កណ្តាលអាណានិគមនៅទ្វីបអឺរ៉ុប និងអាស៊ី រំដោះខ្លួន។

ពិនិត្យឡើងវិញអំពីសភាពការណ៍អន្តរជាតិនាពេលនោះ មានលក្ខណៈអនុគ្រោះយ៉ាងខ្លាំង ដល់ចលនាតស៊ូបដិវត្តដើម្បីរំដោះជាតិ និងលទ្ធិប្រជាធិបតេយ្យ ប៉ុន្តែបដិវត្តន៍កម្ពុជាបែរជាមិនអាចដណ្តើម

បានជ័យជំនះ ក្នុងពេលចលនាតស៊ូមានបក្សនយោបាយដឹកនាំត្រឹមត្រូវហើយ។ កត្តាអនុគ្រោះមួយចំនួនដែលបានកើតឡើង ក្រោយសង្គ្រាមលោកលើកទី ២ ផុតរលត់ទៅ គឺ៖

ទីមួយ៖ ហ្វាស៊ីស្តអាល្លឺម៉ង់ ហ្វាស៊ីស្តជប៉ុន ចាញ់សង្គ្រាម បណ្តាប្រទេសអាណានិគមនិយមត្រូវរង្គោះរង្គើ និងវិបត្តិធ្ងន់ធ្ងរ។

ទីពីរ៖ សហភាពសូវៀតស្ថិតក្នុងប្រៀបជាអ្នកខ្លាំងក្លាបំផុត ក្នុងការបញ្ចប់សង្គ្រាមលោកលើកទី ២ សង្គមនិយមមិនមានតែសហភាពសូវៀតតែម្នាក់ឯងទៀតទេ គឺបានប្រែក្លាយទៅជាប្រព័ន្ធសង្គមនិយមមួយនៅលើសកលលោក ហើយស្ថិតក្នុងភាពវាយសំរុក និងជាបង្អែករឹងមាំបំផុតអោយចលនាតស៊ូរំដោះប្រជាជាតិ និងចលនាតស៊ូរបស់វណ្ណៈកម្មករនៅបណ្តាប្រទេសមូលធន។

ទីបី៖ ចលនាតស៊ូរបស់បណ្តាប្រជាជាតិក្នុងប្រទេសអាណានិគម និងពាក់កណ្តាលអាណានិគម បានរីកចំរើនយ៉ាងខ្លាំងក្លា ក្លាយទៅជាចរន្តមួយវាយសំរុកឥតឈប់ឈរ។

ទីបួន៖ ចលនាតស៊ូរបស់វណ្ណៈកម្មករនៅក្នុងបណ្តាប្រទេសចក្រពត្តិមូលធននិយមបានរីកធំជាត់ បង្កទៅជាវិបត្តិសមរភូមិក្រោយរបស់ពួកអាណានិគមនិយម ផ្តល់នូវការលើកទឹកចិត្តសំរាប់ប្រជាជាតិ ក្រោយអាណានិគមនិយមដើម្បីរំដោះជាតិ។

ក្រៅពីកត្តាអនុគ្រោះទាំងបួនខាងលើ បដិវត្តន៍កម្ពុជា និយាយដោយឡែក និងបដិវត្តន៍នៅឥណ្ឌូចិន និយាយរួម នៅមានកត្តាអនុគ្រោះ

មួយចំនួនទៀត គឺមុខសញ្ញាដែលបដិវត្តន៍ត្រូវតស៊ូ គឺជប៉ុន ត្រូវចាញ់សង្គ្រាម ឯបារាំងមិនទាន់ត្រឡប់មកវិញទាំងស្រុង បដិវត្តន៍ចិន កូរ៉េ ក៏កំពុងស្ថិតក្នុងសភាពការណ៍វាយសំរុកឈានទៅរកជ័យជំនះ។

ភ្ជាប់ជាប់សភាពការណ៍អនុគ្រោះ ខែ សីហា ១៩៤៥ បក្សកុម្មុយនិស្តឥណ្ឌូចិន បានសំរេចធ្វើកុបកម្មនៅទូទាំងឥណ្ឌូចិន។ កុបកម្មបាននាំមកនូវជ័យជំនះរបស់វៀតណាម និងមួយផ្នែកនៅឡាវ នោះគឺជាជោគជ័យធំសម្បើម របស់ប្រជាជាតិនៅឥណ្ឌូចិន។ ទោះជានៅកម្ពុជាមិនអាចដណ្តើមបានរដ្ឋអំណាច ហើយវៀតណាម ឡាវ ក៏មិនទាន់សំរេចជោគជ័យទាំងស្រុង ប៉ុន្តែបដិវត្តន៍ខែ សីហា ១៩៤៥ គឺជាផ្នត់ដ៏សំខាន់មួយនៃប្រវត្តិសាស្ត្រ ជាជោគជ័យដំបូងបំផុតនៃការបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ដែលអាស្រ័យដោយវណ្ណៈកម្មករដឹកនាំ ហើយជាជ័យជំនះដំបូងរបស់ប្រជាជាតិអាស៊ី ក្នុងការប្រឆាំងចក្រពត្តិអាណានិគមនិយម។ ជោគជ័យនៃបដិវត្តន៍ខែ សីហា ១៩៤៥ បាននាំមកនូវការប្រៀបធៀបកម្លាំងថ្មីលើសមរភូមិទូទាំងឥណ្ឌូចិន បង្កើតបានជាមូលដ្ឋានបង្អែកសំរាប់ឈានឡើងរបស់បដិវត្តន៍នាពេលក្រោយ។

ដោយឡែក ចំពោះបដិវត្តន៍កម្ពុជា មិនអាចដណ្តើមបានជ័យជំនះក្នុងពេលដែលលក្ខណៈសម្បត្តិអន្តរជាតិអនុគ្រោះ ប្រការនេះបង្ហាញឡើងនូវកត្តាបី៖

<u>ទីមួយ៖</u> កត្តាសំរេចកំណត់បំផុត គឺលក្ខណៈសម្បត្តិផ្ទៃក្នុង កម្លាំងបដិវត្តថ្វីត្បិតតែបានរីកធំធាត់ ប៉ុន្តែនៅទន់ខ្សោយនៅឡើយ មូលដ្ឋានបដិវត្តទាំងនៅទីក្រុង ទាំងនៅជនបទ មានតិច កម្លាំងប្រដាប់អាវុធមិន

*ទាន់គ្រប់លទ្ធភាព ការភ្ញាក់រលឹករបស់ប្រជាជនមិនទាន់ខ្ពស់ បន្ថែមពីលើនេះ ចលនាក្លែងបន្លំមួយចំនួនចេញពីឧបាយកលសត្រូវបំផ្លិចបំផ្លាញ ដូចជាចលនារបស់ ដាប ឈួន, ចន្ទរង្សី, កៅ តក់, ពុត ឆាយ, ប៊ុន អ៊ំៗលៗ ដែលក្រុមទាំងនេះ តែងធ្វើសកម្មភាពផ្ទុយពីប្រយោជន៍ប្រជាជន បន្ថយនូវជំនឿរបស់ប្រជាជនចំពោះចលនាតស៊ូបដិវត្ត វាក៏ជាចលនាបំបែកបំបាក់សម្ព័ន្ធភាពនៃកម្លាំងប្រឆាំងអាណានិគមនិយម ហ្វាស៊ីស្តនិយមផងដែរ។ ឆ្លងតាមបទពិសោធន៍នេះ អាចដកហូតបាននូវវិធីសាស្ត្រច្បាស់ថា <u>លក្ខណៈសម្បត្តិផ្ទៃក្នុងជាកត្តាសំរេចកំណត់បំផុត ទោះជាលក្ខៈសម្បត្តិអន្តរជាតិអនុគ្រោះយ៉ាងណាក៏ដោយ តែបើកត្តាផ្ទៃក្នុងមិនទុំជោរទេ បដិវត្តន៍នឹងមិនអាចទទួលជ័យជំនះបានឡើយ</u>។*

*<u>ទីពីរ</u>ៈ គឺការប្រៀបធៀបកម្លាំងទូទាំងសមរភូមិឥណ្ឌូចិន មិនទាន់អនុញ្ញាតអោយដណ្តើមជ័យជំនះទាំងស្រុង ក្នុងពេលជាមួយគ្នា។ ចំណុចនេះ អាចដកស្រង់បាននូវការសន្និដ្ឋានមួយថា <u>ការបដិវត្តនៅកម្ពុជា ក៏ដូចជានៅឥណ្ឌូចិន និងការបដិវត្តនៅប្រទេសនានាលើសកលលោកសុទ្ធតែស្ថិតក្នុងក្របខ័ណ្ឌនៃការតស៊ូយូរអង្វែង លំបាកវេទនា ដណ្តើមជ័យជំនះជាជំហានៗ និងឈានទៅដល់ជ័យជំនះទាំងស្រុង ដូច្នេះគ្រប់ការបដិវត្ត តែងតែស្ថិតក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រយូរអង្វែង</u>។ នៅវៀតណាម លក្ខណៈសម្បត្តិផ្ទៃក្នុងអនុគ្រោះបង្គួរ ប៉ុន្តែតាមលទ្ធភាពនៃលក្ខណៈសម្បត្តិផ្ទៃក្នុងនោះ ទើបផ្តល់អោយបដិវត្តន៍វៀតណាមដណ្តើមបានជ័យជំនះពាក់កណ្តាលនាឆ្នាំ ១៩៤៥ - ១៩៥៤ ហើយត្រូវឆ្លងកាត់ការតស៊ូពោរពេញដោយការលំបាក ពលិកម្មអស់រយៈពេលយ៉ាងយូរ*

ទើបឈានទៅជណ្តើមជ័យជំនះទាំងស្រុងនាឆ្នាំ ១៩៧៩។ ថ្វីត្បិតតែជ័យជំនះមួយជំហាន ឬពាក់កណ្តាល ប៉ុន្តែមានសារៈសំខាន់ណាស់សំរាប់ជំហានក្រោយមកទៀត។ ប្រការនេះកាន់តែបង្ហាញច្បាស់នូវសច្ចៈធម៌មួយ គឺ <u>ធន្ទៈមិនអាចរំលងនូវលទ្ធភាពបានឡើយ</u>។ បដិវត្តន៍កម្ពុជាទោះមិនទាន់ជណ្តើមបានរដ្ឋអំណាច តែក៏បានធ្វើអោយចលនាតស៊ូបានរីកធំជាត់ មួយជំហាន សំរាប់រយៈពេលក្រោយមកទៀត។

<u>ទីបី</u>៖ ការប្រៀបធៀបកម្លាំងនៅលើសកលលោក ក៏មិនទាន់ផ្តល់លទ្ធភាពគ្រប់គ្រាន់ ដើម្បីអោយបដិវត្តន៍នៅបណ្តាប្រទេសជណ្តើមបានជ័យជំនះនៅគ្រប់ទីកន្លែងដែរ។ សហភាពសូវៀត ថ្វីត្បិតតែឈ្នះសង្គ្រាម ប៉ុន្តែក៏ត្រូវប្រឈមមុខដោះស្រាយបញ្ហាក្រោយសង្គ្រាម ប្រទេសអឺរ៉ុបប៉ែកខាងកើត ថ្វីត្បិតបានរំដោះ ហើយដើរតាមផ្លូវសង្គមនិយម តែនៅថ្មីថ្មោង ត្រូវប្រឈមមុខដោះស្រាយបញ្ហាការការពាររដ្ឋអំណាច និងការកសាងប្រទេសឡើងវិញ។ ថ្វីត្បិតជប៉ុន ដែលជាមុខសញ្ញាតស៊ូរបស់បដិវត្តន៍ពេលនោះ បានចាញ់សង្គ្រាម ប៉ុន្តែបារាំងត្រូវវិលត្រឡប់មកជណ្តើមអាណានិគមខ្លួនវិញ ដោយមានការជួយឧបត្ថម្ភរបស់អាមេរិក និងអង់គ្លេស។ ឯរដ្ឋអំណាចអាយ៉ង នៅបណ្តាប្រទេសឥណ្ឌូចិន ទោះបីជាជប៉ុនចាញ់ ក៏គេខិតខំរក្សាទុកនូវអំណាចរបស់គេ រង់ចាំបារាំងមកដល់។

កត្តាទាំងបីខាងលើ គឺស្ថិតក្នុងក្របខ័ណ្ឌនៃការប្រៀបធៀបកម្លាំង និងការគួបផ្សំរវាងលក្ខណៈសម្បត្តិផ្ទៃក្នុង និងលក្ខណៈសម្បត្តិអន្តរជាតិ។ បញ្ហានេះ បានដាក់អោយគ្រប់ការបដិវត្តន៍ ជានិច្ចកាលត្រូវយកចិត្ត

*ទុកដាក់កសាងកម្លាំង ពិសេសបក្ស កម្លាំងប្រដាប់អាវុធ ភ្ជាប់ជាប់មូលដ្ឋានមហាជន ក្នុងរណសិរ្សធំទូលាយ និងរឹងមាំ ភ្ជាប់ជាប់ការប្រែប្រួលនៃភាពការណ៍ ចេះបង្កឱកាស ចេះប្រើប្រាស់ឱកាស ចេះគួបផ្សំលក្ខណៈសម្បត្តិផ្ទៃក្នុង និងលក្ខណៈសម្បត្តិអន្តរជាតិ ដើម្បីជំរុញបដិវត្តន៍អោយមានជំហានទៅមុខ និងដណ្តើមបានជ័យជំនះ។*

*ក្រោយជប៉ុនចាញ់ បដិវត្តន៍នៃប្រទេសទាំងបីនៅឥណ្ឌូចិន សុទ្ធតែមានការរីកចំរើន។ ក្រៅពីបដិវត្តន៍ខែ សីហា របស់វៀតណាមដណ្តើមបានទូវរដ្ឋអំណាច បដិវត្តន៍កម្ពុជា ឡាវ ក៏សុទ្ធតែបានរីកធំធាត់។ ប៉ុន្តែព្រមពេលជាមួយគ្នា ពួកអាណានិគមនិយមទាំងចាស់ទាំងថ្មី និងពួកអាយ៉ងអាណានិគម ក៏សុទ្ធតែបានសហការគ្នា។ អង់គ្លេសកាលពីមុនមានទំនាស់ជាមួយបារាំង អំពីដែនអាណានិគម ដែលអង់គ្លេសបានស្ថិតនៅពីក្រោយខ្នងរបស់សៀម ក៏បានចេញមុខជួយអាណានិគមនិយមបារាំង ដើម្បីស្តារឡើងវិញនូវអាណានិគមបារាំងនៅឥណ្ឌូចិន។ អង់គ្លេសបានចូលមកឥណ្ឌូចិន សំខាន់ចូលភាគខាងត្បូងវៀតណាមដោយជ្រកក្រោមផ្លាក "មកដើម្បីដកហូតអាវុធពីពួកហ្វាស៊ីស្តជប៉ុន"។ ផ្អែកលើកម្លាំងរបស់អង់គ្លេស បារាំងក៏បានដណ្តើមត្រួតត្រាភាគខាងត្បូងវៀតណាម ឡាវ និងកម្ពុជាឡើងវិញ បារាំងក៏បានវាយសំរុកទៅលើភាគខាងជើងវៀតណាម បន្ទាប់ពីបានពង្រីកអាណានិគមនៅភាគខាងត្បូង។ ខែធ្នូ ឆ្នាំ ១៩៤៦ ថៃបានប្រគល់ខេត្តមួយចំនួនរបស់កម្ពុជាមកអោយបារាំងវិញ។*

*នៅកម្ពុជា ក្រោយពីបារាំងត្រឡប់ចូលមកវិញនាខែ តុលា ១៩៤៥*

*រាជរដ្ឋាភិបាលស្និទ្ធជប៉ុនក៏ត្រូវដួលរលំ ហើយស្ដេចក៏បានទទួលយកការគ្រប់គ្រងរបស់បារាំងឡើងវិញ ដែលការគ្រប់គ្រងនេះត្រូវបានបដិសេធចោលតាមរាជក្រិត្យ (*) ថ្ងៃ ១២ មីនា ១៩៤៥ របស់ស្ដេច នរោត្តម សីហនុ ស្ដីពី ការបដិសេធចោលនូវកិច្ចព្រមព្រៀងទាំងអស់ ដែលចុះហត្ថលេខាជាមួយបារាំង។ ការបដិសេធនេះធ្វើឡើង ក្រោយពេលជប៉ុនដាក់ការគ្រប់គ្រងប្រទេសខ្មែរតែប៉ុន្មានថ្ងៃ។ ទំនាស់បានផ្ទេរពីទំនាស់រវាងប្រជាជាតិកម្ពុជា ជាមួយហ្វាស៊ីស្តជប៉ុន មកជាទំនាស់រវាងប្រជាជាតិកម្ពុជា ជាមួយអាណានិគមនិយមបារាំងឡើងវិញ។*

*ទោះបីជាបារាំងបានត្រឡប់ចូលមកឥណ្ឌូចិនវិញក៏ដោយ ក៏បារាំងបានឃើញច្បាស់ថា គេត្រូវប្រឈមមុខជាមួយរណសិរ្សជាច្រើនក្នុងពេលជាមួយគ្នា។ ក្រៅពីវៀតណាម ឡាវ នៅកម្ពុជា បារាំងត្រូវប្រឈមមុខនឹងទិសពីរ។ ទិសទីមួយ គឺចលនាតស៊ូបដិវត្តរបស់ប្រជាជនកម្ពុជាបានរីកធំធាត់ ហើយកំពុងគំរាមកំហែងពិតប្រាកដ ទៅលើផលប្រយោជន៍នៃរបបអាណានិគមនិយមបារាំង។ ទិសទីពីរ បារាំង ត្រូវប្រឈមមុខជាមួយពួកសក្តិភូមិ នាហ្មឺនមន្ត្រីក្នុងរាជវាំង និងរាជរដ្ឋាភិបាលស្និទ្ធបារាំងនៅកម្ពុជាផងដែរ។ ពិនិត្យអំពើជាក់ស្ដែងរបស់បារាំង តាមរយៈយុទ្ធវិធីសម្រុះសម្រួលរបស់បារាំង ជាមួយរាជរដ្ឋាភិបាល និងសក្តិភូមិខ្មែរ អាចដកចេញនូវការវាយតម្លៃបានមួយថា <u>បារាំងមិនចង់ប្រឈមមុខជាមួយរណសិរ្សពីរក្នុងពេលជាមួយគ្នាទេ។ ការប្រឈមមុខនឹងទិសពីរក្នុងពេលជាមួយគ្នា នឹងនាំដល់គ្រោះថ្នាក់នៃផលប្រយោជន៍បារាំង</u>*

(*) ប្រវត្តិសាស្រ្តសង្ខេបនៃប្រទេសកម្ពុជា របស់អ្នកនិពន្ធ យ. យ. មីហេយ៉េវ បោះពុម្ពដោយ ប្រូហ្គ្រេស-មូស្គូ ១៩៨៥ ទំព័រទី ៣៤៤។

ដូច្នេះ ត្រូវធ្វើការសម្រុះសម្រួលជាមួយកម្លាំងដែលអាចព្រមព្រៀងគ្នាបាន អំពីផលប្រយោជន៍ ទាំងចំពោះមុខ និងយូរអង្វែង ដើម្បីបង្កើតឡើងនូវរណសិរ្សប្រឆាំងជាមួយចលនាទាមទារឯករាជ្យ សេរីភាព ប្រជាធិបតេយ្យរបស់ប្រជាជន ដែលវាបដិបក្ខជាមួយផលប្រយោជន៍អាណានិគមបារាំង ទាំងចំពោះមុខនិងយូរអង្វែង។ នេះមិនមែនជាការសម្រុះសម្រួលរវាងវណ្ណៈដែលមានផលប្រយោជន៍បដិបក្ខគ្នានោះឡើយ ប៉ុន្តែជាការសម្រុះសម្រួល ជាមួយវណ្ណៈដែលមានផលប្រយោជន៍ស្របគ្នា ហើយការខុសគ្នានោះសុទ្ធតែអាចសម្រុះសម្រួលគ្នាបាន លើមូលដ្ឋានការពារផលប្រយោជន៍គ្នាទៅវិញទៅមក។ ការសម្រុះសម្រួលរបស់បារាំងជាមួយវណ្ណៈត្រួតត្រានៅកម្ពុជានាពេលនោះ គឺជាការចាំបាច់ដើម្បីពង្រឹងស្ថានភាពរបស់បារាំង ទប់ទល់ជាមួយបដិវត្តន៍វៀតណាម ដែលបារាំងយល់ច្បាស់ថា ជាគ្រោះថ្នាក់សំខាន់បំផុតសំរាប់អាណានិគមនិយមបារាំង នៅទូទាំងឥណ្ឌូចិន។

បារាំងអនុវត្តយុទ្ធវិធីសម្រុះសម្រួលជាមួយស្តេច និងរាជរដ្ឋាភិបាលខ្មែរជាច្រើនជំហាន។ ជំហានទីមួយ គឺជ្រកក្រោមផ្លាកផ្តល់នូវស្វ័យភាពផ្ទៃក្នុងអោយកម្ពុជា តាមកិច្ចព្រមព្រៀងបណ្តោះអាសន្នរវាងរាជរដ្ឋាភិបាលជាមួយបារាំង ថ្ងៃ ៧ មករា ១៩៤៦។ កិច្ចព្រមព្រៀងបណ្តោះអាសន្នបារាំង-កម្ពុជា ធាតុពិតគឺជាការប្តូរគ្នារវាងបារាំង និងសក្តិភូមិខ្មែរ ដែលមានផលប្រយោជន៍អោយបារាំង នោះគឺការផ្តល់អោយបារាំងរៀបចំឡើងវិញនូវអាណានិគមនិយមរបស់ខ្លួននៅកម្ពុជា សម្រួលដល់ការគ្រប់គ្រងរបស់បារាំងលើដែនដីអាណានិគមនេះ។ ហើយនេះ ក៏ជា

ដំណាក់កាលដំបូងនៃ នយោបាយខ្មែរូបនីយកម្មសង្គ្រាមរបស់បារាំងនៅកម្ពុជា ជាជំហានឈានទៅប្រើប្រាស់ជនជាតិខ្មែរបង្ក្រាបជនជាតិខ្មែរតាមនយោបាយបំបែកដើម្បីត្រួតត្រា ដែលបារាំងឈរបញ្ជាពីក្រោយ។ នេះក៏ជាជំហានសម្រុះសម្រួល ដើម្បីទប់ស្កាត់ការតស៊ូនៅក្នុងផ្ទៃក្នុងពួកគហបតី ដែលស្និទ្ធបារាំង តម្រង់មុខព្រួញទៅបំបែកបំបាក់ផ្ទៃក្នុងចលនាតស៊ូបដិវត្ត បង្កការស្រមើស្រម៉ៃយចំពោះប្រជាជនអំពីស្វ័យភាពក្លែងក្លាយ ដែលទាំងអស់នេះដើម្បីពង្រឹងរបបអាណានិគមនិយមបារាំង និងដើម្បីបង្ក្រាបចលនាតស៊ូបដិវត្តន៍របស់ប្រជាជន។

កិច្ចព្រមព្រៀងបណ្តោះអាសន្នបារាំង-កម្ពុជា មានការពង្រីកខ្លះទៅដល់អំណាចរាជរដ្ឋាភិបាល ហើយប្រែក្លាយទេសាភិបាលបារាំង ដែលគ្រប់គ្រង មកជាទីប្រឹក្សាស្តេចវិញ។ ប៉ុន្តែប្រការនេះ គ្មានន័យអ្វីទាល់តែសោះដល់ស្វ័យភាពរបស់កម្ពុជា ហើយក៏គ្មានចុះខ្សោយអ្វីសោះដល់ការត្រួតត្រារបស់បារាំងលើប្រទេសកម្ពុជា ប៉ុន្តែផ្ទុយទៅវិញ វាជាការសម្រួលយ៉ាងច្រើនដល់ការត្រួតត្រារបស់បារាំង អាស្រ័យម្យ៉ាងកិច្ចព្រមព្រៀងបានបញ្ជាក់ច្បាស់ថា សេចក្តីសំរេចទាំងអស់ខាងនីតិបញ្ញត្តិ និងនីតិប្រតិបត្តិរបស់រាជរដ្ឋាភិបាល ត្រូវទទួលការយល់ព្រមរបស់ស្នងការបារាំងជាមុនសិន។ សកម្មភាពរបស់អង្គការនីតិប្រតិបត្តិ បានស្ថិតនៅក្រោមការត្រួតត្រារបស់ទីប្រឹក្សាបារាំង ដែលមានការចាត់តាំងអោយធ្វើការអមទីស្តីការរដ្ឋមន្ត្រី និងក្រសួងនានា។ ម្យ៉ាងទៀត ប្រទេសកម្ពុជាក៏នៅតែស្ថិតជាសមាសភាពក្នុងសហព័ន្ធឥណ្ឌូចិន ដែលប្រទេសនេះគ្មានសិទ្ធិរៀបចំទំនាក់ទំនងការទូតជាមួយប្រទេសផ្សេងទៀតឡើយ។

ដើម្បីបង្ក្រាបចលនាតស៊ូរបស់ប្រជាជន ដើម្បីបោកប្រាស់ប្រជាជន និងដើម្បីអូសទាញពួកអភិជន គហបតីអោយនៅខាងខ្លួន បារាំងបានបន្តជំហានសម្រុះសម្រួលរបស់ខ្លួនតាមរយៈរបស់ដែលហៅថា ការកែទម្រង់ខាងនយោបាយ គឺអនុញ្ញាតអោយមានការបង្កើតឡើងនូវបក្សនយោបាយតូចៗ ចំនួនបី ដែលសុទ្ធតែតំណាងអោយផលប្រយោជន៍ពួកសក្តិភូមិ អភិជន ហើយមាននយោបាយស្របជាមួយបារាំង ក្នុងការប្រឆាំងចលនាតស៊ូស្នេហាជាតិកម្ពុជា។ ការអនុញ្ញាតអោយបង្កើតបក្សនយោបាយ ក៏ជាយុទ្ធវិធីរបស់បារាំងដើម្បីពង្រឹងការត្រួតត្រារបស់ខ្លួន។ បារាំងឆ្លៀតប្រើប្រាស់ការខុសគ្នារបស់បក្សទាំងនេះ តាមរបៀបសម្រុះសម្រួលផង និងរារាំងផង ចុងក្រោយបក្សណាក៏ត្រូវតែពឹងពាក់បារាំងដើម្បីតស៊ូជាមួយគ្នា។

ថ្ងៃ ១ កញ្ញា ១៩៤៦ មានការបោះឆ្នោតបង្កើតឡើងនូវរដ្ឋសភាបណ្តោះអាសន្ន ហើយថ្ងៃ ៦ ឧសភា ១៩៤៧ នរោត្តម សីហនុ បានប្រកាសអោយប្រើប្រាស់រដ្ឋធម្មនុញ្ញ ដែលជារដ្ឋធម្មនុញ្ញលើកដំបូងរបស់ប្រទេសកម្ពុជា ដែលតាមរាជក្រមលេខ ៤៦៤ ន.ស. ចុះថ្ងៃ ៦ កញ្ញា ឆ្នាំ១៩៤៨ បានប្រកាសទុកថ្ងៃ ៦ ឧសភា រៀងរាល់ឆ្នាំ ជាថ្ងៃបុណ្យជាតិ។

ប្រសិនបើនិយាយអំពីរបបអាណានិគមនិយមបារាំង ថ្ងៃ ៦ ឧសភា ១៩៤៧ គឺជាថ្ងៃដែលកម្ពុជាបានផ្ទេរពីរបបរាជានិយមមកកាន់របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។ ក្រោយមានរដ្ឋធម្មនុញ្ញនេះ ពួកគេបានដំណើរការបោះឆ្នោតជ្រើសតាំងរដ្ឋសភា ដែលមានរដ្ឋសភាលើកទី ១ ថ្ងៃ ២១ ធ្នូ ១៩៤៧ រដ្ឋសភាលើកទី ២ ថ្ងៃ ៩ កញ្ញា ១៩៥១។

ពីឆ្នាំ ១៩៤៦ ដល់ឆ្នាំ ១៩៥៣ បារាំងបានបន្តជំហានសម្រុះសម្រួលជាមួយរាជរដ្ឋាភិបាលកម្ពុជា រហូតដល់ការប្រគល់របស់ដែលហៅថា ឯករាជភាពជូនកម្ពុជា។ នេះមិនមែនមកពីសុច្ឆន្ទៈរបស់បារាំងចង់ផ្តល់ឯករាជ្យដល់កម្ពុជា ឬមកពីការតស៊ូរបស់មនុស្សក្នុងរាជវង្សនោះឡើយ ប៉ុន្តែនេះជាយុទ្ធវិធីរបស់បារាំង ដើម្បីសង្គ្រោះអាណានិគមនៅឥណ្ឌូចិន ទប់ស្កាត់កុំអោយបាត់បង់ទាំងស្រុង ទាំងរបបអាណានិគមនិយម ទាំងរបបអាយ៉ង ដែលបណ្តាលមកពីការវាយលុកនៃកងកម្លាំងស្នេហាជាតិកម្ពុជា វៀតណាម ឡាវ។

ការតស៊ូរបស់ប្រជាជនកម្ពុជា វៀតណាម ឡាវ ក្រោមការដឹកនាំរបស់បក្សកុម្មុយនិស្តឥណ្ឌូចិន បានដាក់អោយបារាំងស្ថិតក្នុងសភាពការណ៍លំបាក ដែលតម្រូវអោយរដ្ឋាភិបាលបារាំងត្រូវពិនិត្យឡើងវិញនូវគោលនយោបាយរបស់ខ្លួនចំពោះប្រទេសកម្ពុជា ព្រោះថាបារាំងត្រូវប្រឈមមុខសំខាន់បំផុតពីទិសនៃការតស៊ូរបស់ប្រជាជនវៀតណាម ដូច្នេះបារាំងក៏ត្រូវមានកម្ពុជា ជាសមរភូមិដែលស្ងៀមភាព។ ដូច្នេះ វិធីដែលល្អបំផុតរបស់បារាំង គឺត្រូវសម្រុះសម្រួលជាមួយសក្តិភូមិខ្មែរ ប្រសើរជាងទុកអោយចលនាតស៊ូរបស់ប្រជាជនកម្ពុជាដណ្តើមអំណាច ហើយការសម្រុះសម្រួលជាមួយពួកសក្តិភូមិខ្មែរ ក៏ជានារក្សាបាននូវផលប្រយោជន៍ខាងនយោបាយ យោធា សេដ្ឋកិច្ចនៃអាណានិគមនិយមបារាំង។

នេះជាជំហានកែសម្រួលខាងយុទ្ធសាស្ត្រ មានចរិតចាំបាច់របស់បារាំង ដែលបារាំងត្រូវសំរេចចិត្តបន្ធូរបន្ថយចំពោះរាជានិយមនៅកម្ពុជា ក្នុងគោលបំណងដើម្បីរក្សាទុកមហាក្សត្រ និងរាជរដ្ឋាភិបាលកម្ពុជា ក្នុង

ឋានៈជាសម្ព័ន្ធមិត្តរបស់ខ្លួន នៅក្នុងក្រុបខ័ណ្ឌនៃយុទ្ធសាស្ត្រឥណ្ឌូចិនរបស់បារាំង។ ទោះជាបារាំងបានទទួលស្គាល់ប្រទេសកម្ពុជាថាជារដ្ឋឯករាជ្យតាមសន្ធិសញ្ញាក្រុងប៉ារីស ថ្ងៃ ០៨ វិច្ឆិកា ១៩៤៩ រវាងកម្ពុជា និងបារាំង តែបារាំងនៅតែរក្សាការត្រួតត្រារបស់ខ្លួនលើកម្ពុជា តាមរយៈកម្លាំងយោធាបារាំងនៅកម្ពុជា តាមរយៈការក្តាប់កងទ័ពកម្ពុជាដែលត្រូវតែនៅក្រោមគណៈកម្មាធិការយោធាពិសេស ដែលកិច្ចបញ្ជាការស្ថិតក្នុងកណ្តាប់ដៃនៃនាយទាហានបារាំង តាមរយៈការគ្រប់គ្រងដោយបារាំងនូវប្រព័ន្ធតុលាការ តាមរយៈការគ្រប់គ្រងរបស់បារាំង លើការតែងតាំងអគ្គរាជទូតកម្ពុជាប្រចាំប្រទេសក្រៅ ដែលត្រូវមានការយល់ព្រមពីរដ្ឋាភិបាលបារាំង និងតាមរយៈដែលកម្ពុជាត្រូវស្ថិតនៅជារដ្ឋក្នុងសហព័ន្ធបារាំង និងជាភាគីមួយក្នុងសហភាពចតុភាគី (បារាំង កម្ពុជា វៀតណាម ឡាវ) នៃប្រព័ន្ធរដ្ឋាករគយរូបិយវត្ថុ ដែលតាមសហភាពចតុភាគីនេះ បានជួយដល់អាណានិគមនិយមបារាំងអោយបន្តការត្រួតត្រា និងកាន់កាប់ខាងសេដ្ឋកិច្ច ជាមូលដ្ឋាននៅកម្ពុជា ក៏ដូចជានៅវៀតណាម ឡាវ។

តាមការកំណត់នៃសន្ធិសញ្ញាឆ្នាំ ១៩៤៩ ប្រទេសកម្ពុជាបានទទួលសិទ្ធិក្នុងការកសាងកងទ័ព ដែលស្ថិតក្រោមការត្រួតត្រាផ្ទាល់របស់មហាក្សត្រ ហើយនៅពេលមានសង្គ្រាមត្រូវស្ថិតក្រោមគណៈកម្មាធិការពិសេស ដែលកិច្ចបញ្ជាការត្រូវស្ថិតក្នុងដៃនៃតំណាងទីបញ្ជាការរបស់បារាំង។ នេះគឺជាការបន្តនយោបាយខ្សែបនីយកម្មសង្គ្រាមរបស់បារាំង ដែលបារាំងបានត្រៀមរៀបចំតាំងពីឆ្នាំ ១៩៤៦។ បារាំង ត្រូវការ

អោយសក្តិភូមិកម្ពុជា មានកងទ័ពមួយក្រោមបញ្ជារបស់បារាំង ដើម្បីប្រើប្រាស់ដៃរបស់ជនជាតិកម្ពុជាបង្ក្រាបជនជាតិកម្ពុជាគ្នាឯង។

ការធ្វើសម្បទានរបស់បារាំង គ្រាន់តែបានបំពេញចិត្តចំពោះអ្នករាជានិយមតែប៉ុណ្ណោះ ប៉ុន្តែទំនាស់រវាងអាណានិគមនិយមបារាំងជាមួយប្រជាជាតិកម្ពុជា និងទំនាស់រវាងប្រជាកសិករ និងពលករផ្សេងទៀតជាមួយវណ្ណៈជិះជាន់ក្នុងសង្គម កាន់តែកើនឡើងជារៀងរាល់ថ្ងៃអាស្រ័យដោយទំនាស់កាន់តែតានតឹង ការតស៊ូរបស់ប្រជាជនកម្ពុជាកាន់តែមានសន្ទុះទៅមុខៗ ការបដិវត្តប្រជាជាតិប្រជាធិបតេយ្យ កាន់តែមានខ្លឹមសារសមស្រប ទៅនឹងសភាពការណ៍ជាក់ស្តែងរបស់សង្គម។ នោះគឺការទាមទាររំលាយផ្តួលរំលំរបបអាណានិគមនិយមបារាំង លុបបំបាត់ចោលរដ្ឋអំណាចសក្តិភូមិជាបរិវារ ដណ្តើមឯករាជ សេរីភាព ជូនប្រជាជន។

ចលនាតស៊ូរបស់ប្រជាជនកម្ពុជា ក៏ដូចជាប្រជាជនវៀតណាម ឡាវ បានរីកចំរើន និងបន្តជំហានទៅមុខយ៉ាងលឿន។ ដោយឡែក នៅកម្ពុជា ការកសាងថ្មីនូវអង្គការចាត់តាំងបដិវត្ត ការបង្រួបបង្រួមនូវចលនាតស៊ូអោយមានការឯកភាព គឺជាមូលដ្ឋានសំខាន់សំរាប់ឈានដល់ការបង្កើតរណសិរ្សឯកភាពទូទាំងប្រទេស និងរដ្ឋាភិបាលបណ្តោះអាសន្ននៃកម្លាំងតស៊ូកម្ពុជា ដែលសំរេចដោយសន្និបាតកម្មាភិបាលទូទាំងប្រទេសលើកទី ១ ចាប់ពីថ្ងៃ ១៧ ដល់ ១៩ មេសា ១៩៥០។ ការបង្កើតឡើងនូវអង្គការនយោបាយដ៏សំខាន់ទាំងពីរនេះ ជាមួយនឹងសេចក្តីប្រកាសឯករាជដែលអានដោយអាចារ្យ មៀន (សឺង ង៉ុកមិញ) ថ្ងៃ

១៩ មិថុនា ១៩៥០ នៅក្នុងមិទ្ទិញប្រជាជននៅស្រុកស្រែអំបិល ខេត្ត កំពត (*) គឺជាព្រឹត្តិការណ៍នយោបាយដ៏សំខាន់របស់ប្រជាជនកម្ពុជា ក៏ដូចជាចលនាតស៊ូនៅឥណ្ឌូចិនទាំងមូល។ ព្រឹត្តិការណ៍នេះ គឺជាកត្តាជំរុញយ៉ាងខ្លាំងដល់ការពង្រឹងការឯកភាព នៃបណ្តាអង្គការចាត់តាំងខាងនយោបាយ យោធា និងអង្គការមហាជននានានៃចលនាតស៊ូ។ ព្រឹត្តិការណ៍នេះ ក៏ជាកត្តាសំខាន់មួយផ្តល់នូវភាពអនុគ្រោះជាមូលដ្ឋានសំរាប់ការបង្កើតឡើងនូវបក្សប្រជាជនបដិវត្តខ្មែរ នាថ្ងៃ ២៨ មិថុនា ១៩៥១ បន្ទាប់ពីមហាសន្និបាតតំណាងទូទាំងប្រទេសលើកទី ២ នៃបក្សកុម្មុយនិស្តឥណ្ឌូចិន ខែ កុម្ភៈ ១៩៥១ ដែលបានសំរេចថា បក្សនឹងចេញធ្វើសកម្មភាពចំហរ ព្រមទាំងតម្រូវអោយមានការចាត់តាំងឡើងវិញសមស្របតាមសភាពការណ៍ថ្មីនៃប្រទេសនិមួយៗ ដែលចំណុចនេះបានគូសបញ្ជាក់ទៅដល់ភាពចាំបាច់អោយប្រទេសនិមួយៗ មានបក្សដោយឡែក ដើម្បីដឹកនាំប្រជាជនអោយបានសមស្រប ជាមួយសភាពការណ៍ជាក់ស្តែងនៅប្រទេសរបស់ខ្លួន។ ការបំបែកបក្សកុម្មុយនិស្តឥណ្ឌូចិនជាបីបក្ស នៅកម្ពុជា វៀតណាម ឡាវ បានធ្វើអោយលេចធ្លោឡើងនូវតុល្យភាពកម្លាំងក្នុងសភាពការណ៍ថ្មី ដែលអនុគ្រោះអោយការតស៊ូបដិវត្តនៅប្រទេសនិមួយៗ ក្នុងក្របខ័ណ្ឌនៃការតស៊ូរួមប្រឆាំងអាណានិគមនិយមបារាំង និងការជ្រៀតជ្រែករបស់ចក្រពត្តិអាមេរិកនៅឥណ្ឌូចិន។ លក្ខណៈសម្បត្តិផ្ទៃក្នុង និងលក្ខណៈសម្បត្តិអន្តរជាតិ បានអនុញ្ញាត និងតម្រូវអោយដំណើរការយ៉ាងដូច្នេះ។ នេះគឺជាចរិតភ្លឺស្វាងរបស់ជនកុម្មុយនិស្តនៅឥណ្ឌូចិន ដែលបានអនុវត្តយុទ្ធសាស្ត្រ

(*) ឯកសារស្រាវជ្រាវដោយគណៈស្រាវជ្រាវ ប្រវត្តិសាស្ត្រ បក្សប្រជាជនបដិវត្តកម្ពុជា។

យុទ្ធវិធីសមស្របទៅតាមសភាពការណ៍នៃដំណាក់កាលនិមួយៗ។

បក្សនយោបាយនៃបដិវត្តន៍កម្ពុជា បានយកឈ្មោះថាជា បក្សប្រជាជនបដិវត្តខ្មែរ គឺជាការភ្ជាប់ស្ពានមួយស្របជាមួយសភាពការណ៍ជាក់ស្តែងនៃប្រទេសជាតិ។ បក្សបានយកថ្ងៃ ២៨ មិថុនា ១៩៥១ ជាថ្ងៃបង្កើតបក្ស ដោយមិនបានយកថ្ងៃបង្កើតបក្សកុម្មុយនិស្តឥណ្ឌូចិន ឆ្នាំ ១៩៣០ ជាថ្ងៃកំណើតទេ។

ប្រការនេះ តើមានផលប៉ះពាល់អ្វីទៅដល់ចរិតរបស់បក្សនាពេលក្រោយទៀតឬទេ? ហើយបាត់បង់នូវប្រភពកំណើតនៃបក្សនយោបាយនេះឬទេ? ដូចបានរៀបរាប់ខាងលើ អាចកំណត់បានច្បាស់ថា បក្សប្រជាជនបដិវត្តខ្មែរ បានចាប់បដិសន្ធិឡើងដោយមានការគួបផ្សំរវាងទ្រឹស្តីនៃលទ្ធិម៉ាក្ស-ឡេនីន ជាមួយចលនាស្នេហាជាតិដែលមានស្រាប់ ដែលការគួបផ្សំនេះ ធ្វើឡើងក្រោយការបង្កើតបក្សកុម្មុយនិស្តឥណ្ឌូចិន ដោយប្រធាន ហូ ជីមិញ ឆ្នាំ ១៩៣០ ហើយពិសេសបានរីកចំរើនខ្លាំងក្រោយឆ្នាំ ១៩៤៥។ ក្រោយបក្សបានកើតឡើង ហើយបានស្ថិតនៅជាភាគមួយនៃបក្សកុម្មុយនិស្តឥណ្ឌូចិន តាមរយៈបក្សភាគបក្សកុម្មុយនិស្តឥណ្ឌូចិននៅកម្ពុជា គឺជាប្រការសមស្របបំផុត ក្នុងដំណាក់កាលនាពេលនោះ។ ការរីកចំរើនឡើងនៃកម្លាំង និងចលនាបដិវត្ត ក្រោមការដឹកនាំរបស់បក្សភាគបក្សកុម្មុយនិស្តឥណ្ឌូចិននៅកម្ពុជា គឺជាតំណាមរតកដ៏សំខាន់សំរាប់ប្រែក្លាយទៅជា បក្សប្រជាជនបដិវត្តខ្មែរនាពេលក្រោយ ហើយប្រការនេះគ្មានផលប៉ះពាល់អ្វីចំពោះចរិតបក្ស ឬមាគ៌ាយុទ្ធសាស្ត្រយុទ្ធវិធីរបស់បក្សនាពេលក្រោយឡើយ។ អាស្រ័យដោយម្យ៉ាង ទោះជា

បក្សស្ថិតក្នុងស្ថានភាពបែបណាក៏ដោយ ក៏បក្សនេះអាចប្រកាន់ខ្ជាប់នូវលទ្ធិម៉ាក្ស-លេនីន ម្យ៉ាងទៀតបក្សភាគនៃបក្សកុម្មុយនិស្តឥណ្ឌូចិននៅកម្ពុជា ដែលជាមូលដ្ឋានសំខាន់បំផុតសំរាប់ការបង្កើតបក្សប្រជាជនបដិវត្តខ្មែរ បានមានមាគ៌ា យុទ្ធសាស្ត្រ យុទ្ធវិធីសំរាប់ដំណើរការបដិវត្តន៍នៅកម្ពុជាហើយដែរ ដែលមាគ៌ានេះត្រូវបានបង្ហាញតាមរយៈរណសិរ្សឯកភាពជាតិ និងរដ្ឋាភិបាលបណ្តោះអាសន្ននៃកម្លាំងតស៊ូកម្ពុជា។ ការតស៊ូបដិវត្តក្រោយការបង្កើតបក្ស គឺជាការបន្តនូវប្រពៃណីតស៊ូដែលមានពីមុនមក ក្រោមការដឹកនាំរបស់បក្សកុម្មុយនិស្តឥណ្ឌូចិន ហើយឆ្លងតាមព្រឹត្តិការណ៍នៃការបង្កើតបក្សនេះ បានជំរុញយ៉ាងខ្លាំងដល់ចលនាតស៊ូអោយមានការរីកចំរើន និងឈានតាមទិសកាន់តែត្រឹមត្រូវ។

ការបង្កើតរណសិរ្សឯកភាពជាតិ ការបង្កើតរដ្ឋាភិបាលបណ្តោះអាសន្ន និងការបង្កើតបក្សប្រជាជនបដិវត្តខ្មែរ បានធ្វើអោយចលនាបដិវត្តកម្ពុជាស្ថិតក្នុងរបៀបរៀបរយជាងពេលមុន ឯកភាពវាយសំរុកខ្លាំងជាងពេលមុន ហើយប្រជាជនកាន់តែរួមប្រាស្រ័យជាមួយបដិវត្តន៍ច្រើនជាងពេលមុន។ ព្រឹត្តិការណ៍ទាំងអស់នេះ បានដាក់អោយអាណានិគមនិយមបារាំង និងរាជរដ្ឋាភិបាលអាយ៉ង ស្ថិតចំពោះមុខសភាពការណ៍មិនធម្មតា។ ព្រមជាមួយនឹងការវាយលុករបស់បដិវត្តន៍វៀតណាម បដិវត្តន៍ឡាវ ចក្រពត្តិអាមេរិកបានអនុវត្តនយោបាយជ្រៀតជ្រែកដោយចំហ ដើម្បីជួយដល់បារាំងក្នុងការបន្តត្រួតត្រាឥណ្ឌូចិនផង និងត្រៀមរៀបចំលក្ខណៈសម្បត្តិ ដើម្បីជំនួសបារាំងនៅពេលក្រោយផង។ អាមេរិកបានយល់ព្រម និងគាំទ្រដល់នយោបាយបារាំងនៅកម្ពុជា និងបានប្រកាស

ទទួលស្គាល់នូវឯករាជ្យរបស់កម្ពុជា តាមសន្ធិសញ្ញាបារាំង-កម្ពុជាឆ្នាំ ១៩៤៩។ បន្ទាប់ពីបានប្រកាសទទួលស្គាល់ឯករាជ្យកម្ពុជា ខែ កុម្ភៈ ១៩៥០ អាមេរិកបានចុះហត្ថលេខានាខែធ្នូ ១៩៥០ លើកិច្ចព្រមព្រៀងជាមួយបារាំង អំពីការផ្តល់ជំនួយយោធាអោយកម្លាំងបារាំងនៅឥណ្ឌូចិន ដែលជំនួយទាំងនេះក៏បានដល់ដៃរាជរដ្ឋាភិបាលកម្ពុជាតាមរយៈបារាំង។ តាមរយៈកិច្ចព្រមព្រៀងនេះ ទីប្រឹក្សា អ្នកឯកទេស និងគ្រូបង្ហាត់ខាងយោធារបស់អាមេរិក ក៏បានបញ្ជូនមកកាន់ឥណ្ឌូចិន។ បដិវត្តន៍កម្ពុជាក៏ដូចវៀតណាម ឡាវ បានប្រឈមមុខចំពោះសភាពការណ៍ថ្មី គឺទន្ទឹមនឹងបន្តប្រឆាំងអាណានិគមនិយមបារាំង នៅមានភារកិច្ចថ្មីមួយទៀត គឺការប្រឆាំងនឹងការជ្រៀតជ្រែករបស់ចក្រពត្តិអាមេរិក ដែលតម្រូវអោយមាន ការបង្រួបបង្រួមកម្លាំងប្រឆាំងចក្រពត្តិនៅប្រទេសទាំងបី កម្ពុជា វៀតណាម ឡាវ ដែលតាមព្រឹត្តិការណ៍នាពេលនោះ គឺមានសន្និបាតសម្ព័ន្ធភាពប្រជាជននៃប្រទេសទាំងបីនៅឥណ្ឌូចិន ដែលបានបើកប្រជុំក្នុងខែ មីនា ១៩៥១ ដើម្បីពិភាក្សាអំពីការបង្កើតរណសិរ្សរួមលើគោលការណ៍ស្ម័គ្រចិត្ត សមភាព ជួយឧបត្ថម្ភគ្នាទៅវិញទៅមក ក្នុងការវាយបណ្តេញពួកអាណានិគមនិយមបារាំង និងពួកជ្រៀតជ្រែកអាមេរិក ដណ្តើមយកឯករាជ្យ សេរីភាព សុភមង្គល ភាពសម្បូររុងរឿងជូនប្រទេសជាតិខ្លួន។

ការតស៊ូក្នុងចន្លោះពីឆ្នាំ ១៩៥១-១៩៥៤ មានលក្ខណៈប្តូរផ្តាច់ គំរាមកំហែងដល់របបអាណានិគមនិយមនៅទូទាំងឥណ្ឌូចិន។ ការតស៊ូរបស់ប្រជាជននៅប្រទេសទាំងបីនៅឥណ្ឌូចិន ជាកម្លាំងសង្កត់យ៉ាងខ្លាំងចំពោះបារាំង បង្ខំអោយបារាំងត្រូវពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រ

របស់ខ្លួនចំពោះប្រទេសកម្ពុជា។ ស្របពេលជាមួយគ្នានោះ ការតស៊ូរបស់ប្រជាជនកម្ពុជា បានដាក់អោយរាជរដ្ឋាភិបាល ពិសេស នរោត្តម សីហនុ ស្ថិតក្នុងសភាពការណ៍ដ៏លំបាក។ នរោត្តម សីហនុ បានអនុវត្តនូវយុទ្ធវិធីទប់ស្កាត់ និងបង្ក្រាបចលនាតស៊ូ ដើម្បីតថ្លៃជាមួយបារាំងក្នុងការពង្រឹងនូវអំណាចរាជរដ្ឋាភិបាលកម្ពុជាផង។ ឆ្នាំ ១៩៥៣ នរោត្តម សីហនុ បានឈប់សាកល្បងរៀបចំអធិបតេយ្យភាពរដ្ឋបន្តិចម្តងៗ លើមូលដ្ឋាននៃការពង្រីកតំបន់ស្វ័យភាព ដែលបានអនុវត្តតាមសន្ធិសញ្ញាបារាំង-កម្ពុជា ឆ្នាំ ១៩៤៩ ហើយបែរទៅតស៊ូជាមួយបារាំងតាមផ្លូវទូតវិញ។

កម្លាំងសង្កត់នៃចលនាតស៊ូរបស់ប្រជាជនបានបង្ខំអោយបារាំងត្រូវធ្វើសម្បទាន ប៉ុន្តែសម្បទានរបស់បារាំង មិនមែនផ្តល់ដោយត្រង់អោយប្រជាជនកម្ពុជានោះឡើយ។ ការជ្រើសរើសល្អបំផុតរបស់បារាំង គឺធ្វើសម្បទានអោយមហាក្សត្រ និងរាជរដ្ឋាភិបាលកម្ពុជា។ បារាំងយល់ច្បាស់ថា ការធ្វើអោយសភាពការណ៍កម្ពុជាតានតឹងតទៅទៀត នឹងអាចបង្កើតគ្រោះថ្នាក់សំរាប់ខ្លួន។ ការធ្វើសម្បទានអោយរាជរដ្ឋាភិបាល និងមហាក្សត្រ ដើម្បីប្តូរយកមកវិញនូវសម្ព័ន្ធមិត្តដ៏គួរអោយទុកចិត្ត គឺជាការចាំបាច់ដើម្បីរក្សានូវផលប្រយោជន៍បារាំងនៅកម្ពុជា នៅពេលក្រោយ និងពេលចំពោះមុខ វាចាំបាច់សំរាប់អន្តរាគមន៍របស់បារាំងនៅប្រទេសវៀតណាម។ ការធ្វើសម្បទានលើកនេះ រួមមានការប្រគល់សិទ្ធិត្រួតត្រាលើក្រសួងនគរបាល និងយុត្តិធម៌ដល់រាជរដ្ឋាភិបាល តាមកិច្ចព្រមព្រៀងថ្ងៃ ២៩ សីហា ១៩៥៣ ការប្រគល់សិទ្ធិលើកិច្ចបញ្ជាការយោធាជាន់ខ្ពស់លើទឹកដីកម្ពុជាដល់រាជរដ្ឋាភិបាល តាមកិច្ចព្រមព្រៀង ថ្ងៃ

១៧ តុលា ១៩៥៣។ ចេញពីកិច្ចព្រមព្រៀងទាំងនេះ នាំដល់ការប្រកាសឡើងនូវអធិបតេយ្យកម្ពុជា នាខែ វិច្ឆិកា ១៩៥៣ ដែលគេហៅថា ឯករាជ្យទាំងស្រុង ហើយឯករាជ្យនេះត្រូវបានគេប្រើប្រាស់ក្នុងសន្និសីទហ្សឺណែវ ស្តីពីឥណ្ឌូចិន ឆ្នាំ ១៩៥៤ អំពីសិទ្ធិតំណាងរបស់កម្ពុជា ក្នុងសន្និសីទអន្តរជាតិនេះ។ ដូច្នេះ ឯករាជ្យដែលបារាំងបានផ្តល់អោយកម្ពុជាពេលនេះ មួយផ្នែកដើម្បីពង្រឹងស្ថានការណ៍នៃរដ្ឋាភិបាលអាយ៉ងនៅផ្ទៃក្នុងប្រទេស មួយផ្នែកទៀតគឺត្រៀមរៀបចំសំរាប់ការចូលរួមតថ្លៃលើតុចរចានៅសន្និសីទហ្សឺណែវ ព្រោះបារាំងយល់ច្បាស់ថា ពេលចូលដល់ដំណោះស្រាយ ពិតជានឹងមានប្រតិភូកម្ពុជាពីរផ្សេងគ្នា។ បើសង្កេតអំពីអធិបតេយ្យកម្ពុជា ដែលប្រកាសនៅឆ្នាំ ១៩៥៣ គឺពុំមានលក្ខណៈពេញលេញជាប្រទេសឯករាជ្យ មានអធិបតេយ្យ និងបូរណភាពពេញលេញនៅឡើយ អាស្រ័យដោយកត្តាបី៖

<u>ទីមួយ</u> គឺកម្ពុជានៅតែបន្តស្ថិតក្នុងសហព័ន្ធបារាំង

<u>ទីពីរ</u> កងទ័ពបារាំងមួយចំនួននៅតែស្ថិតលើទឹកដីកម្ពុជា ពិសេសបណ្តាខេត្តភាគខាងកើត ជាបន្តទៀត

<u>ទីបី</u> អំពីសេដ្ឋកិច្ច គឺជាសេដ្ឋកិច្ចចំណុះពួកអាណានិគមនិយម ដូចពេលបារាំងនៅត្រួតត្រា គ្មានអ្វីផ្លាស់ប្តូរឡើយ។

អាស្រ័យដោយបរាជ័យយ៉ាងធ្ងន់ធ្ងរនៅវៀតណាម ពិសេសនៅសមរភូមិឌៀនបៀនភូ បារាំងត្រូវបង្ខំចិត្តចូលតុចរចាអោយបានឆាប់បំផុត ដើម្បីសង្គ្រោះស្ថានភាពកងទ័ពបារាំងនៅវៀតណាម។ ដូច្នេះ ខែឧសភា ១៩៥៤ សន្និសីទហ្សឺណែវអំពីឥណ្ឌូចិន បានចាប់ផ្តើមប្រជុំ ក្នុង

ពេលដែលបារាំងបានរៀបចំយុទ្ធសាស្ត្រហើយជាស្រេច សំរាប់ការរក្សានូវផលប្រយោជន៍បារាំងនៅកម្ពុជា និងក្នុងពេលដែលអាមេរិក បានត្រៀមរៀបចំហើយជាស្រេច ដើម្បីលោតចូលមកឥណ្ឌូចិន ព្រមពេលដែលចិន កំពុងស្វែងរកនូវការសម្របសម្រួលដើម្បីការពារខ្លួន។ ដូច្នេះ ការសម្រុះសម្រួលជាបន្តបន្ទាប់នៅសន្និសីទហ្សឺណែវ ធ្វើឡើងដោយមានការឃុបឃិតជាសម្ងាត់រវាងអាមេរិក បារាំង ចិន ដែលការសម្រុះសម្រួលទាំងនោះ បានធ្វើឡើងដោយបាត់បង់ទាំងស្រុងនូវភាពអនុគ្រោះដល់ចលនាតស៊ូរបស់ប្រជាជនកម្ពុជា។

បញ្ហាបានចាប់ផ្ដើមពីសិទ្ធិតំណាងរបស់កម្ពុជាចូលរួមក្នុងសន្និសីទ។ ការត្រៀមរៀបចំរបស់បារាំងអំពីរបស់ដែលហៅថា ការប្រគល់ឯករាជ្យអោយកម្ពុជា នាឆ្នាំ ១៩៥៣ ត្រូវបានគេប្រើប្រាស់ជាសន្លឹកបៀសំខាន់បំផុត ដើម្បីបើកផ្លូវអោយរាជរដ្ឋាភិបាលអាយ៉ងចូលរួម និងបដិសេធការចូលរួមនៃរដ្ឋាភិបាលនៃកម្លាំងស្នេហាជាតិកម្ពុជា ដែលប្រការនេះទាក់ទងយ៉ាងសំខាន់ដល់ការសំរេចចុងក្រោយរបស់សន្និសីទ។ សម សារី បានថ្លែងនៅថ្ងៃ ២៣ សីហា ១៩៥៥ ថា "ប្រាកដជាឯករាជ្យដែលទារបានមុនប្រជុំសន្និសីទហ្សឺណែវនោះហើយ ដែលអាចអោយប្រតិភូខ្មែរនៅហ្សឺណែវ ប្រកាន់ឥរិយាបថជាប្រតិភូប្រទេសឯករាជ្យមួយបានតវ៉ាអោយប្រទេសឯទៀតទទួលស្គាល់ និងប្រតិបត្តិឯករាជ្យនោះបានធ្វើអោយគេទទួលស្គាល់រាជរដ្ឋាភិបាលយើងជាត្រឹមត្រូវបាន និងផាត់តំណាងពួកឥស្សរឧទ្ទាមចេញជាដាច់ខាត"(*)។

(*) សម សារី ថ្លែងនៅមន្ទីរសភាទីប្រឹក្សាជាតិ ថ្ងៃ ២៣ សីហា ១៩៥៥ អំពីកិច្ចព្រមព្រៀង ហ្សឺណែវ និងការបោះឆ្នោតនៅប្រទេសខ្មែរ។

យោងលើហេតុការណ៍នេះ អាចសន្និដ្ឋានបានថា ពួកគេបានប្រើប្រាស់យ៉ាងដាច់ខាតនូវឯករាជ្យ ដែលគេបានត្រៀមរៀបចំអស់ពេលជិតមួយឆ្នាំមកហើយ ដើម្បីឧត្តមភាពក្នុងការសម្រុះសម្រួល និងដើម្បីបំផ្លាញចលនាតស៊ូរបស់បដិវត្តន៍នៅលើតុចរចា។

សភាពការណ៍មុនសន្និសីទ និងក្នុងពេលសន្និសីទ មានការស្មុគ្រស្មាញខ្លាំង អាស្រ័យដោយពួកចក្រពត្តិបានឃុបឃិតគ្នា ផ្អែកលើគ្នា តស៊ូជាមួយគ្នា ដើម្បីសំរេចនូវបំណងដោយឡែកៗ ឯ ចិន ដែលជាសម្ព័ន្ធមិត្តរបស់បដិវត្តន៍នៅឥណ្ឌូចិន ពេលនោះក៏មានយុទ្ធសាស្ត្រមួយដោយឡែក ហើយពួកគេសុទ្ធតែត្រូវការប្រើប្រាស់សន្និសីទហ្សឺណែវដើម្បីសំរេចនូវបំណងរបស់គេ។ បារាំងត្រូវការរក្សាអោយបាននូវរបបស្និទ្ធខ្លួននៅកម្ពុជា នៅភាគខាងត្បូងវៀតណាម នៅឡាវ ព្រោះការស្ថិតស្ថេរនៃរបបទាំងនេះ វាជាតំណាងផលប្រយោជន៍របស់បារាំងនៅអតីតដែនដីអាណានិគមនេះ។ អាមេរិកត្រូវការចូលឥណ្ឌូចិន ក្រោយពេលបារាំងចេញ។ អាមេរិក បានត្រៀមរៀបចំតាំងពីឆ្នាំ ១៩៥០ ដូច្នេះ អាមេរិកក៏ត្រូវការរក្សាទុកនូវរបបអាយ៉ងនៅប្រទេសទាំងនេះ ធ្វើជាមូលដ្ឋានអោយការចូលមករបស់ខ្លួន។

តាមការរៀបរាប់របស់ សម សារី ថា ថ្ងៃ ២០ កក្កដា ១៩៥៤ មុនពេលពិភាក្សាកិច្ចព្រមព្រៀងចុងក្រោយ ទេព ផន និង នង គីមនី ដែលជាសមាជិកប្រតិភូរាជរដ្ឋាភិបាលកម្ពុជាក្នុងសន្និសីទហ្សឺណែវ បានទៅជួបជាមួយរដ្ឋលេខាធិការរងអាមេរិក ដែលជាប្រតិភូអាមេរិកនៅសន្និសីទហ្សឺណែវ ឈ្មោះ វ៉ុលទែ បីដែល ស្មីត (Walter Bedell Smith)។

*បន្ទាប់ពីការជួបជាមួយប្រតិភូអាមេរិក ទេព ផន និង នង គីមនី បាន ទៅជួបជាមួយសហប្រធានសន្និសីទ ដែលពេលនោះមានអង់គ្លេស និង សហភាពសូវៀត ហើយមានការចូលរួមរបស់ប្រតិភូបារាំង និងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមផង ដែលពេលនោះគណៈប្រតិភូរាជរដ្ឋាភិបាលកម្ពុជា បានទាមទារនូវចំណុច ៤ ដែលមានចំណុច ២ ទាក់ទងដល់ឧបាយកលអាមេរិកក្នុងការចូលប្រទេសកម្ពុជា គឺៈ*

*ទីមួយ* *សុំអោយប្រទេសខ្មែរនៅមានអំណាច និងមានសិទ្ធក្នុងសហព័ន្ធសឹកណា* (Alliance Militaire) *ដែលស្របច្បាប់អង្គការសហប្រជាជាតិ ហើយសុំអោយប្រទេសខ្មែរនៅទទួលចំណតទ័ពប្រទេសក្រៅ* (Bases Etrangères) *បាន បើយល់ថាមានការបៀតបៀនដល់សុខទុក្ខ។*

*ទីពីរ* *សុំកុំអោយប្រទេសខ្មែរទទួលយកគ្រឿងអាវុធឬទាហានពីប្រទេសក្រៅអោយចូលមកក្នុងប្រទេសខ្មែរ តាមកន្លែងណាក៏បាន។*

*ដោយសំអាងទៅលើការអះអាងនេះ អាមេរិកបានឆ្លៀតប្រើប្រាស់សន្និសីទហ្សឺណែវ ដើម្បីបើកទ្វារអោយខ្លួនចូលមកកម្ពុជាដោយងាយស្រួល។ ដូច្នេះបានជាប៉ុន្មានខែក្រោយ គឺនៅថ្ងៃ ១៦ ឧសភា ១៩៥៥ អាមេរិកបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយកម្ពុជា អំពីជំនួយយោធា។ ចំពោះចិនវិញ ចិនត្រូវការកសាងប្រទេសឡើងវិញ ហើយចង់បានតំបន់ទ្រនាប់មួយនៅភាគខាងត្បូង គឺភាគខាងជើងវៀតណាម ដើម្បីជៀសវាងការប៉ះទង្គិចដោយផ្ទាល់ជាមួយអាមេរិក។ ដូច្នេះ ចិនត្រូវយកយុទ្ធសាស្ត្រសម្របសម្រួលក្នុងផលប្រយោជន៍របស់ខ្លួន។ ឯចលនាតស៊ូ អាស្រ័យដោយឧបាយកលដែលបានព្រាងទុករបស់ពួក*

ចក្រពត្តិ ទប់ស្កាត់តំណាងអ្នកតស៊ូកម្ពុជា និងឡាវមិនអោយចូលរួមក្នុងសន្និសីទ ដូច្នេះកម្លាំងតស៊ូមានតែសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម (វៀតណាមខាងជើង) មួយតែប៉ុណ្ណោះ ដែលបានចូលរួម ហេតុនេះឃើញថាមិនតុល្យភាពកម្លាំងនៅក្នុងសន្និសីទ ហើយប្រការនេះមិនបានឆ្លុះបញ្ចាំងអំពីការជាក់ស្តែងនៅលើសមរភូមិឡើយ។

អំពីការព្រមព្រៀងនាខែកក្កដា ឆ្នាំ ១៩៥៤ នៅសន្និសីទហ្សឺណែវ បើពិនិត្យមួយជ្រុងឃើញថា ការព្រមព្រៀងនេះគឺជាការព្រមព្រៀងមិនអនុគ្រោះសំរាប់ប្រជាជនកម្ពុជា ព្រោះថាការព្រមព្រៀងនេះតម្រូវអោយចលនាតស៊ូកម្ពុជារំសាយនៅនឹងកន្លែង វាមិនបានឆ្លុះបញ្ចាំងអំពីស្ថានការណ៍ពិតប្រាកដ និងសំណូមពរនយោបាយពិតប្រាកដនៅកម្ពុជាឡើយ។ ប៉ុន្តែ បើសិនជាពិនិត្យអោយបានស៊ីជំរៅ និងគ្រប់ជ្រុងជ្រោយ ក្នុងក្របខ័ណ្ឌធំទូលាយជាង គេទាញបាននូវការវាយតម្លៃថា ទោះបីជាចលនាតស៊ូរបស់ប្រជាជន មិនអាចសំរេចបានទាំងស្រុងនូវបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ <u>ក៏ចលនាតស៊ូនេះបានបំពេញនូវមុខនាទីដ៏សំខាន់ក្នុងការបណ្តេញពួកអាណានិគមនិយមបារាំងចេញពីកម្ពុជា ចាប់បង្ខំអោយពួកចក្រពត្តិអាណានិគមនិយម ទទួលស្គាល់នូវសិទ្ធិរបស់ប្រជាជាតិកម្ពុជា</u>។ អាចនិយាយច្បាស់ថា នៅពេលដែលពួកសក្តិភូមិបានឱនក្បាលទទួលយកនឹមអាណានិគមនិយមហើយនោះ ប្រសិនជាគ្មានចលនាតស៊ូរបស់ប្រជាជនកម្ពុជា ប្រជាជនវៀតណាម ប្រជាជនឡាវទេនោះ ពួកអាណានិគមនិយមបារាំងពិតជាមិនធ្វើការសម្រុះសម្រួលណាមួយក្នុងការផ្តល់ឯករាជ្យ និងទទួលស្គាល់សិទ្ធិនៃប្រជាជាតិទាំងបី

*នេះឡើយ។ គ្មានពេលណាដែលពួកអាណានិគមនិយមយល់ព្រម ដោយសុច្ឆន្ទៈ ហើយធ្វើសម្បទានអោយដោយគ្មានការតស៊ូរបស់ប្រជាជននោះឡើយ។ ក្នុងពេលជាមួយគ្នា ពួកសក្តិភូមិចាំតែព្រមធ្វើតាមពួកចក្រពត្តិ ផុតពីបារាំងដល់ជប៉ុន ផុតពីជប៉ុនដល់បារាំងវិញ ប៉ុន្តែស្ថានភាពត្រីកោណបានធ្វើអោយពួកសក្តិភូមិ តែងបានទទួលផលចំណេញពីសម្បទានរបស់ពួកអាណានិគមនិយម ក្រោមការគាបសង្កត់នៃចលនាតស៊ូរបស់ប្រជាជន។ ចលនាតស៊ូរបស់ប្រជាជន ជាកម្លាំងសង្កត់ទៅលើអាណានិគមនិយម អាណានិគមនិយមធ្វើសម្បទានអោយពួកសក្តិភូមិ ទីចុងបំផុតឯករាជ្យដណ្តើមបានដោយបារមីព្រះមហាក្សត្រ ដែលទឡ្ហីករណ៍នេះ មិនអាចទទួលយកបានឡើយ ព្រោះវាបដិសេធចោលទាំងស្រុងនូវតួនាទីរបស់មហាជនក្នុងការតស៊ូដណ្តើមឯករាជ្យជាតិ។*

*គោលដៅនៃបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ដែលបក្សប្រជាជនបដិវត្តន៍ខ្មែរបានដាក់ចេញ ក៏ស្ថិតក្នុងការដណ្តើមឯករាជ្យជាតិ សន្តិភាព និងសិទ្ធិសេរីភាពជូនប្រជាជន ដូច្នេះការយល់ព្រមអនុវត្តកិច្ចព្រមព្រៀងហ្សឺណែវដែលកម្លាំងតស៊ូមិនបានចូលរួមចុះហត្ថលេខា គឺកាន់តែបង្ហាញច្បាស់នូវការអនុវត្តន៍មាគ៌ារបស់បក្ស គឺការស្ម័គ្រចិត្តធ្វើការសម្រុះសម្រួល ដើម្បីផលប្រយោជន៍នៃឯករាជ្យជាតិ សន្តិភាព និងសេរីភាព។ ការសម្រុះសម្រួលនៅទីនេះចេញមកពីការស្ម័គ្រចិត្តទាំងស្រុង ពីព្រោះថា ម្យ៉ាងលក្ខខណ្ឌដែលតម្រូវអោយកម្លាំងតស៊ូរំសាយនៅនឹងកន្លែង គឺវាធូន់ធ្ងរពេក ម្យ៉ាងទៀត កម្លាំងតស៊ូ មិនមែនជាភាគីដែលត្រូវជាប់ចំណងត្រូវអនុវត្តកិច្ចព្រមព្រៀងនោះឡើយ។ ដូច្នេះ*

ប្រសិនបើកម្លាំងនេះនៅតែបន្តធ្វើសកម្មភាព ទោះបីមានឬគ្មានការគាំទ្រពីខាងក្រៅ ក៏កិច្ចព្រមព្រៀងហ្សឺណែវ ពិបាកអនុវត្ត ហើយសន្តិភាពក៏មិនអាចកើតមានបានដែរ យ៉ាងហោចណាស់ក៏អស់រយៈពេលមួយវែងបន្តួរទើបអាចស្ងប់ស្ងាត់ទៅបាន។ ប៉ុន្តែ បក្សប្រជាជនបដិវត្តខ្មែរ ជាបក្សនយោបាយប្រកបទៅដោយវិចារណញ្ញាណ។ ដើម្បីផលប្រយោជន៍ជាតិ និងប្រជាជន គឺសុខចិត្តពលិកម្ម។ ដូច្នេះ ការសម្រុះសម្រួលនៅទីនេះ គឺជាការសម្រុះសម្រួលជាមួយផលប្រយោជន៍របស់ជាតិ និងប្រជាជន។ ពិនិត្យអំពីទ្រឹស្តី ក្នុងការសម្រុះសម្រួលនាឆ្នាំ ១៩៥៤ គឺត្រឹមត្រូវ។ ការប្រៀបធៀបកម្លាំង ទាំងក្នុង និងក្រៅប្រទេស ក្នុងក្របខណ្ឌទូទាំងឥណ្ឌូចិន គឺអនុញ្ញាតិអោយយើងធ្វើការសម្រុះសម្រួល ត្រឹមកំរិតនេះឯង។ បដិវត្តន៍វៀតណាមបានភាគខាងជើង បដិវត្តន៍ឡាវបានខេត្តពីរប្រមូលផ្តុំកម្លាំង បដិវត្តន៍កម្ពុជា ទោះជាត្រូវរំសាយនៅនឹងកន្លែង ប៉ុន្តែនោះក៏ជាមោទនភាព អាស្រ័យដោយខ្លួនបានបំពេញបេសកកម្មជាប្រវត្តិសាស្ត្រ ចាប់បង្ខំអោយបារាំងត្រូវដកចេញពីកម្ពុជា លុបបំបាត់ចោលជាស្ថាពរនូវលទ្ធិអាណានិគមនិយមចាស់របស់បារាំង ដែលបានត្រួតត្រាកម្ពុជាអស់ ៩ ទសវត្ស។ ម្យ៉ាងទៀត ការសម្រុះសម្រួលនេះ ក៏មិនមែនជាការសារភាពបោះបង់ចោលគោលដៅចុងក្រោយរបស់ខ្លួនឡើយ នេះជាការសម្រុះសម្រួលក្នុងយុទ្ធវិធីតស៊ូ ដែលត្រូវដណ្តើមជ័យជំនះ ជាជំហានៗ និងឈានទៅយកជ័យជំនះទាំងស្រុង ហើយការជាក់ស្តែងចាប់តាំងពីការសម្រុះសម្រួលឆ្នាំ ១៩៥៤ ប្រជាជនកម្ពុជា ប្រជាជនវៀតណាម ប្រជាជនឡាវ គឺនៅតែបន្តការតស៊ូរបស់ខ្លួនតាមគ្រប់រូបភាព និងគ្រប់កាលៈទេសៈ។ ដោយឡែក នៅកម្ពុជា ដើម្បីស្របតាមសភាព

*ការណ៍ថ្មី បក្សមានគោលការណ៍ប្រែទិសពីការតស៊ូប្រដាប់អាវុធ មកតស៊ូនយោបាយវិញ។*

ផ្នែកទី ២

# ស្ថានភាពសង្គមមុនឆ្នាំ ១៩៧០ និងការបដិវត្តន៍

*ក្រោយសន្និសីទហ្សឺណែវឆ្នាំ ១៩៥៤ សភាពការណ៍កម្ពុជាបាន វិវត្តមកកាន់ដំណាក់កាលថ្មី គឺដំណាក់កាលឯករាជ្យខាងនយោបាយ ក្នុងកំរិតមួយមិនទាន់ពេញលេញ និងក្នុងស្ថានភាពដែលកត្តាមូលធន និយមបានកើតឡើងក្នុងក្របខណ្ឌនៃបែបផែនសក្តិភូមិ។*

*ទំនាស់ ជានិច្ចកាលបានប្រមូលផ្តុំរវាងប្រជាជាតិកម្ពុជា ដែលត្រូវ ការពង្រឹងឯករាជ្យ អធិបតេយ្យ ជាមួយចក្រពត្តិអាមេរិក ដែលត្រូវការ ដាក់កម្ពុជាក្នុងក្របខ័ណ្ឌអន្តរាគមន៍របស់ខ្លួន និងរវាងកម្មករ កសិករ ជាមួយវណ្ណៈសក្តិភូមិ និងវណ្ណៈនាយទុន។*

*បណ្តាបក្សនយោបាយ បានសម្របសម្រួលជាមួយសភាពការណ៍ ថ្មី ហើយធ្វើការតស៊ូជាមួយគ្នា ប្រមូលផ្តុំជុំវិញបញ្ហាសេដ្ឋកិច្ចសង្គម បញ្ហានយោបាយ ឯករាជ្យ អព្យាក្រឹត្យ បញ្ហាដណ្តើមអំណាចនៅក្នុង*

ស្រទាប់វណ្ណៈត្រួតត្រា។ ការតស៊ូនេះបានប្រព្រឹត្តទៅយ៉ាងតឹងតែង ធ្វើអោយសង្គមមានការវិវត្តប្រែប្រួលប្រកបដោយការស្មុគ្រស្មាញ។

មុនពេលចូលទៅពិនិត្យបញ្ហាផ្សេងទៀត ចាំបាច់ត្រូវពិនិត្យអំពីស្ថានភាពសេដ្ឋកិច្ចសង្គមក្នុងចន្លោះឆ្នាំ ១៩៥៤-១៩៧០ ព្រោះនេះគឺជាមូលហេតុដ៏ជ្រាលជ្រៅដែលជះឥទ្ធិពលទៅដល់បញ្ហាដ៏ទៃទៀត។

នយោបាយរបស់អ្នកកាន់អំណាចក្រោមការដឹកនាំរបស់ នរោត្តម សីហនុ បានបង្កលក្ខណៈសម្បត្តិអោយមានការប្រណាំងប្រជែងដោយសេរី ដែលតាមរយៈនយោបាយនេះ បានផ្តល់នូវលទ្ធភាពសំរាប់ការរីកចំរើនយ៉ាងឆាប់រហ័សរបស់វណ្ណៈគហបតី និងក្រុមមនុស្សដែលមានលទ្ធភាពខាងដើមទុន។

ក្រោយពេលបារាំងចូលកាន់កាប់ប្រទេសកម្ពុជា មានការកែទម្រង់លើបញ្ហាដីធ្លី ដែលបានផ្តល់លទ្ធភាពសំរាប់ការប្រើប្រាស់ដីធ្លី និងកម្មសិទ្ធិលើដីធ្លី។ ការកែទម្រង់ត្រូវបានបន្តអនុវត្តរហូតមកទល់នឹងឆ្នាំ ១៩៧០ និងរហូតមកដល់ឆ្នាំ ១៩៧៥ ក្រោមតំបន់ លន់ នល់ ត្រួតត្រា។ កម្មសិទ្ធិលើដីធ្លី ប្រសិនបើពិនិត្យលើក្រដាសស្នាម គឺហាក់ដូចជាផ្តល់នូវលទ្ធភាពងាយស្រួលសំរាប់កសិករជាទូទៅ ប៉ុន្តែបើពិនិត្យអោយស៊ីជំរៅដល់ទំនាក់ទំនងក្នុងបញ្ហាកសិកម្ម គឺឃើញមានបញ្ហាជាច្រើន ដែលស្ថិតក្នុងរូបភាពជិះជាន់យ៉ាងធ្ងន់ធ្ងរ។

នយោបាយកម្មសិទ្ធិលើដីធ្លី បានផ្តល់លទ្ធភាពងាយស្រួលសំរាប់ពួកវណ្ណៈដែលមានមធ្យោបាយ និងដើមទុន និងសំរាប់ពួកសក្តិភូមិ នាហ្មឺនដែលហួងហែងដីធ្លី។ ដូច្នេះ វាបានកើតឡើងយ៉ាងឆាប់រហ័សនូវ

ស្រទាប់ពួកម្ចាស់ដី ហើយដែលការរំលោភទីរបស់ម្ចាស់ដីនេះ បានធ្វើអោយកសិករកាន់តែជួបការលំបាក។ ការរំលោភទីរបស់ម្ចាស់ដី បានធ្វើឡើងតាមច្រើនរូបភាព ជារូបភាពទិញដីយកកាន់កាប់ ជារូបភាពចាប់យកដីបង់ពន្ធអោយរាជការទុកលក់ ជួល ឬប្រវាស់អោយកសិករ។ ប៉ុន្តែរូបភាពដែលមានលក្ខណៈជាការជិះជាន់ធ្ងន់ធ្ងរ គឺទុនសំរាប់ចងការអោយកសិករពីសំណាក់ពួកនាយទុន និងឈ្មួញ។ នៅក្នុងរយៈពេលដែលពាណិជ្ជកម្មក្រៅប្រទេសបានរីកចំរើន ហើយស្ថិតក្នុងការគ្រប់គ្រងរបស់ក្រុមហ៊ុននាយទុនក្នុងប្រទេស ដែលមានទំនាក់ទំនងជាមួយក្រុមហ៊ុននាយទុនក្រៅប្រទេស បណ្តាញរបស់ឈ្មួញបានចាក់ឫសទៅគ្រប់មូលដ្ឋាននៃផលិតកម្មកសិកម្ម។ វិធីរបស់ពួកនាយទុន គឺក្តាប់យកនូវប្រភពទំនិញដើម្បីនាំចេញ តាមរយៈការផ្តល់ទុនអោយកសិករមានលក្ខណៈជាការចងការប្រាក់ ដែលមានកំរៃការប្រាក់ខ្ពស់បំផុត គឺ ៥០ ភាគរយរហូតដល់ ១០០ ភាគរយ ក្នុងមួយឆ្នាំៗ ដែលកសិករកម្ពុជាបាននិយាយរត់មាត់ថា "វស្សាមួយកន្តាំង ប្រាំងមួយតៅ"។ កសិករតិចតួចណាស់ដែលគ្មានបំណុល ហើយមួយចំនួនមិនអាចសងបំណុលបាន ក៏ត្រូវពួកឈ្មួញរឹបអូសយកដីស្រែ ចំការ។ វិធីនេះត្រូវបានអនុវត្តជាទូទៅដោយពួកនាយទុន ធ្វងតាមរយៈឈ្មួញនៅជនបទ ដែលនៅជាប់ផ្ទាល់ជាមួយកសិករ។ នៅក្នុងសម័យក្រោមអាណានិគមនិយម ពួកនាយទុនចងការប្រាក់ មិនបានយកចិត្តទុកដាក់ទិញដីធ្លី ដើម្បីធ្វើជាកម្មសិទ្ធរបស់ខ្លួនឡើយ។ ការចងការប្រាក់ពេលនោះ សំខាន់ប្រមូលយកនូវផលិតផលមកវិញ ប៉ុន្តែ ក្រោយឆ្នាំ ១៩៥៤ ពួកនាយទុនបានយកចិត្តទុកដាក់ប្រមូលយកដីស្រែចំការ អាស្រ័យដោយមូលហេតុ ពួកឈ្មួញ

*នៅជនបទ បានទទួលនូវលទ្ធភាពចូលរួមនាំចេញនូវផលកសិកម្ម។ ដូច្នេះ ពួកឈ្មួញនៅជនបទ មិនគ្រាន់តែជាបណ្តាញរបស់នាយទុនក្នុងការប្រមូលទិញពីកសិករដូចពេលមុនឡើយ តែបានក្លាយទៅជាបណ្តាញប្រមូលដី គ្រប់គ្រងដី និងប្រើប្រាស់ដី ជួល ឬប្រវាស់អោយកសិករ ដើម្បីយកកម្រៃពីដីផង និងប្រមូលយកភោគផលសំរាប់នាំចេញផង។*

*ដោយការជិះជាន់របស់នាយទុនចងការប្រាក់ទៅលើកសិករ តាមរយៈឈ្មួញនៅជនបទ និងតាមរយៈនៃការទាមទារនៃកម្លាំងជឿនលឿនសភាពការណ៍នេះ បានតម្រូវអោយរាជរដ្ឋាភិបាលបង្កើតឡើងនូវអង្គការមួយមានឈ្មោះថា រាជសហករណ៍ ក្នុងបំណងធ្វើវិនិយោគអោយកសិករ ទិញលក់ជាមួយកសិករ។ ប៉ុន្តែ ការបង្កើតឡើងនូវអង្គការមួយរបៀបនេះ ដែលមានភាគច្រើនជាវណ្ណៈជិះជាន់កាន់តំណែងសំខាន់ៗក្នុងអង្គការ បានធ្វើអោយមានអំពើពុករលួយ អំពើកេងបន្ទំទុន និងការយកទុនរបស់រដ្ឋទៅទិញដីជាកម្មសិទ្ធឯកជន ឬយកទៅចងការអោយកសិករ។ រាជសហករណ៍ មិនត្រឹមតែមិនបានដោះស្រាយអ្វី សម្រាលដល់ទុក្ខវេទនារបស់កសិករប៉ុណ្ណោះទេ ប៉ុន្តែនៅបានជាទុនមួយសំរាប់ពួកអ្នកមានទ្រព្យ និងអំណាច យកធ្វើជាអាវុធដើម្បីជិះជាន់កសិករថែមទៀត។*

*នៅក្នុងសម័យនៃចលនាដាំដំណាំឧស្សាហកម្ម ដូចជា កៅស៊ូ កប្បាស អំពៅ ម្ទេស ក្រចៅ នាទសវត្សឆ្នាំ ៦០ ពួកនាហ្មឺនម្ចាស់ដី ពួកនាយទុន បានវាតទីយ៉ាងខ្លាំងទៅលើដីធ្លី។ ការវាតទីតាមរបៀបជាច្រើន បានបង្កើតឡើងនូវរូបភាពនៃទំនាក់ទំនងជាច្រើនក្នុងវិស័យកសិ*

កម្ម គឺទំនាក់ទំនងរវាងឈ្មួញចងការប្រាក់ ជាមួយកសិករ រវាងឈ្មួញម្ចាស់ដីដែលជួល ឬប្រវាស់ដីអោយកសិករ រវាងពួកនាយទុនជាមួយកម្មករក្នុងកសិដ្ឋានដំណាំឧស្សាហកម្ម។ ពិតមែនតែទំនាក់ទំនងតាមរបៀបមូលធននិយម ក្នុងវិស័យកសិកម្មមានការរីកចំរើនយឺត ប៉ុន្តែវាបានកើតមានឡើងនៅស្ទើរគ្រប់ទីកន្លែង មានទំហំ និងកំរិតខុសៗ គ្នា។

តាមរយៈនៃការវិវត្តន៍ប្រែប្រួលក្នុងចុងទសវត្សឆ្នាំ ៧០ គេពិនិត្យឃើញនូវការបែងចែកជាស្រទាប់វណ្ណៈជាច្រើននៅជនបទ។ ដំបូងគេសង្កេតឃើញនូវការរីកធំជាត់នៃស្រទាប់ពួកថៅកែពាណិជ្ជកម្មតូចតាចដែលជាបណ្តាញនៃពួកនាយទុនពាណិជ្ជកម្ម និងចងការប្រាក់ ដែលពួកនេះធ្វើសកម្មភាពតាមច្រើនរបៀប ដូចជាចងការប្រាក់ដើម្បីប្រមូលយកកំរៃពីការប្រាក់ផង និងប្រមូលទិញផលិតផលផង ឬតាមរូបភាពជាឈ្មួញចងការប្រាក់ គួបផ្សំនឹងការប្រើប្រាស់ដីដែលរឹបអូសបាន ជួលឬប្រវាស់អោយកសិករ ដែលជារូបភាពជិះជាន់មូលធននិយម និងពាក់កណ្តាលសក្តិភូមិ។ មូលដ្ឋានសង្គមនៃឈ្មួញតាមជនបទ មានការផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយពួកនាយទុនពាណិជ្ជកម្មនៅទីក្រុង។ ឈ្មួញកណ្តាលនៅជនបទ ភាគច្រើនជាអាណិកជនចិន ដែលផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយនាយទុនចិននៅតាមទីក្រុង ដែល គ្របដណ្តប់លើសកម្មភាពពាណិជ្ជកម្មស្ទើរតែទាំងស្រុង។ លោក រ៉េមី ព្រុយដូម បានសរសេរថា "គេអាចប៉ាន់ស្មានថា នៅឆ្នាំ ១៩៦៦ អ្នកដែលជាចិននោះនឹងមានចំនួន ៣៨០.០០០ នាក់ គឺ ៥% នៃប្រជាជនសរុប។ ចិនច្រើនជាអ្នកជំនួញ ពួកគេកាន់កាប់ពាណិជ្ជកម្មស្ទើរតែទាំងស្រុង ពិសេស

*ការលក់ដូរស្រូវអង្ករ។ នៅក្នុងភូមិមួយ យ៉ាងហោចណាស់ក៏មានចិនម្នាក់ទិញស្រូវអង្ករ និងលក់សម្ភារៈប្រើប្រាស់ដែរ(*)"។ លោក រ៉េមី ព្រុយដូម បានសរសេរត្រឹមការលក់ដូររបស់ជនជាតិចិន ប៉ុន្តែជាក់ស្តែង ពួកឈ្មួញចិនទាំងនេះបានធ្វើមុខរបរបន្ថែម ជាអ្នកចងការប្រាក់ និងជាអ្នកកាន់កាប់ដីធ្លីសំរាប់ជួល ឬប្រវាស់អោយកសិករ។*

*ការកើតឡើងនូវកសិដ្ឋានកសិកម្មតូច និងមធ្យម បង្កើតឡើងនូវ<u>ទំនាក់ទំនងមូលធននិយមក្នុងវិស័យកសិកម្ម</u> ជាការដែលផ្តល់លទ្ធភាពអោយពួកអ្នកមាន អាចប្រើប្រាស់នូវពលកម្មដែលមានតម្លៃថោករបស់កសិករដែលអស់ដី ហើយប្រែក្លាយខ្លួនទៅជាកសិករក្នុងកសិដ្ឋាន។ តាមនិន្នាការប្រសិនគ្មានសង្គ្រាមនាឆ្នាំ ១៩៧០ ទេ រូបភាពនេះក៏នឹងមានការរីកចំរើនខ្លាំង។ ក្រោពីនោះ គេអាចឃើញស្រទាប់វណ្ណៈកសិករត្រូវបានបែងចែកជាលំដាប់ថ្នាក់ អាស្រ័យដោយមធ្យោបាយផលិតកម្ម និងមូលដ្ឋានសង្គមរបស់គេ។ កសិករមួយចំនួនតូចមានដីធ្លីច្រើនបង្គួរ ប៉ុន្តែមិនប្រាកដប្រជាថាជាម្ចាស់ដី អាស្រ័យជួនកាលគេអាចជួល ឬប្រវាស់អោយកសិករ ជួនកាលគេធ្វើខ្លួនឯងដោយមានជួលពលកម្មខ្លះមកជំនួយតាមរដូវកាល។ មូលដ្ឋានសង្គមរបស់កសិករប្រភេទនេះដែលគេតែងនិយមហៅថា កសិករមាន គឺបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយកសិករទូទៅ។*

*កសិករភាគច្រើន អាស្រ័យការវាតទីរបស់ម្ចាស់ដី អាស្រ័យដោយបំណុលរបស់ឈ្មួញ ហើយសំខាន់អាស្រ័យដោយអត្រាកើនឡើងនៃ*

(*) សេដ្ឋកិច្ចនៃប្រទេសកម្ពុជា ដោយ រ៉េមី ព្រុយដូម បោះពុម្ពឆ្នាំ ១៩៦៩ ជាភាសាបារាំង។

ចំនួនប្រជាជនក្នុងវង្វង់កសិករ ក្នុងពេលដែលគ្មានលទ្ធភាពខាងមធ្យោបាយសំភារៈសំរាប់ពង្រីកថែមដីថ្មី និងគ្មានការរីកចំរើនខាងបច្ចេកទេសវិទ្យាសាស្ត្រដើម្បីបង្កើនទិន្នផល ជីវភាពរបស់កសិករជាទូទៅមានការធ្លាក់ចុះជាលំដាប់ៗ កសិករដែលមានដី ៥-១០ ហិកតា កាលឆ្នាំ ១៩៥៤ ពេលឆ្នាំ ១៩៧០ គេបានបែងចែកអោយកូន ដូច្នេះទាំងឪពុកម្តាយ ទាំងកូន បានក្លាយទៅជាកសិករដែលមានដីតិច ឬច្រើនទៅតាមចំនួនកូនដែលត្រូវចែកៗ កសិករដែលមានដីតិច ក៏កាន់តែពិបាកទៅទៀតក្រោយពេលបានចែកអោយកូនចៅរួចហើយៗ នេះនៅមិនទាន់គិតដល់មានបញ្ហាផ្សេងៗ ដូចជាទឹកជំនន់ គ្រោះរាំងស្ងួត និងគ្រោះថ្នាក់ផ្សេងទៀត ដែលកសិករត្រូវជួបប្រទះ និងមិនទាន់គិតដល់ករណីមួយចំនួនដែលពួកសក្តិភូមិម្ចាស់ដីប្រើប្រាស់កម្លាំងទាំងកម្រោល ដើម្បីដណ្តើមដីរបស់កសិករផង ដែលគេតែងបានឃើញនូវការតស៊ូ និងការប្តឹងផ្តល់របស់កសិករមកដល់ នរោត្តម សីហនុៗ

តាមហេតុការណ៍ដូចបានរៀបរាប់មកនេះ កសិករមួយចំនួន អាស្រ័យដោយស្ថានភាពភូមិសាស្ត្រនៅជិតខ្លួន មិនអាចផ្តល់លទ្ធភាពអោយរុករានដីថ្មីបានទេ គេបង្ខំចិត្តត្រូវចាកចេញទៅតាំងទីលំនៅថ្មីៗ សំរាប់អ្នកដែលមានលទ្ធភាពខាងដើមទុន និងពលកម្ម ខ្លះបានទៅរកតំបន់ដីថ្មីបន្ត ក្នុងមុខរបរកសិកម្ម ប៉ុន្តែសំរាប់អ្នកដែលគ្មានទុន ភាគច្រើនប្រែក្លាយខ្លួនទៅជាកម្មករចំការកៅស៊ូ ឬកសិដ្ឋាន ឬចូលមកបណ្តាទីក្រុងដើម្បីធ្វើជាកម្មករ ឬពលករស៊ីឈ្នួល ដែលបានធ្វើអោយបណ្តាទីក្រុងមានការកើនឡើងយ៉ាងឆាប់រហ័សនូវចំនួនប្រជាជន និងអាស្រ័យនៅទី

ក្រុងគ្មានការងារគ្រប់គ្រាន់សំរាប់មនុស្សដ៏ច្រើនធ្វើ វាបានកើតឡើងនូវវិបត្តិឥតការងារធ្វើ។

តាមឯកសារលោក រ៉េមី ព្រុយដូម សរសេរនៅឆ្នាំ ១៩៦៩ អំពីសេដ្ឋកិច្ចនៃប្រទេសកម្ពុជា បានរៀបរាប់ថា "ការជំរឿនឆ្នាំ ១៩៦២ បានធ្វើការបែងចែកតំបន់ជនបទ និងតំបន់ទីក្រុង។ តំបន់ទីក្រុងមាន ទីប្រជុំជនធំ (ដូចជា ភ្នំពេញ បូកគោ កែប កំពង់សោម) និងតំបន់ក្រុង (បាត់ដំបង កំពត កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពង់ត្រាច ក្រចេះ ព្រៃវែង ពោធិសាត់ សៀមរាប ស្ទឹងត្រែង ស្វាយរៀង តាកែវ) តាមជំរឿននោះ ប្រជាជនក្រុងមាន ៦០០.០០០ នាក់ (១៩៦២) ស្មើនឹងជាង ១០% នៃប្រជាជនសរុប។ កាលពីឆ្នាំ ១៩២១ ប្រជាជនក្រុងមានតែ ១៣០.០០០ នាក់ស្មើនឹង ៥ ភាគរយនៃប្រជាជនសរុប។ បច្ចុប្បន្ន (១៩៦៧) ប្រជាជនក្រុងមានចំនួន ៧០០.០០០ នាក់ ស្មើនឹងប្រហែល ១២ ភាគរយនៃប្រជាជនសរុប។ កំណើននេះ បង្ហាញនូវការចាកចោលជនបទមកកាន់ទីក្រុង ជាពិសេសក្រោយសង្គ្រាម(*)"។ លោក រ៉េមី ព្រុយដូម បានអះអាងថា "កត្តាចំបងនៃការចាកចោលជនបទនេះ គឺកត្តាសេដ្ឋកិច្ច។ កសិករក្រុរត់រកធនធានឬរត់រកការងារតាមទីក្រុង(*)"។ ចាប់ពីឆ្នាំ ១៩៦៧ ដល់ ១៩៧០ ថ្វីត្បិតតែគេមិនបានដឹងនូវចំនួនប្រជាជនទីក្រុងពិតប្រាកដ តែរយៈពេលនេះជារយៈពេលនៃការកើនឡើងនៃចំនួនប្រជាជន ដែលចាកចោលជនបទមកកាន់ទីក្រុង អាស្រ័យដោយការធ្លាក់ចុះនៃជីវភាពរបស់គេ។

(*) សេដ្ឋកិច្ចនៃប្រទេសកម្ពុជា ដោយ រ៉េមី ព្រុយដូម បោះពុម្ពឆ្នាំ ១៩៦៩ ជាភាសាបារាំង។

ការកើនឡើងដ៏ឆាប់រហ័សរបស់ប្រជាជនតាមទីក្រុង ទីប្រជុំជនធំៗ បានបង្កើតឡើងនូវបញ្ហាឥតការងារធ្វើ ព្រោះថាការកើនឡើងនេះធ្វើដោយឯកឯង គ្មានការចាត់ចែងរបស់រដ្ឋបាលឡើយ ដូច្នេះមានទីក្រុងខ្លះមនុស្សច្រើនទីក្រុងខ្លះមនុស្សតិចៗ តាមឯកសាររបស់ រ៉េមី ព្រុយដូម សរសេរឆ្នាំ ១៩៦៩ ថា ឆ្នាំ ១៩៦៧ ប្រជាជនទីក្រុងមាន ៧០០.០០០ នាក់ ស្មើនឹងប្រហែល ១២ ភាគរយនៃប្រជាជនសរុប ដោយឡែកតែទីក្រុងភ្នំពេញមួយមានប្រជាជន ៥០០.០០០ នាក់ ស្មើនឹង ៧០ ភាគរយនៃប្រជាជននៅតាមទីក្រុងទូទាំងប្រទេស ដូច្នេះបង្ហាញអោយឃើញថា ដង់ស៊ីតេ (Densité) មិនមានតុល្យភាពនៅតាមបណ្តាទីក្រុងទៅហើយ។

ជាមួយនឹងដង់ស៊ីតេតាមទីក្រុងគ្មានតុល្យភាព រដ្ឋាភិបាលជំនាន់នោះក៏មិនបានយកចិត្តទុកដាក់ ដល់ការបែងចែកពលកម្មសង្គមឡើយ។ គេអាចដឹងបានខ្លះថា មានធ្វើដែរតែតិចតួចណាស់ បើប្រៀបធៀបនឹងលក្ខណៈសម្បត្តិដែលអាចធ្វើបាន។ ដូច្នេះ ធ្វើអោយការបែងចែកប្រជាជននៅតាមជនបទមិនស្មើគ្នា នាំអោយកន្លែងខ្លះខ្វះប្រជាជន កន្លែងខ្លះប្រជាជនច្រើនហួសពីផ្ទៃដីដែលមាន។ បើតាមឯកសារដដែលរបស់លោក រ៉េមី ព្រុយដូម ក៏ដូចជាលើការជាក់ស្តែង ប្រទេសកម្ពុជាមានផ្ទៃដីច្រើនជាងចំនួនប្រជាជនយ៉ាងច្រើន ប៉ុន្តែអាស្រ័យដោយមានការបែងចែកប្រជាជនមិនស្មើ ធ្វើអោយផ្ទៃដី ២/៣ ស្ទើរតែគ្មានប្រជាជនរស់នៅ។ ខាងឦសាន្ត ឧត្តរ អាគ្នេយ៍ មានដង់ស៊ីតេតិចជាង ៥ នាក់ក្នុងមួយគីឡូម៉ែត្រក្រឡា។ នៅតំបន់វាលរាប និងខ្ពង់រាប ក៏មិនស្មើគ្នាដែរ តំបន់ខ្លះដង់ស៊ីតេ ១០០ នាក់/គ.ម² តំបន់ខ្លះតិចជាង ៥០ នាក់/គ.ម²

ហើយក៏មានតំបន់ខ្លះលើសពី ២០០ នាក់/គ.ម²។ តំបន់ទន្លេមេគង្គ ទន្លេសាប ទន្លេបាសាក់ ដែលមានប្រជាជនរស់នៅច្រើន ឡើងរហូតដល់ដង់ស៊ីតេ ២០០ ទៅ ៦០០ នាក់/គ.ម²។ តំបន់ដីគ្មានជីជាតិ ដូចជាតាកែវ កំពង់ស្ពឺ កណ្ដាល ដង់ស៊ីតេលើសពី ១០០ ទៅ ២០០ នាក់/គ.ម² តែតំបន់ដីមានជីជាតិ ដូចជាខេត្តបាត់ដំបង បែរជាដង់ស៊ីតេតិចជាង ១០០ នាក់/គ.ម² ទៅវិញ។ នេះមួយផ្នែកមកពីមូលហេតុប្រវត្តិសាស្ត្រ តែមួយផ្នែកទៀត មកពីនយោបាយរដ្ឋាភិបាលក្នុងការបែងចែកពលកម្មសង្គម។

ការរៀបរាប់ និងបណ្ដាតួលេខខាងលើនេះ អាចអោយគេប៉ាន់ស្មានបានពីនិន្នាការនៃការបន្តធ្លាក់ចុះនៃជីវភាពកសិករ ក្នុងចន្លោះឆ្នាំ ១៩៦៧-១៩៧០ មុនពេលកើតមានសង្គ្រាម។

ចំពោះកសិករដែលសល់ដីតិចតួច ឬអត់ដីទាំងស្រុង ហើយមិនចេញពីភូមិកំណើត ត្រូវបង្ខំចិត្តជួល ឬប្រវាស់ដីរបស់ពួកម្ចាស់ដី ឬដើរស៊ីឈ្នួលធ្វើស្រែចំការអោយគេ ដែលប្រភេទនេះអាចរាប់បញ្ចូលទៅក្នុងស្រទាប់នៃវណ្ណៈអធនពាក់កណ្ដាល។ ប្រសិនបើគ្មានសង្គ្រាមនាឆ្នាំ ១៩៧០ ទេ និន្នាការកសិករគ្មានដីធ្វើនឹងកាន់តែកើនឡើង។

នយោបាយអាជីវកម្មសេរី កម្មសិទ្ធិលើដីធ្លី ក្នុងពេលរដ្ឋមិនបានតម្រែតម្រង់ និងវិនិយោគអោយកសិករ ក្នុងរយៈពេលដំបូង ឃើញហាក់ដូចជាបានផ្ដល់ផលប្រយោជន៍អោយកសិករទូទៅ ប៉ុន្តែក្រោយមក ឆ្លងតាមការពង្រីកតួនាទីរបស់ពួកនាយទុន និងម្ចាស់ដីក្នុងទំនាក់ទំនងជាមួយកសិករ តាមរូបភាពជិះជាន់គ្រប់ប្រភេទ បានធ្វើអោយកសិករកាន់តែក្រខ្សត់ និងទន់ខ្សោយជាលំដាប់ ហើយដែលជាបណ្ដើរៗ កសិករ

មួយចំនួនបង្ខំចិត្តត្រូវចាកចោលភូមិកំណើត ផ្លាស់ប្តូរមុខរបរ និងបាន ប្រែក្លាយខ្លួនទៅជាវណ្ណៈកម្មករ និងពលករស៊ីឈ្នួល ដែលតួលេខ ប្រៀបធៀបឆ្នាំ ១៩៥៥-១៩៥៨ កម្មករមានចំនួន ៤០ ទៅ ៤៥ ពាន់ នាក់ ឆ្នាំ ១៩៦៨ មាន ៧៥ ទៅ ៨០ ពាន់នាក់។ បើតាមការប៉ាន់ស្មាន របស់ក្រសួងការងារនាឆ្នាំ ១៩៦៧ ថា មានពលករធ្វើការក្នុងឧស្សាហ កម្មចំនួន ១១០.០០០ នាក់ដែលបែងចែកជា ៥ ផ្នែក ដូចខាងក្រោម៖

| | |
|---|---|
| - ផ្នែកចំណីអាហារ ថ្នាំជក់ តម្បាញ សំលៀកបំពាក់ | ៥២.៤០០ នាក់ |
| - ឈើ សង្ក្ការីម ក្រដាស ពោងពុម្ព ស្បែក | ១៦.៣០០ នាក់ |
| - កៅស៊ូ គីមី រ៉ែមិនមែនលោហធាតុ | ១៤.១០០ នាក់ |
| - លោហធាតុ ម៉ាស៊ីន សំភារៈដឹកជញ្ជូន | ២១.២០០ នាក់ |
| - ឧស្សាហកម្មផ្សេងៗ | ៦.០០០ នាក់ |

ចំនួននេះ ស្មើប្រហែល ៤ ភាគរយនៃប្រជាជនសកម្មទាំងអស់(*)។

ចំនួននេះ មិនទាន់រាប់បញ្ចូលនូវពលករស៊ីឈ្នួលសេរី នៅតាមទី ក្រុង តាមកសិដ្ឋានតូចតាច ដែលមានចំនួនយ៉ាងច្រើន និងមិនទាន់រាប់ ដល់សិប្បករតូចតាច និងអ្នកប្រកបរបរអាជីវកម្មតូចតាច ដែលមាន ចំនួន ៩០-១០០ ពាន់នាក់ផង។ តួលេខនេះមិនធំប៉ុន្មាន ប៉ុន្តែក៏បាន បង្ហាញអោយឃើញនូវការធ្លាក់ចុះរបស់កសិករ ដែលត្រូវប្រែកេទទៅ ជាកម្មករ និងពលករផ្សេងទៀត នៅពេលជីវភាពរបស់គេត្រូវធ្លាក់ចុះ។

(*) សេដ្ឋកិច្ចនៃប្រទេសកម្ពុជា ដោយ រ៉េមី ព្រុយដូម បោះពុម្ពឆ្នាំ ១៩៦៩ ជាភាសាបារាំង។

*តួលេខនេះ ក៏បានបង្ហាញនូវទម្រង់នៃផលិតកម្មរបៀបមូលធននិយម ដែលចាប់ផ្តើមមានការវិវត្តន៍ នៅក្នុងក្របខ័ណ្ឌនៃបែបផែនផលិតកម្មរបបសក្តិភូមិ។*

*ការចុះដុនដាបរបស់កសិករ មិនគ្រាន់តែជីវភាពខាងសម្ភារៈប៉ុណ្ណោះទេ ប៉ុន្តែខាងស្មារតី វប្បធម៌ ក៏មិនបានលើកកំពស់ដែរ។ លោក រ៉េមី ព្រុយដូម បានសរសេរថា "ក្នុងឆ្នាំ ១៩៦២ អនក្ខរជនមាន ៦១ ភាគរយចំពោះប្រជាជននៅជនបទ និង ៣៦ ភាគរយចំពោះប្រជាជននៅទីក្រុង(*)"។ ប្រជាជនដែលមិនចេះអក្សរនៅទីក្រុង ភាគច្រើនគឺជាកសិករមកពីជនបទ។ ពិតមែនតែពីឆ្នាំ ១៩៦២ ដល់ឆ្នាំ ១៩៧០ ចំនួនអ្នកមិនចេះអក្សរទាំងនៅទីក្រុង និងជនបទមានការថយចុះខ្លះ ប៉ុន្តែអ្នកមិនចេះ អក្សរក៏នៅតែមានចំនួនច្រើន។ ប្រការនេះបញ្ជាក់អោយឃើញថា កសិករមិនអាចរើបំរះចេញពីការជិះជាន់បានឡើយ។*

*ផ្ទុយទៅវិញ នយោបាយរបស់អ្នកកាន់អំណាចនៅកម្ពុជាក្នុងវិស័យកសិកម្មនៅពេលនោះ បានផ្តល់លទ្ធភាពគ្រប់គ្រាន់សំរាប់អ្នកមានដើមទុន វាតទី និងសង្កត់សង្កិន។ ទោះបីជាតួលេខឆ្នាំ ១៩៦៣ បានអោយដឹងថា ផ្ទៃដីស្រែចំការ ៩,៦ ភាគរយត្រូវម្ចាស់ដីធំៗ ជាអ្នកកាន់កាប់ ១៦ ភាគរយ ត្រូវម្ចាស់ដីមធ្យមកាន់កាប់ ដែលតាមទិន្នន័យនេះបង្ហាញអោយឃើញថា មិនទាន់មានការប្រមូលផ្តុំដីធ្លីក្នុងដៃពួកម្ចាស់ដីទាំងស្រុងក៏ដោយ ក៏អាចអោយគេឃើញនូវការរីកចំរើនរបស់ពួកម្ចាស់ដី និងនាយទុន ដែលកាលពីប៉ុន្មានឆ្នាំមុនមានតិចតួច ហើយវាបានរីកចំរើនថែម*

(*) សេដ្ឋកិច្ចនៃប្រទេសកម្ពុជា ដោយ រ៉េមី ព្រុយដូម បោះពុម្ពឆ្នាំ ១៩៦៩ ជាភាសាបារាំង។

*ទៀត ពីចន្លោះឆ្នាំ ១៩៦៣-១៩៧០។ ប្រការនេះ ក៏បានចុះបញ្ចាំងទៅដល់ការកសាងឡើងនូវ ទំនាក់ទំនងតាមរបៀបនៃអំពើជិះជាន់មូលធននិយម និងពាក់កណ្តាលសក្តិភូមិ ក្នុងវិស័យកសិកម្ម។*

*ក្នុងវិស័យដ៏ទៃនៃសេដ្ឋកិច្ច គេពិនិត្យឃើញនូវការរីកចំរើនច្រើនតែក្នុងវិស័យពាណិជ្ជកម្ម សេវាកម្ម ក្នុងពេលដែលផលិតកម្មកសិកម្ម ឧស្សាហកម្មមានការរីកចំរើនយឺត។ បញ្ហានេះ ទាក់ទងទៅនឹងនយោបាយវិនិយោគទុនរបស់បរទេសនៅកម្ពុជា និងនយោបាយអភិវឌ្ឍន៍របស់កម្ពុជាផ្ទាល់តែម្តង។ តាំងពីឆ្នាំ ១៩៥៦ មក នៅកម្ពុជាមានការប្រកួតប្រជែងដ៏ស្វិតស្វាញរវាងអាមេរិក បារាំង ជប៉ុន អង់គ្លេស ក្នុងបញ្ហាពាណិជ្ជកម្ម ដើរព្រមនឹងការប្រកួតប្រជែងនូវឥទ្ធិពលនយោបាយនៃប្រទេសទាំងនេះនៅកម្ពុជា។ ដូច្នេះការវិនិយោគសំរាប់ផលិតកម្មមានតិចតួច លើកលែងតែបារាំងដែលបន្តវិនិយោគសំរាប់ទុនចំពោះកៅស៊ូរបស់ខ្លួន ដើម្បីនាំចេញនូវផលិតផលដែលជាវត្ថុធាតុដើមទាំងនេះទៅប្រទេសខ្លួន។ ក្នុងពេលដែលបរទេសមិនបានយកចិត្តទុកដាក់វិនិយោគដល់ផលិតកម្ម នាយទុននៅក្នុងប្រទេសមិនបានយកទុនដែលខ្លួនមានទៅប្រើប្រាស់សំរាប់ពង្រីកផលិតកម្មក្នុងប្រទេសឡើយ តែបែរជាយកទុនទៅវិនិយោគនៅបរទេសទៅវិញ។ ក្នុងជំនាន់នោះ ពួកនាយទុនក៏ដូចជាមន្ត្រីធំៗ តែងយកទុនទៅផ្ញើធនាគារបរទេស ទិញផ្ទះសម្បែងនៅឯបរទេស ដែលមានលក្ខណៈជាការវិនិយោគនៅបរទេសវិញ។ ដូច្នេះហើយបានជាក្រោយឆ្នាំ ១៩៧០ ឬក្រោយឆ្នាំ ១៩៧៥ ពេលគេរត់ទៅប្រទេសក្រៅ គេឃើញពួកនាយទុន ឬមន្ត្រីទាំងនោះ មានផ្ទះ មានមូល*

ដ្ឋានសេដ្ឋកិច្ចហើយស្រេច ដូចជា សឺន សាន អតីតនាយករដ្ឋមន្ត្រី ជំនាន់ សីហនុ ជាដើម។ ការប្រកួតប្រជែងក្នុងវិស័យពាណិជ្ជកម្ម បានបង្កើតឡើងយ៉ាងឆាប់រហ័សនូវស្រទាប់វណ្ណៈនាយទុនកុំប្រាឌ័រ ដែលមានការផ្សារភ្ជាប់យ៉ាងខ្លាំងទៅនឹងនយោបាយរបស់អាមេរិក។ ឥណទានបរទេស ភាគច្រើនបានស្ថិតតែក្នុងសកម្មភាពនៃពាណិជ្ជកម្មក្នុងប្រទេស និងក្នុងការផ្តល់ឥណទានអោយខ្ចី ដែលឥណទាននេះ ត្រូវបានប្រើប្រាស់ ផ្សារភ្ជាប់ជាមួយនឹងការអោយខ្ចីចងការចំពោះកសិករ ដើម្បីប្រមូលមកវិញនូវផលិតផលសំរាប់ការនាំចេញ ដែលធ្វើតាមរយៈឈ្មួញកណ្តាលនៅជនបទ។

តាមឯកសាររបស់លោក រ៉េមី ព្រុយដូម បានបង្ហាញពីការបែងចែកវិស័យសេដ្ឋកិច្ចកម្ពុជាក្នុងប្រជាជនសកម្ម ដែលគាត់អោយនិយមន័យថា ប្រជាជនសកម្មគឺជាជនដែលធ្វើការ ដែលទទួលប្រាក់បំណាច់ ព្រះសង្ឃ អាចារ្យ បុព្វជិតផ្សេងទៀត ព្រមទាំងជនដែលរកការងារធ្វើ អ្នកជំងឺបណ្តោះអាសន្ន។ នាឆ្នាំ ១៩៦២ ប្រជាជនសកម្មមានប្រហែល ២.៥០០.០០០ នាក់ ស្មើនឹង ៤៤ ភាគរយ នៃប្រជាជនសរុប។ ក្នុងចំនួនប្រជាជនសកម្ម បានបែងចែកក្នុងផ្នែកសេដ្ឋកិច្ចបី៖

១. ផ្នែកកសិកម្ម ៨១ ភាគរយ ដែលបែងចែកជាអ្នកធ្វើស្រែ ៨១ ភាគរយ របរកសិកម្មផ្សេងទៀត ១៦ ភាគរយ នេសាទ ៣ ភាគរយ។

២. ផ្នែកឧស្សាហកម្ម ៤ ភាគរយ។

៣. ផ្នែកពាណិជ្ជកម្ម សេវាកម្ម ១៥ ភាគរយ (ដែលក្រសួងការងារបានលើកក្នុងតួលេខឆ្នាំ ១៩៦៧ ថាមាន ៣៨០.០០០ នាក់ ក្នុងចំណោម

ប្រជាជនសកម្មសរុប)។

ពិនិត្យតួលេខនៃប្រជាជនសកម្មដែលធ្វើការក្នុងកសិកម្ម ៨១ ភាគរយ ឧស្សាហកម្ម ៤ ភាគរយ ពាណិជ្ជកម្ម សេវាកម្ម ១៥ ភាគរយ អាចពិនិត្យឃើញថា បន្ទាប់ពីកសិកម្ម គឺពាណិជ្ជកម្ម ឯឧស្សាហកម្មរីកចំរើនយឺត។ នេះបញ្ជាក់អោយឃើញនូវ នយោបាយវិនិយោគទុនមិនបានត្រឹមត្រូវនៃរដ្ឋបាលជំនាន់នោះ។ វិស័យកសិកម្ម ពិតមែនតែគ្របដណ្តប់ ៨១ ភាគរយ តែគឺជាកសិកម្មធម្មជាតិ មិនមែនជាការវិនិយោគទុនអោយកសិកម្មឡើយ។ ទុនវិនិយោគ ទាំងក្នុង ទាំងមកពីក្រៅប្រទេស ប្រមូលផ្តុំលើវិស័យពាណិជ្ជកម្ម សេវាកម្ម។ ដូច្នេះហើយបានជាការរីកចំរើនខាងកសិកម្ម និងឧស្សាហកម្ម ស្ថិតក្នុងកំរិតយឺតយ៉ាវ។

អាចកត់សំគាល់បានថា ជំនួយ និងការវិនិយោគរបស់ប្រទេសក្រៅដែលមានលក្ខណៈជាការផលិត និងជំរុញបច្ចេកទេសវិទ្យាសាស្ត្រ គឺភាគច្រើនបានមកពីបណ្តាប្រទេសសង្គមនិយម ដូចជាសហភាពសូវៀត ចិន ឆេកូស្លូវ៉ាគី មានរោងចក្រអគ្គិសនី តម្បាញ កង់រថយន្ត វិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់ និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ។ល។ ជំនួយនិងការវិនិយោគនេះ មើលទៅដូចជាតិចតួច ប៉ុន្តែបើប្រៀបធៀបលទ្ធភាពខាងសេដ្ឋកិច្ចរបស់ប្រទេសមូលធន ក្នុងពេលដែលមានទំនាក់ទំនងជាមួយកម្ពុជាយូរមកហើយ ជាមួយនឹងលទ្ធភាពខាងសេដ្ឋកិច្ចនៃប្រទេសសង្គមនិយមក្នុងពេលទើបមានទំនាក់ទំនងជាមួយកម្ពុជា ឃើញថាជំនួយ និងការវិនិយោគនេះមានលក្ខណៈធំធេង ដែលវាផ្តល់លទ្ធភាពអោយមានការពង្រីកផលិតកម្មនៅក្នុងប្រទេសផង និងជំរុញដល់

ការអភិវឌ្ឍន៍ផ្នែកបច្ចេកទេសវិទ្យាសាស្ត្រនៅកម្ពុជាផង។ ទំនាក់ទំនងក្នុងការផ្តល់ជំនួយ និងវិនិយោគរបស់ប្រទេសសង្គមនិយម ក៏បានផ្តល់នូវវិភាគទានខាងនយោបាយមួយដល់នយោបាយសកម្មរបស់ នរោត្តម សីហនុ ក្នុងបញ្ហាឯករាជ្យ អព្យាក្រឹត ប្រឆាំងនឹងការគាបសង្កត់របស់ចក្រពត្តិអាមេរិក និងបរិវារ។ អាស្រ័យដោយការវិនិយោគពីសំណាក់មូលធនក្រៅប្រទេស និងមូលធនក្នុងប្រទេសទៅលើផលិតកម្មមានតិចតួចស្តួចស្តើងបានធ្វើអោយការកើនឡើងនៃកម្លាំងផលិតកម្មមានការយឺតយ៉ាវបំផុត បើប្រៀបធៀបជាមួយប្រទេសផ្សេងទៀតនៅអាស៊ីអាគ្នេយ៍។ ពិតមែនហើយ គេមិនអាចបដិសេធចោលទាំងស្រុងនូវការកើតឡើងថ្មីៗ នូវរោងចក្រ សហគ្រាស ដែលបានកើតមានក្នុងចន្លោះឆ្នាំ ១៩៥៥ ដល់ឆ្នាំ ១៩៧០ អាស្រ័យដោយការវិនិយោគរបស់មូលធនឯកជនបរទេសតាមរយៈមូលធនឯកជនក្នុងប្រទេសនោះឡើយ ប៉ុន្តែការរីកចំរើននេះមិនសមល្មមនឹងលទ្ធភាពដែលអាចធ្វើបានទេ។ អាស្រ័យហេតុនេះ ទំនាក់ទំនងផលិតកម្មតាមរបៀបមូលធននិយមក្នុងឧស្សាហកម្ម ក៏មានការរីកចំរើនយឺត បើប្រៀបធៀបជាមួយនឹងទំនាក់ទំនងក្នុងវិស័យពាណិជ្ជកម្ម។ ពួកនាយទុនក្រៅប្រទេស មានចំណុចរួមជាមួយនាយទុនក្នុងប្រទេស អំពីផលប្រយោជន៍ក្នុងការពន្យឺតការពង្រីកផលិតកម្មឧស្សាហកម្មក្នុងប្រទេស នៅត្រង់សេចក្តីត្រូវការនៃការនាំចេញវត្ថុធាតុដើម និងធញ្ញជាតិ និងការនាំចូលផលិតផលសំរេចមកវិញ ដែលគេអាចរកផលចំណេញបានច្រើនតាមរយៈសកម្មភាពរបៀបនេះ។ ដូច្នេះហើយបានជាកម្ពុជា ជានិច្ចកាលត្រូវធ្វើការនាំចេញនូវវត្ថុធាតុដើមទៅប្រទេសក្រៅ ហើយនាំចូលមកវិញនូវផលិតផលសំរេច ដែលរួមមាន

*មុខទំនិញមួយចំនួនជាវត្ថុធាតុដើមរបស់ប្រទេសខ្លួនផង។ ការរត់ប្រណាំងអំពីពាណិជ្ជកម្ម បានផ្តល់នូវភាពងាយស្រួលអោយសហរដ្ឋអាមេរិកបង្កើតបាននូវមូលដ្ឋានសំរាប់ការជ្រៀតចូល តាមរយៈពួកនាយទុនដែលមានផលប្រយោជន៍ស្របជាមួយសហរដ្ឋអាមេរិក។ ប្រការនេះមានឥទ្ធិពលយ៉ាងខ្លាំង ចំពោះនយោបាយក្រៅប្រទេសរបស់រាជរដ្ឋាភិបាល ដែលមួយផ្នែកចង់ពង្រឹងឯករាជ្យ អធិបតេយ្យ រក្សាអព្យាក្រឹត ប្រឆាំងការជ្រៀតជ្រែករបស់ចក្រពត្តិអាមេរិក មួយផ្នែកទៀតចង់រក្សាទំនាក់ទំនងជាមួយអាមេរិក ដើម្បីផលប្រយោជន៍ខាងសេដ្ឋកិច្ចរបស់ខ្លួន។ ពួកនាយទុន ដែលសម្របសម្រួលផលប្រយោជន៍ជាមួយសហរដ្ឋអាមេរិក បានឈានដល់ការជះឥទ្ធិពលខាងនយោបាយទៅលើនយោបាយរបស់រាជរដ្ឋាភិបាល។*

*ដោយមើលឃើញនូវគ្រោះថ្នាក់ បណ្តាលពីការជ្រៀតជ្រែករបស់ចក្រពត្តិអាមេរិកតាមរយៈវិស័យសេដ្ឋកិច្ចឆ្នាំ ១៩៦៣ រាជរដ្ឋាភិបាលបានសម្រេចធ្វើការបញ្ឈប់កម្មវិធីជំនួយរបស់សហរដ្ឋអាមេរិក ដែលបានចុះហត្ថលេខាកាលពីឆ្នាំ ១៩៥៥ ហើយអនុវត្តនូវការកែទម្រង់ប្រព័ន្ធធនាគារ និងពាណិជ្ជកម្មក្រៅប្រទេស ដែលវិស័យទាំងពីរនេះបានស្ថិតនៅក្រោមការគ្រប់គ្រង និងចាត់ចែងរបស់នាយទុន ទាំងក្នុងនិងក្រៅប្រទេសកន្លងមក ហើយដែលជាមូលដ្ឋានសំខាន់សំរាប់ការជ្រៀតជ្រែក និងវិទ្ធង្សនារបស់ពួកចក្រពត្តិ។*

*ការកែទម្រង់នេះសំដៅអោយរដ្ឋបំពេញតួនាទី ក្នុងវិស័យពាណិជ្ជកម្មក្រៅប្រទេស និងវិស័យធនាគារក្នុងពាណិជ្ជកម្ម ក្នុងក្របខ័ណ្ឌមួយ*

មានកំរិត។ ក្នុងពេលជាមួយគ្នា រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់បើកទូលាយកិច្ចសហប្រតិបត្តិការខាងសេដ្ឋកិច្ច បច្ចេកទេសវិទ្យាសាស្ត្រ ជាមួយបណ្ដាប្រទេសសង្គមនិយម ដើម្បីជាកូនជញ្ជីងជួយទប់ជាមួយប្រតិកម្មរបស់ចក្រពត្តិអាមេរិក។

គេអាចផ្ដល់នូវការវាយតម្លៃបានថា ការបញ្ឈប់កម្មវិធីជំនួយរបស់សហរដ្ឋអាមេរិក និងការកែទម្រង់នេះ គឺជានយោបាយសកម្ម និងក្លាហានរបស់រាជរដ្ឋាភិបាល ដើម្បីដាក់ខ្លួនអោយនៅក្រៅវង្វង់នៃឥទ្ធិពលរបស់សហរដ្ឋអាមេរិក។ តាមរយៈនៃការកែទម្រង់នេះ គេបានបង្កើតឡើងនូវក្រុមហ៊ុនអាហារណៃនីហរណៃជាតិមួយ ហៅកាត់ថា "សូណិចសុីម" ដែលមានទុនរបស់រដ្ឋចំនួន ៦០ ភាគរយ និងទុនរបស់ពាណិជ្ជករក្នុងប្រទេស ៤០ ភាគរយ ធ្វើការកិច្ចនាំចេញនាំចូលជំនួសពួកនាយទុនក្នុង និងក្រៅប្រទេសដែលធ្វើនាពេលមុន ព្រមទាំងបានបង្កើតនូវធនាគារពាណិជ្ជកម្មរដ្ឋមួយមានឈ្មោះថា "ឥណទានជាតិ" ដែលមានមុខងារផ្ដល់ឥណទានជំនួសធនាគារបរទេសនានា។ ក្នុងពេលជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏បានអនុញ្ញាតអោយក្រុមហ៊ុនបរទេសខ្លះបន្តធ្វើសកម្មភាព ដែលសំខាន់បណ្ដាក្រុមហ៊ុននាំចូលប្រេងឥន្ធនៈ។ ឆ្នាំ ១៩៦៥ ក្រោយការបង្កើតឡើងក្នុងឆ្នាំ ១៩៦៤ នូវក្រុមហ៊ុនរដ្ឋចម្រុះឯកជនពីរ គឺក្រុមហ៊ុនសំរាប់ទិញផលិតផលកសិកម្ម និងក្រុមហ៊ុនចែកចាយទំនិញនាំចូល សំរាប់ជួយកិច្ចការរបស់ សូណិចសុីម ក្នុងការរៀបចំទិញទំនិញសំរាប់នាំចេញផ្ទាល់ពីសំណាក់អ្នកផលិត និងជួយធ្វើការបែងចែកទំនិញនាំចូល ដែលធ្វើតាមរយៈរាជសហករណ៍ពាណិជ្ជកម្ម

ដែលមានស្រាប់មកហើយនោះ បានធ្វើអោយរដ្ឋកាន់កាប់បានទូវវិស័យពាណិជ្ជកម្មក្រៅប្រទេស បង្កលក្ខណៈអោយរដ្ឋកាន់កាប់បានវិស័យដទៃទៀត។

ការបញ្ឈប់កម្មវិធីជំនួយរបស់សហរដ្ឋអាមេរិក និងការកែទម្រង់ក្នុងវិស័យពាណិជ្ជកម្មក្រៅប្រទេស និងប្រព័ន្ធធនាគារ បានបង្កើតឡើងនូវឧបសគ្គពិតប្រាកដសំរាប់នយោបាយអាមេរិក និងផលប្រយោជន៍របស់ពួកនាយទុន ទាំងក្នុង និងក្រៅប្រទេស។ ពួកនាយទុនបានខិតខំរកវិធីដើម្បីគេចចេញពីឧបសគ្គ ដែលបង្កឡើងដោយនយោបាយរបស់រាជរដ្ឋាភិបាល។ អាស្រ័យដោយភាពខ្លាំងខាងសេដ្ឋកិច្ចរបស់វណ្ណៈនាយទុន និងអាស្រ័យដោយក្បាលម៉ាស៊ីនរដ្ឋត្រូវបានកាន់កាប់ដោយវណ្ណៈគហបតីមូលដ្ឋានសង្គមរបស់វណ្ណៈនាយទុនបានមានឥទ្ធិពលគ្របដណ្តប់ទៅលើនយោបាយ និងការអនុវត្តន៍របស់មន្ត្រីនានា តាំងពីក្នុងរាជវាំងរហូតដល់រដ្ឋសភា រដ្ឋាភិបាល និងស្ថាប័ននានាយ៉ាងនេះទើបធ្វើអោយវណ្ណៈនាយទុនរើបំរះបានយ៉ាងងាយស្រួល។ ការរើបំរះលើកនេះរបស់វណ្ណៈនាយទុន មិនគ្រាន់តែដើម្បីបើកទូលាយនូវទំនាក់ទំនងបែបមូលធននិយមប៉ុណ្ណោះទេ ប៉ុន្តែវាបានធ្វើអោយរង្គោះរង្គើនូវនយោបាយក្នុងប្រទេស និងនយោបាយក្រៅប្រទេសរបស់សង្គមរាស្ត្រនិយម ដឹកនាំដោយ នរោត្តម សីហនុ ទៀតផង។

ពួកនាយទុនបានរកឃើញនូវច្រកទ្វារក្រោយ ដែលបើកដោយមន្ត្រីពុករលួយរបស់រាជរដ្ឋាភិបាល និងមន្ត្រីខាងយោធា ដែលពេលនោះមន្ត្រីយោធាក៏បានបាត់បង់ផលប្រយោជន៍ដែរ អាស្រ័យដោយ នរោត្តម

សីហនុបានឈប់ទទួលជំនួយយោធារបស់សហរដ្ឋអាមេរិក។ ការរត់ពន្ធបានក្លាយទៅជាជំងឺសំរាប់សង្គម ហើយបានធ្វើអោយពួកនាយទុន និងមន្ត្រីពុករលួយមានបានយ៉ាងឆាប់រហ័ស។ ទំនិញ ទាំងនាំចេញ ទាំងនាំចូលជាច្រើនបានរត់គេចពន្ធក្រៅវង្វង់ត្រួតត្រារបស់ សូណិចស៊ីម ដែលផ្តល់លទ្ធភាពអោយពួកនាយទុន គេងប្រវ័ញ្ចខាងហិរញ្ញវត្ថុបានយ៉ាងច្រើនសម្បើម ហើយបានធ្វើអោយចំណូលរបស់រដ្ឋដែលធ្លាប់បានតាមរយៈក្រុមហ៊ុន សូណិចស៊ីម កាន់តែមានការថយចុះជាលំដាប់។ វិបត្តិហិរញ្ញវត្ថុ ថវិកា បានកើតមានឡើងភ្លាម ក្នុងពេលដែលប្រភពចំណូលហិរញ្ញវត្ថុពីបរទេស ពិសេសពីសហរដ្ឋអាមេរិកត្រូវបានកាត់ផ្តាច់។ សភាពការណ៍នេះ មានឥទ្ធិពលជាច្រើនដល់នយោបាយ និងសភាពការណ៍ផ្ទៃក្នុងរបស់រាជរដ្ឋាភិបាល ពិសេសបានបង្កើតនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើស្រទាប់ប្រជាជនក្រីក្រ បណ្តាលពីការបាត់បង់តម្លៃប្រាក់រៀល ដែលរដ្ឋាភិបាលបានអនុវត្តក្នុងស្ថានភាពវិបត្តិហិរញ្ញវត្ថុ និងតម្រូវអោយរដ្ឋាភិបាលត្រូវបន្ថយជាអតិបរមាដល់ការចំណាយទុននៅក្នុងវិស័យផលិតកម្មសំខាន់ៗ នៃសេដ្ឋកិច្ចជាតិ។

សភាពការណ៍វិបត្តិសេដ្ឋកិច្ចហិរញ្ញវត្ថុ ១៩៦៦-១៩៧០ គឺជាដំណាក់កាលនៃការពង្រីកតួនាទីខាងនយោបាយរបស់វណ្ណៈនាយទុន ឆ្ពោះទៅរកការរៀបចំបែបផែនមូលធននិយម និងរៀបចំនយោបាយបរទេសឡើងវិញ។ ចាប់ពីឆ្នាំ ១៩៦៨ អង្គការសង្គមរាស្ត្រនិយម របស់នរោត្តម សីហនុ បង្ខំចិត្តត្រូវធ្វើសម្បទានចំពោះការទាមទាររបស់ពួកនាយទុន និងពួកប្រតិកិរិយាស្តាំបំផុត ដោយអនុវត្តនូវការដាក់ទំនាក់ទំ

នង និងរៀបចំទទួលជំនួយសេដ្ឋកិច្ចជាមួយសហរដ្ឋអាមេរិកឡើងវិញ និងរៀបចំនូវរបៀបរបបសេដ្ឋកិច្ចក្នុងប្រទេសឡើងវិញ។ កំរិតសម្បទានខ្ពស់បំផុតរបស់ នរោត្តម សីហនុ គឺក្នុងឆ្នាំ ១៩៦៩ គឺការយល់ព្រមអោយបង្កើតនូវរដ្ឋាភិបាលស្រោចស្រង់ជាតិមួយ ដើម្បីជំនះលើវិបត្តិសេដ្ឋកិច្ច និងនយោបាយ។ ការសំរេចយកការសម្របសម្រួលបែបនេះ បានបើកទ្វារចំហសំរាប់ពួកប្រតិកិរិយានៅក្នុងប្រទេស អាស្រ័យដោយរដ្ឋាភិបាលស្រោចស្រង់ជាតិនេះ ត្រូវកាន់កាប់ដោយពួកស្តាំបំផុតគឺ លន់ នល់ និង សិរិមតៈ ដែលសុទ្ធតែជាអ្នកផ្សារភ្ជាប់ខ្លួនជាមួយផលប្រយោជន៍ចក្រពត្តិអាមេរិក។ ជំហានដំបូងនៃសកម្មភាពរបស់រដ្ឋាភិបាលនេះ គឺលុបចោលជាតូបនីយកម្ម និងការកែទម្រង់សេដ្ឋកិច្ចអោយទៅជាកម្មសិទ្ធឯកជនវិញ ព្រមទាំងបង្ក្រាបចលនាតស៊ូរបស់ប្រជាជននៅក្នុងផ្ទៃក្នុងប្រទេស។ ការលុបចោលនូវជាតូបនីយកម្មក្នុងវិស័យសេដ្ឋកិច្ច និងការបង្កើនសកម្មភាពបង្ក្រាបចលនាតស៊ូរបស់ប្រជាជន គឺបង្ហាញអោយឃើញថាកម្លាំងស្តាំបំផុត បានកាន់កាប់កិច្ចការខាងនយោបាយក្នុងប្រទេស និងក្រៅប្រទេសរួចហើយ។ អាមេរិកក៏ហាក់ដូចជាបានត្រៀមរៀបចំរួចស្រេចដើម្បីឈានចូលកម្ពុជា។ ការប្រែប្រួលអំពីសេដ្ឋកិច្ចបង្កើតឡើងនូវបញ្ហាស្មុគ្រស្មាញជាច្រើនខាងនយោបាយ ហើយវាកាន់តែស្មុគ្រស្មាញថែមទៀត នៅក្នុងក្របខ័ណ្ឌនៃប្រទេសមួយដែលទើបបានបញ្ចប់ជម្លោះ ដែលបក្សនយោបាយនានាត្រូវតស៊ូជាមួយគ្នាក្នុងស្ថានភាពដែលមានការជ្រៀតជ្រែកដោយពួកចក្រពត្តិពីខាងក្រៅ។ ក្រោយសន្និសីទហ្សឺណែវ បណ្តាបក្សនយោបាយបានឈានដល់ការសម្រុះសម្រួលមានលក្ខណៈជាបណ្តោះអាសន្ន បារាំងដកខ្លួនតែនៅ

ពង្រឹងផលប្រយោជន៍ខ្លួន ក្នុងពេលអាមេរិកជ្រៀតចូលជណ្តើមតួនាទីនៅកម្ពុជាក្នុងយុទ្ធសាស្ត្រនៅឥណ្ឌូចិន។

បញ្ហាស្មុគ្រស្មាញជាដំបូងគឺផ្តើមចេញពីបំណងរបស់ នរោត្តម សីហនុ ប៉ុនប៉ងស្តារឡើងវិញនូវអំណាចរបស់មហាក្សត្រ ដោយប៉ុនប៉ងធ្វើការកែប្រែរដ្ឋធម្មនុញ្ញឆ្នាំ ១៩៤៧ ដែលតម្រូវអោយរដ្ឋាភិបាលទទួលខុសត្រូវចំពោះមុខមហាក្សត្រ គឺមិនមែនចំពោះមុខរដ្ឋសភាទេ ដែលមានលក្ខណៈប្រែក្លាយសភា អោយទៅជាអង្គការពិគ្រោះពិភាក្សា ដែលគ្មានសិទ្ធិបោះឆ្នោតជ្រើសតាំងរដ្ឋាភិបាល ឬរំលាយចោលរដ្ឋាភិបាលឡើយ។ ជាមួយនោះ នរោត្តម សីហនុ ក៏ប៉ុនប៉ងកែប្រែច្បាប់សំរាប់ការបោះឆ្នោតដោយបញ្ចូលនូវលក្ខខណ្ឌមួយចំនួន រាំងស្ទះដល់បេក្ខជនពីបក្សប្រឆាំង ពិសេសពីចលនាតស៊ូខ្មែរឥស្សរៈ។ ការប៉ុនប៉ងនេះត្រូវបរាជ័យ អាស្រ័យដោយការជំទាស់របស់គណៈបក្សនានា ដូច្នេះតម្រូវអោយ នរោត្តម សីហនុ រិះរកវិធីដើម្បីពន្យាពេលការបោះឆ្នោត ដែលតាមការកំណត់នៃសន្និសីទហ្សឺណែវ ត្រូវធ្វើនៅខែមេសា ១៩៥៥ ទៅខែកញ្ញា ១៩៥៥ វិញ ដើម្បីអោយខ្លួនរៀបចំនូវមូលដ្ឋាននយោបាយសំរាប់ឈានចូលការបោះឆ្នោត។ តាមវិធីនេះ នរោត្តម សីហនុ បានអនុវត្តនូវយុទ្ធវិធី <u>បំបែកកម្លាំងដើម្បីដាក់ការហ៊ុំព័ទ្ធ</u> គឺខ្លួន នរោត្តម សីហនុ ត្រូវចាកចេញពីរាជបល្ល័ង្កមកធ្វើនយោបាយ ហើយប្រគល់អោយឪពុករបស់ខ្លួន នរោត្តម សុរាម្រឹត ឡើងសោយរាជ្យជំនួស។ តាមការកំណត់ ពេលធ្វើស្តេចមិនអាចធ្វើនយោបាយបានឡើយ ដូច្នេះ ការប្រើប្រាស់វិធីនេះរបស់ នរោត្តម សីហនុ គឺរក្សាបាននូវរាជបល្ល័ង្ក

ក្នុងដៃខ្លួនផង និងផ្តល់លទ្ធភាពអោយខ្លួនអាចចេញធ្វើនយោបាយបានផង ដែលជាវិធីប្រមូលផ្តុំអំណាចក្នុងកណ្តាប់ដៃខ្លួន និងក្រុមគ្រួសារខ្លួន។ នរោត្តម សីហនុ បានបង្កើតឡើងនូវអង្គការមួយមានឈ្មោះថា "សង្គមរាស្ត្រនិយម" ដែលក្រោយមកបានក្លាយទៅជាអង្គការនយោបាយ គ្រប់ដណ្តប់លើជីវភាពសង្គមទាំងមូល។ តាមគោលការណ៍របស់សង្គមរាស្ត្រនិយម តាំងពីពេលចាប់បង្កើតឡើង អង្គការនេះមិនបានចាត់ខ្លួនជាបក្សនយោបាយមួយទេ ប៉ុន្តែគឺជាអង្គការបង្រួបបង្រួមជាតិ ដែលមានគោលដៅកសាងប្រទេស តាមមាគ៌ាសង្គមនិយមព្រះពុទ្ធសាសនា។ តាមន័យនេះ សង្គមរាស្ត្រនិយម គឺជាអង្គការនៅពីលើអ្វីៗ ទាំង អស់ក្នុងសង្គម។

ការប្រើប្រាស់ពាក្យសង្គមនិយម ក៏ជាការឃោសនាមួយរបស់នរោត្តម សីហនុ ដើម្បីទប់ស្កាត់នូវការទាមទាររបស់មហាជន ដើម្បីបង្កើតឡើងនូវប្រព័ន្ធគ្រប់គ្រងមួយ ដែលមិនមែនជាប្រព័ន្ធគ្រប់គ្រងសក្តិភូមិ។ តាមពិតសង្គមរាស្ត្រនិយម ដែល នរោត្តម សីហនុ លើកឡើងគ្មានលក្ខណៈអ្វីស្របតាមលទ្ធិសង្គមនិយមទេ ដោយហេតុថាមាគ៌ានយោបាយនោះមានគោលគំនិតជាតិនិយមគហបតី ដើម្បីអនុវត្តការកែប្រែខ្លះប្លែកពីរបបសក្តិភូមិ ក្នុងបំណងពង្រីកស្ថានភាពនយោបាយរបស់ប្រទេស ទៅតាមមាគ៌ានៃមូលធននិយម "<u>គឺការរៀបចំនូវបែបផែនមូលធននិយមក្នុងក្របខ័ណ្ឌនៃរបបសក្តិភូមិ</u>"។

សង្គមរាស្ត្រនិយម បានបង្កើតឡើងដោយប្រើប្រាស់នូវឥទ្ធិពល និងតួនាទីរបស់ស្តេច អាស្រ័យដោយពេលនោះ ឥទ្ធិពលរបស់ស្តេច បានគ្រប

ដណ្តាប់យ៉ាងខ្លាំងទៅលើបណ្តាស្រទាប់ប្រជាជន។ ដូច្នេះ សង្គមរាស្ត្រនិយម បានរីកចំរើនយ៉ាងឆាប់រហ័ស បក្សនយោបាយភាគច្រើនបានរំសាយខ្លួនមកចូលរួមក្នុងអង្គការសង្គមរាស្ត្រនិយម។ ជាមួយនោះ គេក៏សង្កេតឃើញនូវសមាសភាពចម្រុះក្នុងអង្គការសង្គម ដែលជាកត្តាសំខាន់បំផុតបំផ្លាញអង្គការនេះនៅពេលក្រោយ។ អង្គការនេះមានកម្លាំងស្នូលដោយការរួបរួមនៃបណ្តាបក្សនយោបាយ ដែលតំណាងអោយវណ្ណៈសក្តិភូមិ នាយទុន ពួកនាហ្មឺនមន្ត្រី និងបញ្ញាវ័ន្ត។

អង្គការសង្គមរាស្ត្រនិយមបានធ្វើសកម្មភាពយ៉ាងមមាញឹក ដើម្បីចូលរួមការបោះឆ្នោតនៅខែកញ្ញាឆ្នាំ ១៩៥៥ ដែលពេលនោះបេក្ខជនរបស់អង្គការសង្គមរាស្ត្រនិយមទាំងអស់ត្រូវបានជាប់ឆ្នោត ហើយកាន់កាប់ទាំងស្រុងនូវរដ្ឋសភា។ ពេលនោះក៏មានបេក្ខជនរបស់ក្រុមប្រជាជន ដែលជាអង្គការចំហររបស់បក្សប្រជាជនបដិវត្តន៍ខ្មែរ បានចូលរួមបោះឆ្នោត ក្នុងកំរិតដ៏តិចតួចបំផុត ដោយហេតុថាសកម្មភាពរបស់គេត្រូវហាមឃាត់ និងកំរិតយ៉ាងខ្លាំងពីសំណាក់អ្នកកាន់អំណាច។ ឯបក្សប្រជាធិបតេយ្យវិញ ក៏បានចូលរួមបោះឆ្នោត ក្នុងលក្ខណៈដែលឥទ្ធិពលរបស់ខ្លួនមានតិចតួចក្នុងស្រទាប់ប្រជាជន។ ដូច្នេះ អង្គការសង្គមរាស្ត្រនិយម បានក្លាយទៅជាអង្គការដឹកនាំផ្តាច់មុខ ក្នុងជីវភាពនយោបាយរបស់ប្រទេស។

ការកាន់កាប់អំណាចរបស់អង្គការសង្គមរាស្ត្រនិយម បានប្រព្រឹត្តទៅក្នុងសភាពការណ៍ដ៏ស្មុគ្រស្មាញ ទាំងនៅក្នុង និងក្រៅប្រទេស។ តាំងពីការកកើតឡើងនូវអង្គការសង្គម គេពិនិត្យឃើញនូវចរន្តប្រតិកម្ម

ពីរផ្ទុយគ្នា គឺចរន្តមួយបានតំណាងអោយផលប្រយោជន៍ខ្ទះនៃស្រទាប់ក្រោម ស្ថិតនៅជិតស្និទ្ធជាមួយប្រជាពលករ និងចង់អោយប្រទេសមានឯករាជ្យ អព្យាក្រឹត ចរន្តមួយទៀត គឺតំណាងផលប្រយោជន៍ពួកស្តាំបំផុត ដែលជាវណ្ណៈជិះជាន់ ដែលមានផលប្រយោជន៍ផ្សារភ្ជាប់ជាមួយពួកចក្រពត្តិអាណានិគមនិយម។ ក្នុងដំណើររបស់ខ្លួន អង្គការសង្គមរាស្ត្រនិយមបានជួបនឹងវិបត្តិច្រើនលើកច្រើនសា អាស្រ័យដោយម្យ៉ាង វិបត្តិផ្ទៃក្នុងអង្គការសង្គមរាស្ត្រនិយមផ្ទាល់ ម្យ៉ាងទៀតការជ្រៀតជ្រែករបស់ចក្រពត្តិអាមេរិក។

គេអាចផ្តល់នូវការវាយតម្លៃថា អង្គការសង្គមរាស្ត្រនិយមបានចាត់វិធានការណ៍ដ៏ត្រឹមត្រូវនៅពេលដំបូង និងក្រោយមកទៀត <u>អំពីការពង្រឹងឯករាជ្យ អធិបតេយ្យរបស់ប្រទេស</u>។

ការដកខ្លួនចេញរបស់កម្ពុជា ពីសហភាពបារាំងនាខែកញ្ញា ឆ្នាំ ១៩៥៥ និងការរំលាយប្រព័ន្ធរដ្ឋាករគយ រវាងបារាំងជាមួយរដ្ឋចូលរួមក្នុងសហព័ន្ធបារាំងនៅឥណ្ឌូចិននៅចុងឆ្នាំ ១៩៥៤ បានផ្តល់លទ្ធភាពអោយរាជរដ្ឋាភិបាលធ្វើការត្រួតត្រាលើប្រព័ន្ធរូបិយវត្ថុ និងរដ្ឋាករគយ ហើយដកខ្លួនចេញពីឥទ្ធិពលប្រាក់ហ្វ្រង់ និងឈានទៅបង្កើតធនាគារ និងបោះពុម្ពប្រាក់ថ្មី ដើម្បីប្រើប្រាស់ដោយខ្លួនឯង។

គេបានដឹងរួចមកហើយថា ក្រោយឆ្នាំ ១៩៥៤ កម្ពុជាបានស្ថិតនៅក្នុងដំណាក់កាលឯករាជ្យខាងនយោបាយ ក្នុងកំរិតមិនទាន់ពេញលេញ គឺក្នុងដំណាក់កាលដែលបារាំងត្រូវដកខ្លួនចេញ តែនៅបន្តរក្សាផលប្រយោជន៍ខាងនយោបាយ និងសេដ្ឋកិច្ច និងក្នុងពេលដែល

ចក្រពត្តិអាមេរិកជ្រៀតចូល ក្នុងបំណងដាក់កម្ពុជាក្រោមឥទ្ធិពលនៃអន្តរាគមន៍របស់ខ្លួន និងបញ្ចូលកម្ពុជាក្នុងបក្សសម្ព័ន្ធអង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍ (សេអាតូ)។ ដូច្នេះ វិធានការណ៍របស់រាជរដ្ឋាភិបាលដែលសង្គមរាស្ត្រនិយមត្រួតត្រា ដាក់ចេញដើម្បីពង្រឹងឯករាជអធិបតេយ្យ គឺជាការត្រឹមត្រូវ ដែលនយោបាយនេះត្រូវបានទទួលការគាំទ្រពីសំណាក់ប្រជាជនកម្ពុជាគ្រប់ស្រទាប់ និងពីបណ្តាប្រទេសដែលស្នេហាសន្តិភាព និងចំរើនជឿនលឿនលើសកលលោក។ ការបង្កើតនូវទំនាក់ទំនងជាមួយបណ្តាប្រទេសសង្គមនិយម និងការគាំទ្ររបស់បណ្តាប្រទេសសង្គមនិយម បានពង្រឹងដល់ជំហររបស់ នរោត្តម សីហនុ ក្នុងការពង្រឹងឯករាជ្យ អព្យាក្រឹត របស់ប្រទេស ធ្វើអោយ នរោត្តម សីហនុ កាន់តែមានសេចក្តីក្លាហាន ក្នុងការប្រឆាំងការគាបសង្កត់ពីសំណាក់ចក្រពត្តិអាមេរិក និងបរិវារ ទាំងនៅភាគខាងត្បូង និងភាគខាងលិចនៃប្រទេស។

ការគាំទ្ររបស់បក្សប្រជាជនបដិវត្តន៍ខ្មែរ ឆ្លងតាមរយៈក្រុមប្រជាជនចំពោះនយោបាយឯករាជ្យ អព្យាក្រឹត របស់ នរោត្តម សីហនុ ក៏បានក្លាយទៅជាកូនជញ្ជីងមួយ រក្សាតុល្យភាពកម្លាំងនៅផ្ទៃក្នុងប្រទេស ប្រឆាំងពួកស្តាំនិយមដែលចង់រុញប្រទេសអោយចូលក្រោមឥទ្ធិពលរបស់ពួកចក្រពត្តិ។ នេះជាករណីពិសេសមួយ ដែលបក្សវណ្ណៈកម្មករដែលមានគោលដៅចុងក្រោយ និងផលប្រយោជន៍វណ្ណៈខុសគ្នាពីវណ្ណៈសក្តិភូមិ បែរជាគាំទ្រនយោបាយរបស់វណ្ណៈសក្តិភូមិ។ ប្រការនេះបានចង្អុលបង្ហាញថា <u>វណ្ណៈបដិបក្ខគ្នានៅក្នុងប្រទេសមួយអាចសម្រុះសម្រួល</u>

ជាមួយគ្នាបាន នៅក្នុងពេលវេលាមួយជាកំណត់ ដើម្បីផលប្រយោជន៍អ្វីមួយដែលមានលក្ខណៈស្របគ្នា វាបានស្ថិតនៅក្នុងក្របខ័ណ្ឌនៃការតស៊ូផង និងសម្រុះសម្រួលផង។

ចំណុចនេះកាន់តែបញ្ជាក់ច្បាស់ថា បក្សប្រជាជនបដិវត្តន៍ខ្មែរមានមាគ៌ាយុទ្ធសាស្ត្រ យុទ្ធវិធីត្រឹមត្រូវ ស្របទៅតាមកាលៈទេសៈនីមួយៗ។ ផលប្រយោជន៍នៃការពង្រឹងឯករាជ្យ អធិបតេយ្យ និងអព្យាក្រឹត របស់ប្រទេសជាតិ គឺជាការកិច្ចចម្បង ដែលតម្រូវអោយបក្សត្រូវតែប្រើប្រាស់គ្រប់កត្តាសកម្មរបស់គ្រប់កម្លាំងនយោបាយ ដើម្បីសំរេចនូវបំណងនេះ។ ការចូលរួមរបស់ក្រុមប្រជាជននៅតាមវេទិកានយោបាយ ដូចជាការចូលរួមក្នុងសមាជ ចូលរួមក្នុងសង្គមរាស្ត្រនិយម ការធ្វើសកម្មភាពតាមកាសែត ការធ្វើញត្តិ មីទ្ទីញ បាតុកម្ម។ល។ ដើម្បីបំផុសប្រជាជនគាំទ្រនយោបាយ ឯករាជ្យ អព្យាក្រឹត គឺជាសកម្មភាពដ៏ត្រឹមត្រូវ វាមិនគ្រាន់តែជាផលប្រយោជន៍ជាតិប៉ុណ្ណោះទេ ប៉ុន្តែវានៅមានខ្លឹមសារអន្តរជាតិដ៏សំខាន់ទៀតផង ព្រោះថាការប្រឆាំងមិនអោយដាក់កម្ពុជាក្រោមអន្តរាគមន៍របស់អាមេរិក និងមិនបញ្ចូលកម្ពុជាក្នុងសេអាតូ វាមានសារៈសំខាន់ខ្លាំងណាស់ដល់តុល្យភាពកម្លាំង រវាងបដិវត្តន៍ និងក្បត់បដិវត្តន៍នៅអាស៊ីអាគ្នេយ៍ ហើយវាមានសារៈសំខាន់ថែមទៀត ដល់ការកំរិតវង្វង់ប្រតិបត្តិការយោធារបស់អាមេរិក ដែលចង់វាយបដិវត្តន៍វៀតណាមពីក្រោយខ្នង តាមរយៈចូលមកកម្ពុជា។

ការកំណត់យកនយោបាយគាំទ្រនយោបាយឯករាជ្យ អព្យាក្រឹត របស់ នរោត្តម សីហនុ របស់បក្សប្រជាជនបដិវត្តន៍ខ្មែរ កាន់តែបង្ហាញ

ច្បាស់អំពីការតស៊ូរបស់ប្រជាជនកម្ពុជា ក្រោមការដឹកនាំរបស់បក្សប្រឆាំងអាណានិគមនិយមបារាំង ហ្វាស៊ីស្តជប៉ុន ការជ្រៀតជ្រែករបស់អាមេរិក គឺដើម្បីគោលដៅឯករាជ្យ សេរីភាព។ ឯការសម្រុះសម្រួល និងការអនុវត្តន៍ដោយស្ម័គ្រចិត្ត នូវកិច្ចព្រមព្រៀងហ្សឺណែវ ក៏ដើម្បីគោលដៅនេះដែរ។ ដូច្នេះ បក្សមានហេតុផលដើម្បីគាំទ្រនយោបាយបរទេសរបស់ នរោត្តម សីហនុ ដែលដាក់ប្រទេសអោយនៅឯករាជ្យ អព្យាក្រឹត មិនចូលបក្សសម្ព័ន្ធ។ ប្រការនេះក៏បញ្ជាក់អះអាងថា បក្សបានវាយតម្លៃទំនាស់ត្រឹមត្រូវ ដោយចាត់ទុកទំនាស់រវាងចក្រពត្តិអាមេរិក ជាមួយប្រជាជាតិកម្ពុជា ជាទំនាស់មូលដ្ឋានដែលត្រូវដោះស្រាយមុន។ វាកាន់តែមានហេតុផល ដើម្បីគាំទ្រ នៅពេល នរោត្តម សីហនុ គាំទ្រដល់ការតស៊ូរបស់ប្រជាជនវៀតណាម ប្រឆាំងការឈ្លានពានរបស់អាមេរិក។ ចំណុចនេះក៏ជាចំណុចដ៏ពិសេសនៃនយោបាយរបស់ នរោត្តម សីហនុ ដែលមាននយោបាយក្នុងប្រទេសបង្ក្រាបចលនាតស៊ូរបស់ប្រជាជន តែនយោបាយក្រៅប្រទេសប្រឆាំងអាមេរិក និងគាំទ្រការតស៊ូរបស់ប្រជាជនវៀតណាម។

វិភាគលើនយោបាយនេះ គេអាចសន្និដ្ឋានបានថា ការជ្រើសរើសមាគ៌ារបៀបនេះ គឺផុសចេញមកពីផលប្រយោជន៍ផ្ទាល់របស់ នរោត្តម សីហនុ ក្នុងការគ្រប់គ្រងអំណាចនៅកម្ពុជា។ ផលប្រយោជន៍ផ្ទាល់របស់ នរោត្តម សីហនុ មានមុខសកម្ម និងមុខអសកម្ម។ មុខសកម្ម គឺផលប្រយោជន៍របស់ សីហនុ បានផ្សារភ្ជាប់ជាមួយផលប្រយោជន៍ជាតិ គឺឯករាជ្យ អព្យាក្រឹត មុខអសកម្ម គឺ នរោត្តម សីហនុ ជានិច្ចកាលខិតខំ

រក្សានូវការត្រួតត្រាអំណាចអោយបានទាំងស្រុង ក្នុងកណ្តាប់ដៃខ្លួន។ អាស្រ័យដោយផលប្រយោជន៍នេះ នរោត្តម សីហនុ ត្រូវអនុវត្តវិធី "ដើរលើខ្សែពួរដោយប្រើប្រាស់លំនឹងខ្លួន" គឺ នយោបាយខាងក្រៅត្រូវទាក់ទងជាមួយបណ្តាប្រទេសសង្គមនិយម គាំទ្រការតស៊ូរបស់ប្រជាជនវៀតណាម ឡាវ ប្រឆាំងចក្រពត្តិអាមេរិក ឯនយោបាយខាងក្នុង គឺអូសទាញផង និងបង្ក្រាបផង។ ការគាំទ្រដល់ចលនាតស៊ូរបស់ប្រជាជនវៀតណាម និងការទាក់ទងជាមួយបណ្តាប្រទេសសង្គមនិយម គឺជាការចាំបាច់ក្នុងយុទ្ធវិធីរបស់ សីហនុ ម្យ៉ាងដើម្បីពង្រឹងជំហរទប់ទល់ជាមួយការវាតទីរបស់អាមេរិក និងសម្ព័ន្ធមិត្ត ពិសេសវៀតណាមខាងត្បូង និងថៃឡង់ដ៍ ម្យ៉ាងទៀត មិនទុកអោយប្រទេសទាំងនេះគាំទ្រដល់ចលនាតស៊ូបដិវត្តន៍នៅផ្ទៃក្នុងប្រទេសផង។

ភាពក្លាហានក្នុងនយោបាយរបស់ នរោត្តម សីហនុ ក្នុងការប្រឆាំងការជ្រៀតជ្រែករបស់អាមេរិក បានឡើងដល់កំរិតកំពូលនៅពេលប្រកាសឈប់ទទួលជំនួយរបស់សហរដ្ឋអាមេរិក ឆ្នាំ ១៩៦៣ និងការបើកសន្និសីទប្រជាជនឥណ្ឌូចិននៅភ្នំពេញ ឆ្នាំ ១៩៦៥ គួបផ្សំនឹងបាតុកម្មរបស់ប្រជាជន សិស្ស និស្សិត ១៩៦៤-១៩៦៥ ដែលសកម្មភាពទាំងអស់នេះ សុទ្ធតែប្រមូលផ្តុំមុខព្រួញប្រឆាំងចក្រពត្តិអាមេរិក ហើយផ្តល់ការគាំទ្រដល់ការតស៊ូរបស់ប្រជាជនវៀតណាម ប្រជាជនឡាវ។

នយោបាយប្រឆាំងការជ្រៀតជ្រែករបស់អាមេរិក ពង្រឹងឯករាជ្យ អធិបតេយ្យ អព្យាក្រឹត របស់ នរោត្តម សីហនុ ត្រូវបានចុះខ្សោយទៅវិញជាលំដាប់រហូតដល់អាមេរិកចូលឈ្លានពានកម្ពុជាក្រោយខែ មីនា

១៩៧០ អាស្រ័យដោយកត្តាមួយចំនួន គឺកត្តាខាងសេដ្ឋកិច្ច កត្តានយោបាយផ្ទៃក្នុងផ្ទាល់របស់សង្គមរាស្ត្រនិយម ដឹកនាំដោយ នរោត្តម សីហនុ និងវិបត្តិរាជបល្ល័ង្គ កត្តានៃការខុសឆ្គងរបស់បក្សប្រជាជនបដិវត្តន៍ខ្មែរ ក្រោយពេល ប៉ុល ពត ឡើងកាន់តំណែងដឹកនាំបក្ស ហើយក្បត់បក្ស និងកត្តានៃការជ្រៀតជ្រែកពីសំណាក់ចក្រពត្តិអាមេរិក។ កត្តាទាំងបួននេះ បានក្លាយទៅជាវត្ថុធាតុគួបផ្សំឈានដល់ការដួលរលំនៃរបបរាជានិយមអាស្រ័យធម្មនុញ្ញ។

ទីមួយៈ **កត្តាខាងសេដ្ឋកិច្ច**។ ដូចបានរៀបរាប់ខាងលើ កត្តាខាងសេដ្ឋកិច្ច ជាកត្តាមានអត្ថន័យសំខាន់ កំណត់ការវិវត្តន៍ប្រែប្រួលដ៏ស្មុគ្រស្មាញនៃសង្គមកម្ពុជា។

ទីពីរៈ **កត្តាផ្ទៃក្នុងផ្ទាល់របស់សង្គមរាស្ត្រនិយម និងវិបត្តិរាជបល្ល័ង្គ**។ អាចនិយាយបានថា សីហនុ បានធ្វើនយោបាយអត្តឃាតខ្លួនឯងលើចំណុចមួយចំនួន ដំបូងលើការកិច្ច និងការប្រមូលកម្លាំងមិនស៊ីចង្វាក់គ្នា។ ការតស៊ូដើម្បីពង្រឹងឯករាជ្យ អធិបតេយ្យ និងការពារនយោបាយអព្យាក្រឹត តម្រូវអោយមានការប្រមូលផ្តុំកម្លាំងប្រជាធិបតេយ្យ និងស្នេហាជាតិ ប៉ុន្តែ នរោត្តម សីហនុ មិនបានបោះបង់ចោលនូវការបង្ក្រាបកម្លាំងប្រជាធិបតេយ្យ និងស្នេហាជាតិឡើយ។ ចរន្តបដិបក្ខមុខពីរ និងនិន្នាការផ្ទុយគ្នាក្នុងនយោបាយរបស់ នរោត្តម សីហនុ បានក្លាយទៅជានយោបាយអត្តឃាតខ្លួនឯងដ៏ច្បាស់លាស់។ ការពង្រឹងឯករាជ្យ អធិបតេយ្យ និងអព្យាក្រឹត ក្នុងពេលដែលពួកចក្រពត្តិអាមេរិកធ្វើសកម្មភាពយ៉ាងខ្លាំង ហើយមានការគាំទ្ររបស់មជ្ឈដ្ឋានស្តាំនិយមក្នុង

ប្រទេសផងនោះ ទាមទារអោយ សីហនុ ត្រូវប្រមូលកម្លាំងដែលអាច ប្រមូលបាន ដើម្បីគាំទ្រនយោបាយខ្លួន។ មិនធ្វើដូច្នេះ សីហនុ បែរជា បើកការបង្ក្រាបកម្លាំងដែលគាំទ្រនយោបាយរបស់ខ្លួន ធ្វើអោយបាត់ នូវតុល្យភាពកម្លាំងក្បែរខ្លួនរបស់គាត់ជាដំបូង។ ការបង្ក្រាបបានធ្វើជា បន្ត តាំងពីការបិទកាសែត ចាប់ចង ឃុំឃាំង រហូតប្រើប្រាស់កម្លាំងយោ ធាដើម្បីបង្ក្រាប។ ប្រការនេះ បានធ្វើអោយកម្លាំងខាងស្តាំអើបំរះបានយ៉ាង ស្រួល។ កម្លាំងប្រតិកិរិយាខាងស្តាំ បានឆ្លៀតប្រើប្រាស់សភាពការណ៍នៃ ការបង្ក្រាបរបស់ នរោត្តម សីហនុ ទៅលើកម្លាំងប្រជាធិបតេយ្យ និង ស្នេហាជាតិ ប្រើប្រាស់វិបត្តិរាជបល្ល័ង្គ និងវិបត្តិខាងសេដ្ឋកិច្ច ដើម្បីធ្វើ ការដណ្តើមអំណាច។

គេបានដឹងរួចមកហើយថា អង្គការសង្គមរាស្ត្រនិយមមានកម្លាំង ស្នូលគឺវណ្ណៈនាយទុន និងសក្តិភូមិ ហើយមានចរន្តពីរបដិបក្ខគ្នាក្នុង អង្គការនេះ។ ជាមួយនោះ ខាងរាជវាំងក៏មានចរន្តពីរ ដែលមានការត ស៊ូប្រឆាំងគ្នាផង និងសម្រុះសម្រួលគ្នាផង។ វិបត្តិរាជបល្ល័ង្គ ក៏ជាមូល ហេតុដ៏សំខាន់មួយនាំដល់ការប្រែប្រួលយ៉ាងច្រើន ជះឥទ្ធិពលដល់ សង្គម ហើយមានមូលហេតុតភ្ជាប់មកព្រឹត្តិការណ៍រដ្ឋប្រហារ ខែ មីនា ១៩៧០។ គេអាចទម្លាក់ការទទួលខុសត្រូវអោយ នរោត្តម សីហនុ តែ ម្នាក់គត់ ដែលបានបង្កើតនូវបញ្ហានេះ ព្រោះមនុស្សផ្សេងទៀតមិន អាចធ្វើអ្វីបាន ចំពោះកិច្ចការដែលទាក់ទងដល់រាជបល្ល័ង្គឡើយ។

អាចលើកមករៀបរាប់អោយបានពិស្តារបន្តិច នូវបញ្ហាមានលក្ខណៈ ជាប្រវត្តិសាស្ត្រទាក់ទងដល់វិបត្តិរាជបល្ល័ង្គឆ្នាំ ១៩៦០។ តាមប្រវត្តិ

សាស្ត្រដែលបានកត់ត្រាទុក និងតាមការវិភាគរបស់អ្នកនយោបាយមួយចំនួន សុទ្ធតែកំណត់ថា វិបត្តិនេះចេញមកពីជម្លោះនៃក្រសែនរោត្តម និងក្រសែ ស៊ីសុវត្ថិ ដែលជម្លោះនេះមានអាយុ ១០០ ឆ្នាំគត់ គឺ ១៨៦០-១៩៦០។ ព្រះបាទអង្គឌួង បានសោយរាជ្យនៅកម្ពុជាក្រោមចំណុះសៀម។ ស្តេចនេះ មានមហេសីបី៖ មហេសីទីមួយមានកូនប្រុសឈ្មោះ នរោត្តម មហេសីទីពីរមានកូនប្រុសឈ្មោះ ស៊ីសុវត្ថិ និងមហេសីមួយទៀតមានកូនប្រុសឈ្មោះ ស៊ីវត្ថា។ ក្រោយពេលព្រះអង្គឌួងចូលទីវង្គតនាឆ្នាំ ១៨៦០ នរោត្តមបានឡើងសោយរាជ្យជំនួស ទំនាស់បងប្អូនបីនាក់បានកើតមានភ្លាម។ ស៊ីសុវត្ថិ ទៅពឹងពាក់បារាំង បារាំងបានប្រើប្រាស់ ស៊ីសុវត្ថិ ទប់ នរោត្តម ផង និងបង្ក្រាបចលនាតស៊ូរបស់ប្រជាជនផង ៦ ស៊ីវត្ថា ផ្អែកលើប្រជាជន តស៊ូជាមួយ នរោត្តម ប្រឆាំងនឹងអាណានិគមនិយមបារាំង។ ដោយសារ ស៊ីសុវត្ថិ មានសគុណជាមួយបារាំង ទើប ស៊ីសុវត្ថិ បានឡើងសោយរាជ្យជំនួស នរោត្តម ជាបងបន្ទាប់ពីនរោត្តម សោយទីវង្គតក្នុងឆ្នាំ ១៩០៤ ធ្វើអោយរាជបុត្រនរោត្តម ក្តៅក្រហាយ ព្រោះតាមទម្លាប់ គឺកូនរបស់អ្នកសោយរាជ្យមុនទេ ត្រូវឡើងសោយរាជក្រោយពេលឪពុកស្លាប់។ ឆ្នាំ ១៩២៧ បន្ទាប់ពីស៊ីសុវត្ថិ សុគត រាជសម្បត្តិ ក៏ធ្លាក់ទៅលើ ស៊ីសុវត្ថិ មុនីវង្ស ជាបុត្រ។ ព្រឹត្តិការណ៍នេះបានធ្វើអោយខ្សែ នរោត្តម ក្តៅក្រហាយកាន់តែខ្លាំងទំនាស់រវាងខ្សែស្រឡាយទាំងពីរកាន់តែតានតឹង រហូតដល់មានការហាមប្រាមមិនអោយរៀបការរវាងខ្សែ នរោត្តម ជាមួយខ្សែ ស៊ីសុវត្ថិ។ ប៉ុន្តែការហាមឃាត់នេះត្រូវបាន នរោត្តម សុរាម្រឹត និងស៊ីសុវត្ថិ កុសុមនារីរត្ន ជាបិតាមាតា នរោត្តម សីហនុ បំផ្លាញចោល គឺអ្នកទាំងពីរបាន

បំផ្លាញចោលនូវរបងខ័ណ្ឌរវាងខ្សែ នរោត្តម និងខ្សែ ស៊ីសុវត្ថិ។ ឆ្នាំ ១៩៤១ ស៊ីសុវត្ថិ មុនីវង្ស ចូលទីវង្គតក្នុងពេលបារាំងចាញ់សង្គ្រាមជាមួយអាល្លឺម៉ង់។ បារាំងត្រូវខំទប់ខ្លួននៅកម្ពុជា ដូច្នេះ ម្យ៉ាងបារាំងត្រូវការមនុស្សម្នាក់ដែលបារាំងងាយដឹកនាំផង ម្យ៉ាងទៀតចង់ផ្សះផ្សាជម្លោះរវាងខ្សែ ស៊ីសុវត្ថិ និងខ្សែ នរោត្តមផង ដូច្នេះរាជសម្បត្តិត្រូវធ្លាក់ទៅលើ នរោត្តម សីហនុ ដែលមានខ្សែលោហិតនៃត្រកូលទាំងពីរ។ ប្រការនេះបានធ្វើអោយប៉ះពាល់ផ្ទាល់ចំពោះ ស៊ីសុវត្ថិ មុនីរ៉េត ដែលជាឪពុកមាបង្កើតរបស់ នរោត្តម សីហនុ ព្រោះរាជសម្បត្តិដែលខ្លួនត្រូវទទួលជាស្វ័យប្រវត្តិ បែរជាមិនបានទទួលទៅវិញ។ ខែ មីនា ១៩៥៥ នរោត្តម សីហនុ បានប្រកាសដកខ្លួនចេញពីរាជបល្ល័ង្កដើម្បីធ្វើនយោបាយ ដោយបង្កើត និងដឹកនាំអង្គការសង្គមរាស្ត្រនិយម ហើយប្រគល់រាជបល្ល័ង្កអោយ នរោត្តម សុរាម្រឹត ជាឪពុកសោយរាជ្យជំនួស ដោយបានស្បថថាមិនចូលសោយរាជ្យវិញទេ។ ថ្ងៃ ៣ មេសា ១៩៦០ នរោត្តម សុរាម្រឹត ចូលទីវង្គត ដោយគ្មានចង្អុលតែងតាំងអ្នកណាអោយជំនួស។ វិបត្តិរាជបល្ល័ង្ក បានចាប់ផ្តើមហើយរង្គោះរង្គើរហូតរដ្ឋធម្មនុញ្ញ។ ការជ្រើសរើសស្តេចសោយរាជ្យថ្មីមិនអាចធ្វើទៅបាន អាស្រ័យដោយភាពស្មុគ្រស្មាញក្នុងរាជវង្ស។ នៅត្រង់នេះ អ្នកនយោបាយជាច្រើនបានទម្លាក់កំហុសអោយ នរោត្តម សីហនុ គឺជាការត្រឹមត្រូវ ព្រោះថាការរើសស្តេចថ្មីមិនបាន មិនមែនបណ្តាលមកពីខ្វះមនុស្សនោះទេ ប៉ុន្តែគឺជាឧបាយកលរបស់ នរោត្តម សីហនុ ក្នុងការប្រមូលផ្តុំអំណាចក្នុងកណ្តាប់ដៃខ្លួន។ គេទម្លាក់ការទទួលខុសត្រូវអោយ នរោត្តម សីហនុ អាស្រ័យដោយពេលនោះគាត់ជាអ្នកចាត់ចែងទាំងអស់ក្នុងរឿងវិបត្តិរាជបល្ល័ង្ក

*ពិតមែនតែ នរោត្តម សីហនុ ពេលនោះគ្រាន់តែជាសម្តេចឧបយុវរាជ និងប្រធានសង្គមរាស្ត្រនិយម មិនមែនជាប្រធានរដ្ឋសភាដែលរដ្ឋធម្មនុញ្ញបានបើកអោយប្រើអំណាចក្នុងឋានៈប្រមុខរដ្ឋស្តីទី ក្នុងពេលរាជបល្ល័ង្គទំនេររហូតជ្រើសរើសបានក្សត្រថ្មី ឬព្រះរាជានុសិទ្ធិមិនមែនជានាយករដ្ឋមន្ត្រី ដែលជាប្រមុខនៃអង្គការនីតិប្រតិបត្តិ (នាយករដ្ឋមន្ត្រីក៏ជាសមាជិកក្រុមប្រឹក្សារាជសម្បត្តិ) ហើយ នរោត្តម សីហនុ ក៏មិនមែនជាប្រធានក្រុមប្រឹក្សារាជសម្បត្តិ ដែលមានភារៈត្រូវកោះប្រជុំក្រុមប្រឹក្សានេះ ក្នុងរវាងបីថ្ងៃក្រោយព្រឹត្តិការណ៍ដែលធ្វើអោយរាជសម្បត្តិទំនេរ ដើម្បីជ្រើសតាំងក្សត្រថ្មី ព្រមទាំងរាជានុសិទ្ធិ បើព្រះមហាក្សត្រថ្មីស្ថិតនៅក្នុងអនីតិភាព*។ តាមរដ្ឋធម្មនុញ្ញ ក្រុមប្រឹក្សារាជសម្បត្តិត្រូវប្រជុំបីថ្ងៃក្រោយពេលស្តេចចូលទីវង្គត គឺត្រូវប្រជុំនៅថ្ងៃ ៥ មេសា ១៩៦០។ នរោត្តម សីហនុ បានរកវិធីទប់ស្កាត់កុំអោយព្រឹត្តិការណ៍វិវត្តន៍ទៅតាមក្របខ័ណ្ឌនៃរដ្ឋធម្មនុញ្ញ ព្រោះបើត្រូវប្រជុំក្រុមប្រឹក្សារាជសម្បត្តិដើម្បីរើសក្សត្រថ្មី នឹងផ្តល់នូវវិបាកសំរាប់គាត់ មិនដឹងថាអ្នកណាឡើងសោយរាជ្យ ព្រោះ ស៊ីសុវត្ថិ មុនីរ៉េត ជាប្រធានក្រុមប្រឹក្សារាជសម្បត្តិស្រាប់។ ពេលនោះមានមតិជាច្រើនចង់អោយមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមនារីរត្ន ជាមាតារបស់ព្រះនរោត្តម សីហនុ ឡើងសោយរាជ្យ ប៉ុន្តែវាផ្ទុយនឹងមាត្រា ២៥ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា៖* (**) *"រាជសម្បត្តិប្រទេសកម្ពុជា ជាមត៌ករបស់ក្សត្រាទាំងឡាយដែលជាតំណពីព្រះបាទសម្តេចព្រះហរិរក្សរាមាធិបតីអង្គឌួង" គឺមានន័យថា មានតែក្សត្រភេទប្រុស*

(*) មាត្រា ៣០ នៃរដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ក្រោយការកែប្រែ (១៣.៦.៦០)។

(**) មាត្រា ២៥ នៃរដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ក្រោយការកែប្រែ (១៣.៦.៦៣)

ដែលជាសាច់ឈាមអង្គឱ្យទេ ទើបឡើងសោយរាជ្យបាន។ នរោត្តម សីហនុ បានយកចំណុចនេះដើម្បីទប់មាតារបស់ខ្លួនកុំអោយឡើងសោយរាជ្យ រហូតដល់ផ្លាស់ប្តូរចៅហ្វាយខេត្តបាត់ដំបងដែលបានដឹកនាំប្រជាជនធ្វើបាតុកម្មគាំទ្រអោយមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមនារីរត្ន ឡើងសោយរាជ្យ។ មិនមែនមកពីរដ្ឋធម្មនុញ្ញទើបឡើងសោយរាជ្យមិនបាននោះទេ គេគ្រាន់តែកែរដ្ឋធម្មនុញ្ញដោយបញ្ចូលថែមពាក្យ "ក្សត្រិយ៍" វាជារឿងស្រេច ហើយស្របច្បាប់ផង ព្រោះពេលនោះ នរោត្តម សីហនុ ក៏បានបញ្ជាអោយកែរដ្ឋធម្មនុញ្ញដល់ទៅពីរលើកដែរ ដែលចំណុចទាំងពីរនេះសុទ្ធតែផ្ទុយជាមួយរចនាសម្ព័ន្ធ និងទម្លាប់នៃប្រទេសមានស្តេច។ ក្នុងចំណុចនេះ គេអាចពិនិត្យឃើញនូវអាថ៌កំបាំងរបស់ នរោត្តម សីហនុ ដែលចង់ក្តាប់អំណាចរដ្ឋទាំងស្រុងក្នុងដៃរបស់ខ្លួន ព្រោះថាបើមាតារបស់ខ្លួនឡើងសោយរាជ្យ មាតាជាខ្សែ ស៊ីសុវត្ថិ ដូច្នេះអាចបង្កលក្ខណៈងាយស្រួលអោយ ស៊ីសុវត្ថិ មុនីរ៉េត ជាអនុជ ហើយដែលជាគូទំនាស់ជាមួយ នរោត្តម សីហនុ កាច់ចង្កូតប្រទេស។ម្យ៉ាងទៀត បើមានមហាក្សត្រ គឺមិនអាចបង្កើតតំណែងប្រមុខរដ្ឋបានទេ។ ប្រសិនបើប្រគល់អោយ ស៊ីសុវត្ថិ មុនីរ៉េត តែម្តង ក៏កាន់តែគ្រោះថ្នាក់ ហើយបើរើសបុត្រារបស់ខ្លួនក៏ពិបាក ព្រោះខ្លួនមានប្រពន្ធច្រើន និងមានកូនច្រើន។ មតិមួយចំនួនបានលើកឡើងថា ការរើសស្តេចមិនបាន អាស្រ័យដោយមិនចុះសម្រុងគ្នា ក្នុងការរើសកូនដែលមានម្តាយផ្សេងគ្នានេះ ក៏អាចជាមូលហេតុមួយ តែមូលហេតុសំខាន់គឺដំណើរឆ្ពោះទៅរកការប្រមូលផ្តុំអំណាច តាមរយៈការបង្កើតតំណែងប្រមុខរដ្ឋ ក្នុងពេលប្រទេសនៅមានរាជបល្ល័ង្ក តែគ្មានស្តេចសោយរាជ្យ។

ដើម្បីទប់កុំអោយក្រុមប្រឹក្សារាជសម្បត្តិប្រជុំនៅថ្ងៃទី ៥ មេសា ១៩៦០ បាន នរោត្តម សីហនុ បានបញ្ជាអោយកែរដ្ឋធម្មនុញ្ញនៅថ្ងៃទី ៤ មេសា ១៩៦០ ហើយប្រកាសអោយប្រើនៅថ្ងៃ ៥ មេសា ១៩៦០ ដែលជាការប្រកាសដ៏ប្រញាប់ប្រញាល់ ផ្ទុយនឹងរដ្ឋធម្មនុញ្ញបានកំណត់។ ការធ្វើនេះ សំដៅសំខាន់ទប់ស្កាត់កុំអោយក្រុមប្រឹក្សារាជសម្បត្តិប្រជុំដើម្បីជ្រើសរើសស្តេចថ្មី។ ការកែរដ្ឋធម្មនុញ្ញលើកនេះ គឺដើម្បីចាត់តាំងក្រុមប្រឹក្សារាជានុសិទ្ធិ ដែលមានសមាជិកបីរូបធ្វើការជំនួសមហាក្សត្រក្នុងពេលរាជបល្ល័ង្គនៅទំនេរ។ តាមច្បាប់ លុះត្រាតែមានស្តេចទើបស្តេចចាត់តាំងក្រុមប្រឹក្សារាជានុសិទ្ធិបាន ដើម្បីជំនួសក្នុងពេលអវត្តមាន ឬបំពេញកិច្ចការមិនបាន។ ឯក្រុមប្រឹក្សារាជសម្បត្តិអាចចាត់តាំងរាជានុសិទ្ធិដែលយកចេញពីរាជវង្ស តែក្នុងលក្ខខណ្ឌដែលក្សត្រស្ថិតក្នុងអនីតិភាព "គឺនៅក្មេងមិនទាន់គ្រប់ការ"។ ដូច្នេះ ការកែរដ្ឋធម្មនុញ្ញនៅពេលនេះ ប្រៀបដូចជាចំណែកមួយនៃរដ្ឋប្រហាររំលំរាជានិយមដោយពួកសក្តិភូមិខ្លួនឯង។

ក្រុមប្រឹក្សារាជានុសិទ្ធិដែលបានចាត់តាំងនេះ ត្រូវបានប្រគល់អោយ ស៊ីសុវត្ថិ មុនីរ៉េត ធ្វើជាប្រធាន និងមានសមាជិកពីររូបទៀត ប៉ុន្តែត្រូវបរាជ័យ អាស្រ័យដោយ ស៊ីសុវត្ថិ មុនីរ៉េត និងសមាជិកទាំងនោះបដិសេធមិនព្រមទទួលកិច្ចការនេះ។ ការបដិសេធរបស់ ស៊ីសុវត្ថិ មុនីរ៉េត គឺជាឱកាសមួយបើកច្រកសំរាប់ជំហានទៅមុខរបស់ នរោត្តម សីហនុ។

វិបត្តិបានអូសបន្លាយរហូតដល់ខែមិថុនា ១៩៦០។ មន្ត្រីនានាបានខិតខំរកវិធីដោះស្រាយវិបត្តិរាជបល្ល័ង្គ ដោយខំបញ្ចុះបញ្ចូលអោយ

*មានបាតុកម្មរបស់ប្រជាជនទាមទារអោយសភាអនុម័តច្បាប់ ដែលមានក្នុងជំពូកទី ១២ មាត្រា ១២២ នៃរដ្ឋធម្មនុញ្ញ អំពីបទបញ្ញត្តិពិសេស ដើម្បីបង្កើតឡើងនូវតំណែងប្រមុខរដ្ឋ ដែលមានកាលបរិច្ឆេទលំដាប់លំដោយដូចខាងក្រោម៖ ថ្ងៃទី ១៣ មិថុនា សភាអនុម័តមាត្រា ១២២ នៃរដ្ឋធម្មនុញ្ញ អំពីការបង្កើតតំណែងប្រមុខរដ្ឋ ថ្ងៃទី ១៤ មិថុនា ប្រកាសអោយប្រើ ថ្ងៃ ១៧ មិថុនា សភាប្រគល់តំណែងប្រមុខរដ្ឋអោយ នរោត្តម សីហនុ ថ្ងៃ ២១ មិថុនា ១៩៦០ នរោត្តម សីហនុ ធ្វើសច្ចាប្រណិធានទទួលតំណែងប្រមុខរដ្ឋ។ ព្រឹត្តិការណ៍នេះ ក៏ជាចំណែកមួយទៀតនៃរដ្ឋប្រហាររំលំរាជានិយម ដោយសាមីខ្លួនសក្តិភូមិ។ ចាប់ពីពេលនោះមក សង្គមកម្ពុជាបានក្លាយទៅជាសង្គមមួយ ដែលខុសប្លែកពីរបបរាជានិយមនៅប្រទេសនានា វាច្របូកច្របល់រវាងច្បាប់ជាមួយរចនាសម្ព័ន្ធគ្រប់គ្រង ដែលជាឱកាសអោយ នរោត្តម សីហនុ ប្រមូលផ្តុំក្តាប់អំណាចតែម្នាក់ឯង ក្នុងឋានៈជាប្រមុខរដ្ឋផង ប្រធានសង្គមរាស្ត្រនិយមផង និងតំណាងអោយមហាក្សត្រផង។ តាមធម្មតា របបរាជានិយមគ្មានប្រមុខរដ្ឋទេ គឺមានត្រឹមនាយករដ្ឋមន្ត្រី ព្រោះមហាក្សត្រជានិមិត្តរូបនៃអំណាច ប្រមុខរដ្ឋធ្វើកិច្ចការនីតិបញ្ញត្តិហើយ តែនៅកម្ពុជាមានរាជបល្ល័ង្គគ្មានក្សត្រផង មានប្រមុខរដ្ឋដែលមានមុខងារនីតិបញ្ញត្តិផង នីតិប្រតិបត្តិផង។ អ្វីៗ បានប្រព្រឹត្តិទៅនៅក្រៅច្បាប់ ព្រោះថាមាត្រាទី ១ នៃរដ្ឋធម្មនុញ្ញសរសេរថា (*) "ប្រទេសកម្ពុជាជាប្រជាជាតិមួយមានព្រះមហាក្សត្រិយ៍សោយរាជ្យ"។ មាត្រា ២១ សរសេរថា (*)៖ "អំណាចគ្រប់យ៉ាងមកពីមហាក្សត្រិយ៍ អំណាចទាំងនោះត្រូវប្រើទៅ*

(*) រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ក្រោយការកែប្រែ ចុងក្រោយ (១៣.៦.៦០)។

តាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញនេះ"។ មាត្រាទី ២២ សរសេរថា (*)៖ "រដ្ឋសភាជាអ្នកប្រើអំណាចនីតិបញ្ញត្តិ ក្នុងព្រះបរមនាមនៃព្រះមហាក្សត្រិយ៍។ អ្នកដែលមានសិទ្ធិផ្តើមគំនិតច្បាប់នោះ គឺ ព្រះមហាក្សត្រិយ៍ គណៈរដ្ឋមន្ត្រី សមាជិកនៃរដ្ឋសភា និងសមាជិកនៃក្រុមប្រឹក្សាព្រះរាជាណាចក្រ"។ នៅមានមាត្រាច្រើនទៀត និយាយអំពីមហាក្សត្រ ដែលមាត្រាទាំងនេះបន្តរក្សារហូតដល់រដ្ឋប្រហារឆ្នាំ ១៩៧០។

នៅក្នុងពេលនិយាយដល់អំណាចរបស់មហាក្សត្រ គឺរាជបល្ល័ង្គគ្មានមនុស្សសោយរាជ្យទេ ដូច្នេះប្រាកដណាស់ថា ពេលនោះក្រៅពីតំណែងប្រមុខរដ្ឋ និងប្រធានសង្គមរាស្ត្រនិយម នរោត្តម សីហនុ នៅបានបំពេញមុខងារមួយទៀតជា ព្រះមហាក្សត្រ ទោះជាគាត់មិនសោយរាជ្យក៏ដោយ ក៏ជាទូទៅគេបានឃើញយ៉ាងដូច្នេះ ព្រោះថាតាំងពីមុនពេលគាត់ក្លាយជាប្រមុខរដ្ឋក្នុងវិបត្តិរាជបល្ល័ង្គ ទោះបីគាត់គ្មានតួនាទីអ្វីក្នុងផ្លូវរដ្ឋ ហើយគាត់ក៏មិនមែនជាក្សត្រសោយរាជ្យ ក៏គាត់អាចចាត់ចែងកិច្ចការបានគ្រប់យ៉ាងក្នុងអំណាចមួយដ៏ពេញលេញ។ ដូច្នេះគេគ្មានការងឿងឆ្ងល់អ្វីទេថា ក្រោយខែ មិថុនា ១៩៦០ នរោត្តម សីហនុ បានក្លាយទៅជាអ្នកក្តាប់អំណាចទាំងស្រុងលើគ្រប់ផ្នែកនៅកម្ពុជា រាប់ទាំងអំណាចរបស់មហាក្សត្រផង។

ក្រោយពេលដោះស្រាយបាននូវវិបត្តិរាជបល្ល័ង្គ និងប្រមូលបានអំណាចក្នុងដៃរបស់ខ្លួន នរោត្តម សីហនុ បានបន្តនូវនយោបាយបរទេសយ៉ាងសកម្ម សំដៅពង្រឹងដល់ឯករាជ្យ អព្យាក្រឹត្យរបស់ប្រទេស ប៉ុន្តែ

(*) រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ក្រោយការកែប្រែ ចុងក្រោយ (១៣.៦.៦០)។

ក្នុងពេលជាមួយគ្នា គាត់ក៏បន្តអនុវត្តនយោបាយអត្តឃាតខ្លួន ដែលនាំដល់ភាពផ្ទុយជាមួយការអនុវត្តន៍នយោបាយក្រៅប្រទេស ដែលតម្រូវអោយមានការប្រមូលផ្តុំកម្លាំងគាំទ្រនយោបាយឯករាជ្យ អព្យាក្រឹត្យ។ ចរន្តនយោបាយបដិបក្ខមុខពីររបស់ នរោត្តម សីហនុ បានអនុវត្តជាបន្ត ដោយគ្មានការសម្រុះសម្រួលជាមួយកម្លាំងប្រជាធិបតេយ្យបដិវត្តដែលទីបំផុត គាត់ត្រូវស្ថិតក្នុងភាពឯកោចំពោះមុខការវាយលុករបស់ចក្រពត្តិអាមេរិក។ ជំហររបស់គាត់ត្រូវចុះខ្សោយជាលំដាប់ តម្រូវអោយគាត់ធ្វើសម្បទាន និងការសម្រុះសម្រួលជាមួយកម្លាំងខាងស្តាំ ព្រោះថាគាត់គ្មានកូនជញ្ជីងណាផ្សេងទៀត សំរាប់លំនឹងតុល្យភាពកម្លាំងនៅជុំវិញគាត់ទៀតទេ ព្រោះកម្លាំងប្រជាធិបតេយ្យ និងស្នេហាជាតិត្រូវបានកំចាត់ចេញអស់។ ឯពួកស្តាំបានត្រួតត្រាពេញរដ្ឋសភា យោធាសន្តិសុខជាតិ និងទាំងអង្គការសង្គមរាស្ត្រនិយមផង និងក្តាប់យ៉ាងណែននូវសកម្មភាពខាងសេដ្ឋកិច្ចរបស់សង្គម។ ការធ្វើសម្បទានជិតចុងក្រោយបង្អស់គឺ នរោត្តម សីហនុ បានបោះបង់ចោលសិទ្ធិជាប្រពៃណីរបស់ខ្លួន ក្នុងការជ្រើសរើសបេក្ខជនរបស់សង្គមរាស្ត្រនិយមដើម្បីបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រសំរាប់រដ្ឋសភា។ ការបោះឆ្នោតឆ្នាំ ១៩៦៦ បានផ្តល់ជ័យជំនះសំរាប់ពួកខាងស្តាំ ដែលមានសម្លេងភាគច្រើននៅក្នុងរដ្ឋសភា ហើយបង្កើតរដ្ឋាភិបាលមួយឡើងដែលដឹកនាំដោយឧត្តមសេនីយ៍ លន់ នល់។ ទោះជារដ្ឋាភិបាលនេះមានអាយុតែ ៦ ខែក៏ដោយ ក៏បានបង្ហាញអោយឃើញថា នរោត្តម សីហនុ បាត់បង់នូវឥទ្ធិពលក្នុងការត្រួតត្រាខាងនយោបាយ ហើយត្រូវសម្របខ្លួនតាមកម្លាំងខាងស្តាំ ទាំងនយោបាយក្នុងប្រទេស ក៏ដូចជានយោ

បាយក្រៅប្រទេស។ ក្នុងគោលបំណងរក្សាអំណាចតទៅទៀត នរោត្តម សីហនុ បានធ្មៀតប្រើប្រាស់វេទិកានៃសមាជជាតិ ដែលគាត់ធ្លាប់ប្រើប្រាស់ដោយជោគជ័យ ក្នុងការពង្រឹងនយោបាយរបស់គាត់តាំងពីយូរមកហើយ។ សមាជបានប្រព្រឹត្តិទៅនៅចុងខែ កក្កដា ១៩៦៩ បន្ទាប់ពីរដ្ឋាភិបាលពិសេសមួយ ដឹកនាំដោយ នរោត្តម សីហនុ ផ្ទាល់ និងមាន សឺន សាន ជានាយករដ្ឋមន្ត្រី និងរដ្ឋាភិបាលថ្មីមួយទៀត ដែលមាន ប៉ែន នុត នាយករដ្ឋមន្ត្រី ទ្រទ្រង់សភាពការណ៍មិនបាន។ តែសមាជលើកនេះ នរោត្តម សីហនុ ត្រូវបរាជ័យធ្ងន់ធ្ងរ អាស្រ័យដោយសម្លេងក្នុងសភា និងក្នុងសង្គមរាស្ត្រនិយម ភាគច្រើនជាកម្លាំងខាងស្តាំ។ ហេតុការណ៍តម្រូវអោយ នរោត្តម សីហនុ ធ្វើនូវជំហានសម្បទានចុងក្រោយ គឺការសំរេចអោយបង្កើតរដ្ឋាភិបាលស្រោចស្រង់ជាតិមួយឡើង នៅខែសីហា ១៩៦៩ ដែលរដ្ឋាភិបាលនេះត្រូវដឹកនាំដោយ លន់ នល់ ដែលជាមនុស្សមានកំហឹងស្រាប់ បន្ទាប់ពីត្រូវធ្លាក់ពីនាយករដ្ឋមន្ត្រី ខែ ឧសភា ១៩៦៧។ រដ្ឋាភិបាលនេះក៏មាន សិរីមតៈ ជាឧបនាយករដ្ឋមន្ត្រីផងដែរ។ ការសំរេចរបៀបនេះ គឺជាការត្រួសត្រាយផ្លូវ សំរាប់ពួកខាងស្តាំរំលំ នរោត្តម សីហនុ តាមរយៈរដ្ឋប្រហារ ១៨ មីនា ១៩៧០។

ឆ្លងតាមបណ្តាសកម្មភាពរបស់ នរោត្តម សីហនុ ក៏គួរស្វែងយល់អំពីធាតុពិតវណ្ណៈពិតប្រាកដរបស់អតីតស្តេចនេះ តើឈរលើធាតុវណ្ណៈអ្វី ដែលបញ្ចាទៅលើសកម្មភាពនយោបាយនៃរបបដែលគាត់ដឹកនាំ។ កន្លងមករហូតបច្ចុប្បន្ននេះ មានការវាយតម្លៃខុសៗ គ្នាជាច្រើន អំពីធាតុពិតវណ្ណៈ និងនយោបាយរបស់ នរោត្តម សីហនុ។ មតិខ្លះលើក

ឡើងថា នរោត្តម សីហនុ មានធាតុដើមជាសក្តិភូមិ តែប្រែធាតុជានាយទុន អាស្រ័យដោយរបបដែលគាត់ដឹកនាំមានការកើតឡើងនូវទំនាក់ទំនងមូលធននិយមៗ មតិខ្លះទៀតលើកឡើងថា នរោត្តម សីហនុ លំអៀងទៅរកកសិករៗ ជានយោបាយក្រៅប្រទេស ក៏មានការវាយតម្លៃខុសៗ គ្នា មតិខ្លះថា សីហនុ ស្ថិតជាមួយបណ្តាប្រទេសមូលធន ខ្លះទៀតថា ស្ថិតជាមួយបណ្តាប្រទេសសង្គមនិយមៗលៗ និងៗលៗ

ពិតជាមានការពិបាកក្នុងការស្វែងយល់ អំពីធាតុពិតវណ្ណៈរបស់ នរោត្តម សីហនុ អាស្រ័យអតីតស្តេចអង្គនេះគ្មានមនោគមវិជ្ជា និង យុទ្ធសាស្ត្រពិតប្រាកដឡើយ តែក៏ត្រូវទទួលស្គាល់ថា នរោត្តម សីហនុ ចេះសម្របសម្រួលជាមួយសភាពការណ៍សត្យានុម័តៗ ជាតុពិតវណ្ណៈពិតប្រាកដរបស់ នរោត្តម សីហនុ គឺសក្តិភូមិ ហើយជាសក្តិភូមិក្នុងដំណាក់កាលរាជានិយមផ្តាច់ការ មិនមែនក្នុងដំណាក់កាលរាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញឡើយៗ ការអះអាងនេះ មិនមែនផ្អែកលើសាមីខ្លួន គាត់ប្រសូតចេញពីត្រកូលមហាក្សត្រ ហើយធ្លាប់បានធ្វើជាស្តេចនោះឡើយ តែជាការពិនិត្យលើការអនុវត្តន៍ក្នុងនយោបាយជាបន្តបន្ទាប់រៀងរហូតមកៗ តាំងពីនៅកាន់អំណាចរហូតដល់អស់អំណាច ក្នុងរយៈពេលមួយដ៏យូរ នរោត្តម សីហនុ នៅតែរក្សាខ្ជាប់ធាតុវណ្ណៈជាសក្តិភូមិ គ្មានការកែប្រែអ្វីឡើយ ពេលណាក៏គាត់នៅតែតាំងខ្លួនជាបិតាជាតិខ្មែរ ជាអ្នកដែលនៅពីលើគេ ហើយចាត់ទុកទឹកដីកម្ពុជា និងប្រជាជនកម្ពុជាដូចជារបស់បុគ្គលខ្លួនម្នាក់ៗ សីហនុ គឺជាមនុស្សដែលចាត់ទុកខ្លួន ថាគ្មានកំហុស ទោះបីគាត់បានប្រព្រឹត្តិកំហុសយ៉ាងច្រើន កំហុសតែង

ត្រូវបានទម្លាក់អោយអ្នកដទៃ ជាមនុស្សផ្តាច់ការគួរអោយភ័យខ្លាច ជាអ្នកនិយមការសងសឹកដ៏កម្រោលម្នាក់ ហើយក៏ជាមនុស្សប្រែប្រួលក្រឡេចក្រឡុច ដែលគ្មានអ្នកណាប៉ាន់ស្មានបានមុនឡើយៗលៗ

ជាការពិតហើយ ក្នុងរបបដែល នរោត្តម សីហនុ ដឹកនាំមានកើតឡើងនូវទំនាក់ទំនងមូលធននិយម ដែលជាទំនាក់ទំនងមួយជឿនលឿនជាងទំនាក់ទំនងសក្តិភូមិ តែគេមិនត្រូវចាត់ទុកប្រការនេះជាការប្រែជាតុវណ្ណៈរបស់គាត់ពីសក្តិភូមិ ទៅកាន់នាយទុនឡើយៗ <u>អ្វីដែលបានកើតឡើងនាពេលនោះ គឺក្រឹត្យក្រមសត្យានុម័តនៃការរីកចំរើនរបស់សង្គមមនុស្ស ដែលគាត់មិនអាចរាំងខ្ទប់បាន ហើយតម្រូវអោយគាត់ត្រូវតែទទួលយកកត្តាសត្យានុម័តនេះ</u>ៗ កត្តាសត្យានុម័តបញ្ជាទៅលើកត្តាអត្តនោម័ត នេះជាក្រឹត្យក្រមៗ ចំណុចនេះ នរោត្តម សីហនុ ចេះប្រើប្រាស់ក្រឹត្យក្រមនេះ ដើម្បីរក្សានូវអំណាចរបស់គាត់ទាំងនយោបាយក្នុងប្រទេស ទាំងនយោបាយក្រៅប្រទេស ប៉ុន្តែប្រការនេះមិនមានឥទ្ធិពលលុបបំបាត់នូវធាតុសក្តិភូមិរបស់ នរោត្តម សីហនុ ឡើយៗ សកម្មភាពនយោបាយបត់បែនរបស់ នរោត្តម សីហនុ ប្រមូលផ្តុំលើអំណាច ទោះត្រូវងាកឆ្វេង ឬត្រូវងាកស្តាំ គឺដើម្បីអំណាចនេះឯងៗ រដ្ឋប្រហារយោធា ១៨ មីនា ១៩៧០ បានធ្វើអោយគាត់អស់អំណាចតាំងពីពេលនេះមកៗ ការចូលរួមរបស់គាត់ក្នុងចលនាតស៊ូប្រឆាំងអាមេរិកនិងបរិវារ ពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥ មានហេតុផលត្រឹមត្រូវ ទោះជាគាត់ចង់ដណ្តើមអំណាចមកវិញ ក៏អំណាចនេះបានផ្សារភ្ជាប់ជាមួយផលប្រយោជន៍ជាតិ និងប្រជាជន ដូច្នេះក្នុងដំណាក់កាលនេះ

មិនអាចទម្លាក់កំហុសអោយគាត់បានឡើយ។ ប៉ុន្តែ ក្នុងដំណាក់កាល ១៩៧៥-១៩៧៨ ដែលគាត់បានផ្សារភ្ជាប់ខ្លួនជាមួយរបប ប៉ុល ពត ក្នុងពេលដែលរបបនេះអនុវត្តការប្រល័យពូជសាសន៍ បង្ហាញកាន់តែច្បាស់នូវធាតុសក្តិភូមិរបស់គាត់ ក្នុងឋានៈជាអ្នកនិយមការសងសឹកដ៏កម្រោលម្នាក់។ អ្វីដែលគាត់ត្រូវការ គឺប្រើប្រាស់ដៃរបស់ ប៉ុល ពត ដើម្បីអនុវត្តការសងសឹកទៅលើពួក លន់ នល់ និងប្រជាជនដែលគាំទ្ររបប លន់ នល់ផ្តួលរំលំគាត់។ ចាប់ពីឆ្នាំ ១៩៧៩ រហូតមកដល់ពេលនេះ ក៏កាន់តែមានភស្តុតាងបង្ហាញអំពីធាតុសក្តិភូមិ និងល្មោភអំណាចរបស់ នរោត្តម សីហនុ តាមរយៈការដែលគាត់ចងសម្ព័ន្ធភាព និងធ្វើជាមេក្លោងពួកប្រល័យពូជសាសន៍ ប៉ុល ពត ដើម្បីប្រឆាំងប្រជាជនកម្ពុជា។ ដើម្បីអំណាច នរោត្តម សីហនុ មិនខ្លាចនឹងធ្វើសម្ព័ន្ធភាពជាមួយព្រាយបីសាចឡើយ។ ដូចនេះ អាចកំណត់បានថា <u>តាំងពីដើមដល់ចប់ នរោត្តម សីហនុ បានស្ថិតក្នុងជំហរជាសក្តិភូមិផ្តាច់ការ នេះជាធាតុពិតវណ្ណៈពិតប្រាកដរបស់គាត់</u>។

ទីបី៖ **កត្តានៃការខុសឆ្គងរបស់បក្សប្រជាជនបដិវត្តន៍ខ្មែរ** ក្រោយពេល ប៉ុល ពត ឡើងកាន់តំណែងដឹកនាំបក្ស ហើយក្បត់បក្ស ក៏ត្រូវនិយាយអំពីផ្នែកត្រូវ និងផ្នែកពុំត្រឹមត្រូវរបស់ចលនាបដិវត្តទៅតាមដំណាក់កាលនីមួយៗ ព្រោះថា នេះក៏ជាកត្តាគួបផ្សំមួយដ៏សំខាន់ ជះឥទ្ធិពលដល់ការវិវត្តន៍នៃសង្គមកម្ពុជា។

+ <u>ផ្នែកត្រូវ</u>

ក្រោយសន្និសីទហ្សឺណែវ អាចារ្យមៀន (សឹង ង៉ុកមិញ) បានចេញ

នូវសេចក្តីថ្លែងការណ៍អំពាវនាវដល់ជនរួមជាតិទាំងមូល រក្សាអោយខ្ជាប់ខ្ជួននូវឆន្ទៈប្រយុទ្ធ លើកកំពស់ការប្រុងប្រយ័ត្ន ទាមទារអោយខ្លាំង អនុវត្តបានត្រឹមត្រូវនូវប្រការទាំងឡាយដែលបានចុះហត្ថលេខា។ ផ្តើមចេញពីនេះ ដើម្បីស្របតាមសភាពការណ៍ថ្មី បក្សមានគោលការណ៍ប្រែទិសតស៊ូ ពីតស៊ូប្រដាប់អាវុធមកតស៊ូនយោបាយវិញ។ នេះគឺភាពត្រឹមត្រូវរបស់បក្ស ដែលក្រោយការដឹកនាំការតស៊ូរបស់ប្រជាជនប្រឆាំងអាណានិគមនិយមបារាំង ត្រូវបានបញ្ចប់ សភាពការណ៍ទាមទារអោយបក្សកែសម្រួលខាងចាត់តាំង ហើយប្រែទិសបានទាន់ពេលវេលា សំដៅបំពេញនូវភារកិច្ចនយោបាយថ្មី និងបែបផែនតស៊ូក្នុងសភាពការណ៍ថ្មី ដើម្បីការពារនូវសមិទ្ធិផលដែលដណ្តើមបាន គឺឯករាជ្យជាតិ ដោយយកគោលការណ៍រក្សាខ្ជាប់សន្តិភាព ឯករាជ្យ អព្យាក្រឹត្យ និងទាមទារសិទ្ធិប្រជាធិបតេយ្យ កែប្រែជីវភាពប្រជាជន។

អាចនិយាយបានថា រូបភាពតស៊ូ និងខ្លឹមសារតស៊ូនាពេលនោះ គឺសមស្របបំផុត សមស្របជាមួយនឹងស្ថានភាពទំនាស់ សមស្របជាមួយលទ្ធភាពដែលអាចធ្វើបានរបស់មហាជន និងសមស្របជាមួយគោលដៅនៃដំណាក់កាលបដិវត្តប្រជាជាតិប្រជាធិបតេយ្យ ដែលពេលវេលានោះ ភារកិច្ចប្រជាជាតិកំពុងស្ថិតនៅក្នុងភារកិច្ចចម្បង គឺប្រឆាំងការជ្រៀតជ្រែករបស់ចក្រពត្តិអាមេរិក ពង្រឹងឯករាជ្យ អធិបតេយ្យ និងអព្យាក្រឹត្យរបស់ប្រទេសជាតិ។

រូបភាពចាត់តាំងសកម្មភាពរបស់បក្សនាពេលនោះ ក៏សមស្របនឹងសភាពការណ៍ គឺមានផ្នែកសម្ងាត់ផង ផ្នែកចំហផង និងមានការ

ត្រៀមរៀបចំសំរាប់យូរអង្វែងផង ដោយបានចាត់បញ្ជូនកម្មាភិបាល យុទ្ធជន អោយទៅបណ្តុះបណ្តាលនៅបរទេស។ ការប្រើប្រាស់រូបភាព ចំហតស៊ូស្របច្បាប់ដោយចូលរួមនៅតាមវេទិកាជាច្រើន ធ្វើសម្ព័ន្ធភាព ដោយមានកំរិតជាមួយបក្សនយោបាយផ្សេងទៀត ដើម្បីតស៊ូប្រឆាំង ការជ្រៀតជ្រែករបស់ចក្រពត្តិអាមេរិក សុទ្ធតែបានផ្តល់នូវវិភាគទាន ក្នុងការពង្រឹងឯករាជ្យអព្យាក្រឹត្យរបស់ប្រទេស ជាមួយនោះក៏បានបន្ថយ នូវមុខអសកម្មនៃនយោបាយរបស់រាជរដ្ឋាភិបាល ទាំងនយោបាយក្រៅ ប្រទេស ក៏ដូចជានយោបាយក្នុងប្រទេស ហើយរួមចំណែកយ៉ាងសម ស្របដល់ការទាមទារសិទ្ធិប្រជាធិបតេយ្យ និងកែប្រែជីវភាពប្រជាជន។ ខ្លឹមសារតស៊ូដែលបានប្រកាសផ្សាយដោយក្រុមប្រជាជន ដែលមាន បំណងប្រមូលផ្តុំសាមគ្គីឯកភាពពលរដ្ឋខ្មែរស្នេហាជាតិ មិនបែងចែក ស្រទាប់ជាន់ថ្នាក់ បក្សពួក សាសនា ធ្វើការតស៊ូដើម្បី៖

- ប្រឆាំងរាល់ការជិះជាន់ ឈ្លានពាន គំរាមកំហែង ជ្រៀតជ្រែក ចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសខ្មែរ

- ប្រឆាំងរាល់ឧបាយកល អូសទាញប្រទេសខ្មែរចូលក្នុងអង្គការជិះ ជាន់ណាមួយ អំពើវិទ្ធង្សនាណាមួយ ឬសន្ធិសញ្ញាយោធាណាមួយ ដូចជា អង្គការសេអាតូ ជាដើម

- ប្រឆាំងរាល់ឧបាយកល និងអាកប្បកិរិយារបស់ពួកចក្រពត្តិ ព្រម ទាំងបក្ខពួកវា គណៈបក្សនយោបាយ បក្ខពួកដែលមិនគោរពអធិបតេយ្យ មើលងាយមើលថោក ជាន់ឈ្លីបំផ្លាញកិច្ចព្រមព្រៀងហ្សឺណែវ និង លក្ខណ៍ការណ៍ទាំង ៩ បង្កភាពអន្តរាយ អសន្តិសុខ បង្ករសង្គ្រាមបំផ្លាញ

នូវសន្តិសហវិជ្ជមាន(*)។

ខ្លឹមសារទាំងនេះត្រឹមត្រូវបំផុត និងសមស្របបំផុតចំពោះសភាពការណ៍ និងលទ្ធភាពនៃការភ្ញាក់រលឹករបស់មហាជន។

+ ផ្នែកពុំត្រឹមត្រូវ

- ក្រោយការប្រែទិសពីតស៊ូអាវុធមកតស៊ូនយោបាយ ការស្មុគ្រស្មាញក៏ចាប់មាន។ ស៊ីវ ហេង ដែលជាលេខាបក្សត្រូវចេញសារភាពជាមួយរដ្ឋអំណាច សីហនុ នាចុងឆ្នាំ ១៩៥៨។ ការបង្ក្រាបរបស់ពួកសក្តិភូមិតម្រូវអោយបក្សស្វែងរករូបភាព និងខ្លឹមសារកាន់តែសមស្របដើម្បីតស៊ូ។ ក្នុងពេលនោះដែរ ប៉ុល ពត បានឈានជើងចូលក្នុងក្បាលម៉ាស៊ីនដឹកនាំបក្ស តាមរយៈមហាសន្និបាតតំណាងទូទាំងប្រទេសលើកទី ២ ខែកញ្ញា ១៩៦០ ហើយបានដណ្តើមអំណាចទាំងស្រុង ក្រោយព្រឹត្តិការណ៍ នៃការបាត់ខ្លួនរបស់សមមិត្ត ទូ សាមុត លេខាបក្សនាឆ្នាំ ១៩៦២។

- ក្រោយពេលបានកាន់តំណែងដឹកនាំបក្សអស់មួយរយៈ ប៉ុល ពត បានប្រែក្លាយបក្សពីកត្តាវិជ្ជមានសំរាប់នយោបាយឯករាជ្យ អព្យាក្រឹត្យរបស់រាជរដ្ឋាភិបាល អោយទៅជាកត្តាអវិជ្ជមានសំរាប់ការអនុវត្តន៍នយោបាយនេះ។

- ការក្បត់របស់ ប៉ុល ពត ផ្តើមចេញពីការកំណត់ទំនាស់មិនបានត្រឹមត្រូវ ស្គាល់សត្រូវមិនបានច្បាស់លាស់។ ចេញពីការវាយតម្លៃមិនបានត្រឹមត្រូវនេះ ទើបដាក់ចេញនូវយុទ្ធសាស្ត្រ យុទ្ធវិធី មិនបានត្រឹម

(*) សេចក្តីថ្លែងការណ៍របស់ក្រុមប្រជាជន (ឯកសារតម្កល់នៅគណៈស្រាវជ្រាវប្រវត្តិសាស្ត្របក្សប្រជាជនបដិវត្តកម្ពុជា)។

ត្រូវតាមដំណាក់កាលនីមួយៗ។

– ការក្បត់របស់ ប៉ុល ពត បានបង្ហាញតាមចំណុចមួយចំនួន ដំបូងបង្អស់តាមរយៈការបង្វែរទំនាស់ ពីទំនាស់រវាងប្រជាជាតិកម្ពុជា ជាមួយចក្រពត្តិអាមេរិក ដែលការកិច្ចទាំងនោះតម្រូវអោយគ្រប់កម្លាំងទាំងអស់ចូលរួមយ៉ាងសកម្មក្នុងនយោបាយពង្រឹងឯករាជ្យ អព្យាក្រឹត្យ ទៅជាទំនាស់ជាមូលដ្ឋានជាមួយរដ្ឋអំណាច សីហនុ ហើយជំរុញអោយមានការតស៊ូប្រដាប់អាវុធប្រឆាំងរដ្ឋអំណាច សីហនុ ដែលកំពុងប្រឆាំងចក្រពត្តិអាមេរិកដែរ។ នៅក្នុងព្រឹត្តិការណ៍មួយទៀត ប៉ុល ពត ក៏បានបង្វែរទំនាស់ពីចក្រពត្តិអាមេរិក ទៅជាទំនាស់ជាមួយបារាំង ជំរុញការប្រឆាំងបារាំងមកកម្ពុជាជាលើកទីបី ក្នុងពេលបារាំងគាំទ្រនយោបាយឯករាជ្យ អព្យាក្រឹត្យរបស់កម្ពុជា និងប្រឆាំងការឈ្លានពានរបស់អាមេរិកទៅលើវៀតណាម។

តាមព្រឹត្តិការណ៍នេះ ពួក ប៉ុល ពត បានដាក់ចលនាបដិវត្តអោយស្ថិតនៅឆ្ងាយពីសភាពការណ៍ និងភារកិច្ចរបស់ប្រជាជាតិ កាត់ផ្តាច់ខ្លួនចេញពីនិន្នាការនៃយុគសម័យ ពីសម្ព័ន្ធភាពនៃការតស៊ូរបស់ប្រជាជាតិទាំងបីនៅឥណ្ឌូចិន។ តាមរបៀបធ្វើនេះ ប៉ុល ពត បានដាក់បដិវត្តន៍អោយស្ថិតនៅក្នុងស្ថានភាពឯកោខ្លួន ដោយបោះបង់ចោលទាំងស្រុងនូវការសម្រុះសម្រួល និងសហការជាមួយផ្នែកសកម្មនៃនយោបាយរបស់រាជរដ្ឋាភិបាល និងកម្លាំងផ្សេងទៀត ដើម្បីគោលដៅឯករាជ្យ អព្យាក្រឹត្យ បោះបង់ចោលទាំងស្រុងនូវទីតាំងជំហរស្របច្បាប់ ដែលបក្សបានខិតខំកសាងតាំងពីក្រោយសន្និសីទហ្សឺណែវ ឆ្នាំ

*១៩៥៤ ហើយដំណើរការតស៊ូប្រដាប់អាវុធដោយសម្ងាត់ប្រឆាំងទៅលើរដ្ឋាភិបាល។ ការផ្ដាច់ខ្លួនចេញពីចរន្តជាតិ មិនគ្រាន់តែមិនបានធ្វើអោយបដិវត្តន៍រីកចំរើនឡើងប៉ុណ្ណោះទេ តែធ្វើអោយបាត់បង់អស់នូវសម្ព័ន្ធមិត្ត រុញសម្ព័ន្ធមិត្តអោយចូលជាមួយសត្រូវ ធ្វើអោយកម្លាំងបដិវត្តមានការលំបាក។*

*នៅទីនេះ មិនមានន័យថាជំទាស់នឹងការតស៊ូបដិវត្តនោះឡើយ ប៉ុន្តែការតស៊ូវាទាមទារក្ដាប់ជាប់ និងដោះស្រាយអោយបានត្រឹមត្រូវនូវទំនាស់ ទំនាស់ណាមូលដ្ឋានត្រូវដោះស្រាយមុន ហើយក្នុងដំណាក់កាលនៃទំនាស់នីមួយៗ ត្រូវដោះស្រាយរបៀបណា សហការជាមួយកម្លាំងណា ដើម្បីដោះស្រាយ មិនអាចដោះស្រាយតាមរបៀបឯកោដែលនាំដល់ការចុះខ្សោយនៃកម្លាំងបដិវត្តនោះឡើយ។ ម្យ៉ាងទៀត បដិវត្តន៍ត្រូវមានលក្ខណៈសម្បត្តិ និងឱកាសដើម្បីដណ្ដើមជ័យជំនះ ប្រសិនបើលក្ខណសម្បត្តិ និងឱកាសមិនអនុញ្ញាត ហើយក៏ចេះតែជំរុញមហាជនទាំងល្ងិតល្ងង់ មិនត្រឹមតែមិនអាចសំរេចជ័យជំនះបានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើអោយមហាជនបាត់ជំនឿ ហើយបដិវត្តន៍នឹងត្រូវចុះខ្សោយថែមទៀត។ លក្ខណៈសម្បត្តិទាំងក្នុង និងក្រៅប្រទេស និងឱកាសនាពេលនោះ គឺអនុគ្រោះសំរាប់ការប្រមូលកម្លាំងប្រឆាំងចក្រពត្តិអាមេរិក ពង្រឹងឯករាជ្យ អព្យាក្រឹត្យ។ តាមភាពអនុគ្រោះនេះ គឺផ្ដល់លក្ខណៈសម្បត្តិសំរាប់បដិវត្តន៍ច្បាមយកមហាជនទាំងនៅទីក្រុង ទាំងនៅជនបទ ដោយវិធីប្រើប្រាស់រូបភាពគួបផ្សំតាមចំហស្រប ច្បាប់ផង តាមរូបភាពសម្ងាត់ផង ដើម្បីប្រមូលមហាជន អប់រំមហាជន*

*ម្យ៉ាងដើម្បីបំរើដល់គោលដៅចំពោះមុខ គឺពង្រឹងឯករាជ្យ អព្យាក្រឹត្យ ទាមទារសិទ្ធិប្រជាធិបតេយ្យ កែប្រែជីវភាពប្រជាជន ម្យ៉ាងត្រៀមរៀបចំ លក្ខណៈសម្បត្តិដើម្បីសំរេចគោលដៅខ្ពស់ជាង គឺសំរេចបដិវត្តន៍ប្រជា ជាតិប្រជាធិបតេយ្យ។*

*ជំងឺឆ្វេងនិយមអនុធនរបស់ ប៉ុល ពត បានរួមចំណែកធ្វើអោយប្រែ ក្រឡាស់នូវសម្ព័ន្ធភាពនៅកម្ពុជា គួបផ្សំជាមួយនយោបាយខុសឆ្គងអត្ត ឃាតខ្លួនឯងរបស់ នរោត្តម សីហនុ តុល្យភាពកម្លាំងជុំវិញនយោបាយ ឯករាជ្យ អព្យាក្រឹត្យ ត្រូវបាត់ភាពអំណោយផល ផ្តល់ឧត្តមភាពទាំង ស្រុងអោយពួកស្តាំនិយមបរិវារចក្រពត្តិ បញ្ឆានយោបាយក្នុង និងក្រៅ ប្រទេស។*

*ការតស៊ូប្រដាប់អាវុធ ដែល ប៉ុល ពត បង្កឡើងដើម្បីប្រឆាំងរដ្ឋ អំណាច សីហនុ បានធ្វើអោយសម្ព័ន្ធភាពដែលអាចធ្វើបានជាមួយ សីហនុ និងអ្នកដើរតាម សីហនុ ត្រូវកាត់ផ្តាច់ រុញកម្លាំងដែលអាចធ្វើ សម្ព័ន្ធភាពបានទៅអោយសត្រូវក្តាប់ ហើយសំខាន់បំផុតគឺរុញ សីហនុ អោយសម្រុះសម្រួលជាមួយពួកស្តាំស្និទ្ធអាមេរិក បង្កលទ្ធភាពងាយ ស្រួលអោយអាមេរិក និងបរិវារលុបចោលនូវឯករាជ្យ អព្យាក្រឹត្យ របស់ កម្ពុជា។ ម្យ៉ាងទៀត ការតស៊ូប្រដាប់អាវុធនេះ មិនត្រឹមតែមិនអាចដោះ ស្រាយបានបញ្ហា ប៉ុន្តែបានរុញអោយបដិវត្តន៍កម្ពុជា ប្រឈមមុខទល់ នឹងសភាពការណ៍លំបាកបណ្តាលមកពីរាជរដ្ឋាភិបាល ដែលមានពួក ស្តាំនៅពីក្រោយបង្ក្រាប។ ឯបដិវត្តន៍វៀតណាម ក៏ត្រូវជួបការលំបាកថ្មី បណ្តាលមកពីការចុះខ្សោយនៃនយោបាយសកម្មរបស់ សីហនុ ដែល*

បើកឱកាសអោយអាមេរិក វាយបដិវត្តន៍វៀតណាមពីក្រោយខ្នង។

ទិទៀនអំពើក្បត់របស់ ប៉ុល ពត មិនមានន័យថា បដិវត្តន៍ត្រូវស្ថិតនៅក្នុងស្របច្បាប់និយម គ្មានការប្រើប្រាស់ហឹង្សាបដិវត្តន៍ ហើយនៅមួយកន្លែងនោះទេ។ បដិវត្តន៍ត្រូវតែឈានដល់គោលដៅចុងក្រោយរបស់ខ្លួន គឺរំដោះជាតិ និងវណ្ណៈ។ ប៉ុន្តែ ការលើកឡើងនៅទីនេះសំដៅបង្ហាញអំពីអំពើក្បត់នាំដល់ការខុសឆ្គងខាងយុទ្ធសាស្ត្រ យុទ្ធវិធីបដិវត្តនៃដំណាក់កាលនោះ ដែលជាកត្តាគួបផ្សំមួយរុញកម្ពុជា អោយធ្លាក់ទៅក្នុងការឈ្លានពានរបស់ចក្រពត្តិអាមេរិក តាមរយៈរដ្ឋប្រហារខែ មីនា ១៩៧០។

ទីបួន៖ **កត្តានៃការជ្រៀតជ្រែករបស់ចក្រពត្តិអាមេរិក។**

ការជ្រៀតជ្រែករបស់ចក្រពត្តិអាមេរិក បានប្រព្រឹត្តិទៅដោយគ្មានឈប់ឈរអស់រយៈពេល ២០ ឆ្នាំ (១៩៥០-១៩៧០)។ តាំងពីឆ្នាំ ១៩៥០ អាមេរិកបានត្រៀមរៀបចំលក្ខណៈសម្បត្តិ ដើម្បីចូលជំនួសបារាំង។ ក្រោយឆ្នាំ ១៩៥៤ រហូតមក អាមេរិកបានធ្វើសកម្មភាពយ៉ាងមមាញឹកទាំងនយោបាយ យោធា សេដ្ឋកិច្ចចូលកម្ពុជា ប៉ុនប៉ងបញ្ចូលកម្ពុជាក្នុងរង្វង់ប្រតិបត្តិការរបស់ខ្លួននៅអាស៊ីអាគ្នេយ៍ ពិសេសក្នុងសង្គ្រាមនៅវៀតណាម ប៉ុន្តែនយោបាយជ្រៀតជ្រែករបស់អាមេរិក បានប្រឈមមុខជាមួយកម្លាំងប្រឆាំង ក្នុងនោះមាននយោបាយសកម្មរបស់ នរោត្តម សីហនុផង។ អាមេរិក បានប្រើប្រាស់វិធានការណ៍ជាច្រើន ជាការអូសទាញនិងគាបសង្កត់។ ការគាបសង្កត់បានធ្វើដោយច្រើនរូបភាព ជារូបភាពប្រើប្រាស់កម្លាំងយោធារបស់អាមេរិក របស់រដ្ឋអំណាចសាយហ្គន

បាង៍កក វាយចូលតាមព្រំដែនភាគខាង៍លិច និង៍ភាគខាង៍កើត ជារូបភាពបង្កើតចលនាប្រដាប់អាវុធមានឈ្មោះថា ខ្មែរសេរី នៅតាមព្រំដែនកម្ពុជា-ថៃ កម្ពុជា-វៀតណាម ជារូបភាពប្ងន់អំណាចដោយពួក ដាប ឈួន ឆ្នាំ ១៩៥៩ និង៍ការដាក់គ្រាប់បែកធ្វើគតមហាក្សត្រ ខែ កញ្ញា ឆ្នាំ ១៩៥៩ និង៍ជាវិច្ឆទកម្ម វិទ្ធង្សនាផ្សេង៍ៗ ទៀត ជាច្រើនៗ ប៉ុន្តែ គ្រប់ល្បិចកលរបស់អាមេរិក តាមរយៈការគាបសង្កត់ ពុំមានប្រសិទ្ធភាពប៉ុន្មានឡើយ ប៉ុន្តែវាបានបង្កើតឡើង៍នូវចលនាប្រឆាំង៍អាមេរិកទៅវិញៗ

លទ្ធភាពដែលអាមេរិកអាចធ្វើបាន ហើយមានប្រសិទ្ធភាពគឺតាមរយៈការអូសទាញខាង៍សេដ្ឋកិច្ច ដែលអាមេរិកបានបង្កើតឡើង៍នូវស្រទាប់មូលធននិយម ដែលមានប្រយោជន៍ស្របជាមួយអាមេរិក ដែលពួកនេះបានពង្រីកនូវទីតាំង៍ក្នុង៍សង្គម ពីមួយថ្ងៃទៅមួយថ្ងៃកាន់តែទូលំទូលាយ និង៍ឈានទៅត្រួតត្រានយោបាយរបស់កម្ពុជា ក្រោយពេលដែលសម្ព័ន្ធភាពនៃកម្លាំង៍ប្រឆាំង៍ទល់នឹង៍ការជ្រៀតជ្រែករបស់អាមេរិក ដើម្បីពង្រឹង៍ឯករាជ្យ អព្យាក្រឹត្យ ត្រូវបានចុះខ្សោយ បណ្តាលមកពីនយោបាយអត្តឃាតខ្លួនរបស់ នរោត្តម សីហនុ និង៍អំពើក្បត់របស់ ប៉ុល ពតៗ

ការពង្រីកឥទ្ធិពលរបស់ពួកស្តាំបំផុតក្នុង៍នយោបាយរបស់កម្ពុជា គឺជាលក្ខណៈសម្បត្តិង៍ាយស្រួល សំរាប់ការចូលកម្ពុជារបស់អាមេរិកតាមរយៈរដ្ឋប្រហារ ១៨ មីនា ១៩៧០ៗ

កត្តាទាំង៍បួន បានប្រមូលផ្តុំជាវត្ថុធាតុសំរាប់ការដួលរលំនៃអំណាចរបស់ នរោត្តម សីហនុ ដែលពួកធ្វើរដ្ឋប្រហារបានហៅថា ការបដិវត្តន៍ផ្តួលរំលំរបបរាជានិយមសក្តិភូមិៗ

*គួរលើកមកពិចារណាពីរដ្ឋប្រហារឆ្នាំ ១៩៧០ តើមានលក្ខណៈជាការបដិវត្តន៍ដូចដែលពួក លន់ នល់ បានអោយនិយមន័យឬទេ?*

*ប្រសិនជាមិនលើកមកពិនិត្យនូវសារជាតិដ៏ធំទូលាយ ទាំងទិដ្ឋភាពផ្ទៃក្នុង ទាំងទិដ្ឋភាពអន្តរជាតិនៃរដ្ឋប្រហារ ១៨ មីនា ១៩៧០ គេហាក់ដូចជាបានជឿខ្លះទៅលើការផ្តល់និយមន័យរដ្ឋប្រហារនេះថាជា ការបដិវត្តន៍មួយ ព្រោះវាមានចរិតខ្លះប្រហាក់ប្រហែលជាមួយបដិវត្តន៍ប្រជាធិបតេយ្យនាយទុនបែបចាស់ នៅត្រង់ផ្តួលរំលំរបបរាជានិយម បង្កើតឡើងនូវរបបសាធារណរដ្ឋ ដែលមានចរិតជាការរំដោះវណ្ណៈនាយទុនខាងនយោបាយ បន្ទាប់ពីវណ្ណៈនាយទុនបានពង្រីកទីតាំងខាងនយោបាយ និងសេដ្ឋកិច្ច ក្នុងក្របខ័ណ្ឌនៃរបបសក្តិភូមិ ធ្វើអោយវណ្ណៈនាយទុនក្តាប់បាននូវអំណាច ក្នុងពេលនៅបន្តរក្សាក្បាលម៉ាស៊ីនត្រួតត្រានាហ្មឺននិយមនៃរបបសក្តិភូមិ ដោយមានការកែសម្រួលខ្លះៗ គេអាចមើលឃើញនូវការផ្លាស់ប្តូរជាដំបូងនៅក្នុងមាត្រាទី ១ នៃរដ្ឋធម្មនុញ្ញដែលមុនរដ្ឋប្រហារ ១៩៧០ សរសេរថា "ប្រទេសកម្ពុជា ជាប្រជាជាតិមួយមានព្រះមហាក្សត្រិយ៍សោយរាជ្យ (*)" ប្រែទៅជា "ប្រទេសកម្ពុជាជាសាធារណរដ្ឋឯករាជ្យ ប្រជាធិបតេយ្យ ហើយនិយមប្រយោជន៍សង្គម។ ប្រទេសកម្ពុជាមិនអាចបែងចែកបាន។ ប្រទេសកម្ពុជាមានានាមថា សាធារណរដ្ឋខ្មែរ។ បាវចនារបស់សាធារណរដ្ឋខ្មែរ គឺ សេរីភាព សមភាព ភាតរភាព វឌ្ឍនភាព និងសុភមង្គល។ គោលការណ៍របស់សាធារណរដ្ឋខ្មែរ គឺការគ្រប់គ្រងរបស់ប្រជារាស្ត្រ ដោយប្រជារាស្ត្រ និងដើម្បីប្រ*

(*) រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ក្រោយការកែប្រែឆ្នាំ ១៩៦០។

យោជន៍ប្រជារាស្ត្រ (*)"។ តាមរយៈនេះ មាត្រាដទៃដែលទាក់ទងនឹងបុព្វសិទ្ធរបស់ស្តេច ក៏ត្រូវបានលុបចោល។ ដូច្នេះ ប្រសិនបើមើលមួយជ្រុង គេក៏អាចកំណត់បានថាវាមានខ្លឹមសារបដិវត្តប្រជាធិបតេយ្យនាយទុនបែបចាស់ នៅត្រង់លុបចោលរបបរាជានិយមបង្កើតរបបសាធារណរដ្ឋរបស់វណ្ណៈនាយទុន ដែលផ្តល់ជាកត្តាសកម្មសំរាប់វណ្ណៈនាយទុន។ ប៉ុន្តែ បើពិនិត្យអោយគ្រប់ជ្រុងជ្រោយ រដ្ឋប្រហារ ១៨ មីនា ១៩៧០ គឺជាអំពើក្បត់របស់វណ្ណៈនាយទុនប្រតិកិរិយា ដែលមិនអាចអត់ឱនអោយបាន ព្រោះថារដ្ឋប្រហារនេះ មិនមែនជាការបដិវត្តន៍ដែលត្រូវធ្វើនោះឡើយ ព្រោះវាមិនមែនជាសំណូមពរនៃការផ្លាស់ប្តូរបែបផែនផលិតកម្ម ដែលតម្រូវអោយលុបបំបាត់ចោលនូវបែបផែនផលិតកម្មសក្តិភូមិ បង្កើតឡើងនូវបែបផែនផលិតកម្មមូលធននិយម។ រដ្ឋប្រហារ ១៩៧០ គ្មានការផ្សារភ្ជាប់បន្តិចណាសោះចំពោះសំណូមពរសេដ្ឋកិច្ច សង្គម ព្រោះតាំងពីនរោត្តម សីហនុ បានធ្វើសម្បទានជាលើកចុងក្រោយ អោយពួកស្តាំបង្កើតរដ្ឋាភិបាលស្រោចស្រង់ជាតិ ពួកនេះបានលុបបំបាត់ចោលនូវជាតូបនីយកម្មក្នុងសេដ្ឋកិច្ច ដែលពួកនេះចាត់ទុកថាជាឧបសគ្គរួចទៅហើយ ដែលពួកនាយទុនមានលទ្ធភាពគ្រប់បែបយ៉ាងក្នុងជីវភាពសេដ្ឋកិច្ចនៅកម្ពុជា។ ការផ្តួលរំលំរបបរាជានិយម គ្រាន់តែជាលេសមួយដើម្បីអូសទាញប្រជាជនអោយចូលរួមតែប៉ុណ្ណោះ។ ផ្ទុយទៅវិញ រដ្ឋប្រហារខែមីនា ១៩៧០ គឺជាអំពើបើកទ្វារអោយចក្រពត្តិអាមេរិកចូលមកឈ្លានពានកម្ពុជា ដែលវាស្ថិតនៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់អាមេរិក ក្នុង

(*) រដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ ឆ្នាំ ១៩៧២ (សាធារណរដ្ឋខ្មែរ បានបង្កើតឡើងពីថ្ងៃ ០៩ តុលា ឆ្នាំ ១៩៧០)

សង្គ្រាមនៅឥណ្ឌូចិន។ អំពើក្បត់ដែលប្រើនៅទីនេះ មិនមែនគ្រាន់តែជាអំពើក្បត់ពីសំណាក់ពួកប្រតិកិរិយាស្តាំបំផុត ចំពោះរបបរាជានិយមដែលតំណាងដោយ នរោត្តម សីហនុ នោះឡើយ ប៉ុន្តែវាជាអំពើក្បត់ចំពោះជាតិ ចំពោះប្រជាជន។ គ្មានអ្នកណាស្តាយស្រណោះអ្វីឡើយចំពោះរបបរាជានិយមសក្តិភូមិ ឬ នរោត្តម សីហនុ ប្រសិនជាពួកវណ្ណៈនាយទុនផ្តួលរំលំរបបរាជានិយមនេះ អាស្រ័យដោយសំណូមពរនៃការលុបបំបាត់បែបផែនផលិតកម្មសក្តិភូមិ ហើយរៀបចំទំនាក់ទំនងផលិតកម្មមូលធននិយម ដែលជាទំនាក់ទំនងផលិតកម្មមួយជឿនលឿនជាងទំនាក់ទំនងផលិតកម្មសក្តិភូមិ ដែលវានឹងធ្វើអោយផ្លូវឈានទៅរៀបចំទំនាក់ទំនងផលិតកម្មសង្គមនិយមកាន់តែជិត។ ប៉ុន្តែ ដូចបានរៀបរាប់ខាងលើហើយ រដ្ឋប្រហារខែ មីនា ១៩៧០ គ្មានទំនាក់ទំនងនឹងបញ្ហានេះឡើយ ផ្ទុយទៅវិញរដ្ឋប្រហារនេះ គឺជាដំណើរដាក់កម្ពុជាក្រោមអាណានិគមថ្មីរបស់ចក្រពត្តិអាមេរិក។ ដូច្នេះ កត្តាអន្តរជាតិវាបានដើរតួនាទីគ្របដណ្តប់កត្តាផ្ទៃក្នុង វាជាដំណាក់កាលផ្ទេរកម្ពុជាពីដំណាក់កាលអភិវឌ្ឍន៍ដោយសន្តិភាព ដោយមានការគំរាមកំហែងទៅកាន់ដំណាក់កាលសង្គ្រាមទាំងស្រុង។ ទំនាស់រវាងប្រជាជាតិកម្ពុជាជាមួយចក្រពត្តិអាមេរិក និងបរិវារដែលមានស្រាប់មកហើយ បានក្លាយទៅជាទំនាស់ស្លាប់រស់ដែលត្រូវដោះស្រាយបន្ទាន់។ ដំណាក់កាលថ្មីសំរាប់ការបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ពិសេសភារកិច្ចតស៊ូរំដោះជាតិបានមកដល់។

ផ្នែកទី ៣

# ការតស៊ូរំដោះជាតិ និង ការក្បត់បដិវត្តន៍

*ដូចបានរៀបរាប់ខាងលើ រដ្ឋប្រហារ ១៨ មីនា ១៩៧០ ជាតុពិតគឺជាអន្តរាគមន៍យោធារបស់ចក្រពត្តិអាមេរិក ដើម្បីពង្រីកសមរភូមិនៃយុទ្ធនាការលើទឹកដីឥណ្ឌូចិនទាំងមូល វាជាការបង្កើតឡើងនូវប្រព័ន្ធមូលដ្ឋានយោធាដែលតភ្ជាប់ពីវៀតណាមខាងត្បូង ថៃឡង់ដ៍ កម្ពុជា ឡាវ សំរាប់ប្រតិបត្តិការយោធារបស់ខ្លួន។ ដូច្នេះ ព្រំដែនរបស់រដ្ឋលែងមានន័យអ្វីទៀតសំរាប់ចក្រពត្តិអាមេរិក និងបរិវារ កិច្ចព្រមព្រៀងហ្សឺណែវ ត្រូវបានលុបបំបាត់ ឯករាជ្យ អព្យាក្រឹត្យរបស់កម្ពុជា ត្រូវបានបំផ្លាញចោលទាំងស្រុង។*

*មិនបានប៉ុន្មាន ការវាយលុកខាងយោធារបស់សហរដ្ឋអាមេរិក និងរដ្ឋការសាយហ្គូន បានធ្វើឡើងក្រោមផ្លាក "អន្តរាគមន៍ចាំបាច់ដើម្បីការពារទាហានអាមេរិកនៅវៀតណាម"។ ចក្រពត្តិអាមេរិក បានរង់ចាំឱកាសនេះយូរមកហើយ ដើម្បីវាយបដិវត្តន៍វៀតណាមពីក្រោយខ្នង ព្រោះថាកង់ទ័ពអាមេរិក បានត្រូវជាប់ផុងក្នុងសង្គ្រាមនៅវៀតណាម*

ជាយូរមកហើយ ដូច្នេះមានន័យថា អាមេរិកបានឈ្នានពានប្រទេសមួយរួចទៅហើយ ហើយដើម្បីការពារទាហានអាមេរិកនៅប្រទេសដែលខ្លួនឈ្លានពានទីមួយនោះ អាមេរិកចាំបាច់ត្រូវតែឈ្លានពានប្រទេសទីពីរ គឺកម្ពុជាទៀត។ ក្នុងពេលប្រកាសអំពីមូលហេតុនៃការចេញបញ្ជាអោយទាហានអាមេរិកវាយលុកចូលកម្ពុជា ដើម្បីសង្គ្រោះទាហានអាមេរិកនៅវៀតណាមខាងត្បូង ថ្ងៃ ៣០ មេសា ១៩៧០ និចសុន ប្រធានាធិបតីអាមេរិកក៏បានបង្ហាញផងដែរនូវសុច្ឆន្ទៈចង់បញ្ចប់សង្គ្រាមនៅឥណ្ឌូចិនអោយបានឆាប់។ នេះជាសុច្ឆន្ទៈដ៏ចម្លែករបស់ចក្រពត្តិអាមេរិក ដែលយកហេតុផលនៃការបង្កើតសមរភូមិនៅកម្ពុជាទៅជាការបញ្ចប់សង្គ្រាមនៅវៀតណាមអោយបានឆាប់ទៅវិញ មានន័យថាការបើកទូលាយយុទ្ធនាការទូទាំងឥណ្ឌូចិន បែរជាមិនមែនជាការពង្រីកក្របខ័ណ្ឌនៃសង្គ្រាមទេ តែជាការបំព្រួញក្របខ័ណ្ឌសង្គ្រាមទៅវិញ។

ក្រោយរដ្ឋប្រហារខែ មីនា ១៩៧០ និងក្រោយពេលអាមេរិកនាំកងទ័ព ទាំងកងទ័ពអាមេរិក ទាំងកងទ័ពរដ្ឋការសាយហ្គន ចូលមកកម្ពុជា សភាពការណ៍មានការផ្លាស់ប្តូរឆាប់រហ័ស និងក្រឡាប់ចាក់នៅទូទាំងប្រទេស ទីណាក៏ត្រូវចូលក្នុងភ្នក់ភ្លើងសង្គ្រាមទាំងអស់។ ទោះបីអាមេរិកបានដកកងទ័ពជើងដើងចេញពីកម្ពុជា នាខែ កក្កដា ១៩៧០ ក៏ដោយក៏អាមេរិកនៅតែបន្តសង្គ្រាមតាមផ្លូវអាកាស រហូតដល់ខែ សីហា ១៩៧៣។ កងទ័ពសាយហ្គន បានបន្តជួយពួក លន់ នល់ ក្នុងការកាប់សម្លាប់ប្រជាជនកម្ពុជាតទៅទៀត។ ទោះជាត្រូវបានដកកងទ័ពចេញ

ប៉ុន្តែអាមេរិកនៅតែបន្តផ្តល់ជំនួយយោធា និងហិរញ្ញវត្ថុ ការទ្រទ្រង់គ្រប់បែបយ៉ាងដល់រដ្ឋការ លន់ នល់ ក្នុងដំណើរការខ្សែបនីយកម្មសង្គ្រាមនៅកម្ពុជា រហូតពេលរបបនេះត្រូវដួលរលំ។ រដ្ឋប្រហារខែ មីនា ១៩៧០ និងការចូលឈ្លានពានដោយផ្ទាល់របស់ចក្រពត្តិអាមេរិក បានដាក់អោយបដិវត្តន៍កម្ពុជា និងប្រជាជាតិកម្ពុជា ស្ថិតក្នុងដំណាក់កាលថ្មី សំរាប់ការបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ពិសេសវាមានលក្ខណៈសម្បត្តិថ្មីសំរាប់ការប្រមូលផ្តុំកម្លាំង តស៊ូប្រឆាំងចក្រពត្តិអាមេរិកដើម្បីរំដោះជាតិ។ គេអាចសន្និដ្ឋានបានថា កម្លាំងបដិវត្ត និងស្នេហាជាតិ មានជំហានរីកចំរើនដោយលោតផ្លោះ នៅក្នុងរយៈពេលនោះ អាស្រ័យដោយលក្ខណៈសម្បត្តិអន្តរជាតិ និងលក្ខណៈសម្បត្តិផ្ទៃក្នុងអនុគ្រោះ។

លក្ខណៈសម្បត្តិអន្តរជាតិអនុគ្រោះនៅពេលនោះ គឺសហភាពសូវៀត និងបណ្តាប្រទេសសង្គមនិយម បានក្លាយទៅជាកត្តាដ៏សំខាន់កំណត់ការរីកចំរើននៃយុគសម័យ ជាកម្លាំងសំខាន់បំផុត ផ្តល់ការគាំទ្រចំពោះការតស៊ូរំដោះប្រជាជាតិនៅគ្រប់ទ្វីបនៃសកលលោក។ ចលនារំដោះប្រជាជាតិ និងការពារឯករាជ្យជាតិ ស្ថិតក្នុងភាពវាយសំរុក។ ចលនាតស៊ូរបស់វណ្ណៈកម្មករ និងប្រជាពលករក្នុងប្រទេសចក្រពត្តិមូលធននិយមដើម្បីសន្តិភាព ប្រឆាំងការឈ្លានពាន ទាមទារសិទ្ធសេរីភាព រីកចំរើនខ្ពស់។ វិបត្តិសេដ្ឋកិច្ចរបស់អាមេរិក និងប្រទេសមូលធនផ្សេងទៀត បានកើតឡើងចំពេលដែលសហភាពសូវៀត និងប្រទេសសង្គមនិយមពង្រឹងនូវប្រៀប និងកម្លាំងរបស់ខ្លួន បង្កើតបាននូវតុល្យ

ភាពខាងយុទ្ធសាស្ត្រ និងក្នុងក្របខ័ណ្ឌអឺរ៉ុប និងនៅតំបន់ផ្សេងទៀតលើពិភពលោក។ ការជាប់ផុងរបស់អាមេរិកក្នុងសង្គ្រាមនៅវៀតណាម ទំនាស់ផ្ទៃក្នុងរបស់អាមេរិក និងសម្ព័ន្ធមិត្តប៉ែកខាងលិច ជុំវិញការឈ្លានពានរបស់អាមេរិកលើវៀតណាម កម្ពុជា ឡាវ បានឡើងដល់កំរិតខ្ពស់។ ការប្រឆាំងការឈ្លានពាន និងការផ្តល់ការគាំទ្រ ចំពោះប្រជាជនវៀតណាមប្រឆាំងអាមេរិក បានកើតមានជាយូរមកហើយ ពីសំណាក់ប្រជាជនអាមេរិក ពីសំណាក់ប្រជាជននៅបណ្តាប្រទេសគ្រប់ទិសទីលើសកលលោក ហើយបានរីកចំរើនមួយកំរិតថែមទៀត ពេលអាមេរិកចូលឈ្លានពានឡាវ និងកម្ពុជា។ ជោគជ័យរបស់ប្រជាជនវៀតណាម ក្នុងការប្រឆាំងអាមេរិក បានបង្កើតឡើងនូវតុល្យភាពកម្លាំង ដែលអនុគ្រោះសំរាប់ការតស៊ូរបស់ប្រជាជាតិទាំង ៣ នៅឥណ្ឌូចិន។ កត្តាអនុគ្រោះបំផុត ដែលជះឥទ្ធិពលផ្ទាល់ដល់ជ័យជំនះរបស់បដិវត្តន៍កម្ពុជា គឺសម្ព័ន្ធភាពតស៊ូរបស់ប្រជាជនកម្ពុជា វៀតណាម ឡាវ ដែលបានរួមគ្នាក្នុងរណសិរ្សប្រឆាំងការឈ្លានពានអាមេរិក។

សម្ព័ន្ធភាពតស៊ូរបស់ប្រទេសទាំងបីនៅឥណ្ឌូចិន មានការប្រែប្រួលរីកចំរើនក្នុងជំហានលោតផ្លោះ តាមរយៈសេចក្តីប្រកាសរួមនៃសន្និសីទកំពូលចតុភាគីនៃប្រទេសនៅឥណ្ឌូចិន ថ្ងៃ ២៤-២៥ មេសា ១៩៧០។ សេចក្តីប្រកាសរួមនេះ បានបង្កើតឡើងនូវមូលដ្ឋានស្របច្បាប់សំរាប់សម្របសម្រួលការប្រឹងប្រែង និងការជួយគ្នាទៅវិញទៅមកក្នុងសង្គ្រាមប្រឆាំងចក្រពត្តិអាមេរិក។ តាមរយៈសេចក្តីប្រកាសរួមនេះ សម្ព័ន្ធភាពនៃការតស៊ូរបស់ប្រទេសនៅឥណ្ឌូចិន មានការប្រែប្រួលយ៉ាងសំខាន់អំ

*ពីគុណភាពដោយបានផ្ទេរពីការគាំទ្រគ្នាខាងនយោបាយ និងការទូតទៅជាការជួយគ្នាខាងនយោបាយ យោធា ការទូត និងសម្ភារៈ។ ការជួយខាងយោធារបស់បដិវត្តន៍វៀតណាម បានរាំងស្កាត់ដោយមានប្រសិទ្ធភាពនូវការវាយលុករបស់កងទ័ពអាមេរិក និងបរិវារ មកលើប្រជាជនកម្ពុជា បង្កើតបាននូវតំបន់រំដោះដ៏ធំល្វឹងល្វើយ ផ្តល់លទ្ធភាព សំរាប់ការបង្កើតឡើងនូវរដ្ឋអំណាចប្រជាជន និងការកសាងកម្លាំងប្រដាប់អាវុធបដិវត្តកម្ពុជា។ ក៏តាមរយៈនៃសេចក្តីប្រកាសរួមនៃសន្និសីទកំពូលនេះដែរ រណសិរ្សអន្តរជាតិប្រឆាំងអាមេរិក ត្រូវបានបើកទូលាយ ធ្វើអោយសម្ព័ន្ធភាពជុំវិញសង្គ្រាមនៅឥណ្ឌូចិន មានការផ្លាស់ប្តូរយ៉ាងជ្រាលជ្រៅ រុញចក្រពត្តិអាមេរិក និងបរិវារអោយធ្លាក់ក្នុងភាពខ្សោយនិងឯកោយ៉ាងខ្លាំង។ ការគាំទ្ររបស់ប្រជាជននៅបណ្តាប្រទេសលើសកលលោក បានក្លាយទៅជាចរន្តអន្តរជាតិមួយមានអត្ថន័យយ៉ាងសំខាន់ ដល់ការតស៊ូប្រឆាំងចក្រពត្តិអាមេរិករបស់បណ្តាប្រជាជាតិនៅឥណ្ឌូចិន។*

*សម្ព័ន្ធភាពរបស់ប្រជាជននៃប្រទេសទាំងបីនៅឥណ្ឌូចិន នាឆ្នាំ ១៩៧០ មានចរិតប្លែក ពីសម្ព័ន្ធភាពកាលពីដំណាក់កាលតស៊ូប្រឆាំងអាណានិគមបារាំង នៅត្រង់ពេលនេះ នរោត្តម សីហនុ និងអ្នកដើរតាមគាត់នៅពេលនោះ បានមកចូលរួមក្នុងសម្ព័ន្ធភាពនេះ។ ប្រការនេះ កាន់តែបញ្ជាក់ច្បាស់អំពីចរិតចាប់បង្ខំ និងចរិតស្ម័គ្រចិត្ត ដែលមានលក្ខណៈយុទ្ធសាស្ត្រយូរអង្វែង នៃសម្ព័ន្ធភាពរវាងប្រទេសទាំងបីនៅឥណ្ឌូចិន (ដែលសៀវភៅនេះបានលើកឡើងក្នុងចំណុចទី ១ តូច)។*

ទោះបី នរោត្តម សីហនុ ធ្លាប់បានចូលរួមក្នុងសម្ព័ន្ធភាពរបស់វណ្ណៈជិះជាន់ក្រោមចំណុះបារាំង ដើម្បីប្រឆាំងការតស៊ូរបស់ប្រជាជននៅឥណ្ឌូចិន ប៉ុន្តែពេលនេះ ផលប្រយោជន៍តម្រូវអោយគាត់ត្រូវតែមានសម្ព័ន្ធភាពជាមួយចលនាតស៊ូរបស់ប្រជាជនទាំងនៅកម្ពុជា ទាំងជាមួយវៀតណាម ទាំងជាមួយឡាវ ដើម្បីដោះស្រាយទំនាស់ជាមួយចក្រពត្តិអាមេរិក។ និយាយពីការចូលរួមក្នុងសម្ព័ន្ធភាពតស៊ូរបស់ប្រជាជាតិនៅឥណ្ឌូចិនរបស់ នរោត្តម សីហនុ ដែលជាវណ្ណៈសក្តិភូមិ មិនមានន័យថាបដិសេធចោលនូវ <u>ចរិតវណ្ណៈនៃសម្ព័ន្ធភាព</u> ដែលបានលើកឡើងនៅក្នុងសៀវភៅនេះទេ។ <u>ចរិតវណ្ណៈនៃសម្ព័ន្ធភាពនៅតែបានរក្សា អាស្រ័យដោយពួកវណ្ណៈត្រួតត្រារដ្ឋ នៅកម្ពុជា វៀតណាមខាងត្បូង ឡាវ នៅតែបន្តធ្វើសម្ព័ន្ធភាពជាមួយគ្នា ដើម្បីប្រឆាំងចលនាតស៊ូរបស់ប្រជាជន</u>។ ឯ នរោត្តម សីហនុ និងអ្នកដើរតាមគាត់ ទោះជាមានវណ្ណៈដើមជាសក្តិភូមិ ជានាយទុន ឬអភិជន ក៏បានក្លាយទៅជាជនរងគ្រោះ មិនស្ថិតនៅជាមនុស្សដែលត្រួតត្រារដ្ឋតទៅទៀតឡើយ។ មូលដ្ឋានសេដ្ឋកិច្ចសង្គមរបស់គាត់ត្រូវបានផ្សារភ្ជាប់ជាមួយនឹងការតស៊ូរបស់ប្រជាជន ហើយដើម្បីដោះស្រាយទំនាស់ជាមួយចក្រពត្តិអាមេរិក ដើម្បីសង្គ្រោះជាតិ គាត់គ្មានការជ្រើសរើសណាផ្សេង ក្រៅពីធ្វើសម្ព័ន្ធភាពជាមួយចលនាតស៊ូរបស់វៀតណាម ឡាវឡើយ។

ចំពោះលក្ខណៈសម្បត្តិផ្ទៃក្នុងវិញ អាចនិយាយបានថា កម្លាំងបដិវត្តកម្ពុជាបានរីកចំរើនក្នុង <u>ជំហានលោតផ្លោះ</u> នៅត្រង់ថាការឈ្លានពានរបស់ចក្រពត្តិអាមេរិក បានប៉ះពាល់ចំពោះផលប្រយោជន៍គ្រប់ស្រទាប់វណ្ណៈ

និងគ្រប់ជនជាតិនៅកម្ពុជា តម្រូវអោយមានសម្ព័ន្ធភាពគ្រប់កម្លាំងទាំងអស់ ដើម្បីប្រឆាំងការឈ្លានពានរបស់ចក្រពត្តិអាមេរិក។ ទំនាស់ប្រជាជាតិបានលេចឡើងច្បាស់ចំពោះមុខប្រជាជនកម្ពុជា ដែលទំនាស់នេះបានស្ថិតនៅក្រោមរូបភាពលាក់កំបាំងអស់រយៈពេល ១៦ ឆ្នាំ (១៩៥៤-១៩៧០)។ ការលេចឡើងច្បាស់នូវទំនាស់នេះ បានបង្កលក្ខណៈសម្បត្តិអនុគ្រោះសំរាប់បដិវត្តន៍ ប្រមូលផ្តុំកម្លាំងដំណើរការបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យងាយស្រួលជាងមុន។

អាស្រ័យដោយរដ្ឋប្រហារខែ មីនា ១៩៧០ និងការឈ្លានពានរបស់អាមេរិក បានធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍របស់ នរោត្តម សីហនុ និងអ្នកជុំវិញគាត់ ក៏ដូចជាប្រជាជនកម្ពុជាទូទៅ គួបផ្សំនឹងចលនាបដិវត្តក្រោមការដឹកនាំរបស់បក្សមានស្រេចមកហើយ អាចនិយាយបានថាជាការផ្ទុះឡើងនូវចលនាតស៊ូរំដោះជាតិដែលមានចរិតប្រជាធិបតេយ្យ។ សម្ព័ន្ធភាពនៃអ្នកដែលធ្លាប់ធ្វើសត្រូវនឹងគ្នា ហើយមានផលប្រយោជន៍យូរអង្វែងខុសគ្នា បានកើតមានឡើងក្រោមរណសិរ្សរួបរួមជាតិមួយ ដឹកនាំដោយ នរោត្តម សីហនុ និងឥស្សរជនសំខាន់ៗជាអ្នកដើរតាម សីហនុ និងឥស្សរជនដែលធ្លាប់បានរួមក្នុងចលនាតស៊ូបដិវត្តប្រឆាំងបារាំង និងអាមេរិក។ អាស្រ័យដោយរូបភាពនៃសម្ព័ន្ធភាពក្នុងរណសិរ្សរួបរួមជាតិ និងរដ្ឋាភិបាលរួបរួមជាតិ ព្រមទាំងគោលការណ៍ត្រឹមត្រូវនៃរណសិរ្ស និងរដ្ឋាភិបាលនេះ គួបផ្សំដោយកម្លាំងបដិវត្តជាស្នូលដឹកនាំសំខាន់នៅក្នុងប្រទេស និងការជួយឧបត្ថម្ភទាន់ពេលវេលារបស់បដិវត្តន៍វៀតណាម ចលនាតស៊ូបានរីកចំរើនមានចរិត

*លោតផ្លោះ។ នេះជាដំណាក់កាលផ្ទេរបដិវត្តន៍ពីភាពឯកោ និងការពារខ្លួន មកកាន់ដំណាក់កាលពង្រីកតួនាទីក្នុងមហាជននៅទូទាំងតំបន់រំដោះ និងពង្រីកឥទ្ធិពលក្នុងតំបន់រដ្ឋការ លន់ នល់ កាន់កាប់ ហើយស្ថិតក្នុងភាពវាយសំរុក រហូតដល់ការបញ្ចប់ការឈ្លានពានរបស់អាមេរិក និងរបប លន់ នល់ នាថ្ងៃ ១៧ មេសា ១៩៧៥។*

*ជាមួយនឹងការរីកចំរើននៃកម្លាំងបដិវត្ត អំពើក្បត់បដិវត្តន៍ក៏បានធ្វើដំណើរភ្ជាប់ខ្លួនជាមួយដែរ។ ការបដិវត្តន៍ និងក្បត់បដិវត្តន៍ បានស្ថិតស្ថេរជាមួយគ្នានៅក្នុងអង្គធាតុរួមមួយ។ នេះគឺជាបញ្ហាដ៏ស្មុគស្មាញបំផុត ក្នុងដំណើរការបដិវត្តន៍កម្ពុជា ពិសេសក្នុងចន្លោះឆ្នាំ ១៩៥៤-១៩៧៥។ វាខុសពីមុនឆ្នាំ ១៩៥៤ ដែលមានក្រុមក្បត់ជាច្រើនយកនាមជាចលនាតស៊ូប្រឆាំងបារាំង ពេលនោះកម្លាំងបដិវត្តក៏ដូចជាប្រជាជនងាយនឹងពិនិត្យឃើញ អាស្រ័យដោយក្រុមក្បត់ទាំងនោះមានអង្គការចាត់តាំងដាច់ដោយឡែក ពីអង្គការចាត់តាំងបដិវត្ត។ ប៉ុន្តែ ក្រោយឆ្នាំ ១៩៥៤ ពិសេសក្រោយពេល ប៉ុល ពត ចូលបានក្នុងអង្គការដឹកនាំ និងដណ្តើមបានតួនាទីដឹកនាំខ្ពស់បំផុត (១៩៦០-១៩៦២) ទាំងកម្លាំងបដិវត្ត ទាំងប្រជាជនពិបាកនឹងមើលឃើញនូវអំពើក្បត់របស់ពួកនេះ អាស្រ័យដោយវាស្ថិតនៅក្នុងអង្គការចាត់តាំងបដិវត្តដែរ។*

*ដូចបានរៀបរាប់ក្នុងចំណុចទីពីរតូចនៃសៀវភៅនេះ បង្ហាញអោយឃើញពីអំពើក្បត់របស់ក្រុមនិយមឆ្វេងជ្រុល ដែលដឹកនាំដោយ ប៉ុល ពត។ ក្រុមនេះ ជានិច្ចកាលបានខិតខំផ្តាច់ចលនាបដិវត្តពីចរន្តជាតិ និងអន្តរជាតិ បង្កអោយមានគ្រោះមហន្តរាយយ៉ាងធ្ងន់ធ្ងរចំពោះបដិវត្តន៍។*

ប្រសិនជាពិនិត្យពួក ប៉ុល ពត នៅតាមដំណាក់កាលនីមួយៗ គេអាចសន្និដ្ឋានថា ពួកនេះមានការខុសឆ្គងខាងគោលការណ៍ និងសកម្មភាពក្នុងក្របខ័ណ្ឌបដិវត្ត ប៉ុន្តែប្រសិនបើពិនិត្យដោយផ្សារភ្ជាប់ដំណាក់កាលតស៊ូទាំងអស់បញ្ចូលគ្នា គេអាចសន្និដ្ឋានបានថា នេះជាអំពើក្បត់បដិវត្តន៍ទាំងស្រុង វាគ្រាន់តែអំពើក្បត់នេះអនុវត្តដោយវិធីឆ្លៀតប្រើប្រាស់កម្លាំងបដិវត្ត ដើម្បីដណ្តើមអំណាចសំរាប់ពួកគេតែប៉ុណ្ណោះ។ ដូចនេះ មិនអាចប្រើពាក្យ "ខុសឆ្គង" ជំនួសពាក្យ "ក្បត់" បានឡើយ។

ការផ្តាច់ខ្លួនចេញពីចរន្តជាតិ និងអន្តរជាតិ បានជំរុញពួក ប៉ុល ពត អោយបង្វែរទិសពីការធ្វើសម្ព័ន្ធភាពជាមួយកម្លាំងជាតិទាំងមូល ដើម្បីអនុវត្តមាគ៌ាឯករាជ្យ អព្យាក្រឹត្យ ប្រឆាំងការជ្រៀតជ្រែកឈ្លានពានរបស់ចក្រពត្តិអាមេរិក ដែលបក្សប្រជាជនបដិវត្តន៍ខ្មែរ និងក្រុមប្រជាជនបានអនុវត្ត ទៅជាការធ្វើសកម្មភាពប្រដាប់អាវុធប្រឆាំងរដ្ឋអំណាច សីហនុ ក្នុងពេលដែលរដ្ឋអំណាចនេះកំពុងប្រឆាំងចក្រពត្តិអាមេរិកមុនឆ្នាំ ១៩៧០ ដែលធ្វើអោយចុះខ្សោយដល់សម្ព័ន្ធភាពប្រឆាំងចក្រពត្តិ បង្កើតជាលេសខាងនយោបាយសំរាប់ពួកចក្រពត្តិ និងពួកប្រតិកិរិយាខាងស្តាំ បង្ក្រាបការតស៊ូរបស់បដិវត្តន៍ និងឈ្លានពានកម្ពុជា។ ក្រុមក្បត់ ប៉ុល ពត ដែលមានមូលដ្ឋានសតិអារម្មណ៍ឆ្វេងជ្រុល គ្មានបានផ្សារភ្ជាប់ខ្លួនបន្តិចណាសោះ ចំពោះផលប្រយោជន៍ជាតិដែលកំពុងត្រូវការគ្រប់កម្លាំង ដើម្បីការពារ ហើយក៏គ្មានបានផ្សារភ្ជាប់អ្វីបន្តិចណាសោះ ជាមួយយុទ្ធសាស្ត្ររួមនៃចលនាតស៊ូរបស់ប្រជាជនលើសកលលោក ពិសេសប្រទេសទាំងបីនៅឥណ្ឌូចិន ក្នុងការប្រឆាំងចក្រពត្តិអា

*មេរិក។ គេធ្វើសកម្មភាពតាមរបៀបបញ្ជូនកម្លាំងបដិវត្តអោយស្ថិតក្នុងភាពឯកោពីប្រជាជន និងចលនាខាងក្រៅ។*

*លើកឡើងបញ្ហានេះ នឹងអាចចោទឡើងនូវសំណួរថា បើ ប៉ុល ពត ក្បត់ ហេតុអ្វីក៏មានប្រជាជនចូលរួមតស៊ូ ហើយដណ្តើមបានជ័យជំនះនាខែ មេសា ១៩៧៥? ដើម្បីឆ្លើយតបនឹងសំណួរនេះអោយបានត្រឹមត្រូវ គប្បីពិនិត្យដោយមានខ្សែរយៈ នូវដំណើរវិវត្តន៍ប្រែប្រួលនៃកម្លាំងបដិវត្តកម្ពុជា ហើយអាចដាក់ចេញនូវចម្លើយមួយចំនួន៖*

***ទីមួយ៖*** *មាគ៌ារបស់បក្សប្រជាជនបដិវត្តខ្មែរ បានក្លាយទៅជាផែនគ្រឹះនៃសកម្មភាពរបស់កម្លាំងតស៊ូអស់រយៈពេលដ៏យូរ។ កម្មាភិបាលបដិវត្តភាគច្រើនបានដើរតាមមាគ៌ានេះ។ ដូច្នេះ ពេលក្រុមរបស់ ប៉ុល ពត ក្តាប់បានអំណាចដឹកនាំបក្ស ក៏ពួកនេះគ្មានលទ្ធភាពនឹងកែប្រែមាគ៌ាបក្សទាំងស្រុងបានភ្លាមដែរ ពេលបានកែប្រែហើយ ក៏គ្មានលទ្ធភាពនឹងដឹកនាំអនុវត្តបានទាំងស្រុងដែរ។ កម្មាភិបាល បក្ខជនល្អ របស់បក្ស ទាំងនៅក្នុងប្រទេស ទាំងមកពីវៀតណាម នៅតែជាស្នូលដឹកនាំសំខាន់នៅតាមតំបន់នានា ប្រមូលផ្តុំមហាជនបង្កើតបានជាចលនាដ៏ខ្លាំងសម្បើមក្រោយខែ មីនា ឆ្នាំ ១៩៧០។ ម្យ៉ាងទៀត ទោះបី ប៉ុល ពត ដណ្តើមបានតួនាទីដឹកនាំបក្ស ក៏ពួកនេះមិនបានចេញមុខ ចេញឈ្មោះជាចំហ រហូតដល់ពេលដណ្តើមបានរដ្ឋអំណាចទាំងស្រុង អាស្រ័យហេតុនេះ កម្មាភិបាល បក្ខជន និងប្រជាជនភាគច្រើន នៅតែយល់ច្រឡំថា បក្សនៅតែដឹកនាំដោយមគ្គុទេសក៏ចាស់ៗ ដូចជា ទូ សាមុត សឺង ង៉ុកមិញ ជាដើម។ ឯបក្សកុម្មុយនិស្តទៀតសោត ក៏ទើបចេញមុខ*

*នាខែកញ្ញា ឆ្នាំ ១៩៧៧ ក្នុងខួបលើកទី ១៧ (ឆ្នាំ ១៩៦០-១៩៧៧) គឺក្រោយរយៈពេលពីរឆ្នាំនៃការក្តាប់រដ្ឋអំណាចរបស់ ប៉ុល ពត។*

*__ទីពីរ__៖ រណសិរ្សរួបរួមជាតិ ដែលមានការចូលរួមរបស់ នរោត្តម សីហនុ និងស្រទាប់ផ្សេងទៀត ក៏ជាកត្តាដ៏សំខាន់ក្នុងការប្រមូលកម្លាំងប្រជាជនតស៊ូប្រឆាំងចក្រពត្តិអាមេរិក ហើយគោលនយោបាយរណសិរ្សដែលបានផ្សព្វផ្សាយយ៉ាងទូលំទូលាយនេះ ក៏ជារបាំងមួយទប់ល្បឿននៃមនោគមវិជ្ជារបស់ ប៉ុល ពត មិនអោយពង្រីកឆាប់ពេកនៅក្នុងកម្លាំងបដិវត្ត និងប្រជាជន បន្ថែមទៅដោយការប្រឆាំងជំទាស់ពីសំណាក់កម្មាភិបាលបដិវត្តនៅតាមតំបន់ជាច្រើនចំពោះមាគ៌ា ប៉ុល ពត។*

*__ទីបី__៖ ការជួយឧបត្ថមរបស់បដិវត្តន៍វៀតណាមជាកត្តាសំខាន់ក្នុងការបង្កើត និងពង្រីកតំបន់រំដោះ បង្កើតឡើងនូវរដ្ឋអំណាច និងកម្លាំងប្រដាប់អាវុធ និងជាមូលដ្ឋានអោយការសំរេចជ័យជំនះ។*

*__ទីបួន__៖ ការឧបត្ថម្ភគាំទ្រ ពីសំណាក់ប្រជាជនលើសកលលោកចំពោះការតស៊ូរបស់ប្រជាជនកម្ពុជា។*

*__ទីប្រាំ__៖ ការដណ្តើមអំណាច គឺជាសំណួមពរសំខាន់បំផុតរបស់ពួកក្បត់ ប៉ុល ពត ដូច្នេះ ពួកនេះក៏ត្រូវការប្រើប្រាស់កម្លាំងរបស់បដិវត្តន៍កម្ពុជាក៏ដូចជាការជួយឧបត្ថម្ភរបស់បដិវត្តន៍វៀតណាម ដើម្បីដណ្តើមអំណាច។ ពួក ប៉ុល ពត មានផលប្រយោជន៍ក្នុងការសម្របខ្លួនតាមមាគ៌ាប្រឆាំងចក្រពត្តិអាមេរិក និងបរិវារ ដើម្បីដណ្តើមអំណាច អាស្រ័យដោយស្រេកឃ្លានអំណាច ទើបធ្វើការសម្របខ្លួន។ ប្រការនេះ អាចធ្វើការប្រៀបធៀបបានអំពី ប៉ុល ពត ប្រែទិសពីការប្រឆាំងចក្រពត្តិអាមេរិក*

*មកប្រឆាំងរដ្ឋអំណាច សីហនុ មុនឆ្នាំ ១៩៧០ និងការដែល ប៉ុល ពត ព្រមសម្របខ្លួនក្នុងមាគ៌ាប្រឆាំងចក្រពត្តិ ក្រោយឆ្នាំ ១៩៧០ ពីព្រោះទាំងមាគ៌ាបក្ស ក៏ដូចជាមាគ៌ារណសិរ្ស សុទ្ធតែបានកំណត់ថា ត្រូវវាយបណ្តេញការឈ្លានពានរបស់ចក្រពត្តិអាមេរិក និងផ្តួលរំលំរបប លន់ នល់។ ដូច្នេះ ការប្រើប្រាស់កម្លាំងបដិវត្តដើម្បីសំរេចគោលដៅទាំងពីរនេះ គឺជាការចាំបាច់សំរាប់ការដណ្តើមអំណាចរបស់ពួក ប៉ុល ពត។ ខុសគ្នានឹងមុនឆ្នាំ ១៩៧០ ដែលត្រូវតស៊ូប្រឆាំងអាមេរិក តែត្រូវពង្រឹងឯករាជ្យ អព្យាក្រឹត្យតាមរយៈការរក្សារបបគ្រប់គ្រងរបស់ សីហនុ។ ដើម្បីដណ្តើមបានអំណាចទាំងស្រុង អនុវត្តមាគ៌ារបស់ខ្លួនទាំងស្រុង ប៉ុល ពត បានអនុវត្តយុទ្ធវិធី "**សាមគ្គីផង និងកំចាត់ផង**" ពោលគឺវាមិនស្ថិតនៅក្នុងក្របខ័ណ្ឌនៃមាគ៌ាសាមគ្គីផង តស៊ូផង ដែលជាទម្លាប់របស់រណសិរ្សដែលមានការចូលរួមពីគ្រប់ស្រទាប់វណ្ណៈនោះទេ។ ដំណើរការសាមគ្គីផង កំចាត់ផង របស់ពួក ប៉ុល ពត បានអនុវត្តជាប្រចាំ ហើយស្របគ្នានឹងការកសាងមូលដ្ឋានរបស់ពួកនេះ ក្នុងកម្លាំងបដិវត្ត និងប្រជាជនផង។*

*<u>ការសាមគ្គី</u>៖ ប៉ុល ពត បានឆ្លៀតប្រើប្រាស់យ៉ាងសកម្មនូវចលនាតស៊ូរបស់ប្រជាជន នូវជួរកម្មាភិបាលបដិវត្ត នូវរណសិរ្សរួបរួមជាតិ នូវការជួយឧបត្ថម្ភរបស់វៀតណាម ដើម្បីឈានទៅដណ្តើមអំណាច។*

*<u>ការកំចាត់</u>៖ ត្រូវបានដំណើរការក្លាមនៅតំបន់ដែលរំដោះបានដំបូង បានធ្វើចំពោះអ្នកជាប់និន្នាការនយោបាយរបបមុន ក្នុងប្រជាជន អ្នករដ្ឋការ ឬទាហាន ប៉ូលីស នៃរបបចាស់ ទោះបីអ្នកទាំងនោះបានចូលរួមយ៉ាងសកម្មក្នុងចលនាតស៊ូបដិវត្ត ឬលើកដៃចុះចូលជាមួយបដិវត្តន៍*

ក៏ដោយ។ នាយទាហាន ពលទាហាន និងមន្ត្រីស៊ីវិលជាច្រើន ដែលបានចុះចូលជាមួយបដិវត្តន៍ ត្រូវបានសម្លាប់។ ប្រការនេះ មានឥទ្ធិពលអាក្រក់យ៉ាងខ្លាំង ចំពោះការអនុវត្តគោលនយោបាយរណសិរ្សប្រមូលកម្លាំង ដើម្បីប្រឆាំងចក្រពត្តិអាមេរិក ជំរុញអោយប្រជាជនមួយចំនួនត្រូវរត់ចូលតំបន់ លន់ នល់ កាន់កាប់ ពង្រឹងស្មារតីទាហាន លន់ នល់ អោយប្រយុទ្ធដោយគ្មានការសារភាពចុះចូល ដែលតម្រូវអោយកម្លាំងបដិវត្តត្រូវចំណាយសាច់ឈាម អាយុជិវិត សំភារៈច្រើន ទើបដណ្តើមបានជ័យជំនះក្នុងការប្រយុទ្ធ។ កសាង និងពង្រីកបានឥទ្ធិពលរបស់ខ្លួននៅក្នុងបក្ស ក្នុងកងទ័ព ក្នុងរដ្ឋអំណាច បានកាន់តែច្រើន ពួក ប៉ុល ពត ដំណើរការកំចាត់កាន់តែខ្លាំង។ ចេញដំណើរពីការកំចាត់ចំពោះប្រជាជន នាយទាហាន ពលទាហាន មន្ត្រីនៃរបប សីហនុ របប លន់ នល់ ប៉ុល ពត បានដំណើរការយ៉ាងសកម្មក្នុងការកំចាត់កម្លាំងបដិវត្តន៍តាមរបស់ដែលហៅថា "**ការតស៊ូវណ្ណៈ និងកំចាត់ឥទ្ធិពលបរទេស**"។ ផ្អែកលើការតស៊ូវណ្ណៈ ពួកគេដំណើរការឃោសនាយ៉ាងចំហប្រឆាំងសក្តិភូមិ នាយទុន ដែលតម្រង់មុខព្រួញទៅលើ នរោត្តម សីហនុ និងឥស្សរជនផ្សេងទៀតក្នុងរណសិរ្សរួបរួមជាតិ និងរដ្ឋាភិបាលរួបរួមកម្ពុជា។ របស់ដែលហៅថា ការតស៊ូវណ្ណៈ បានប្រព្រឹត្តឡើងយ៉ាងតឹងតែងនៅទូទាំងតំបន់រំដោះ ទាំងក្នុងប្រជាជន ទាំងក្នុងជួរបដិវត្ត កំចាត់ ឬគាបសង្កត់ទៅលើជួរកម្មាភិបាល បក្ខជន ដែលជាប់និន្នាការ សីហនុ ឬមានវណ្ណភាពដើមជាអនុធន កសិករមាន ឬវណ្ណៈផ្សេងទៀត ដែលមិនមែនជាកសិករក្រ ឬកម្មករ។ ព្រមជាមួយនោះ ពួក ប៉ុល ពត បានដំណើរការបដិរូប មធ្យោបាយ ឧបករណ៍ផលិតកម្ម និងការទាក់ទងផលិតកម្ម

នៅជនបទ តាមរយៈសមូហភាវូបនីយកម្មជនបទ តំបន់មួយចំនួនត្រូវធ្វើរួមស៊ីរួម តំបន់មួយចំនួនត្រូវដំណើរការធ្វើសហករណ៍កំរិតទាប ឬកំរិតខ្ពស់។ របស់ដែលហៅថាបដិវត្តន៍ប្រជាធិបតេយ្យដោយដាច់ខាត ការតស៊ូវណ្ណៈដោយដាច់ខាត តាមរយៈការបង្ខិតបង្ខំ រឹបអូសខាងមធ្យោបាយ ឧបករណ៍ផលិតកម្ម ដែលជាកម្មសិទ្ធឯកជន ហើយបង្ខំអោយបង្កើតទំនាក់ទំនងផលិតកម្មសមូហភាព កំចាត់ចោលអ្នកមិនព្រមចូលរួម បានធ្វើអោយប៉ះពាល់យ៉ាងខ្លាំងចំពោះទឹកចិត្តប្រជាជន ធ្វើអោយផលិតកម្មក្នុងតំបន់រំដោះចុះថយយ៉ាងខ្លាំង។ ព្រមគ្នានឹងដំណើរការតស៊ូវណ្ណៈដោយដាច់ខាតសំដៅកំចាត់កម្លាំងដែលមិនឯកភាពជាមួយមាគ៌ា ប៉ុល ពត នៅខាងក្នុងប្រទេស ពួក ប៉ុល ពត បានដំណើរការយ៉ាងសកម្មតាមទិសស្លោកកំចាត់ចោលឥទ្ធិពលបរទេស សំដៅមុខព្រួញប្រឆាំងវៀតណាម។ ដើម្បីងាយស្រួលបំផុសចលនាប្រឆាំងវៀតណាម ពួក ប៉ុល ពត បានដំណើរការសំរិតសំរាំង កំចាត់ចោល កម្មាភិបាល បក្ខជន ដែលបានទៅរៀនសូត្រនៅភាគខាងជើងវៀតណាម ហើយត្រឡប់មកវិញ កម្មាភិបាល បក្ខជន ដែលបានចូលរួមក្នុងអង្គភាពកងទ័ពវៀតណាម ឬវៀតណាមជួយទំនុកបំរុង និងហ្វឹកហ្វឺនមុនពេលប្រគល់អោយកម្ពុជា ជនកម្ពុជាដែលមានមនោសញ្ចេតនាចំពោះមិត្តភាពជាមួយវៀតណាម។ កិច្ចការនេះប្រព្រឹត្តិទៅតាំងពីឆ្នាំ ១៩៧៣ ហើយខ្លាំងបំផុតនៅក្នុងឆ្នាំ ១៩៧៤ និងដើមឆ្នាំ ១៩៧៥ ពេលដែលពួក ប៉ុលពតដឹងច្បាស់ថាជ័យជំនះក្នុងការដណ្តើមអំណាចជិតមកដល់។

ការប្រឆាំងវៀតណាម របស់ ពួក ប៉ុល ពត បានដំណើរការតាម

របៀប "អូសទាញផង ទប់ស្កាត់ផង និងកំចាត់ផង"។

*<u>ការអូសទាញ</u>* ធ្វើឡើងសំដៅទាញយកការជួយឧបត្ថម្ភរបស់វៀតណាម ក្នុងការវាយអាមេរិក និង លន់ នល់។ ពួកវាត្រូវការកម្លាំងកងទ័ពវៀតណាមនៅតាមសមរភូមិដែលក្តៅ ដើម្បីវាយបំបាក់កងទ័ពអាមេរិក និង លន់ នល់ បើកទូលាយតំបន់រំដោះ ត្រូវការជំនួយអាវុធគ្រាប់ សំភារៈយោធា ការដឹកជញ្ជូនសំភារៈ គ្រប់បែបយ៉ាងពីចិន មកកម្ពុជា។ល។ សមរភូមិមួយចំនួនដែលត្រូវវាយលុកដោយកងថ្មើរជើងកម្ពុជា គេត្រូវការជំនួយផ្នែកអាវុធគាំទ្ររបស់កងទ័ពវៀតណាម។ តាមការពិត ជំនួយរបស់វៀតណាមមានប្រសិទ្ធិភាពខ្លាំងណាស់ ក្នុងការធ្វើអោយប្រែប្រួលតុល្យភាពកម្លាំងលើសមរភូមិកម្ពុជា ក្នុងការពង្រីកនូវតំបន់រំដោះ និងក្នុងការកសាងកម្លាំងបដិវត្តកម្ពុជា។ ដូច្នេះ មិនមែនតែប្រជាជនកម្ពុជាទេ ដែលត្រូវការជំនួយឧបត្ថម្ភនេះ ប៉ុល ពត កាន់តែត្រូវការជាងទៀត ដើម្បីសំរេចនូវបំណងអាក្រក់របស់ពួកវា។

*<u>ការទប់ស្កាត់ និងការកំចាត់</u>* ត្រូវបានដំណើរការព្រមគ្នាជាមួយនឹងការអូសទាញ។ ព្រមពេលនឹងការអូសទាញយកជំនួយរបស់បដិវត្តន៍វៀតណាម យុទ្ធនាការប្រឆាំងវៀតណាមបានដំណើរការយ៉ាងខ្លាំងពិសេសក្នុងតំបន់រំដោះដែលពួក លន់ នល់ គ្មានលទ្ធភាពនឹងជណ្តើមកាន់កាប់បានវិញ ការសំរិតសំរាំងចំពោះអ្នកដែលស្និទ្ធវៀតណាម បានដំណើរការព្រមគ្នា ជាមួយនឹងការបង្កអរិភាពជាមួយកម្លាំងបដិវត្តវៀតណាម ដែលមកជួយកម្ពុជា តាមរយៈការចាប់សម្លាប់ ប្លន់អាវុធ សំភារៈ ហើយចុងបំផុតគឺការបង្ក្រាប រាតត្បាត បណ្តេញអាណិកជនវៀតណាម

*ត្រឡប់ទៅវៀតណាមវិញ។ ពួក ប៉ុល ពត បានបង្វែរមុខព្រួញពីការប្រឆាំងពួកវៀតណាមអាយ៉ងអាមេរិកនៅភាគខាងត្បូងវៀតណាម ទៅជាការប្រឆាំងចំពោះបដិវត្តន៍វៀតណាម ដោយប្រើប្រាស់នូវរបស់ដែលហៅថា "សេរីនិយម" តាមរយៈដែលវៀតណាមបានចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងប៉ារីស៍ ជាមួយអាមេរិក។ តាមការពិត ពួក ប៉ុល ពត ក៏បានដឹងដែរថា កិច្ចព្រមព្រៀងប៉ារីស៍ ឆ្នាំ ១៩៧៣ បានផ្តល់នូវប្រយោជន៍សំរាប់ការរំដោះជាតិកម្ពុជាដែរ ប៉ុន្តែអាស្រ័យដោយអំពើក្បត់ វាបានប្រើប្រាស់កិច្ចព្រមព្រៀងនេះធ្វើជាព្រួញមួយបាញ់ត្រូវគោលដៅពីរ <u>**គោលដៅទីមួយ**</u> គឺឆ្លៀតយកចំណេញពីកិច្ចព្រមព្រៀងដែលអាមេរិកត្រូវដកកងទ័ពចេញពីឥណ្ឌូចិន រាប់ទាំងកងអន្តរាគមន៍តាមផ្លូវអាកាសផង ដែលបង្កលក្ខណៈសម្បត្តិអនុគ្រោះយ៉ាងច្រើនសំរាប់ការរំដោះជាតិនៅឥណ្ឌូចិន។ <u>**គោលដៅទីពីរ**</u> គឺប្រើប្រាស់នូវកិច្ចព្រមព្រៀងប៉ារីស៍ ដើម្បីបំផុសការប្រឆាំងជាមួយវៀតណាម តាមរយៈរបស់ដែលហៅថា សេរីនិយម (*)។*

*ការបង្វែរមុខព្រួញប្រឆាំងបដិវត្តន៍វៀតណាម បានជំរុញអោយពួក ប៉ុល ពត បំបែកកម្លាំងប្រដាប់អាវុធមួយចំនួនទៅដាក់នៅជាប់ដំបន់ព្រំប្រទល់ជាមួយវៀតណាម ក្នុងពេលដែលទឹកដីវៀតណាមនៅជាប់ព្រំប្រទល់នោះ ជាតំបន់កាន់កាប់ដោយកម្លាំងរំដោះជាតិវៀតណាម ប្រែតំបន់ព្រំដែន ដែលធ្លាប់តែជាមូលដ្ឋានបង្អែកក្រោយខ្នងរបស់បដិវត្តន៍តាំងពីយូរហើយ អោយទៅជាសមរភូមិមួយថ្មី ក្នុងពេលជាមួយគ្នាដែរ*

(*) ពាក្យសេរីនិយមដែល ប៉ុល ពត អោយនិយមន័យពេលនោះ គឺបដិវត្តន៍វៀតណាមបានសម្រុះសម្រួលជាមួយចក្រពត្តិអាមេរិក និងបរិវារនៅភាគខាងត្បូងវៀតណាម។

សេចក្ដីត្រូវការកម្លាំងមនុស្ស និងសំភារៈក្នុងការវាយពួក លន់ នល់ មានទំហំកាន់តែធំៗ តាមការត្រៀមរៀបចំនេះហើយ ដែលពួក ប៉ុល ពត មានលទ្ធភាពនឹងវាយប្រហារភ្លាមទៅលើវៀតណាម ក្រោយពេលដណ្ដើមបានអំណាចៗ

ឆ្លងតាមព្រឹត្តិការណ៍នេះ ក្នុងពេលតែមួយ ពួក ប៉ុល ពត បានបង្កើតឡើងនូវទំនាស់បី ហើយចាត់ទុកសុទ្ធតែជាទំនាស់បដិបក្ខទាំងអស់ ដែលវាបានក្លាយទៅជាសមរភូមិបីត្រូវប្រឈមមុខដោះស្រាយក្នុងពេលជាមួយគ្នាៗ សមរភូមិទីមួយ គឺជាមួយនឹងចក្រពត្តិអាមេរិក និងបរិវារ លន់ នល់ សមរភូមិទីពីរ គឺជាមួយផ្ទៃក្នុងបដិវត្តន៍ និងប្រជាជន សមរភូមិទីបី ជាមួយបដិវត្តន៍វៀតណាមៗ តាមរយៈនេះ ទោះបីពួក ប៉ុល ពត ប្រើពាក្យបដិវត្តន៍ ពាក្យសង្គមនិយម ឬប្រើពាក្យលទ្ធិម៉ាក្ស-ឡេនីន យ៉ាងណាក៏ដោយ ក៏ដំណើរការរបស់វា គ្មានចរិតបន្តិចណាសោះជាបដិវត្តន៍ ជាសង្គមនិយម ជាលទ្ធិម៉ាក្ស-ឡេនីនៗ ការប្រើពាក្យទាំងអស់នេះ គ្រាន់តែដើម្បីបិទបាំងនូវអំពើក្បត់របស់ពួកគេតែប៉ុណ្ណោះៗ

ចំណុចទាំងអស់នេះ មិនអាចហៅថា **<u>ការខុសឆ្គង</u>** ធម្មតា ដែលបដិវត្តន៍ប្រទេសខ្លះធ្លាប់បានជួបប្រទះនោះឡើយ ផ្ទុយទៅវិញគឺជាអំពើក្បត់ជាតិ ក្បត់បដិវត្តន៍ទាំងស្រុង គ្រាន់តែអំពើក្បត់នេះមិនស្ថិតនៅជាអង្គការចាត់តាំងដោយឡែក ដូចពួក លន់ នល់ ដែលគេឃើញគ្រប់ៗ គ្នាៗ អំពើក្បត់របស់ ប៉ុល ពត បានស្ថិតនៅក្នុងអង្គការចាត់តាំងបដិវត្ត ប្រើប្រាស់អង្គការនេះដើម្បីដណ្ដើមអំណាចទាំងស្រុង រួចហើយទើបចេញមុខៗ ប្រការនេះ បានបង្ហាញតាមរយៈនៃសកម្មភាពដែល

*បានរៀបរាប់ខាងលើ បង្ហាញតាមរយៈមាត់ា និងអំពើរបស់វា ក្រោយរំដោះជាតិ ១៧ មេសា ១៩៧៩ ហើយក៏បង្ហាញតាមរយៈនៃការប្រកាសយកថ្ងៃកំណើតបក្ស (១៩៦០)។ ការប្រកាសចេញមុខ បក្សកុម្មុយនិស្តកម្ពុជា នៅឆ្នាំ ១៩៧៧ ដែលមានថ្ងៃកំណើតឆ្នាំ ១៩៦០ កាន់តែបង្ហាញច្បាស់ថា ប៉ុល ពត មានអង្គការចាត់តាំងក្បត់ដោយឡែក និងមាត់ាដោយឡែកមួយ ស្ថិតនៅក្នុងចលនាតស៊ូបដិវត្តដែលដឹកនាំដោយបក្សប្រជាជនបដិវត្តខ្មែរ ប្រើប្រាស់ចលនាតស៊ូបដិវត្តផង និងកំចាត់ផងដណ្ដើមអំណាចផ្ដាច់មុខអោយអង្គការចាត់តាំងក្បត់របស់ពួកវា។ អាស្រ័យហេតុនេះបានជាជ័យជំនះលើចក្រពត្តិអាមេរិក និងបរិវារ ថ្ងៃ ១៧ មេសា ១៩៧៥ របស់ប្រជាជនកម្ពុជា ត្រូវបានបញ្ចប់ទៅវិញតាមរយៈនៃអំពើក្បត់មួយដែលសម្ងំនៅក្នុងជួរបដិវត្ត។*

**ជំពូក ២**

# ការបដិវត្តន៍មួយ
# ត្រូវធ្វើឡើងវិញ

ផ្នែកទី ១
## ជាតុពិតនៃរបប ប៉ុល ពត

ផ្នែកទី ២
## ការរីកចំរើនឡើងនៃកម្លាំងបដិវត្តន៍ និង ស្នេហាជាតិ ក្រោមរបបប្រល័យពូជសាសន៍ ប៉ុល ពត និងការតួបផ្សំរវាងកម្លាំងបដិវត្ត ជាតិ និងកម្លាំងអន្តរជាតិ ក្នុងការផ្តួលរំលំ របបប្រល័យពូជសាសន៍ ប៉ុល ពត

ផ្នែកទី ៣
## ការរស់ឡើងវិញរបស់ជាតិក្នុងស្ថានភាព មានសន្តិភាពផង និងមានសង្គ្រាមផង

ផ្នែកទី ១

# ធាតុពិតនៃរបប ប៉ុល ពត

*មកទល់ពេលនេះ គេមិនទាន់ឈានដល់ការឯកភាពគ្នាក្នុងការវាយតម្លៃអំពីធាតុពិតនៃរបប ប៉ុល ពត នៅឡើយ ពិតមែនតែគេបានប្រើពាក្យប្រល័យពូជសាសន៍ ហើយនិយាយច្រើនដល់អំពើកាប់សម្លាប់បំផ្លិចបំផ្លាញនៃរបបនេះ។ នៅក្នុងការវិភាគវែកញែកអំពីរបប ប៉ុល ពត មានមនុស្សមួយចំនួនវែកញែកថា ប៉ុល ពត ជាជនបដិវត្តមានមាគ៌ាត្រឹមត្រូវ ប៉ុន្តែការអនុវត្តន៍មានការខុសឆ្គង។ ការកំចាត់ផ្ទៃក្នុងបណ្តាលមកពីចង់ការពារបដិវត្តន៍សង្គមនិយម ការប្រឆាំងវៀតណាមបណ្តាលមកពីគោលជំហរការពារផលប្រយោជន៍ជាតិ។ អាស្រ័យដោយ ប៉ុល ពត បានជ្រកក្រោមផ្លាក «បដិវត្តន៍» ផ្លាក «សង្គមនិយម» ផ្លាក «លទ្ធិម៉ាក្ស-ឡេនីន» និងអាស្រ័យដោយការបកស្រាយប្លែកៗគ្នា ពួកចក្រពត្តិមូលធននិយម បានធ្មៀតប្រើប្រាស់ ដើម្បីប្រឆាំងជាមួយបដិវត្តន៍ជាទូទៅ ។*

*សៀវភៅនេះ សូមលើកឡើងនូវការវិភាគវែកញែក អំពីធាតុពិតនៃរបប ប៉ុល ពត តាមការទាញយកទ្រឹស្តី មនោគមន៍វិជ្ជា និងសកម្មភាពមកធ្វើជាមូលដ្ឋានអោយការវាយតម្លៃ។*

*ដូចបានលើកឡើងនៅក្នុងជំពូក ១ ចំណុចទី ៣ នៃសៀវភៅនេះ គឺ ប៉ុល ពត មានអង្គការចាត់តាំងដោយឡែក និងមាគ៌ាដោយឡែក ស្ថិតក្នុងចលនាបដិវត្ត ក្រោមការដឹកនាំរបស់បក្សប្រជាជនបដិវត្តខ្មែរ ដោយប្រើប្រាស់នូវចលនាបដិវត្តន៍នេះផង និងកំចាត់ចលនាបដិវត្តន៍នេះផង ដើម្បីដណ្តើមអំណាចទាំងស្រុង។ ដូច្នេះពួក ប៉ុល ពត គ្មានមូលដ្ឋានមនោគមន៍វិជ្ជាដូចបក្សប្រជាជនបដិវត្តន៍ខ្មែរ ដែលយកលទ្ធិម៉ាក្ស-ឡេនីនធ្វើជាគ្រឹះនៃមាគ៌ា និងសកម្មភាពឡើយ។ បើធ្វើការប្រៀបធៀប គេអាចឃើញថា មូលដ្ឋានមនោគមន៍វិជ្ជារបស់ ប៉ុល ពត មានចំណុចប្រហាក់ប្រហែលមនោគមវិជ្ជាចិន ក្នុងដំណាក់កាល «មហាបដិវត្តន៍វប្បធម៌អធន» ដែលលេចចេញមកពីសតិអារម្មណ៍ឆ្វេងជ្រុលហួសហេតុ ។*

*អាចនិយាយបានច្បាស់ថែមទៀតថា មនោគមវិជ្ជារបស់ចិនក្នុងដំណាក់កាល «មហាបដិវត្តន៍វប្បធម៌អធន» គឺមានឫសគល់ពីលទ្ធិម៉ៅ ដូច្នេះមនោគមវិជ្ជារបស់ ប៉ុល ពត ក៏មានឫសគល់ពីលទ្ធិម៉ៅ។ ដោយហេតុនេះ លទ្ធិម៉ៅ ត្រូវបានអនុវត្តដកពិសោធន៍ដោយពិតប្រាកដនៅកម្ពុជា ហើយបរាជ័យលទ្ធិម៉ៅ ក៏នៅកម្ពុជា។*

*កន្លងទៅមានអ្នកវិភាគជាច្រើន បានចាត់ទុកថាមាគ៌ា និងសកម្មភាពរបស់ ប៉ុល ពត មានមូលដ្ឋានពី<u>គោលជំហរឆ្វេងជ្រុលហួសហេតុគួបផ្សំជាមួយគោលជំហរជាតិនិយមហួសហេតុ</u>។ តាមសកម្មភាពដែលពួក ប៉ុល ពត បានអនុវត្តអាចសន្និដ្ឋានបានថា ពួក ប៉ុល ពត ស្ថិតក្នុងក្របខ័ណ្ឌនៃលទ្ធិឆ្វេងជ្រុលហួសហេតុ គឺមានភាពត្រឹមត្រូវតាមសកម្មភាពរបស់វា ប៉ុន្តែចំពោះជាតិនិយមចង្អៀតចង្អល់ហួសហេតុ ហាក់ដូច*

ជាមិនទាន់ត្រឹមត្រូវស្របនឹងអ្វីដែល ប៉ុល ពត បានធ្វើចំពោះជាតិឡើយ។ ការប្រើប្រាស់ពាក្យជាតិនិយមចង្អៀតចង្អល់ហួសហេតុ ក្នុងពេលពួក ប៉ុល ពត បានអនុវត្តការប្រល័យពូជសាសន៍ឯង ដូចជាមិនស្រប រវាង ទ្រឹស្ដី និងការដាក់ស្ដែងដែលបានកើតមាន។ តាមសកម្មភាពរបស់ពួក ប៉ុល ពត គេអាចផ្ដល់នូវការវាយតម្លៃថាជាក្រុមប្រកាន់លទ្ធិនិយមជ្រុលហួសហេតុ។ លទ្ធិឆ្វេងជ្រុលហួសហេតុគឺជាកត្តាដើរតួសំខាន់ក្នុងមនោគមវិជ្ជារបស់ពួក ប៉ុល ពត នៅគ្រប់ដំណាក់កាល ឯលទ្ធិនិយមជ្រុលហួសហេតុ គឺជាកត្តាដើរតួក្នុងសកម្មភាពរបស់ ប៉ុល ពត នៅគ្រប់ដំណាក់កាល។

លទ្ធិឆ្វេងជ្រុលហួសហេតុ និងលទ្ធិនិយមជ្រុលហួសហេតុបានគ្របដណ្ដប់ក្នុងមនោគមវិជ្ជា ទ្រឹស្ដី មាគ៌ា គោលការណ៍ និងគ្រប់សកម្មភាពរបស់ពួក ប៉ុល ពត តាំងពីដើមរហូតដល់ចប់។ វាមានភាពចម្រែកយ៉ាងច្រើនរវាងជាតិនិយមចង្អៀតចង្អល់ហួសហេតុ និងលទ្ធិនិយមជ្រុលហួសហេតុ។ ការដែលមិនអាចកំណត់បានថា ពួក ប៉ុល ពត ស្ថិតក្នុងគោលជំហរនៃលទ្ធិជាតិនិយមចង្អៀតចង្អល់ហួសហេតុ នៅត្រង់ជានិច្ចកាល ពួកនេះតែងប្រឆាំងជាមួយផលប្រយោជន៍ជាតិ រហូតឈានដល់ការប្រល័យពូជសាសន៍ជាតិឯង។ ប្រសិនជាឈរលើលទ្ធិជាតិនិយមចង្អៀតចង្អល់ តិច ឬច្រើន ពួកនេះអាចគិតដល់ផលប្រយោជន៍របស់ជាតិសាសន៍ខ្លួនខ្លះ ក្នុងពេលដែលពួកនេះ ប្រឆាំងចំពោះជាតិសាសន៍ដទៃ ដែលមានឧទាហរណ៍នៅ ចិន អ៊ីស្រាអែល អាហ្វ្រិកខាងត្បូង ពួកហ្វាស៊ីស្តអាល្លឺម៉ង់ ជប៉ុន ។ល។ ប៉ុន្តែ សំរាប់ពួក ប៉ុល ពត មិនមាន

សកម្មភាព ត្រឹមកំរិតនៃលទ្ធិជាតិនិយមចង្អៀតចង្អល់ហួសហេតុនេះឡើយ វាទៅហួសពីនេះ គឺឈានទៅដល់លទ្ធិនិយមជ្រុលហួសហេតុ។

ឆ្វេងជ្រុលហួសហេតុ និងនិយមជ្រុលហួសហេតុ បានបង្កើតឡើងនូវមនោគមវិជ្ជាមួយដោយឡែក ដែលមានលំនាំដើមខ្លះ ពីទ្រឹស្តីមហាបដិវត្តន៍វប្បធម៌អធនចិន ហើយការអនុវត្តន៍វាមានចំណុចជាច្រើនជ្រុលហួសពីអ្វីដែលចិនបានធ្វើក្នុងសម័យ «មហាបដិវត្តន៍វប្បធម៌អធន»។

មនោគមវិជ្ជាដែលចេញមកពីលទ្ធិឆ្វេងជ្រុលហួសហេតុ និងលទ្ធិនិយមជ្រុលហួសហេតុ ជានិច្ចកាលមានដំណើរផ្ទុយជាមួយផលប្រយោជន៍ជាតិតាំងពីដើមដល់ចប់។ តាំងពីពេលដណ្តើមបានសិទ្ធិដឹកនាំខ្ពស់បំផុតនៅក្នុងបក្ស ប៉ុល ពត បានផ្តាច់ ខ្លួនចេញពីផលប្រយោជន៍ជាតិ គឺផ្តាច់ចេញពីនយោបាយឯករាជ្យ អព្យាក្រឹត ដែលប្រជាជនកម្ពុជាកំពុងត្រូវការនាមុនឆ្នាំ ១៩៧០ ហើយក្រោយឆ្នាំ ១៩៧០ អំពើក្បត់នេះ ត្រូវបានបន្តក្រោមយុទ្ធវិធី និងក្រោមរូបភាពថ្មី។ ពេលដណ្តើមបានអំណាចទាំងស្រុងនាឆ្នាំ ១៩៧៥ លទ្ធិឆ្វេងជ្រុល និងនិយមជ្រុល ត្រូវបានដំណើរការយ៉ាងចំហ និងជាទូទៅ វាមិនគ្រាន់តែបដិបក្ខជាមួយលទ្ធិម៉ាក្ស-ឡេនីន មួយប៉ុណ្ណោះទេ ប៉ុន្តែវាបដិបក្ខទាំងស្រុង ជាមួយផលប្រយោជន៍របស់ជាតិកម្ពុជា។ មុនឆ្នាំ ១៩៧០ ពួក ប៉ុល ពត ធ្វើត្រឹមកម្រិតបដិសេធចោលនូវការសម្រុះសម្រួលក្នុងនយោបាយឯករាជ្យ អព្យាក្រឹត។ ឆ្នាំ ១៩៧០-១៩៧៥ ពួក ប៉ុល ពត ធ្វើក្នុងកំរិតសម្រុះសម្រួលផងកំចាត់ផងដើម្បីឈានដល់ការដណ្តើមអំណាចទាំងស្រុង។ តែក្រោយពេលដណ្តើមបានអំណាចទាំងស្រុង នាឆ្នាំ ១៩៧៥ សភាពការណ៍អនុញ្ញាតអោយ

ប៉ុល ពត អនុវត្តបានទាំងស្រុងនូវលទ្ធិឆ្វេងជ្រុល និងនិយមជ្រុល ដោយគ្មានការសម្រុះសម្រួលជាមួយអ្វីៗ ទាំងអស់ ដែលសេសសល់ពីសង្គមចាស់ រាប់តាំងពីខឿនវប្បធម៌ ប្រពៃណីរបស់ជាតិ និងបដិសេធចោលអ្វីៗ ទាំងអស់ ដែលកើតមានថ្មី ផ្ទុយនឹងការចង់បានរបស់ក្រុមនេះ រាប់ទាំងផលប្រយោជន៍ ដែលសមស្របបំផុតរបស់ជាតិ។

និយាយដូចខាងលើ គ្មានន័យចាត់ទុក ប៉ុល ពត និងបក្ខពួកជាជនជាតិផ្សេង ហើយចង់អោយជនជាតិផ្សេងទៀត ប្រែក្លាយជនកម្ពុជា ទៅជាជនជាតិនោះឡើយ។ ប៉ុល ពត និងបក្ខពួក គឺជាជនជាតិកម្ពុជាយ៉ាងច្បាស់លាស់ ប៉ុន្តែអាស្រ័យដោយលទ្ធិឆ្វេងជ្រុលហួសហេតុ និងលទ្ធិនិយមជ្រុលហួសហេតុ ធ្វើអោយពួកនេះ ផ្តាច់ខ្លួនចេញជាស្វ័យប្រវត្តិ ពីផលប្រយោជន៍សមស្របរបស់ជាតិ និងប្រឆាំងផលប្រយោជន៍របស់ជាតិ។ ពួក ប៉ុល ពត ក៏នៅតែប្រើប្រាស់ពាក្យស្នេហាជាតិ ពាក្យបដិវត្តន៍ ពាក្យសង្គមនិយម ពាក្យលទ្ធិម៉ាក្ស-ឡេនីន ពាក្យបក្សកុម្មុយនិស្ត ពាក្យតស៊ូវណ្ណៈ ពាក្យផ្តាច់ការអធន និងពាក្យដទៃទៀត ដែលបដិវត្តន៍ធ្លាប់ប្រើ។ ដូច្នេះ នៅពេលដំបូង គេពិបាកនឹងពិនិត្យអំពីអំពើក្បត់របស់ ប៉ុល ពត អាស្រ័យដោយវាជ្រកក្រោមផ្លាក «<u>ជាតិ និងបដិវត្តន៍</u>» ដែរ ប៉ុន្តែគេអាចមើលឃើញពួកនេះ តាមរយៈនៃការប្រើប្រាស់ភាសា «<u>ដាច់ខាត</u>» ឬ «<u>ទាំងស្រុង</u>» ពាក្យ «<u>មហាលោតផ្លោះ មហាអស្ចារ្យ</u>» នៅគ្រប់ការលើកឡើងអំពីមាគ៌ា គោលការណ៍ និងគ្រប់សកម្មភាព។ ភាសា «ដាច់ខាត» ឬ «ទាំងស្រុង» ដែលពួកឆ្វេងជ្រុល និងនិយមជ្រុលប្រើប្រាស់ វាខុសពី «ដាច់ខាត» ឬ «ទាំងស្រុង» ដែលបដិវត្តន៍បាន

ប្រើប្រាស់ ព្រោះ «ដាច់ខាត» ឬ «ទាំងស្រុង» ដែលពួក ប៉ុល ពត បាន ប្រើ គឺគ្មានការសម្រុះសម្រួលជាមួយអ្វីទាំងអស់ ដែលខុសពីបំណង ពួកវា សូម្បីតែសេចក្តីត្រូវការអប្បបរមារបស់ជាតិ និងប្រជាជន ក៏គ្មាន ការសម្រុះសម្រួលដែរ ហើយទោះជាអ្វីដែលកើតឡើងដោយក្រឹត្យក្រម សត្យានុម័ត ឬប្រវត្តិសាស្ត្របន្សល់ទុក ក៏គ្មានការសម្រុះសម្រួលដែរ។

នឹងអាចមានសំណួរថា តើចំណុចចាប់ផ្តើមរបស់ ប៉ុល ពត ចេញ ពីទីណា? ចេញពីលទ្ធិឱកាសនិយមឆ្វេងជ្រុលហួសហេតុ ជាមួយលទ្ធិ និយមជ្រុលហួសហេតុ? ឬពីលទ្ធិឱកាសនិយមឆ្វេងជ្រុលហួសហេតុជា មួយលទ្ធិជាតិនិយមចង្អៀតចង្អល់ហួសហេតុ?

អាចឆ្លើយដោយសមហេតុសមផល តាមឡូស៊ីចនៃការវិវត្តន៍ គឺពួក ប៉ុល ពត ចេញដំណើរពីចំណុចនៃលទ្ធិឱកាសនិយមឆ្វេងជ្រុលហួស ហេតុជាមួយលទ្ធិជាតិនិយមចង្អៀតចង្អល់ហួសហេតុ ប៉ុន្តែអាស្រ័យដោយ ជិតជាប់ក្នុងខួរក្បាលនូវលទ្ធិគំនិតនិយមអត្តនោម័ត បានជំរុញអោយ ពួកនេះឃ្លាតចាកលទ្ធិជាតិនិយមចង្អៀតចង្អល់ហួសហេតុ ទៅកាន់ លទ្ធិនិយមជ្រុលហួសហេតុ កាប់សម្លាប់ប្រជាជនឯង។

ក្នុងពេលពួក ប៉ុល ពត អនុវត្តការប្រល័យពូជសាសន៍ឯង គ្មាន ហេតុផលណាមួយត្រូវដាក់ពួក ប៉ុល ពត អោយមានទីតាំងឈរជើង ក្នុងជនជាតិកម្ពុជានេះឡើយ ទោះជាហេតុផលខាងនយោបាយ ខាង ផ្លូវច្បាប់ ខាងសីលធម៌ ខាងលក្ខណៈជនជាតិ ។ល។ ក៏ដោយ។ ក្រៅពី ការប្រល័យពូជសាសន៍តាមរយៈការកាប់សម្លាប់មនុស្ស គេត្រូវចាប់អា រម្មណ៍លើចំណុចពិសេសមួយទៀតរបស់ពួក ប៉ុល ពត គឺការបំផ្លាញ

ចោលស្ទើរតែទាំងស្រុងនូវចរឹត និងលក្ខណៈរបស់ជនជាតិ។ ជនជាតិណាក៏មានលក្ខណៈសំរាប់សំគាល់ជនជាតិនោះ តាមរយៈការនិយាយស្តី អាកប្បកិរិយា ការស្លៀកពាក់ វប្បធម៌ សិល្បៈ ប្រពៃណី សាសនាភាសា អក្សរសាស្ត្រ ។ល។ ក្នុងជំនាន់ ប៉ុល ពត ដូចជានៅសេសសល់តែភាសា អក្សរសាស្ត្រប៉ុណ្ណោះទេដែលមិនត្រូវបានបំផ្លាញ ឬកែប្រែអោយខុសពីទម្លាប់របស់ជាតិ។ ការដែលមិនអាចកែប្រែបាន ប្រហែលជាគេគ្មានលទ្ធភាពនឹងកែប្រែ។ ក្រៅពីនោះ ត្រូវបំផ្លាញ ឬត្រូវកែប្រែ ឧទាហរណ៍ គេសំគាល់នារីខ្មែរ តាមរយៈការស្លៀកពាក់ហូល ផាមួងសារុង ឬសំពត់អាវមានពណ៌ ទុកសក់វែង តែ ប៉ុល ពត តម្រូវអោយស្លៀកពាក់ខ្មៅជាទូទៅ កាត់សក់ខ្លីជាទូទៅ។ បុរស នារី រៀបអាពាហ៍ពិពាហ៍ម្តងមួយគូដោយធ្វើតាមប្រពៃណី តែប៉ុល ពត តម្រូវអោយរៀបការរាប់សិបរាប់រយគូម្តងៗ។ ជនជាតិកម្ពុជាគោរពព្រះពុទ្ធសាសនា តែព្រះពុទ្ធសាសនាត្រូវបំផ្លាញ វត្តអារាម ត្រូវបំផ្លាញ ក្លាយទៅជាកន្លែងឃុំមនុស្ស សម្លាប់មនុស្ស ជាឃ្លាំង។ ព្រះសង្ឃត្រូវធ្វើគត ឬចាប់អោយចាកផ្នួស។ សិល្បៈមានច្រើនប្រភេទ ត្រូវលុបចោល នៅសេសសល់ខ្លះតម្រូវអោយលែងតុបតែង ខុសពីប្រពៃណី ដោយស្លៀកពាក់ខ្មៅ។ល។ ឧទាហរណ៍មួយចំនួនខាងលើនេះ កាន់តែបង្ហាញថា ពួក ប៉ុល ពត គ្មានទីតាំងក្នុងជាតិកម្ពុជាឡើយ អាស្រ័យដោយបានបំផ្លាញអស់នូវលក្ខណៈ ពណ៌សម្បុរ ដែលជាព្រលឹងជាតិ។

គេអាចចោទនូវសំណួរបន្ថែមថា ប៉ុល ពត ជាជនជាតិកម្ពុជា ហើយពេលអនុវត្តការប្រល័យពូជសាសន៍ ក៏ ប៉ុល ពត ស្ថិតនៅកម្ពុជា

ហេតុអ្វីក៏ ប៉ុល ពត គ្មានទីតាំងឈរជើង នៅក្នុងជាតិកម្ពុជា? ត្រឹមត្រូវ ប៉ុល ពតជាជនជាតិកម្ពុជា ហើយស្ថិតនៅកម្ពុជា ពេលអនុវត្តការប្រល័យពូជសាសន៍ ប៉ុន្តែអាស្រ័យលទ្ធិឆ្វេងជ្រុលហួសហេតុ និងនិយមជ្រុលហួសហេតុបូកជាមួយគំនិតនិយមអត្តនោម័ត បានជំរុញពួក ប៉ុល ពត អោយស្ថិតនៅលើជាតិ ហើយអនុវត្តការបំផ្លាញជាតិគឺមិនស្ថិតក្នុងទីតាំងរបស់ជាតិឡើយ។ តាមសកម្មភាពរបស់ពួក ប៉ុល ពត អង្គការគឺជា ជាតិ។ លក្ខណៈសំគាល់សំរាប់ជនជាតិត្រូវលុបចោល ហើយតម្រូវអោយយកមកវិញនូវលក្ខណៈសំគាល់ជាតិពីអង្គការដែលថ្មី និងផ្ទុយទាំងស្រុងពីលក្ខណៈសំគាល់ជនជាតិកម្ពុជា ដែលមានអាយុរាប់ពាន់ឆ្នាំមកហើយ។ តាមន័យនេះ អង្គការដូចជាជនជាតិកម្ពុជាមួយថ្មី គ្រាន់តែមានតំណខាងភាសា និងអក្សរសាស្ត្រប៉ុណ្ណោះ។

ឆ្វេងជ្រុលហួសហេតុ និងឈានហួសពីក្របខណ្ឌជាតិនិយមចង្អៀតចង្អល់ហួសហេតុ ទៅកាន់ក្របខ័ណ្ឌនិយមជ្រុលហួសហេតុ បានជំរុញពួក ប៉ុល ពត ទៅស្ថិតក្នុងក្របខ័ណ្ឌនៃមនុស្សមួយក្រុមដែលគ្មានស្គាល់អ្វីដែលហៅថាសមិទ្ធផលរបស់មនុស្ស អ្វីដែលហៅថា ក្រឹត្យក្រមសត្យានុម័ត ជំរុញពួកនេះអោយលុបបំបាត់នូវអ្វីៗ ទាំងអស់ ហើយកសាងនូវអ្វីដែលថ្មីតាមការនឹកឃើញរបស់វា។

ក្រោយពេលដណ្តើមបានអំណាចទាំងស្រុង នាខែមេសា ១៩៧៥ ប៉ុល ពត បានប្រកាសថា បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យសំរេចបានទាំងស្រុង ហើយត្រូវបន្តធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមនៅកម្ពុជាអោយសំរេចក្នុងរង្វង់ ១០ ទៅ១៥ឆ្នាំ។តាមន័យដែលពួក ប៉ុល

ពត ចង់និយាយ គឺការសំរេចបដិវត្តន៍ប្រជាជាតិតាមរយៈការបណ្តេញចក្រពត្តិអាមេរិកចេញពីកម្ពុជា។ ប្រការនេះ ពុំទាន់មានអ្វីគួរអោយចាប់អារម្មណ៍ទេ តែប្រការគួរអោយចាប់អារម្មណ៍នោះ គឺ ប៉ុល ពត បានចាត់ទុកការសំរេចបដិវត្តន៍ប្រជាធិបតេយ្យទាំងស្រុង គឺតាមរយៈនៃការបំបាត់ចោលរបបកម្មសិទ្ធិឯកជន ដែលធ្វើតាមរយៈជម្លៀសប្រជាជនចេញពីទីក្រុង លុបបំបាត់ចោលទំនាក់ទំនងរវាងរូបិយវត្ថុ និងទំនិញ លុបបំបាត់ចោលអ្វីៗ ដែលជាសំណល់ពីរបបចាស់ រឹបអូសមធ្យោបាយឧបករណ៍ផលិត និងការរៀបចំទំនាក់ទំនងផលិតកម្មសមូហភាពទាំងស្រុង។ តាមរបៀបនេះ ប៉ុល ពត បានអោយនិយមន័យថា សំរេចបានទាំងស្រុងនូវបដិវត្តន៍ប្រជាធិបតេយ្យ អាស្រ័យដោយបានបំបាត់ចោលនូវកម្មសិទ្ធិរបស់គ្រប់វណ្ណៈក្នុងសង្គមរាប់ទាំងវណ្ណៈកម្មករ កសិករ ពលករឯកជនផង ហើយបង្កើតឡើងនូវរបបសមូហភាពទាំងស្រុងមួយ ដែល ប៉ុល ពត ចាត់ទុកថា មានចំណុច ៤ គឺ៖

- មធ្យោបាយផលិតកម្មសមូហភាព
- ឧបករណ៍បង្កើនផលសមូហភាព
- ស៊ីចុក រស់នៅ សមូហភាព
- ធ្វើការងារសមូហភាព (*)។

តាំងពីក្រោយរំដោះភ្លាម ប៉ុល ពត លើកឡើងពីការបន្តធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមក្រោមផ្ទាំកនៃ«ការតស៊ូវណ្ណៈដោយ

(*) បទឧទ្ទេសនាម ប៉ុល ពត ក្នុងរបាយការណ៍សកម្មភាពរបស់មជ្ឈិមបក្ស តាមភារកិច្ចនយោបាយរួម ឆ្នាំ ១៩៧៦ (ថ្ងៃ ២០/១២/៧៦)។

ដាច់ខាត និងការកសាងសង្គមមួយថ្មីទាំងស្រុង»។ ក្នុងឱកាសបូកសរុបការកិច្ចបដិវត្តសង្គមនិយម ដែលបានអនុវត្តក្នុងឆ្នាំ ១៩៧៦ ប៉ុល ពត បានលើកឡើងនូវភារកិច្ច ៣ ដែលបានអនុវត្ត ហើយត្រូវបន្តអនុវត្តពេលខាងមុខទៀតគឺ៖

ទី១ - វណ្ណៈជិះជាន់ផ្សេងៗ ដែលត្រូវវាយរំលំហើយ យើងវាយតទៅទៀត។ វាងើបឡើងវិញមិនបានទេ ទាំងនៅជនបទក្តី នៅទីក្រុងក្តី នៅក្នុងក្រសួងមន្ទីរក្តី ទាំងនៅក្នុងជួរបដិវត្តន៍ក្តី ក្នុងបក្សក្តី ហើយការវាយរំលំរលើងនេះ មិនមែនវាយដោយផ្នែកៗ មួយពីរទេ គឺវាយជាខ្សែចង្វាក់ វាយគ្រប់ផ្នែក ជីក រំលើងទាំងឫសធំទាំងឫសតូច។

ទី២ - របបឯកជនរបស់សក្តិភូមិ របស់នាយទុន ក៏ដូចជារបស់វណ្ណៈផ្សេងៗទៀតដែលមិនមែនអធនដូចជារបស់កសិករឯកជន របស់កម្មករឯកជន របស់ពលករឯកជន ក៏យើងគាស់រំលើងថែមទៀត ក្នុងឆ្នាំ ១៩៧៦ នេះ ហើយមិនអោយរបបឯកជននេះងើបឡើងវិញបានទេ។

ទី៣ - យើងបានវាយរបបកម្មសិទ្ធិឯកជន បានមួយកំរិតធំ ហើយជ្រាលជ្រៅក្នុងឆ្នាំ ១៩៧៦ នេះ វាយនៅក្នុងបក្ស វាយក្នុងកងទ័ព វាយទាំងក្នុងប្រជាជន ពិសេសនៅក្នុងជួរបក្ស នៅក្នុងជួរបដិវត្តយើង (*)។ ប៉ុល ពត ចាត់ទុកទិដ្ឋភាពទាំងបីនេះជាជ័យជំនះយ៉ាងធំ ក្នុងការបន្តបដិវត្តន៍សង្គមនិយម ក្នុងឆ្នាំ ១៩៧៦។ ក្នុងពេលលើកឡើងថា ក្រោយរំដោះខែមេសា ឆ្នាំ ១៩៧៥ នៅកម្ពុជានៅសេសសល់តែវណ្ណៈពីរទេ គឺ

(*) បទឧទ្ទេសនាម ប៉ុល ពត ក្នុងរបាយការណ៍សកម្មភាពរបស់មជ្ឈិមបក្ស តាមភារកិច្ចនយោបាយរួម ឆ្នាំ ១៩៧៦ (ថ្ងៃ ២០/១២/៧៦)។

កម្មករសម្ព័ន្ធភាព និងកសិករសម្ព័ន្ធភាព ហើយស្ថិតស្ថេរជាមួយវណ្ណៈទាំងពីរនេះ គឺនៅមានជួរបដិវត្ត ដែលកំពុងកាន់អំណាច។ ពេលនេះដែរ ប៉ុល ពត បានលើកអំពីកម្មវត្ថុ ដែលបដិវត្តន៍សង្គមនិយមត្រូវវាយនោះគឺជាតុពិតនៃវណ្ណៈនាយទុន និងវណ្ណៈជិះជាន់ផ្សេងៗទៀត ទាំងគ្រប់ផ្នែក សេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ច មនោសញ្ចេតនា ។ល។ (*) ប៉ុល ពត បានចាត់ទុកកម្មសិទ្ធិឯកជនទាំងអស់ មានជាតុពិតជានាយទុន សូម្បីតែកម្មសិទ្ធិឯកជនរបស់វណ្ណៈកម្មករ កសិករ ពលករ ក៏មានជាតុពិតជានាយទុនដែរ ដែលត្រូវតស៊ូកំចាត់។ នៅពេលលើកឡើងអំពីតើត្រូវតស៊ូកំចាត់ និងតស៊ូកសាងលើអ្វីខ្លះ ប៉ុល ពត បានកំណត់ច្បាស់ថា «លើគ្រប់ផ្នែក លើលោកទស្សនៈ លើជីវទស្សនៈ លើការរស់នៅរបស់យើង លើសេដ្ឋកិច្ចគ្រប់ផ្នែករបស់យើង លើវប្បធម៌ លើសិល្បៈ លើអក្សរសាស្ត្រ លើមនោសញ្ចេតនា លើមនោគមវិជ្ជា លើគំនិត។ កំចាត់លោកទស្សនៈវណ្ណៈនាយទុន កំចាត់លោកទស្សនៈវណ្ណៈផ្សេងៗ កំចាត់លោកទស្សនៈឯកជន» (**) ។

ប៉ុល ពត បានកំណត់ច្បាស់ថា រូបភាពចាត់តាំងវណ្ណៈ នៅសល់តែពីរទេគឺវណ្ណៈកម្មករ និងវណ្ណៈកសិករ ហើយនៅក្បែរនោះមានជួរបដិវត្ត ដែល ប៉ុល ពត ចាត់ទុកថាជាស្រទាប់មួយដែរ ដែលត្រូវតស៊ូលុបបំបាត់តាមរយៈប្រែក្លាយអោយទៅជាកម្មករ កសិករទាំងអស់។ ឯខ្លឹមសារ និងជាតុពិតវណ្ណៈ ប៉ុល ពត ចាត់ទុកថា បានស្ថិតនៅដដែល

(*) បទឧទ្ទេសនាម ប៉ុល ពត អំពីបដិវត្តន៍សង្គមនិយមគ្រប់ផ្នែក (ទង់បដិវត្ត លេខពិសេស កញ្ញា ១៩៧៦)

(*) បទឧទ្ទេសនាម ប៉ុល ពត អំពីបដិវត្តន៍សង្គមនិយមគ្រប់ផ្នែក (ទង់បដិវត្ត លេខពិសេស កញ្ញា-តុលា ១៩៧៦)

ទោះជារូបភាពចាត់តាំងវណ្ណៈ ក្នុងសង្គមមានតែ កម្មករ កសិករ ក៏ដោយ ក៏ខ្លឹមសារ និងជាតុពិតវណ្ណៈនាយទុន សក្តិភូមិ អនុធន កសិករឯកជន កម្មករឯកជន នៅតែគ្របដណ្តប់ក្នុងសង្គម និងក្នុងជួរបដិវត្តទាំងមូល ដែលត្រូវតស៊ូកំចាត់ក្នុងបដិវត្តន៍សង្គមនិយម។ ជាមួយគ្នានេះ ប៉ុល ពត បានលើកពីទំនាស់វណ្ណៈ ដែលនៅតែលេចឡើង មានចរិតជាទំនាស់ស្លាប់រស់ គឺទំនាស់ជាមួយវណ្ណៈសក្តិភូមិ ជាម្ចាស់ដី ជាអភិជន មេឃុំ ចៅហ្វាយស្រុក ចៅហ្វាយខេត្ត អ្នករដ្ឋការ ប៉ូលិស ទាហាន ក្នុងពេលដែលអ្នកទាំងនេះ អស់មានកម្មសិទ្ធិ អស់មានអំណាចអ្វីទាំងអស់។ ឯក្នុងជួរកសិករវិញ គេបានលើកអំពីកសិករចាស់ និងកសិករថ្មី។ កសិករចាស់ក៏មានការបែងចែកជាទំនាស់ស្លាប់រស់រវាងកសិករក្រ កសិករថ្នាក់ក្រោម កសិករថ្នាក់កណ្តាល ជាមួយកសិករកណ្តាលថ្នាក់លើ និងកសិករមាន។ ឯកសិករថ្មី កាន់តែលំបាកទៅទៀត ដោយ ប៉ុល ពត ចាត់ទុកថា កសិករថ្មីនេះ រួមមាន អនុធន នាយទុន សក្តិភូមិ កម្មករ និងពលករទីក្រុងផ្សេងទៀត ដែលទើបជម្លៀសចេញពីទីក្រុង។

ត្រូវដូចដែល ប៉ុល ពត បានលើកឡើង ក្នុងឯកសារនៃពល់មាគ៌ារបស់វា គឺកំចាត់ចោលអ្វីៗទាំងអស់ ហើយកសាងឡើងវិញជាថ្មីតាមរយៈបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមតាមគំនិតអត្តនោម័តឆ្វេងជ្រុល និងនិយមជ្រុលរបស់វា។ ការពិត ប៉ុល ពត គ្មានស្គាល់អ្វីដែលហៅថាសង្គមនិយម ក្រៅពីការលុបបំបាត់ចោលរបបកម្មសិទ្ធិឯកជន និងកសាងរបបកម្មសិទ្ធិសមូហភាពនោះឡើយ។ ពួកនេះគ្មានបាន

យល់អ្វីដែលហៅថាក្រឹត្យក្រមសត្យានុម័ត ក្រៅពីគំនិតអត្តនោម័តរបស់វាឡើយ។ ចំណុចលេចឡើងជាបឋមនៃមាគ៌ារបស់ ប៉ុល ពត គឺការដើរផ្ទុយជាមួយក្រឹត្យក្រមនៃទំនាក់ទំនង រវាងកម្លាំងផលិតកម្មជាមួយទំនាក់ទំនងផលិតកម្ម។ តាមក្រឹត្យក្រម ការរៀបចំទំនាក់ទំនងផលិតកម្មត្រូវតែស្របជាមួយចរិត និងកំរិតនៃកម្លាំងផលិតកម្ម ប៉ុន្តែ ប៉ុល ពត បែរជាយកនយោបាយឆ្វេងជ្រុលរបស់ខ្លួន ដើម្បីរៀបចំនូវទំនាក់ទំនងផលិតកម្មមួយដែលហៅថា សមូហភាព តាមរយៈនៃការបំផ្លាញចោលនូវកម្លាំងផលិតកម្ម ពោលគឺជាការរៀបចំនូវទំនាក់ទំនងផលិតកម្មដោយចាប់បង្ខំ តាមរយៈនៃកម្លាំងនយោបាយរបស់ខ្លួន។

ដើម្បីបំផ្លាញចោលនូវទំនាក់ទំនងផ្លាស់ប្តូរទំនិញ សំដៅលុបបំបាត់របបកម្មសិទ្ធិឯកជន ប៉ុល ពត បានប្រកាសនៅថ្ងៃ ៣០ កញ្ញា ១៩៧៦ ក្នុងឱកាសខួបលើកទី ១៦ របស់បក្សថា «លុយគឺជាឧបករណ៍មួយពិសពុលបំផុត វាទាញយើងអោយរកឯកជនវិញរាល់ពេលរាល់វេលា។ បើមានលុយ យើងចេះតែចង់ទិញនេះទិញនោះ។ ឥឡូវនេះ គ្មាននរណានឹកនាចង់ចាយលុយទេ។ នេះជាលក្ខណសម្បត្តិមួយសំខាន់ អនុគ្រោះអោយយើង កំចាត់ចោលគោលជំហរកម្មសិទ្ធិឯកជន និងបំពាក់គោលជំហរសមូហភាពបានឆាប់រហ័ស»។ ជាមួយគ្នា ប៉ុល ពត ចាត់ទុកជាលក្ខណសម្បត្តិងាយស្រួល ដល់ការកសាងសង្គមសមូហភាពមួយទៀត គឺគ្មានប្រាក់ខែ។ វាចាត់ទុកថា «បើមានលុយ មានប្រាក់ខែ លុយវាគាបត្បៀតយើងជាប់ ហើយទាញយើងមិនអោយទៅសមូហភាពបានទេ»។ ប៉ុល ពត បានសន្និដ្ឋានថា ការបំបាត់ផ្សារលក់ដូរនៅតំបន់

*រំដោះនាឆ្នាំ ១៩៧២ និងបំបាត់ទាំងស្រុងនៅទូទាំងប្រទេសក្រោយឆ្នាំ ១៩៧៥ បំបាត់ចោលការចាយលុយ គឺជាការវាយចំទៅលើមូលដ្ឋាននៃវណ្ណៈនាយទុន សក្តិភូមិតែម្តង ហើយចាត់ទុកថានេះជាវិធានការសំខាន់ក្នុងការលុបចោលរបបកម្មសិទ្ធិឯកជន កសាងរបបកម្មសិទ្ធិសមូហភាព។*

*ដើម្បីកសាងសង្គមមួយថ្មី ដែលប្លែកពីគេ បានជំរុញពួក ប៉ុល ពត អោយលុបចោលនូវអ្វីៗ ទាំងអស់ ដែលគេសំគាល់ថាជាសំណល់នៃរបបចាស់ រាប់តាំងពីមនោសញ្ចេតនាឡើងទៅ។*

*ប៉ុល ពត បានអោយនិយមន័យទៅលើការកសាងសង្គមនិយម <u>ត្រឹមតែរបបកម្មសិទ្ធិសមូហភាពតែប៉ុណ្ណោះ។ សមូហភាព គឺជាខ្លឹមសារពិតប្រាកដនៃសង្គមនិយមរបស់ ប៉ុល ពត ហើយការរៀបចំនូវទំនាក់ទំនងសមូហភាពនេះ គឺប្រើប្រាស់នយោបាយ និងហិង្សាទាំងស្រុង។</u> ដូច្នេះ បដិវត្តន៍សង្គមនិយមមានន័យថា ត្រូវកំចាត់ចោលនូវរាល់ កាកសំណល់នៃរបបសង្គមចាស់ គ្រប់ផ្នែក និងទាំងស្រុង តាមរយៈការតស៊ូវណ្ណៈដោយដាច់ខាត។ ឯការកសាងសង្គមនិយម គឺការរៀបចំនូវទំនាក់ទំនងសមូហភាពទាំងស្រុង និងដាច់ខាត តាមវិធានការនយោបាយ និងចាត់តាំង។*

*តាមរបៀបគិតគូររបស់ ប៉ុល ពត សង្គមថ្មីមួយត្រូវតែបានកសាងលើមូលដ្ឋានសមូហភាពទាំងស្រុង ដូច្នេះរបស់ដែលហៅថាបដិវត្តន៍សង្គមនិយមតាមរយៈការកំចាត់ និងកសាងសង្គមនិយម តាមរយៈការបង្កើតរបបសមូហភាព ត្រូវបានដំណើរការព្រមៗ គ្នា ក្នុងពេលតែមួយ។ ការចាប់ផ្តើមបានចេញដំណើរពីការតស៊ូវណ្ណៈដោយដាច់ខាត ហើយក៏ជាការបន្តដំណើរឆ្វេងជ្រុល ដែលពួក ប៉ុល ពត បានធ្វើ មុនពេលដណ្តើម*

បានអំណាច។ ការកំចាត់ចោលរបបកម្មសិទ្ធិឯកជន លុបបំបាត់ចោលរចនាសម្ព័ន្ធវណ្ណៈក្នុងសង្គម ត្រូវបានអនុវត្តក្នុងរយៈពេលដ៏ខ្លី។ ជំហានចាប់ផ្តើមក្រោយពេលដណ្តើមបានអំណាច គឺការជម្លៀសប្រជាជនចេញពីទីក្រុង ការផ្ទេរប្រជាជនពីកន្លែងមួយទៅកាន់កន្លែងមួយទៀត ដើម្បីកាត់ផ្តាច់ចោលនូវកម្មសិទ្ធិខាងមធ្យោបាយ ឧបករណ៍ផលិតកម្ម ការលុបបំបាត់ចោលការចាយវាយប្រាក់ និងការផ្លាស់ប្តូរទំនិញ ដើម្បីបំបាត់ចោលកម្មសិទ្ធិខាងទ្រព្យសម្បត្តិ។ តាមវិធានការនេះ ពួក ប៉ុល ពត បានស្រែកថា ជាជ័យជំនះដ៏ធំធេងក្នុងការសំរេចបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ព្រោះប្រជាជនដែលត្រូវចេញពីទីក្រុង ពីកន្លែងមួយទៅកាន់កន្លែងមួយទៀត អ្នកទាំងនោះមិនអាចនាំមកជាមួយនូវមធ្យោបាយ និងឧបករណ៍ផលិតកម្មទេ ហើយប្រសិនជាគេយកមកជាមួយនូវប្រាក់កាស មាស ពេជ្រ ក៏គ្មានតម្លៃដែរ ព្រោះគ្មានការចាយប្រាក់ គ្មានការលក់ដូរទំនិញ។ នេះជាជំហានលប់បំបាត់ចោលកម្មសិទ្ធិឯកជន ព្រមពេលជាមួយនឹងការបំផ្លាញចោលនូវកម្លាំងផលិតកម្មដែលមានក្នុងសង្គម ។ ជំហានបន្តក្រោមរូបភាព នៃបដិវត្តន៍សង្គមនិយម ដោយដាច់ខាត គឺការកាប់សម្លាប់ដែលបានប្រព្រឹត្តទៅយ៉ាងខ្លាំងបំផុត ក្រោមផ្លាកនៃការតស៊ូវណ្ណៈ។ ដំបូងគេឃើញការកាប់សម្លាប់នេះ ធ្វើឡើងចំពោះមន្ត្រី អ្នករដ្ឋការ នាយទាហាន ពលទាហាន ប៉ូលីស បញ្ញវ័ន្ត និងប្រជាជនដែលជម្លៀសចេញពីទីក្រុង តែបញ្ហានេះមិនត្រូវបានបញ្ចប់ក្នុងកំរិតនេះឡើយ វាបានដំណើរការទូទាំងសង្គមរាប់ទាំងក្នុងជួររបស់ ប៉ុល ពត ផង។

ក្នុងដំណើរការលុបបំបាត់ចោលវណ្ណៈក្នុងសង្គម ប៉ុល ពត មិនត្រឹមតែលុបបំបាត់ចោលរបបកម្មសិទ្ធិឯកជនផ្នែកមធ្យោបាយ និងឧបករណ៍ផលិតកម្មប៉ុណ្ណោះទេ តែថែមទាំងបំបាត់ចោលកម្មសិទ្ធិលើគ្រប់ផ្នែក រាប់ទាំងសមត្ថភាព និងមនោសញ្ចេតនារបស់មនុស្សទៀតផង។ ដោយហេតុនេះបានជាគេឃើញ ប៉ុល ពត តស៊ូបំបាត់ចោលនូវវណ្ណៈកម្មករពលករចាស់ ដែលគេហៅថាវណ្ណៈកម្មករឯកជន ពលករឯកជន បំបាត់ចោលកសិករចាស់ ដែលគេហៅថាកសិករឯកជន ហើយកសាងឡើងនូវវណ្ណៈកម្មករ ពលករ និងកសិករសមូហភាពថ្មី តម្រូវអោយមនុស្សទាំងអស់ត្រូវរស់នៅស៊ីចុក ធ្វើការងារជាសមូហភាពទាំងស្រុង។ តាមរបៀបនេះ គេបំបែកគ្រួសារអោយនៅដាច់ពីគ្នា ប្រុសដោយប្រុស ស្រីដោយស្រី កូន និងឪពុកម្ដាយរស់នៅដាច់ដោយឡែកពីគ្នាទៅតាមក្រុមរបស់គេ។ ឪពុកម្ដាយគ្មានសិទ្ធិលើកូន ព្រោះកូនក្លាយទៅជាកូនអង្គការ(*) រាប់ទាំងអាពាហ៍ពិពាហ៍ ក៏អង្គការជាអ្នកសំរេចទាំងស្រុង។ នេះហើយគឺជាការតស៊ូបំបាត់ចោលកម្មសិទ្ធិឯកជនខាងមនោសញ្ចេតនា។ ការកំចាត់ចោលរបបកម្មសិទ្ធិឯកជន ត្រូវបានដំណើរការតាមរយៈនៃការកំទេចចោលមនុស្ស មិនមែនត្រឹមកំរឹតរឹបអូសទ្រព្យសម្បត្តិនោះឡើយ។ ដូច្នេះការកាប់សម្លាប់ត្រូវបានពង្រីកក្របខ័ណ្ឌរបស់វា ពីមួយថ្ងៃទៅមួយថ្ងៃកាន់តែធំ។

គួររំលឹកថា ក្នុងដំណើរការដ៏ឆាប់រហ័ស នៃការបំបាត់ចោលវណ្ណៈ និងរបបកម្មសិទ្ធិឯកជន តាមជំហាននៃការកាប់សម្លាប់ កំទេចចោលនូវ

(*) អង្គការ គឺជាស្រទាប់កាន់អំណាច គឺបក្សរបស់ ប៉ុល ពត ដែលគេនិយមហៅសំរាប់អ្នកដឹកនាំ តាំងពីឃុំឡើងទៅ។

*មនុស្ស ត្រូវបានអនុវត្តតាមទ្រឹស្តី និងរបៀបមួយចំនួន៖*

*ទីមួយ ទ្រឹស្តីអំពីលោកទស្សនៈបដិវត្តន៍៖ ទ្រឹស្តីនេះ បានផ្សព្វផ្សាយរៀនសូត្រនៅក្នុងជួរកម្មាភិបាលសំខាន់ៗ តាំងពីមុនឆ្នាំ ១៩៧៥។ ទ្រឹស្តីនេះវិភាគសំខាន់អំពីការបែងចែកវណ្ណៈ ការតស៊ូវណ្ណៈក្នុងសង្គមកម្ពុជា ដែលចាត់ទុកទំនាស់បដិបក្ខស្លាប់រស់ មិនគ្រាន់តែរវាងវណ្ណៈកម្មករកសិករជាមួយវណ្ណៈនាយទុនសក្តិភូមិ ម្ចាស់ដី នាហ្មឺនមន្ត្រីប៉ុណ្ណោះទេ តែថែមទាំងមានទំនាស់បដិបក្ខស្លាប់រស់ រវាងកសិករក្រ កណ្តាលថ្នាក់ក្រោម កណ្តាលថ្នាក់កណ្តាល ជាមួយកសិករកណ្តាលថ្នាក់លើ កសិករមាន និងឈ្មួញកណ្តាលទៀតផង។ ឯកសារនេះ គឺជាមូលដ្ឋានទ្រឹស្តីបង្កើតនូវពួកនិយមជ្រុល ក្នុងការអនុវត្តន៍មាគ៌ាឆ្វេងជ្រុលរបស់ ប៉ុល ពត ក្នុងដំណាក់កាលបដិវត្តសង្គមនិយមរបស់វា ដែលវាឈានដល់ការកំទេចចោលមនុស្ស ក្រោមផ្លាកនៃការតស៊ូវណ្ណៈ។*

*ទីពីរ - វិធីវិចារវិទ្យាដែលពេលនោះហៅថា វិធីបដិច្ចសមុប្បាទ មិនមែនជាវិធីវិចារវិទ្យានៃទស្សនវិជ្ជាម៉ាក្ស-ឡេនីន ពិតប្រាកដនោះឡើយ តែជាវិធីមួយដែលពួក ប៉ុល ពត បានសរសេរជ្រើសរើសយកក្រឹត្យក្រមខ្លះសំដៅបំរើនូវឧបាយកលរបស់វា។ វិធីវិចារវិទ្យា ដែល ប៉ុល ពត បានយកមកផ្សព្វផ្សាយ និងបង្រៀនជាទូទៅ មានក្រឹត្យក្រម ៤ គឺ៖*

- *អ្វីៗទាំងអស់តែងមានការទាក់ទង*
- *អ្វីៗទាំងអស់តែងមានទំនាស់*
- *អ្វីៗទាំងអស់តែងមានការវិវត្តន៍*

- អ្វីៗទាំងអស់តែងមានការប្រែប្រួលពីបរិមាណទៅគុណភាព

គួររំលឹកផងដែរថា ចំណុចខ្សោយនៃបដិវត្តន៍កម្ពុជា គឺជួរកម្មាភិបាលបក្ខជនស្ទើរតែទូទៅ មិនបានសិក្សាដោយផ្ទាល់នូវអ្វីដែលហៅថាលទ្ធិម៉ាក្ស-ឡេនីន អ្វីដែលហៅថាលទ្ធិសង្គមនិយមវិទ្យាសាស្ត្រនោះឡើយ។ គេបានស្ថិតនៅក្នុងក្របខ័ណ្ឌនៃការយល់ដឹងដ៏ចង្អៀត អំពីបដិវត្តន៍ ហើយចេះបានតែតាមរយៈការបំភ្លៃរបស់ពួក ប៉ុល ពត ចង់អោយចេះតាមគំនិតរបស់វា។ ឯកម្មាភិបាលដែលបានរៀនសូត្រនៅវៀតណាម ក៏គ្មានលទ្ធភាពនឹងបញ្ចេញទ្រឹស្តីពិតប្រាកដនៃលទ្ធិម៉ាក្ស-ឡេនីន ហើយថែមទាំងពួក ប៉ុល ពត បានកំចាត់អស់ទៅទៀត។ អាស្រ័យហេតុនេះ បានជាទ្រឹស្តីរបស់ពួក ប៉ុល ពត បានពង្រីកខ្លួនដោយឯករាជ្យ នៅក្នុងជួរកម្មាភិបាល បក្ខជន បង្កើតជាក្រុមឆ្វេងជ្រុល និងនិយមជ្រុលកាន់តែច្រើន។

ក្រឹត្យក្រមទាំងបួននៃវិធីវិចារវិទ្យារបស់ ប៉ុល ពត បានបំរើដោយមានប្រសិទ្ធភាព ចំពោះដំណើរការបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមរបស់វា។ ពួក ប៉ុល ពត បានប្រើប្រាស់ក្រឹត្យក្រមទាំងនេះសំខាន់ក្នុងទំនាក់ទំនងរវាងមនុស្ស និងរបបនយោបាយ។ ឧទាហរណ៍ អ្វីៗ ទាំងអស់តែងតែមានការទាក់ទង បើសម្លាប់ឪពុកត្រូវសម្លាប់កូន សម្លាប់បងត្រូវសម្លាប់ប្អូនទៀត បើសិនជាទុកវាពិតជាសងសឹកវិញ។ ចេញពីនេះ កើតមានពាក្យស្លោក «ជីកស្មៅត្រូវជីកទាំងឫស» ធ្វើបែកចានមួយទាក់ទងដល់ការបំផ្លាញបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម។ល។ អ្វីៗទាំងអស់តែងមានទំនាស់ ទំនាស់គ្រប់ទិដ្ឋភាពទាំង

អស់ ហើយដោយផ្អែកលើគ្រឹត្យក្រម អ្វីៗទាំងអស់តែងមានការវិវត្តន៍ អ្វីៗ ទាំងអស់តែងមានការប្រែប្រួលពីបរិមាណទៅគុណភាព ទំនាស់ណាក៏សុទ្ធតែជាទំនាស់បដិបក្ខស្លាប់រស់ទាំងអស់។ គេតែងឮពាក្យជាទូទៅដែលពួក ប៉ុល ពត ធ្លាប់និយាយ ថ្ងៃនេះធ្វើអោយបាត់ផ្ទៃចបមួយ ថ្ងៃក្រោយនឹងក្បត់សង្គមនិយម ថ្ងៃនេះមើលគោអោយគោស៊ីស្រូវថ្ងៃក្រោយនឹងក្បត់បដិវត្តន៍ ថ្ងៃនេះលួចស្ងោរចេកស៊ី ឬអំពៅមួយដើម ថ្ងៃក្រោយនឹងក្បត់ជាតិ។ល។ និង ។ល។

ទីបី ប៉ុល ពត បានឆ្លៀតប្រើប្រាស់ស្នាមប្រេះឆារបស់ជាតិ ដើម្បីអនុវត្តការបង្ក្រាប និងត្រួតត្រា។ ត្រូវតែទទួលស្គាល់ថា ការប្រេះឆាក្នុងជនជាតិកម្ពុជា បានកើតមានយូរយារមកហើយ តាមរយៈនៃការបែកបាក់ ក្បាលម៉ាស៊ីនដឹកនាំប្រទេស។ ស្ដេចមានជម្លោះគ្នាអំពីការដណ្ដើមអំណាច ប្រជាជនត្រូវចែកជាពីរ ឬជាបី គាំទ្រម្ខាងៗ ឬនៅកណ្ដាល។ ក្រៅពីនេះ ក្នុងរបបអាណានិគមបារាំង និងក្នុងរបបសីហនុ មានការរើសអើងយ៉ាងខ្លាំងអំពីតំបន់ប្រជាជនរស់នៅ ដែលគេសង្កេតឃើញមានការបែងចែក ជាបួនតំបន់៖ **ទីមួយ** អ្នកទីក្រុង ទីប្រជុំជន **ទីពីរ** អ្នកកំពង់ ភាគច្រើនតាមទន្លេមេគង្គ **ទីបី** អ្នកស្រែ តំបន់ជនបទ ដែលធ្វើស្រែ **ទីបួន** ជនជាតិភាគតិច។ តំបន់ទីមួយ និងទីពីរ ច្រើនមានទំនាក់ទំនងល្អជាមួយគ្នា ហើយតំបន់ទាំងពីរនេះច្រើនមើលងាយមើលថោក ចំពោះតំបន់ទីបី និងទីបួន។ ជាមួយនេះ សង្គ្រាមឈ្លានពានរបស់អាមេរិក ក្នុងរយៈពេល ៥ ឆ្នាំ ក៏បានបែងចែកតំបន់ទីក្រុង ទីប្រជុំជន និងជនបទព្រៃភ្នំ អោយនៅដាច់ពីគ្នាដែលផ្នែកណាមួយនោះបានបង្កើតអោយមាន

កំហឹងរវាងគ្នា និងគ្នា រវាងប្រជាជននៅតំបន់ទាំងពីរនេះ។ នេះជាចំណុចខ្សោយមួយរបស់ជាតិ ដែល ប៉ុល ពត ធ្លៀតប្រើប្រាស់គួបផ្សំនឹងការបំផុសកំហឹងវណ្ណៈ។ ការជម្លៀសប្រជាជនទីក្រុង ទីប្រជុំជន ឬតាមដងទន្លេមេគង្គទៅកាន់តំបន់ជនបទព្រៃភ្នំ ហើយបែងចែកប្រជាជនជាបីប្រភេទ បង្កើតឡើងនូវភាពងាយស្រួលមួយ សំរាប់ការត្រួតត្រារបស់ ប៉ុល ពត (ប្រជាជនចាស់ គឺប្រជាជននៅមូលដ្ឋាននោះយូរហើយ ប្រជាជនថ្មី គឺប្រជាជនដែលត្រូវជម្លៀសចេញពីទីក្រុង ឬកន្លែងផ្សេង ទៅតាំងទីលំនៅថ្មីនៅមូលដ្ឋាននោះ ប្រជាជនថ្មី គឺប្រជាជនដែលជម្លៀសពីកន្លែងមួយទៅកន្លែងមួយ ហើយមិនទាន់កំណត់អោយតាំងទីលំនៅនៅកន្លែងណាមួយច្បាស់លាស់)។

ការប្រើប្រាស់ប្រជាជនចាស់ សំរាប់គ្រប់គ្រងប្រជាជនថ្មី គួបផ្សំនឹងការជ្រើសរើសកម្មាភិបាលដែលយកចេញពីស្រទាប់ក្របំផុត ទោះជាក្រដោយរបៀបណាក៏ដោយ គឺ ប៉ុល ពត មិនបានគិតគូរឡើយ អោយតែក្រ ហើយជាអ្នកនៅមូលដ្ឋាន សុទ្ធតែជាប្រភេទកម្មាភិបាលល្អរបស់ ប៉ុល ពត ដើម្បីអនុវត្តការតស៊ូវណ្ណៈដោយដាច់ខាតបំផុត ព្រោះអ្នកទាំងនោះមានកំហឹងស្រាប់ជាមួយអ្នកមានទ្រព្យសម្បត្តិ។ អាស្រ័យដោយទ្រឹស្តី និងរបៀបអនុវត្តរបស់ ប៉ុល ពត ដូចបានរៀបរាប់ខាងលើ គេបានបង្កើតឡើងនូវក្រុមដែដល់និយមជ្រុលដ៏ងងិតងងល់ ត្រៀមជាស្រេចដើម្បីអនុវត្តតាមបញ្ជារបស់អង្គការ ជាយន្តការនៃការកាប់សម្លាប់ និងត្រួតត្រាតាមទម្រង់នៃសង្គមមួយបែបថ្មី ដែលមិនដែលធ្លាប់មាន ក្នុងប្រវត្តិសាស្ត្រលើសកលលោក។ ជនទាំងឡាយដែលនៅក្នុង

យន្តការរបស់ ប៉ុល ពត ជាឃាតករដ៏សាហាវឃោរឃៅផង ជាអ្នករង គ្រោះ នៃរបបភេរវកម្មនេះផង។ គេអាចទទួលនូវទារុណកម្មភ្លាម បើ ត្រូវថ្នាក់លើសង្ស័យ។ ហេតុនេះហើយ ជានិច្ចកាល គេត្រូវបង្ហាញនូវ ភាពស្មោះត្រង់របស់ខ្លួន គឺកាប់សម្លាប់ជនរួមឈាមរបស់ខ្លួនឥត ញញើតដៃ។ តាមការជាក់ស្តែង មនុស្សស្ថិតក្នុងជួរ ប៉ុល ពត មួយ ចំនួនធំ គឺជាចំណាប់ខ្មាំង ក្នុងចំណោមនោះ មានមួយចំនួនជាចំណាប់ ខ្មាំងដងឹតដងល់ គេត្រូវធ្វើនូវអ្វីទាំងអស់ដើម្បីការរស់ផ្ទាល់ខ្លួនរបស់ គេ។ ក្នុងបំណងបង្ហាញនូវភាពស្មោះត្រង់របស់គេ ដើម្បីការរស់ផ្ទាល់ ខ្លួន គេមិនខ្លាចនឹងធ្វើសកម្មភាពដោយដាច់ខាតតាមបញ្ជារបស់អង្គ ការ ទោះជាត្រូវសម្លាប់សាច់ញាតិ មិត្តភក្តិ ក៏គេធ្វើដោយគ្មានញញើត ដៃ។ ក្នុងជំនាន់ ប៉ុល ពត គេបានឃើញមនុស្សមួយចំនួន ដែលជា អតីតអ្នកបួសអស់ច្រើនព្រះវស្សា ធ្វើជាអ្នកចាប់ផ្សឹកព្រះសង្ឃ ធ្វើគត ព្រះសង្ឃ វាយបំផ្លាញព្រះវិហារ ពុទ្ធបដិមាករ ដើម្បីបង្ហាញនូវភាព ស្មោះត្រង់ចំពោះអង្គការថា ខ្លួនបានចាកឆ្ងាយពីព្រះពុទ្ធសាសនា បដិបក្ខជាមួយព្រះពុទ្ធសាសនាហើយ។ នេះហើយ ដែលយើងនិយាយ ថាមនុស្សទាំងឡាយដែលស្ថិតនៅក្នុងយន្តការកាប់សម្លាប់របស់ ប៉ុល ពត ជាឃាតករផង និងជាជនរងគ្រោះផង ដូច្នេះបានជាគេឃើញថា មនុស្សមួយចំនួនត្រូវបានពួក ប៉ុល ពត ប្រើអោយសម្លាប់អ្នកដទៃ តែ មិនយូរប៉ុន្មាន ខ្លួនក៏ត្រូវពួក ប៉ុល ពត សម្លាប់បន្តដែរ។

តាមរយៈនៃការបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម ដោយដាច់ខាត ក្នុងរយៈពេលមួយដ៏ខ្លី សង្គមកម្ពុជាបានផ្លាស់ប្តូរទៅ

*កាន់ទ្រង់ទ្រាយនៃសង្គមមួយ ដែលគេនឹងពិបាកកំណត់ថា វាជាសង្គមអ្វី។ របបប្រល័យពូជសាសន៍ គឺជាន័យត្រឹមត្រូវណាស់ សំរាប់របប ប៉ុល ពត ប៉ុន្តែប្រល័យពូជសាសន៍ក្នុងស្ថានភាពសង្គមបែបណា គឺជាការពិបាកកំណត់ អាស្រ័យដោយការវិវត្តន៍នៃសង្គមមនុស្ស មិនដែលបានជួបប្រទះដូចនេះឡើយ។ តាមលទ្ធិសំការៈនិយមប្រវត្តិសាស្ត្រ ក៏គ្មានទ្រឹស្តីណាកំណត់អំពីស្ថានភាពសង្គមបែប ប៉ុល ពត នេះឡើយ ព្រោះវាក៏មិនមែនជាបែបផែននៃសង្គមកុម្មុយនិស្តបុព្វកាល មិនមែនជាបែបផែនទាសភាព បែបផែនសក្តិភូមិ ឬបែបផែននាយទុននោះឡើយ ហើយក៏កាន់តែមិនមែនជាបែបផែនសង្គមនិយម ឬកុម្មុយនិស្តនិយមនោះឡើយ ទោះបី ប៉ុល ពត ប្រើពាក្យសង្គមនិយមក៏ដោយ។*

*ប្រសិនបើធ្វើការប្រៀបធៀប គេពិនិត្យឃើញនូវចំណុចមួយចំនួននៃសង្គមកម្ពុជា ក្រោមរបប ប៉ុល ពត ប្រហាក់ប្រហែលជាមួយនឹងបែបផែនទាសភាព តែក៏មានចំណុចមួយចំនួនខុសប្លែកដែរ អាស្រ័យដោយលក្ខណសម្បត្តិសង្គមកម្ពុជា នាទសវត្សទី ៧០ នេះ ខុសប្លែកពីសម័យទាសភាពនាពេលមុន។*

### ក្នុងបញ្ហារចនាសម្ព័ន្ធវណ្ណៈ និងក្បាលម៉ាស៊ីនត្រួតត្រាសង្គម៖

*អាស្រ័យដោយបានបំផ្លាញចោលនូវកម្លាំងផលិតកម្ម និងទំនាក់ទំនងផលិតកម្មចាស់ ហើយរៀបចំនូវទំនាក់ទំនងផលិតកម្មថ្មី ដោយមិនផ្អែកលើមូលដ្ឋាននៃកម្លាំងផលិតកម្ម តែផ្អែកលើនយោបាយ និងចាត់តាំងជាសំខាន់នោះ ព្រមជាមួយនឹងនយោបាយសេដ្ឋកិច្ចផ្អែកទាំងស្រុងលើកសិកម្ម ក្នុងពេលដែលត្រូវលុបចោលទាំងស្រុង នូវទំនាក់*

ទំនង៉ផ្លាស់ប្តូរទំនិញ ប្រាក់កាស និង៉ក្នុងពេលអនុវត្តនយោបាយបិទទ្វារជាមួយពិភពលោកខាង៉ក្រៅ រចនាសម្ព័ន្ធវណ្ណៈ ក្នុងសង្គមជាទូទៅ គឺសុទ្ធតែជាកសិករ ដែលពួក ប៉ុល ពត ហៅថាកសិករសមូហភាព ដែលជាតុពិត គឺជាទាសករសុទ្ធសាធ។ តាម ប៉ុល ពត លើកឡើងគឺនៅកម្ពុជាក្រោយឆ្នាំ ១៩៧៥ មានរូបភាពចាត់តាំងវណ្ណៈតែពីរទេ គឺកម្មករសមូហភាព និងកសិករសមូហភាព ហើយនៅក្បែរនោះមានជួរបដិវត្តដែលពួក ប៉ុល ពត ចាត់ទុកជាស្រទាប់មួយដែរ។ កម្មករដែល ប៉ុល ពត ចង់និយាយនេះ មិនមែនជាជួរវណ្ណៈកម្មករដែលបានផ្សារភ្ជាប់ជាមួយផលិតកម្មឧស្សាហកម្មតាំងពីមុនមកទេ។ កម្មករចាស់ទាំងនោះស្ថិតនៅក្នុងមុខសញ្ញាត្រូវកំចាត់ អាស្រ័យដោយគេចាត់ទុកថាជាកម្មករឯកជន។ ដូច្នេះកម្មកររបស់ ប៉ុល ពត គឺជាកម្មករថ្មីសុទ្ធសាធដែលបានផ្ទេរពីកសិករ ឬពីកង៉ទ័ពចូលមក ដែលគ្មានមុខជំនាញជាកម្មករឡើយ ហើយអាស្រ័យដោយពោង៉ចក្រ សហគ្រាស ស្ទើរតែទាំងអស់ត្រូវបានបិទទ្វារ កម្មករថ្មីនេះច្រើនស្ថិតក្នុងចំការកៅស៊ូ កម្មករកាប់ឈើ ស្រែអំបិល ដឹកជញ្ជូន ឬជាងជួសជុល ឬកន្ទេងផលិតរបៀបជាសិប្បកម្មខ្លះ។ ដូច្នេះ កម្មករថ្មីនេះមានចំនួនតិចបំផុត ហើយជាទូទៅ ស្ថិតក្នុងចរិតជាទាសករដែរ វាមិនមែនជាប្រភេទនៃវណ្ណៈកម្មករ ឬវណ្ណៈអធនដែលគេធ្លាប់ឃើញ ក្នុងក្របខ័ណ្ឌនៃទំនាក់ទំនងផលិតកម្មមូលធននិយម ឬសង្គមនិយមនោះឡើយ។

អាស្រ័យដោយការកាប់សម្លាប់ ដោយសិទ្ធិរបស់គេត្រូវបានដកហូត អាស្រ័យដោយពលកម្មរបស់គេ គ្មានបានទទួលនូវផលប្រយោជន៍អ្វី

សំរាប់ខ្លួនគេ និងអាស្រ័យដោយស្ថិតនៅជាចំណាប់ខ្មាំងនៃពួកក្តាប់អំណាច មនុស្សទាំងអស់ដែលពួក ប៉ុល ពត ចាត់ទុកថាជាកម្មករសមូហភាព ជាកសិករសមូហភាពសុទ្ធសឹងតែជាទាសករទាំងអស់ ព្រោះវាគ្មានចំណុចត្រង់ណា សំរាប់វិនិច្ឆ័យថា អ្នកទាំងនេះជាកម្មករ ឬជាកសិករឡើយ គេទាំងឡាយប្រៀបដូចជាឧបករណ៍ចេះនិយាយ ដែលគេប្រើប្រាស់ដូចឧបករណ៍។

ដូច ប៉ុល ពត បានកំណត់ នៅក្បែរវណ្ណៈកម្មករ កសិករសមូហភាព គឺមានជួរបដិវត្ត ដែលជួរបដិវត្តនេះ ធាតុពិតគឺជាក្រុមឆ្វេងជ្រុល និងនិយមជ្រុលដែលគេហៅថា អង្គការ។ អង្គការបានក្លាយទៅជា ស្រទាប់នៃម្ចាស់ទាសករ ដែលមានអំណាចគ្រប់បែបយ៉ាងរាប់ទាំងអំណាចសម្លាប់មនុស្សដោយសេរី។ ប៉ុល ពត ក៏បានលើកឡើងអំពីការតស៊ូកុំអោយជួរបដិវត្តដាច់ចេញពីកម្មករ និងកសិករសមូហភាព ប៉ុន្តែអាស្រ័យដោយសំណូមពរក្នុងការគ្រប់គ្រង សង្គមមួយបែបទាសភាពរបៀបនេះ វាមិនអាចនឹងមិនបង្កើតនូវក្បាលម៉ាស៊ីនត្រួតត្រាមួយ ដែលមានបណ្តាញពីលើចុះក្រោមបានទេ។ ក្បាលម៉ាស៊ីននោះហើយ គឺជាសម្ព័ន្ធកាន់អំណាច ដែលគេហៅថា អង្គការ ដែលចរិតពិតប្រាកដរបស់វា គឺជាម្ចាស់ទាសករ។ អំពីធាតុពិតរបស់វណ្ណៈរបស់ ប៉ុល ពត នឹងអាចចោទឡើងនូវការងឿងឆ្ងល់ថា តើធាតុវណ្ណៈពិតប្រាកដរបស់វាជាអ្វី ដែលបញ្ជាទៅក្នុងមនោគមវិជ្ជា និងបណ្តាសកម្មភាពរបស់ពួកនេះ អាស្រ័យដោយធាតុដើមរបស់មេដឹកនាំសំខាន់ៗ នៃរបបនេះ ភាគច្រើនជាកសិករ និងអនុជន។ នេះជាបញ្ហាមួយ ក្នុងចំណោមបញ្ហាដែលត្រូវបន្តស្រាវ

ជ្រាវ អំពីបាតុភាពរបស់ ប៉ុល ពត។

តាមពិត ទាំងសាមីខ្លួន ប៉ុល ពត ទាំងមេដឹកនាំសំខាន់ៗ នៃរបប នេះ ភាគច្រើនប្រសូត្រចេញពីកសិករ និងអនុជន អាចជាចំណុចចាប់ផ្តើមរបស់ពួកនេះ គឺចេញពីគោលជំហរកសិករ និងអនុជន មិនមែនពីគោលជំហររបស់កម្មករ ឬអជនឡើយ។ ដោយហេតុថា មូលដ្ឋានមនោគមវិជ្ជារបស់ពួក ប៉ុល ពត មានប្រភពពីមនោគមវិជ្ជា ម៉ៅ សេទុង ដែលចេញពីគោលជំហរកសិករ និងអាស្រ័យដោយហេតុថា ពួក ប៉ុល ពត ជានិច្ចកាលស្ថិតក្នុងគោលជំហរឆ្វេងជ្រុល និងនិយមជ្រុល ព្រមទាំងដើរតាមលទ្ធិគំនិតនិយមអត្តនោម័ត ម្យ៉ាងទៀត អាស្រ័យដោយទំនាក់ទំនងផលិតកម្មនៃរបប ប៉ុល ពត ជាទំនាក់ទំនងបែបទាសភាពនោះ ជាតុពិតវណ្ណៈពិតប្រាកដរបស់ ប៉ុល ពត ដែលបញ្ចាំទៅលើនយោបាយ និងសកម្មភាព គឺជាម្ចាស់ទាសករដ៏កំណាចឃោរឃៅ។ ការអះអាងនៅទីនេះ សំខាន់គឺផ្អែកទៅលើទំនាក់ទំនងរវាងរចនាសម្ព័ន្ធថ្នាក់ក្រោម និងរចនាសម្ព័ន្ធថ្នាក់លើ ក្នុងក្របខ័ណ្ឌសង្គមមួយ។

រចនាសម្ព័ន្ធគ្រប់គ្រង និងត្រួតត្រាក្នុងសម័យ ប៉ុល ពត ប្លែកទាំងស្រុងពីប្រទេសនានា និងសង្គមកម្ពុជានាសម័យមុនៗ។ ពិតមែនហើយ ដើម្បីបោកប្រាស់សាធារណមតិសកលលោក ប៉ុល ពត បានធ្វើជារៀបចំការបោះឆ្នោត បង្កើតឡើងនូវរដ្ឋសភា រដ្ឋាភិបាល និងអង្គការតុលាការ ដែលមានអំណាចទាំងបី ដូចគេឯងដែរ គឺអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ ប៉ុន្តែលើការជាក់ស្តែងផ្ទុយពីនេះទាំងស្រុង អំណាចពិតប្រាកដ មានតែសម្ព័ន្ធកាន់អំណាច

*មួយប៉ុណ្ណោះ ដែលប្រមូលផ្តុំសុទ្ធតែពួកនិយមជ្រុលនៅគ្រប់លំដាប់ថ្នាក់ ដែលគេហៅថា អង្គការ។ ពាក្យ អង្គការមួយម៉ាត់គ្របដណ្តប់បានអំណាច ទាំងបក្ស ទាំងនីតិបញ្ញត្តិ ទាំងនីតិប្រតិបត្តិ និងទាំងអំណាចតុលាការ។ ក្រោយពេលដណ្តើមបានអំណាចភ្លាម គេប្រកាសរំសាយភ្លាមនូវអង្គការរណសិរ្សគ្រប់ថ្នាក់នៅក្នុងប្រទេស សល់តែ សីហនុ និងមនុស្សមួយចំនួនដែលមិនទាន់ចូលក្នុងប្រទេសទេ ដែលនៅមានឈ្មោះជារណសិរ្ស។ ឯគណៈកម្មាធិការបំរើប្រជាជននៅភូមិ ឃុំ រំសាយបញ្ចូលជាគណៈដឹកនាំសហករណ៍ ហើយបន្ទាប់មកជាគណៈបញ្ជាការកងផលិតតូច គណៈបញ្ជាការកងផលិតធំ(*)។ ចំពោះថ្នាក់ស្រុកឡើង ទោះបីនៅមានគណៈកម្មាធិការប្រជាជន ក៏គ្មានធ្វើសកម្មភាពអ្វីត្រូវនឹងសមត្ថកិច្ចជារដ្ឋអំណាចដែរ។ ដើម្បីងាយស្រួលគ្រប់គ្រង ប៉ុល ពត បានបង្កើតឡើងនូវតំបន់រដ្ឋបាលមានភូមិភាគ តំបន់ ស្រុក កងផលិតធំ(ឃុំ) កងផលិតតូច(ភូមិ)។ ភូមិភាគមិនមែនជាថ្នាក់ គ្រាន់តែគ្រប់គ្រងខាងយោធាជាយោធភូមិភាគ ដូចទម្លាប់ដែលគេធ្លាប់ធ្វើនោះទេ តែជាក្បាលម៉ាស៊ីនគ្រប់គ្រងលើគ្រប់វិស័យ។*

*តាមការរៀបចំរបៀបនេះ គេបានបង្កើតឡើងនូវក្បាលម៉ាស៊ីនបង្ក្រាបថ្នាក់ភូមិភាគមួយថ្នាក់ទៀត បន្ថែមលើខេត្តក្រុង ដែលមុននោះមានតែ ១៨ ទៅ ជា ២៨ តំបន់ ជំនួសអោយខេត្ត ដោយមិនទាន់គិតភូមិភាគពិសេសភ្នំពេញផង។ នៅតាមថ្នាក់នីមួយៗ ចាប់ពីថ្នាក់ស្រុកឡើងគេមានបង្កើតស្ថាប័នជំនួយការខ្លះ ប៉ុន្តែសំខាន់គេចាត់គណៈបញ្ជាការ ក្នុង*

(*) ចាប់ពីឆ្នាំ ១៩៧៦ មក ភូមិចាត់តាំង ជាកងផលិតតូច ឃុំចាត់តាំង ជាកងផលិតធំ។

*នោះគណៈបញ្ជាការសេដ្ឋកិច្ច ត្រូវបានចាត់តាំង តាំងពីមជ្ឈិមរហូតដល់កងផលិតតូច ដូចជាគណៈបញ្ជាការយោធាដែរ (*)។ អ្នកដឹកនាំគ្រប់ថ្នាក់ បានក្លាយទៅជាស្រទាប់ម្ចាស់ទាសករយ៉ាងព្រៃផ្សៃ ពិតមែនតែវាមិនដូចជាកុលសម្ព័ន្ធ ដូចសង្គមទាសភាពនាសម័យមុនដែលគ្មានខ្សែរយៈច្រើនថ្នាក់ តែនេះគឺជាបែបផែនទាសភាពមួយ ដែលមានការចាត់តាំងក្បាលម៉ាស៊ីនបង្ក្រាបជាខ្សែចង្វាក់ ដោយពួកម្ចាស់ទាសករថ្មី។*

## <u>ក្នុងបញ្ហាសេដ្ឋកិច្ច-សង្គម៖</u>

*របបទាសភាព ប៉ុល ពត ខុសគ្នាជាមួយរបបទាសភាពចាស់ នៅត្រង់ របបទាសភាពចាស់ជាកាំជណ្ដើរនៃការវិវត្តន៍ តាមក្រិត្យក្រមរីកចំរើននៃទំរង់សេដ្ឋកិច្ចសង្គម ហើយកើតឡើងនូវស្រទាប់វណ្ណៈម្ចាស់ទាសករ និងទាសករ ដែលជាមូលហេតុសំខាន់ នៃការផ្ទេរពីដំណាក់កាលសង្គមកុម្មុយនិស្តបុព្វកាលមកសង្គមទាសភាព ឯរបបទាសភាព ប៉ុល ពត បានដើរបញ្ច្រាសត្រឡប់ទៅវិញ គឺផ្ទេរពីសង្គមសក្តិភូមិ ដែលមានទំនាក់ទំនងផលិតកម្មមូលធននិយមមួយផ្នែក ទៅកាន់ដំណាក់កាលទាសភាពវិញ។ ប៉ុន្តែ បើពិនិត្យក្នុងក្របខ័ណ្ឌនៃទំនាក់ទំនងផលិតកម្មនាសម័យ ប៉ុល ពត គឺ <u>ជាទំនាក់ទំនងផលិតកម្មនៃសង្គមទាសភាពនៅត្រង់ អង្គការជាអ្នកក្ដាប់ទាំងស្រុងអំពីមធ្យោបាយផលិតកម្ម ជាអ្នកមានឋានៈពេញទី ក្នុងការចាត់តាំងពលកម្ម និងជាអ្នកមានសិទ្ធិពេញទីក្នុងការបែងចែកផលិតផលពលកម្ម។ រាល់ទំនាក់ទំនងទាំងនេះ បានក្លាយទៅជារចនាសម្ព័ន្ធថ្នាក់ក្រោម ដែលមានអង្គការជាអ្នកត្រួតត្រា។</u>*

(*) កំណត់ហេតុប្រជុំមជ្ឈិម ថ្ងៃ ២១ ដល់ ២៣/០៨/៧៦ អំពីផែនការ ៤ ឆ្នាំ លើកទី ១ "១៩៧៧-១៩៨០"។

ចេញពីនោះ អង្គការក៏បានក្លាយទៅជារចនាសម្ព័ន្ធថ្នាក់លើ ដែលតែង រកគ្រប់វិធីរហូតដល់ការអនុវត្តន៍ការប្រល័យពូជសាសន៍ ដើម្បីការពារ ទំនាក់ទំនងផលិតកម្មបែបទាសភាពនេះ។ និយាយពីអង្គការ ដែល ចាត់ទុកដូចជាស្រទាប់នៃវណ្ណៈម្ចាស់ទាសករ មិនមានន័យថា អ្នកណា ក៏ដោយអោយតែស្ថិតនៅក្នុងជួរ ប៉ុល ពត សុទ្ធតែប្រដូចជាមួយវណ្ណៈ ម្ចាស់ទាសករនោះឡើយ។ ស្រទាប់នេះ ប្រមូលផ្តុំពួកអ្នកមានសិទ្ធិអំ ណាចពិតប្រាកដ មានបុព្វសិទ្ធិពិសេស រហូតដល់មានអំណាចសម្លាប់ មនុស្ស បានតាមចិត្តទៀតផង។ ពួកអ្នកមានសិទ្ធិអំណាចទាំងនេះ ការ ពិតគេមានជីវភាពធូរធារ សម្បូរសប្បាយខ្លាំងមែនទែន ក្នុងពេលប្រជា ជននៅទូទាំងប្រទេសកំពុងស្លាប់ដោយអត់ឃ្លានដោយជំងឺ និងដោយ ការកាប់សម្លាប់។ ដូច្នេះការចាត់ទុកពួកកាន់អំណាចស្ថិតក្នុងប្រភេទនៃ ពួកម្ចាស់ទាសករ គឺមិនមែនជារឿងហួសហេតុនោះឡើយ។

តាមទំនាក់ទំនងរបៀបនេះ គេអាចប្រៀបធៀបបានថាសង្គមកម្ពុជា ក្រោមរបប ប៉ុល ពត មានចរិតប្រហាក់ប្រហែលជាមួយសង្គមទាស ភាពជាងសង្គមផ្សេងៗ ដែលបានកើតឡើងក្នុងប្រវត្តិសាស្ត្ររបស់មនុស្ស អាស្រ័យដោយទំនាក់ទំនងផលិតកម្ម អាស្រ័យដោយរចនាសម្ព័ន្ធវណ្ណៈ ការចាត់តាំងរដ្ឋអំណាច ដោយមានការឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាង រចនាសម្ព័ន្ធថ្នាក់ក្រោម និងរចនាសម្ព័ន្ធថ្នាក់លើនៃសង្គមទាសភាព។ ក្នុងបញ្ហាសេដ្ឋកិច្ចសង្គម ក៏គួរលើកឡើងអំពីមហិច្ឆតារបស់ ប៉ុល ពត ដែលបញ្ហានេះ វាបានក្លាយទៅជាទំនាស់ដ៏ធំ រវាងមហិច្ឆិតាជាមួយនឹង សមត្ថភាពពិតប្រាកដរបស់ ប៉ុល ពត ដែលជាកត្តាមួយជំរុញអោយពួក

ប៉ុល ពត ឈានដល់ការប្រល័យពូជសាសន៍។

ក្នុងពេលបាន និងកំពុងបំផ្លាញចោលនូវកម្លាំងផលិតកម្ម ដែលសេសសល់ពីរបបចាស់ បាននិងកំពុងដំណើរការកាប់សម្លាប់យ៉ាងធំទូលាយ ក្នុងនេះមានជួរកម្មករ អ្នកបច្ចេកទេស បញ្ញាវន្ត បំបិទចោលសាលារៀន បាននិងកំពុងដំណើរការសមូហភាវូបនីយកម្មលើគ្រប់ផ្នែក និងគ្រប់វិស័យ តាមរយៈនៃការបំបាត់ចោលរបបកម្មសិទ្ធិឯកជនលើគ្រប់ផ្នែក និងការកសាងទំនាក់ទំនងសមូហភាពលើគ្រប់ផ្នែក ដែលបង្កើតឡើងនូវទំនាស់យ៉ាងជ្រាលជ្រៅក្នុងសង្គម ដំបូងទំនាស់រវាងកម្លាំងផលិតកម្ម និងទំនាក់ទំនងផលិតកម្ម ដែលវាមិនសមស្របជាមួយគ្នា ផលិតកម្មមានការធ្លាក់ចុះ ការអត់ឃ្លានបាននិងកំពុងកើតមាននៅទូទាំងប្រទេស។ ពួក ប៉ុលពត បានលើកឡើងនូវពាក្យស្លោក «<u>មហាលោតផ្លោះ មហាអស្ចារ្យ</u>» ហើយបានដាក់ចេញនូវផែនការកសាងសង្គមនិយមអោយសំរេចក្នុងរយៈពេល ១០-១៥ ឆ្នាំ។ ខ្លឹមសារដែលពួក ប៉ុល ពត កំណត់ក្នុងការសំរេចផែនការកសាងសង្គមនិយម ១០-១៥ ឆ្នាំ គឺការប្រែក្លាយកសិកម្មឱនថយទៅជាកសិកម្មសម័យ ហើយកំណត់ទិសប្រែក្លាយពីប្រទេសកសិកម្មទៅជាប្រទេសឧស្សាហកម្ម ក្នុងរង្វង់ពី ១៥-២០ ឆ្នាំ។ ចេញពីការកំណត់ទិសដៅរបៀបនេះ ប៉ុល ពត បានលើកឡើងនូវផែនការ ៤ ឆ្នាំ លើកទី ១ (១៩៧៧-១៩៨០)។ ដោយប្រើប្រាស់នយោបាយកំណត់ទៅលើអ្វីៗ ទាំងអស់ ក្នុងដំណើរវិវត្តរីកចំរើននៃផលិតកម្ម និងទំនាក់ទំនងក្នុងសង្គម ប៉ុល ពត បានកំណត់ថា «បើរបបសមូហភាពរឹង ព្រែកជីកក៏ធ្វើរហ័ស ប្រព័ន្ធភ្លឺស្រែក៏ធ្វើរហ័ស

ព្រោះគ្មានអ្វីប្រទាញ»(*)។ ដូចនេះ របបនយោបាយ វាជាកត្តាសំរេច វាជំរុញការចាត់ចែងផលិតកម្ម(**)។ តាមអត្ថនោម័តនៃពួកគំនិតនិយមឆ្វេងជ្រុល និងនិយមជ្រុល ពួកគេបានលើកឡើងនូវតួលេខជាក់ស្តែង និងគោលដៅខ្ទះ នៃវិស័យសេដ្ឋកិច្ចតាមផ្នែកនីមួយៗ ក្នុងនោះមានវិស័យកសិកម្ម «គឺក្នុងរយៈ ៤ ឆ្នាំ នៃផែនការលើកទី ១ នេះ ត្រូវសំរេចអោយបាននូវការនាំចេញអង្ករជាងមួយលានតោនស្មើនឹង ១.៣៩៥.៦៤០.០០០ ដុល្លារអាមេរិក ក្រោយពីការទុកហូប ទុកពូជ គ្រប់គ្រាន់សំរាប់ក្នុងស្រុក ហើយសរុបទាំងកៅស៊ូ និងផលិតផលផ្សេងៗ ទៀត ត្រូវនាំចេញអោយបាន ១.៤៩៤.៦៤០.០០០ ដុល្លារអាមេរិក ក្នុងរង្វង់ ៤ ឆ្នាំ នៃផែនការលើកទី ១ នេះ(***)។

ខាងឧស្សាហកម្ម ប៉ុល ពត បានលើកថា «យើងត្រូវឈរលើកសិកម្ម ដើម្បីកសាងឧស្សាហកម្ម ដោយត្រូវកសាងទាំងឧស្សាហកម្មស្រាល និងឧស្សាហកម្មធ្ងន់»។ ចេញពីទិសដៅនេះ គេបានកំណត់មុខព្រួញត្រូវធ្វើ មានប្រភេទឧស្សាហកម្មស្រាល ដូចជា តម្បាញ ស្បៀង ប្រដាប់ប្រដារប្រើប្រាស់ផ្សេងៗ។ ខាងឧស្សាហកម្មធ្ងន់ មានការផលិតគ្រឿងចក្រកសិកម្ម ដូចជា ម៉ាស៊ីនបូមទឹក ម៉ាស៊ីនបោកស្រូវ ម៉ាស៊ីនកិនស្រូវ ត្រាក់ទ័រ ម៉ាស៊ីនអារឈើ។ ប៉ុល ពត កំណត់ច្បាស់ថា «៤-៥ ឆ្នាំខាងមុខ ត្រូវធ្វើត្រាក់ទ័រ ម៉ាស៊ីនបូមទឹក ម៉ាស៊ីនបោកស្រូវដោយខ្លួនឯងអោយបាន»។ ក្រៅពីនោះ គេលើកផែនការអភិវឌ្ឍន៍ឧស្សាហកម្ម មានឧស្សាហ

(*) គ្មានស្អីប្រទាញ គឺគ្មានរបបកម្មសិទ្ធឯកជន។

(**) កំណត់ហេតុប្រជុំមជ្ឈិម ប៉ុល ពត ពីថ្ងៃ ២១ ដល់ ២៣ ខែ សីហា ឆ្នាំ ១៩៧៦។

(***) ផែនការ ៤ ឆ្នាំ លើកទី ១ (១៩៧៧/១៩៨០) របស់ ប៉ុល ពត។

កម្មដែកថែប ឧស្សាហកម្មគីមី ឧស្សាហកម្មរ៉ែ ឧស្សាហកម្មថាមពលអគ្គិសនី ឧស្សាហកម្មប្រេងកាត ឧស្សាហកម្មសំភារៈសំណង់ (*) និងឧស្សាហកម្មផ្សេងទៀតជាច្រើន។

គួរអោយភ្ញាក់ផ្អើលយ៉ាងខ្លាំង នៅពេលពិនិត្យឃើញផែនការដ៏ធំសម្បើមរបស់ ប៉ុល ពត ទាំងក្នុងវិស័យកសិកម្ម ទាំងក្នុងវិស័យឧស្សាហកម្ម ក្នុងពេលប្រជាជនកំពុងអត់ឃ្លាន ផលិតកម្មកសិកម្មមិនគ្រប់គ្រាន់ប្រើប្រាស់ក្នុងស្រុក ក្នុងពេលរោងចក្រសហគ្រាសជាច្រើនកំពុងបិទទ្វារ និងកំពុងត្រូវបំផ្លាញ ក្នុងពេលគ្មានអ្នកបច្ចេកទេស ហើយបន្ថែមដោយការកាប់សម្លាប់ជួរអ្នកបច្ចេកទេសវិទ្យាសាស្ត្រ ក្នុងពេលអនុវត្តនយោបាយបិទទ្វារពីលោកខាងក្រៅ គ្មានប្រទេសណាធ្វើវិនិយោគទុន។ តាមផែនការនេះ ទាំងវិស័យកសិកម្ម ទាំងវិស័យឧស្សាហកម្ម ក៏ដូចជាវិស័យផ្សេងទៀត ទាមទារយ៉ាងខ្លាំងនូវពលកម្មជំនាញ និងបច្ចេកវិទ្យាយ៉ាងខ្ពស់។ ពេលនោះដែរ ទន្ទឹមនឹងកាប់សម្លាប់បញ្ញវន្តអ្នកបច្ចេកទេស ប៉ុល ពត បានដំណើរការបិទសាលាគ្រប់ភូមិសិក្សាចំណោះទូទៅ ឧត្តមសិក្សា និងសិក្សាឯកទេស ហើយរៀបចំផែនការសិក្សាជាថ្មី ដែលមានបឋមសិក្សា ៣ ឆ្នាំ មធ្យមសិក្សា ៣ ឆ្នាំ ឧត្តមសិក្សាដែលត្រូវរៀនបច្ចេកទេសសុទ្ធ ៣ ឆ្នាំ សរុប ៩ ឆ្នាំ។ ក្នុងពេលថ្កោលទោសរបបមុន ដែលមានកម្មវិធីសកលគឺចំណោះទូទៅ ១៣ ឆ្នាំ ឧត្តមសិក្សា ៤-៦ ឆ្នាំ ប៉ុល ពត បានលើកថា «ចំណុចសំខាន់គឺ ត្រូវមានគោលជំហរនយោបាយសតិអារម្មណ៍សង្គមនិយម។ យើងប្រែក្លាយអ្នកមិនចេះអក្សរ ឬចេះតិចតួច អោយទៅជាអ្នកបច្ចេកទេសជាន់ខ្ពស់បាន ពី ក ខ មកក្តាប់វិជ្ជា

(*) ផែនការ ៤ ឆ្នាំ លើកទី ១ (១៩៧៧/១៩៨០) របស់ ប៉ុល ពត។

អាស្សាណ្ហបាន តែក្នុងរយៈ ២ ខែ គឺលោតផ្លោះ»។ ប៉ុល ពត បញ្ជាក់ច្បាស់ថា «នយោបាយសតិអារម្មណ៍ជាកត្តាកំណត់ បើយើងរើសតែវប្បធម៌ គឺគ្រោះថ្នាក់ដល់អាយុជីវិតរបស់បក្ស» (*)។

ជាមួយនឹងការដើរផ្ទុយនឹងក្រឹត្យក្រមរីកចំរើននៃសង្គមមនុស្ស ផ្ទុយនឹងក្រឹត្យក្រមនៃទំនាក់ទំនងផលិតកម្ម ដែលត្រូវសមស្របនឹងចរិត និងកំរិតរបស់ផលិតកម្ម ផ្ទុយនឹងបំណងប្រាថ្នារបស់ប្រជាជន ប៉ុល ពត បានលើកផែនការក្រោមមហិច្ឆតាដ៏ធំធេង ដែលធ្វើអោយមានទំនាស់យ៉ាងជ្រាលជ្រៅជាមួយសមត្ថភាព និងលទ្ធភាពពិតប្រាកដរបស់វា។ នៅពេលអនុវត្តមិនបាន ប៉ុល ពត បានជំរុញការកាប់សម្លាប់នេះកាន់តែធំទូលាយ រហូតចូលដល់ផ្ទៃក្នុងរបស់វា ក្រោមផ្លាកនៃការសំរិតសំរាំងផ្ទៃក្នុង មិនគ្រាន់តែកាប់សម្លាប់កម្មាភិបាលនៅថ្នាក់ក្រោមប៉ុណ្ណោះទេ តែនៅថ្នាក់ជាន់ខ្ពស់ជាថ្នាក់តំបន់ កងពល ភូមិភាគ និងក្នុងមជ្ឈិម រហូតអនុប្រធានរដ្ឋ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី។ល។ ក្នុងដំណើរការសំរិតសំរាំងផ្ទៃក្នុង ប៉ុល ពត បានធ្វើការបូកសរុបក្នុងរបាយការណ៍សកម្មភាពរបស់មជ្ឈិម មានចំណុចមួយថា «ឧទាហរណ៍ជាក់ស្តែង ក្នុងឆ្នាំ ១៩៧៦ និយាយតែក្នុងបក្ស ដោយយើងធ្វើបដិវត្តន៍សង្គមនិយមជ្រាលជ្រៅ ជំងឺនៅក្នុងបក្សដែលកើតមានតាំងពី បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ដែលយើងរកមិនឃើញ ជំងឺនេះវាត្រូវចេញ ពីព្រោះកំដៅនៃបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យវាមិនគ្រប់។ កំរិតនៃការតស៊ូប្រជាជាតិ និងការតស៊ូវណ្ណៈ ក្នុងក្របខ័ណ្ឌបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ យើងរកមេរោគនៅក្នុងបក្សមិនឃើញ វាបង្កប់បាន។ តែដល់យើងដំណើរ

(*) របាយការណ៍សកម្មភាពរបស់មជ្ឈិម ប៉ុល ពត តាមភារកិច្ចនយោបាយរួម ឆ្នាំ ១៩៧៦។

ការបដិវត្តន៍សង្គមនិយមបានជ្រាលជ្រៅ បានខ្លាំងក្លា បានធំទូលាយ ក្នុងបក្ស ក្នុងកងទ័ព ក្នុងប្រជាជន យើងរកមេរោគអាក្រក់ឃើញ វាចេញមក។ វាចេញមក ដោយធាតុពិតនៃបដិវត្តន៍សង្គមនិយម វាជំរុញអោយចេញ។ ដូច្នេះ នាំអោយយើងកំចាត់នូវសមាសភាពក្បត់ ដែលគ្រោះថ្នាក់ដល់បក្ស ដល់បដិវត្តន៍ បានទាន់ពេលវេលា» (*)។ ពាក្យសំដីរបស់ ប៉ុល ពត ធ្លុះបញ្ចាំងយ៉ាងច្បាស់លាស់នូវអំពើក្បត់ ដែលមានតាំងពីយូរមកហើយ។ ជនដែល ប៉ុល ពត ចាត់ទុកថា ក្បត់តាំងពីបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ សុទ្ធសឹងជាជនបដិវត្តបរិសុទ្ធ ដែលតស៊ូប្រឆាំងមាគ៌ារបស់ ប៉ុល ពត។ ការសំរិតសំរាំងរបស់ ប៉ុល ពត បានដំណើរការជាប់មិនដាច់រហូតដល់របបនេះ ត្រូវដួលរលំ។ ស្របជាមួយនឹងការអនុវត្តន៍នយោបាយប្រល័យពូជសាសន៍នៅផ្ទៃក្នុងកម្ពុជា ប៉ុល ពត បានអនុវត្តនយោបាយបរទេសបិទទ្វារចំពោះសកលលោកខាងក្រៅ។ តាំងពីក្រោយរំដោះភ្លាម ប៉ុល ពត បានចាប់ផ្តើមបណ្តេញអ្នកការទូតនៃប្រទេសជាច្រើន និងបណ្តាអង្គការអន្តរជាតិចេញពីកម្ពុជា ហើយក៏បានដាក់តំបន់ព្រំដែនជាមួយប្រទេសជិតខាងទាំងអស់ ជាសមរភូមិប្រយុទ្ធ ពិសេសជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម។ ក្រៅពីការវាយលុក ទៅលើព្រំដែនប្រទេសថៃ និងប្រទេសឡាវ ប៉ុល ពត បានប្រមូលកងទ័ព ១៩ កងពលធំ ក្នុងចំណោម ២៣ កងពលធំ វាយលុកដោយទ្រង់ទ្រាយធំនៅតាមបណ្តោយព្រំដែន កម្ពុជា-វៀតណាម សម្លាប់រង្គាលប្រជាជនវៀតណាម សម្លាប់គោក្របី ឆក់ប្លន់ទ្រព្យសម្បត្តិ ដុតផ្ទះសម្បែង បំផ្លាញភូមិករ ទ្រព្យសម្បត្តិ ដំណាំដាំដុះ។ល។ អស់ជា

(*) របាយការណ៍សកម្មភាពរបស់មជ្ឈិម ប៉ុល ពត តាមភារកិច្ចនយោបាយរួម ឆ្នាំ ១៩៧៦។

ច្រើនៗ ការប្រឆាំងវៀតណាមរបស់ ប៉ុល ពត ត្រូវបានដំណើរការតាំងពីពេលមុនដណ្តើមបានអំណាច ដូច្នេះ ពួកនេះ មានលទ្ធភាពនឹងវាយប្រហារដោយទ្រង់ទ្រាយធំភ្លាម បន្ទាប់ពីគេដណ្តើមបានអំណាចទាំងស្រុងៗ

ប្រសិនបើគេពិនិត្យត្រឹមតែជម្លោះជាមួយប្រជាជាតិវៀតណាម គេងាយចាត់ទុក ប៉ុល ពត ថា ស្ថិតក្នុងគោលជំហរជាតិនិយម ឬជាតិនិយមចង្អៀតចង្អល់ ប៉ុន្តែបើផ្សារភ្ជាប់ជាមួយការអនុវត្តន៍នយោបាយក្នុងប្រទេសដែលក្បត់ជាតិ ក្បត់ប្រជាជនខ្លួន ហើយដោយធ្វើការប្រៀបធៀបនូវនយោបាយរបស់អ្នកកាន់អំណាចមុនៗ ចំពោះវៀតណាម គេនឹងបានឃើញថា ប៉ុល ពត បានដើរហួសពីក្របខ័ណ្ឌនៃជាតិនិយមចង្អៀតចង្អល់ទៅក្នុងក្របខ័ណ្ឌនៃលទ្ធិនិយមជ្រុលហួសហេតុៗ អ្នកដឹកនាំនៅកម្ពុជានៃរបបមុនៗ គេប្រឆាំងវៀតណាមដោយឈរលើផលប្រយោជន៍វណ្ណៈ គេប្រឆាំងចំពោះចលនាតស៊ូ របស់ប្រជាជនវៀតណាម តែគេធ្វើជាសម្ព័ន្ធមិត្តជាមួយវៀតណាមដែលជាវណ្ណៈត្រួតត្រាៗ ឯ ប៉ុល ពត ប្រឆាំងវៀតណាមទាំងអស់ ទោះជាវៀតណាមមានរដ្ឋអំណាចមួយក្រោមការដឹកនាំរបស់បក្សកុម្មុយនិស្តតាមលទ្ធិម៉ាក្ស-ឡេនីន ហើយដែលធ្លាប់បានជួយឧបត្ថម្ភយ៉ាងច្រើន ចំពោះបដិវត្តន៍របស់ប្រជាជនកម្ពុជាៗ អំពើឆ្កួតលេលារបស់ ប៉ុល ពត គឺចង់កំទេចចោលជនជាតិវៀតណាមទាំងស្រុងៗ ឆ្នាំ ១៩៧៨ ប៉ុល ពត ប្រកាសថា ជនកម្ពុជាមួយនាក់ត្រូវកំទេចជនវៀតណាមអោយបានសាមសិបនាក់ ដូច្នេះ ប្រើជនកម្ពុជា ២ លាននាក់ដើម្បីកំទេចចោលជនវៀតណាម ៦០ លាននាក់ៗ ក្រៅពីពួក

ហ្វាស៊ីស្តអាល្លឺម៉ង់សម្លាប់រង្គាលជនជាតិជ្វីហ្វដែលគ្មានប្រទេស គ្មានពួកស្តាំ ឬពួកឆ្វេងណាមួយធ្លាប់បានគិត និងប្រព្រឹត្តដូចពួក ប៉ុល ពត ដែលចង់កំទេចចោលជនជាតិមួយ ដែលជាប្រទេសមានឯករាជ្យ អធិបតេយ្យនោះឡើយ សូម្បីតែពួកអាណានិគមមកត្រួតត្រាក៏វារក្សាទុកនូវមនុស្សនៃជនជាតិនោះដែរ។

សរុបមកការវាយតម្លៃជាតុពិតនៃរបប ប៉ុល ពត ប្រសិនបើមិនឈរលើទស្សនវិជ្ជាម៉ាក្ស-ឡេនីន គឺលទ្ធិសំភារនិយមវិចារវិទ្យា និងលទ្ធិសំភារនិយមប្រវត្តិសាស្រ្ត ហើយបែរជាឈរលើទស្សនៈគំនិតនិយមអំពីប្រវត្តិសាស្រ្ត ដែលចាត់ទុកមូលហេតុនៃការវិវត្តន៍ប្រែប្រួលនៃប្រវត្តិសាស្រ្ត អាស្រ័យដោយការផ្លាស់ប្តូរនៃសតិអារម្មណ៍របស់មនុស្ស គឺនយោបាយមានតួនាទីកំណត់សំរេច ក្នុងការធ្វើអោយប្រែប្រួលប្រវត្តិសាស្រ្ត គេអាចចាត់ទុកថា របប ប៉ុល ពត គឺជារបបសង្គមនិយម អាស្រ័យដោយ ប៉ុល ពត បានប្រើប្រាស់នូវនយោបាយសតិអារម្មណ៍ និងហិង្សា បង្កើតឡើងនូវទំនាក់ទំនងផលិតកម្ម សមូហភាពមួយ ហើយបើគ្រាន់តែចាត់ទុកថាអោយតែសមូហភាព គឺសង្គមនិយម ក៏អាចចាត់ទុករបប ប៉ុល ពត គឺជាសង្គមនិយមដែរ។ ប្រការនេះហើយដែលធ្វើអោយប្រជាជនមួយចំនួនចាត់ទុករបប ប៉ុល ពត ជាសង្គមនិយម ហើយមានការខុសឆ្គងក្នុងការអនុវត្តន៍តែប៉ុណ្ណោះ។ ប៉ុន្តែបើឈរលើទស្សនៈសំភារនិយមវិចារវិទ្យា និងទស្សនៈសំភារនិយមប្រវត្តិសាស្រ្តនៃលទ្ធិម៉ាក្ស-ឡេនីន ដែលផ្អែកលើដំណើររីកចំរើននៃប្រវត្តិសាស្រ្ត អាស្រ័យដោយបែបផែនផលិតកម្ម ផលិតចេញទ្រព្យសម្បត្តិសំភារៈរបស់សង្គម ដែលជា

*កត្តាកំណត់ជីវភាពសង្គមលើគ្រប់ផ្នែក កំណត់ការរីកចំរើនរបស់សង្គម ហើយជាពិសេស បើផ្អែកលើក្រឹត្យក្រមទំនាក់ទំនងរវាងកម្លាំងផលិតកម្ម និងទំនាក់ទំនងផលិតកម្ម ដើម្បីពិនិត្យរបប ប៉ុល ពត របបនេះ ពិតជាមិនមែនសង្គមនិយមឡើយ។*

*ដូចបានលើកឡើងខាងលើ ប្រសិនបើយករបប ប៉ុល ពត ទៅធ្វើការប្រៀបធៀបជាមួយរបបសង្គម ដែលមនុស្សលោកបានឆ្លងកាត់កន្លងមក គេឃើញនូវចំណុចមួយចំនួនប្រហាក់ប្រហែលរបបសង្គមទាសភាព សំខាន់នៅត្រង់រចនាសម្ព័ន្ធថ្នាក់ក្រោម និងរចនាសម្ព័ន្ធថ្នាក់លើដែលទាក់ទងសំខាន់ចំពោះបញ្ហាកម្មសិទ្ធិរបស់ប្រជាជន ដែលត្រូវដកហូត ហើយប្រមូលផ្តុំក្តាប់កម្មសិទ្ធិទាំងអស់ ដោយស្រទាប់មនុស្សមួយក្តាប់តូចដែលកាន់អំណាច ដែលហៅថា អង្គការ បន្ថែមទៅដោយនយោបាយប្រតិកិរិយាទាំងក្នុង និងក្រៅប្រទេស ដែលរុញប្រជាជនកម្ពុជាអោយធ្លាក់ទៅក្នុងគ្រោះ នៃការប្រល័យពូជសាសន៍។ ប៉ុន្តែ ក្នុងរបបទាសភាព ម្ចាស់ទាសករជាវណ្ណៈតំណាងអោយបែបផែនផលិតកម្មមួយ ដែលកកើតពីការចាំបាច់នៃប្រវត្តិសាស្ត្រ ហើយក្នុងសង្គមទាសភាពក៏នៅមានអ្នកសេរីដែលមានកម្មសិទ្ធិតូចតាច។ ចំណែករបប ប៉ុល ពត វិញ គឺដាច់ខាតគ្មានអ្នកសេរីទេ។ ពិនិត្យលើទិដ្ឋភាពវិទ្យាសាស្ត្រ គឺពួក ប៉ុល ពត ពុំមែនជាវណ្ណៈមួយទេ តែពួកនេះគ្រាន់តែជាក្រុមកាន់អំណាចមួយត្រួតត្រាសង្គម ដោយប្រើប្រាស់ហិង្សាឃោរឃៅដើម្បីរក្សាបុព្វសិទ្ធិរបស់ពួកវា។*

*ចំពោះការប្រៀបធៀបរបប ប៉ុល ពត ជាមួយលទ្ធិសង្គមនិយម គឺ*

*ដាច់ខាតមិនអាចប្រៀបធៀបបានឡើយ អាស្រ័យដោយលទ្ធិសង្គមនិយមជាការរំដោះមនុស្ស រំដោះប្រជាពលករ ចេញពីការជិះជាន់សង្កត់សង្កិន ឯរបប ប៉ុល ពត ជារបបប្រល័យពូជសាសន៍ ប្រឆាំងការរស់រានរបស់មនុស្ស ប្រែក្លាយអ្នកដែលសល់ពីស្លាប់អោយទៅជាទាសករ។*

*អាចនឹងធ្វើការសន្និដ្ឋានចំពោះពួក ប៉ុល ពត បានថា <u>តាំងពីដើមដល់ចប់ ពួកនេះស្ថិតនៅលើគោលជំហរនៃលទ្ធិឆ្វេងជ្រុលហួសហេតុ និងនិយមជ្រុលហួសហេតុ ហើយដើរតាមលទ្ធិគំនិតនិយមអត្តនោម័តទាំងស្រុង</u>។ ឆ្វេងជ្រុលហួសហេតុ និងដើរតាមលទ្ធិគំនិតនិយមអត្តនោម័ត គឺជាប្រការងាយស្រួលយល់ចំពោះបាតុភាព ប៉ុល ពត ប៉ុន្តែបញ្ហាជាតិនិយមចង្អៀតចង្អល់ហួសហេតុ និងនិយមជ្រុលហួសហេតុ គឺជាការពិបាកយល់។ ប្រការនេះហើយ បានជាមានមនុស្សមួយចំនួនចាត់ទុក ប៉ុល ពត ថា ជាអ្នកជាតិនិយមចង្អៀតចង្អល់ តែបើពិនិត្យអំពីការអនុវត្តន៍របស់ ប៉ុល ពត តាំងពីដើមដល់ចប់ ចំពោះជាតិ ឃើញថាអំពើក្បត់ផលប្រយោជន៍ជាតិ បានកើតមានឡើងជារៀងរហូតមក រហូតដល់ការប្រល័យពូជសាសន៍ជាតិរបស់ខ្លួន គឺវាខុសនឹងទម្លាប់នៃពួកជាតិនិយមចង្អៀតចង្អល់ដែលបានធ្វើ រាប់ទាំងពួកឆ្វេងជ្រុល និងស្តាំជ្រុល។*

*<u>ឆ្វេងជ្រុលហួសហេតុ បូកនឹងនិយមជ្រុលហួសហេតុ បានជំរុញអោយ ប៉ុល ពត ធ្វើសកម្មភាពយ៉ាងច្រួតលេលា ទោះជាផលប្រយោជន៍ជាតិដ៏សមស្រប និងទាបបំផុតក៏មិនគិតដល់ដែរ។ ប្រការសំខាន់ គឺរក្សាអោយបាននូវផលប្រយោជន៍អោយអង្គការចាត់តាំងក្បត់របស់វា</u>។*

ផ្នែកទី ២

# ការរីកចំរើនឡើងនៃកម្លាំងបដិវត្តន៍ និង ស្នេហាជាតិ ក្រោមរបបប្រល័យពូជសាសន៍ ប៉ុល ពត និងការតួបផ្សំរវាងកម្លាំង បដិវត្ត ជាតិ និងកម្លាំងអន្តរជាតិ ក្នុងការផ្តួលរំលំ របបប្រល័យពូជសាសន៍ ប៉ុល ពត

*អំពើក្បត់របស់ពួក ប៉ុល ពត មានសភាពប្លែកពីអង្គការចាត់តាំងក្បត់ផ្សេងទៀត នៅត្រង់ពួក ប៉ុល ពត មានអង្គការចាត់តាំងដោយឡែកមួយ និងមានមាគ៌ាដោយឡែកមួយស្ថិតក្នុងចលនាបដិវត្ត ដោយប្រើប្រាស់ចលនាបដិវត្តផង និងកំចាត់ចលនាបដិវត្តផង។ ទីចុងបំផុតអង្គការចាត់តាំងក្បត់របស់វា និងមាគ៌ារបស់វាបានគ្របដណ្តប់ទាំងស្រុងទៅលើចលនាបដិវត្ត។ ការពង្រីកនូវមនោគមវិជ្ជារបស់ ប៉ុល ពត បានរុញច្រានអោយថយក្រោយ និងឈានទៅជំនួសជាលំដាប់ នូវមនោគមវិជ្ជានៃលទ្ធិម៉ាក្ស-ឡេនីន ដែលបក្សប្រជាជនបដិវត្តខ្មែរបានប្រកាន់យក។ ចំណុចខ្សោយបំផុតរបស់បដិវត្តន៍កម្ពុជាគឺជួរកម្មាភិបាលបក្ខជនតិចតួចណាស់ ដែលមានការយល់ដឹងអំពីទ្រឹស្តីពិតប្រាកដនៃ*

លទ្ធិម៉ាក្ស-ឡេនីន។ គេមានការយល់ដឹងអំពីទ្រឹស្តីបដិវត្ត និងសភាពការណ៍ពិតរបស់ជាតិ ក៏ដូចជា សភាពការណ៍អន្តរជាតិ មានកំរិតដ៏ចង្អៀត។ ម្យ៉ាងទៀត អាស្រ័យដោយសភាពការណ៍សត្បានុម័តរបស់សង្គម ដែលលំអៀងស្តាំយូរយារមកហើយ ពេលមានការបដិវត្តន៍ ហើយបញ្ចូលនូវមនោគមវិជ្ជាឆ្វេងជ្រុល គឺជាប្រការងាប់ទទួលយកសំរាប់ស្រទាប់យុវជន និងមនុស្ស ទើបប្រែក្លាយជាជនកុម្មុយនិស្តថ្មីថ្មោងការឈានពីស្តាំទៅឆ្វេង គឺជាប្រការធ្វើទៅបានយ៉ាងងាប់សំរាប់ស្រទាប់យុវជន ដែលធ្លាប់បានរស់នៅ ក្នុងសង្គមមាននិន្នាការស្តាំ។ ក្នុងសភាពការណ៍ដែលជួរបដិវត្តខ្វះការចេះដឹងអំពីទ្រឹស្តីម៉ាក្ស-ឡេនីនពិតប្រាកដ ប៉ុល ពត បានពង្រីកនូវមនោគមវិជ្ជាឆ្វេងជ្រុលរបស់វាបានយ៉ាងងាប់រហ័ស ដោយជ្រកក្រោមផ្លាកលទ្ធិម៉ាក្ស-ឡេនីន ដែលធ្វើអោយចលនាបដិវត្តបាត់បង់អស់នូវមនោគមវិជ្ជាម៉ាក្ស-ឡេនីន។ ព្រមពេលនឹងការពង្រីកខ្លួន ខាងមនោគមវិជ្ជា និងទ្រឹស្តី ប៉ុល ពត បានដំណើរការប្រែក្លាយអង្គការចាត់តាំងទាំងអស់របស់បដិវត្តន៍ អោយទៅជាឧបករណ៍របស់វា។ ដំណើរការប្រែក្លាយអង្គការចាត់តាំងបដិវត្តអោយទៅជាអង្គការក្បត់របស់ ប៉ុល ពត បានអនុវត្តដោយជំហានព្រមៗគ្នារវាងមនោគមវិជ្ជា និងចាត់តាំង។ ដំណើរការចាត់តាំងបានអនុវត្ត តាមរបៀបកំចាត់ផងនិងកសាងផង គឺកំចាត់ចោលចំពោះជនបដិវត្តបរិសុទ្ធ ហើយកសាងចំពោះជនដែលបានជ្រាបចូលទៅក្នុងខ្លួន នូវមនោគមវិជ្ជាឆ្វេងជ្រុលរបស់ ប៉ុល ពត ហើយត្រូវបានប្រើប្រាស់ជាឧបករណ៍សំរាប់អនុវត្តកលល្បិចនយោបាយដ៏ខ្មៅងងឹត។ ជាបណ្តើរៗ ពួកឆ្វេងជ្រុល និងនិយមជ្រុល បានកាន់តំណែងសំខាន់ៗ ទាំងអស់ នៅក្នុងអង្គការចាត់តាំងរបស់

បដិវត្តន៍។ ដោយហេតុនេះហើយ បានជា ប៉ុល ពត មានលទ្ធភាពនឹងអនុវត្តនយោបាយរបស់វាទាំងស្រុង ក្រោយពេលវាដណ្តើមបានអំណាចប្រែក្លាយអង្គការចាត់តាំងទាំងនេះ អោយទៅជាអង្គការក្បត់ជាតិ ក្បត់បដិវត្តន៍ ជាឧបករណ៍សំរាប់ការអនុវត្តនយោបាយប្រល័យពូជសាសន៍របស់ ប៉ុល ពត។

នៅក្បែរអំពើក្បត់ដែលកំពុងពង្រីកខ្លួន ការតស៊ូបដិវត្ត ទោះជាត្រូវបំផ្លិចបំផ្លាញ ក៏នៅតែមានជីវិត។ ការប្រឆាំងចំពោះមាគ៌ា និងសកម្មភាពរបស់ពួក ប៉ុល ពត បានកើតមានឡើងទាំងសម្ងាត់ទាំងចំហ។ ប្រជាជនជាច្រើន ដែលគ្មានការដឹកនាំរបស់កម្មាភិបាលបដិវត្ត បាននាំគ្នារត់ចូលតំបន់ លន់ នល់ ត្រួតត្រា ដែលមានជាបន្តបន្ទាប់ តាំងពីឆ្នាំ ១៩៧០-១៩៧៥។ អ្នកទាំងនេះ ភាគច្រើនមិនមែនចូលចិត្ត របប លន់ នល់ ឬគាំទ្រការឈ្លានពានរបស់ចក្រពត្តិអាមេរិកទេ ប៉ុន្តែ គេមិនអាចទ្រាំទ្ររស់នៅបាន ជំរុញអោយគេក្លាយទៅជាចំណាប់ខ្មាំងនៃរបប លន់ នល់។ កម្មាភិបាល បក្ខជនមួយចំនួន ធ្វើការតស៊ូតាមមធ្យោបាយផ្សេងៗ ហើយទីទៃៗពីគ្នា។ ចលនាតស៊ូដែលខ្លាំងបំផុត ហើយដែលមានការដឹកនាំពីកម្មាភិបាលបដិវត្តបរិសុទ្ធ គឺចលនាបដិវត្តរបស់ប្រជាជននៅខេត្តកោះកុង និងចលនាតស៊ូបដិវត្តរបស់ប្រជាជននៅភូមិភាគឦសាន។ ចលនាទាំងពីរនេះ បានក្រោកឡើងប្រឆាំង តាំងពីឆ្នាំ ១៩៧៤ ហើយការពារបាននូវកម្លាំងរៀងរហូតមក។ ឯការតស៊ូផ្សេងៗទៀត ដែលនៅរាយប៉ាយទូទាំងប្រទេស ត្រូវបង្ក្រាបទាំងស្រុង។

ក្រោយខែមេសា ១៩៧៥ ទំនាស់បានកើតឡើងយ៉ាងជ្រាលជ្រៅទូ

ទាំងសង្គម និងទូទាំងផ្ទៃក្នុងដែលមានកម្លាំងបដិវត្ត និងក្បត់បដិវត្ត កំពុងស្ថិតស្មេរជាមួយគ្នា។ ពិតមែនតែពួក ប៉ុល ពត មានឧត្តមភាពទាំងស្រុង ក្នុងការចាត់ចែងមាគ៌ានយោបាយ និងអង្គការចាត់តាំង ប៉ុន្តែក៏នៅសេសសល់កម្មាភិបាលបដិវត្តបរិសុទ្ធខ្លះ បានស្ថិតនៅទីនោះ ក្នុងស្ថានភាពជាអ្នកទ័លច្រកខាងសតិអារម្មណ៍ និងចាត់តាំង។ គួររំលឹកថា តាំងពីប្រទេសធ្លាក់ចូលក្នុងសង្គ្រាម ប្រជាជនកម្ពុជាទូទៅ បានក្លាយជាចំណាប់ខ្មាំងនៃសង្គ្រាម បើមិននៅខាងបដិវត្តន៍ប្រឆាំង លន់ នល់ ក៏ត្រូវនៅខាង លន់ នល់ ប្រឆាំងបដិវត្តន៍ដែរ ព្រោះទាំងសងខាងសុទ្ធតែត្រូវការកម្លាំង ដូច្នេះគ្មានផ្លូវទីបីសំរាប់ជ្រើសរើសទេ។ សំរាប់ខាងតំបន់រំដោះ អាស្រ័យដោយអំពើក្បត់របស់ ប៉ុល ពត ប្រជាជនទូទៅបានក្លាយជាចំណាប់ខ្មាំងទាំងស្រុង ទោះបីជាពេញចិត្ត ឬមិនពេញចិត្តក៏ត្រូវទ្រាំទ្ររស់នៅជាមួយគេ។ ពិបាកបំផុត គឺសំរាប់មនុស្សនៅក្នុងជួរបដិវត្តដែលគេមិនអាចសុំចាកចេញពីជួរ ឬលាលែងពីតំណែងបាន។ ក្រោកឡើងប្រឆាំងនឹងត្រូវកំទេចភ្លាម ដូច្នេះទោះពេញចិត្តក្តី មិនពេញចិត្តក្តី ត្រូវបន្តស្ថិតនៅក្នុងជួរតទៅទៀត។ ការពិបាកម្យ៉ាងទៀត នាមុនឆ្នាំ ១៩៧៥ អាស្រ័យដោយមាគ៌ាបដិវត្ត និងមាគ៌ាក្បត់បដិវត្ត បានស្ថិតស្មេរក្នុងអង្គការចាត់តាំងជាមួយគ្នា ជនបដិវត្តត្រឹមត្រូវ និងពួកក្បត់បដិវត្តន៍ស្ថិតក្នុងជួរជាមួយគ្នា បន្ថែមទៅដោយគោលនយោបាយរណសិរ្ស បានអនុវត្តខ្លះនាដំណាក់កាលនោះ ព្រមទាំងយុទ្ធវិធី សាមគ្គីផង កំចាត់ផងរបស់ ប៉ុល ពត បានធ្វើអោយកម្មាភិបាល បក្ខជនខាងក្រោម ពិបាកយល់យ៉ាងខ្លាំង ច្របូកច្របល់យ៉ាងខ្លាំង រវាងបដិវត្តន៍ និងក្បត់បដិវត្តន៍។ ហើយទោះបីបានមើលឃើញអំពើឃោរឃៅបានកើតមានឡើង ក៏ជា

ទូទៅ គេពិបាកនឹងសន្និដ្ឋានថា តើវាជាកំហុសរបស់ថ្នាក់មូលដ្ឋាន ឬជាអំពើក្បត់របស់ថ្នាក់មជ្ឈិម ហើយទោះបីបានដឹងច្បាស់ថា ជាអំពើក្បត់របស់ថ្នាក់មជ្ឈិម ទាំងមាគ៌ា និងសកម្មភាព ក៏គេពិបាកនឹងដោះស្រាយថា តើត្រូវធ្វើអ្វី ហើយត្រូវធ្វើយ៉ាងណា។ តំបន់មួយចំនួន ដែលមានភាពអនុគ្រោះ ហើយមានការដឹកនាំពីកម្មាភិបាលបដិវត្ត ដូចជា នៅភូមិភាគឦសាន និងខេត្តកោះកុង អាចគេចខ្លួនចេញ ហើយធ្វើការប្រយុទ្ធដោយមានទឹកដីវៀតណាម និងថៃឡង់ដ៍ធ្វើជាបង្អែកក្រោយខ្នង ប៉ុន្តែតំបន់ផ្សេងទៀតជាច្រើនខ្វះលក្ខណសម្បត្តិនេះ ដូច្នេះជនបដិវត្ត និងអ្នកស្នេហាជាតិជាច្រើន បានស្ថិតនៅក្នុងសភាពទ័លច្រក។ ដោយហេតុនេះហើយ បានជាជនបដិវត្តជាច្រើន ត្រូវបានកាប់សម្លាប់ជាបន្តបន្ទាប់ តាមរយៈវិធានការសំរិតសំរាំងរបស់ពួក ប៉ុល ពត ។

ក្នុងចន្លោះឆ្នាំ ១៩៧៥-១៩៧៩ ទំនាស់បានវិវត្តកាន់តែជ្រាលជ្រៅ វាមិនមែនគ្រាន់តែរវាងបដិវត្តន៍ និងក្បត់បដិវត្តន៍ ក្នុងអង្គការចាត់តាំងមួយប៉ុណ្ណោះទេ តែទំនាស់ជ្រាលជ្រៅបំផុត ដែលនាំដល់ការផ្លាស់ប្តូររបបសង្គម គឺទំនាស់ក្នុងបញ្ហាបែបផែនផលិតកម្ម អាស្រ័យដោយបែបផែនផលិតកម្ម ដែលពួក ប៉ុល ពត ប្រើប្រាស់នយោបាយ និងហឹង្សាក្បត់បដិវត្តន៍ បង្កើតឡើងនេះ វាផ្ទុយនឹងក្រឹត្យក្រមរីកចំរើនជាសត្យានុម័តរបស់សង្គម ហើយប្រែក្លាយមនុស្សគ្រប់រូប អោយទៅជាទាសករ។ ការតស៊ូបានប្រមូលផ្តុំ មុខព្រួញជាបឋម គឺលុបបំបាត់ចោល បែបផែនផលិតកម្មរបៀបទាសភាពនេះ។ អាស្រ័យដោយទំនាស់ដ៏ជ្រាលជ្រៅក្នុងទំនាក់ទំនងផលិតកម្ម ការតស៊ូបដិវត្ត មិនមែនកើតមានត្រឹមកំរិត

តែជនបដិវត្តបរិសុទ្ធ ត្រូវរំដោះខ្លួនចេញ ពីការកាប់សម្លាប់ប៉ុណ្ណោះទេ តែវាជាចលនារួមរបស់ប្រជាជនកម្ពុជា ប្រឆាំងរបប ប៉ុល ពត។ ចលនានេះ បានបង្កើតឡើងនូវលក្ខណសម្បត្តិថ្មីសំរាប់កម្មាភិបាល បក្ខជនរបស់បក្សដែលត្រូវបែកខ្ញែកផ្តាច់ខ្លួនចេញពីអង្គការចាត់តាំងក្បត់របស់ ប៉ុល ពត ឬសម្ងំក្នុងជួរ ប៉ុល ពត បង្កើតឡើងនូវកម្លាំងនយោបាយ ក្នុងការតស៊ូ។ ទោះបីជាទូទៅ ប្រជាជនប្រឆាំងនឹងរបបប្រល័យពូជសាសន៍ ប៉ុល ពត ប៉ុន្តែការតស៊ូជួបការលំបាកយ៉ាងខ្លាំង អាស្រ័យដោយកត្តាមួយចំនួន៖

***ទីមួយ*** ស្ថានភាពសង្គមមានទ្រង់ទ្រាយដូចជាបន្ទាយទាហាន ដែលរស់នៅ ស៊ីចុក ធ្វើការជាសមូហភាព ក្បាលម៉ាស៊ីនបង្ក្រាបមានទំហំធំ ហើយឃោរឃៅព្រៃផ្សៃបំផុត គ្មានការចាយវាយប្រាក់កាស គ្មានការលក់ដូរផលិតផល ត្រូវប្រមូលផ្តុំគ្រប់គ្រង ដោយពួកកាន់អំណាច ដូច្នេះគេពិបាកនឹងពង្រីកក្របខ័ណ្ឌនៃការតស៊ូ។ ប្រសិនបើបំបែកខ្លួនចេញទៅតស៊ូប្រដាប់អាវុធនៅតាមតំបន់ព្រៃភ្នំ ក៏ពិបាកនឹងធ្វើសកម្មភាពដោយគ្មានបង្អែកលើគ្រប់ផ្នែក ដំបូងគឺសេដ្ឋកិច្ចសំរាប់ចិញ្ចឹមខ្លួន។

***ទីពីរ*** ក្នុងស្ថានភាពសង្គមរបៀបនេះ ការតស៊ូបានកើតមានដោយដាច់ដោយដុំ គ្មានការដឹកនាំ គ្មានមាគ៌ា គ្មានការចាត់តាំង ពិតមែនតែមានបក្ខជនដឹកនាំ ឬកន្លែងខ្លះ មានរហូតសាខាបក្សដឹកនាំ តែជាតុពិតគ្រាន់តែជាការប្រមូលផ្តុំកម្លាំងតូចតាច តស៊ូតាមក្របខ័ណ្ឌដ៏ចង្អៀត គ្មានការផ្សារភ្ជាប់គ្នា ពីកន្លែងមួយទៅកន្លែងមួយ ហើយគ្មានខ្សែរយៈចាត់តាំងអ្វីទាំងអស់ សំខាន់គឺគ្មានមាគ៌ា។

***ទីបី*** គ្រាដំបូងសកលលោក មិនបានយល់អស់សភាពការណ៍នៅផ្ទៃក្នុងកម្ពុជាឡើយ រាប់ទាំងវៀតណាមផង។ អ្នករត់ទៅខាងថៃ មួយចំនួនរក្សាបានកម្លាំង មួយចំនួនត្រូវថៃបង្ខំអោយចូលជាពួកខ្មែរសេរីដើម្បីការពារព្រំដែនអោយថៃ មួយចំនួនសុំជ្រកកោននៅប្រទេសទីបី។ សភាពការណ៍នេះ បានដាក់អោយជនបដិវត្តកម្ពុជាជាច្រើន ត្រូវស្ថិតក្នុងសភាពការណ៍ទ័លច្រក ហើយតស៊ូក្នុងក្របខ័ណ្ឌដ៏ចង្អៀត និងរីកចំរើនយឺតបំផុត ក្នុងគ្រាដំបូង។

*សភាពការណ៍បានវិវត្តឆាប់រហ័ស តាមរយៈនៃការអនុវត្តន៍នយោបាយប្រល័យពូជសាសន៍របស់ ប៉ុល ពត។ ការតស៊ូរបស់ប្រជាជនកាន់តែខ្លាំង លទ្ធភាពរបស់ជនបដិវត្ត និងស្នេហាជាតិមានកាន់តែច្រើន អាស្រ័យដោយចលនាតស៊ូរបស់ប្រជាជនកាន់តែខ្លាំងផង និងអាស្រ័យដោយវៀតណាម ឡាវ បានយល់សភាពការណ៍ពិតប្រាកដរបស់កម្ពុជាផង។*

*<u>ការបដិវត្តន៍មួយត្រូវធ្វើឡើងវិញទាំងស្រុង</u> នេះជាការទាមទារដ៏ចាំបាច់ និងបន្ទាន់របស់ប្រជាជាតិទាំងមូល ដើម្បីសង្គ្រោះជាតិចេញពីរបបប្រល័យពូជសាសន៍ ប៉ុន្តែអ្នកណាជាអ្នកធ្វើ ហើយធ្វើតាមរបៀបណា។ ខុសប្លែកពីដំណាក់កាល បដិវត្តនាពេលមុន ហើយក៏ខុសប្លែកពីបដិវត្តនៃប្រទេសនានាលើសកលលោក ទាំងខ្លឹមសារ ទាំងរូបភាព នៃដំណើរការបដិវត្តន៍ ប៉ុន្តែយោលទៅតាមស្ថានភាពទំនាស់ក្នុងសង្គមចរិតនៃបដិវត្តន៍ ក៏ត្រូវដំណើរការតាមក្រឹត្យក្រមរួម នៅត្រង់<u>លេចចេញពីសំណូមពររបស់មហាជន ជាបុព្វហេតុរបស់មហាជន ជាសំណូមពរនៃការបំបាត់ចោលរបប ប៉ុល ពត បំបាត់ចោលបែបផែនផលិតកម្ម</u>*

ចាស់ ហើយរៀបចំនូវបែបផែនផលិតកម្មថ្មី នាំមកនូវឯករាជ្យ សេរីភាព ជូនប្រជាជន។ តាមរយៈនៃស្ថានភាពទំនាស់ក្នុងសង្គម គេអាចសន្និដ្ឋានបានថា ការបដិវត្តន៍មួយដែលត្រូវធ្វើឡើងវិញនេះ គឺស្ថិតក្នុងក្របខ័ណ្ឌនិងខ្លឹមសារនៃបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យប្រជាជន។ ខ្លឹមសារបដិវត្តប្រជាជាតិនាពេលនេះ ខុសពីពេលមុននៅត្រង់កម្ពុជាមិនស្ថិតនៅជាប្រទេសក្រោមអាណានិគម ឬការឈ្លានពានរបស់ចក្រពត្តិអាណានិគមទេ។ ពិតមែនហើយ គេត្រូវទទួលស្គាល់ថាចិនមានតួនាទីដ៏សំខាន់ក្នុងការគាំទ្រការប្រល័យពូជសាសន៍របស់ ប៉ុលពត ចំពោះប្រជាជនកម្ពុជា ក៏ដូចជាក្នុងដំណើរឈ្លានពានវៀតណាមរបស់ ប៉ុល ពត ប៉ុន្តែចរិតពិតដែលចិនបានធ្វើនៅកម្ពុជា មានខ្លឹមសារប្លែកពីចក្រពត្តិអាមេរិក បារាំង ឬជប៉ុន បានធ្វើនៅកម្ពុជានាពេលមុនៗ មនោគមវិជ្ជានៃមហាបដិវត្តន៍វប្បធម៌អធនរបស់ចិនត្រូវបានអនុវត្តនៅកម្ពុជា ហើយតាមរយៈជំនួយរបស់ចិនបានផ្តល់លទ្ធភាពអោយ ប៉ុល ពត អនុវត្តដោយពេញលេញនូវនយោបាយឆ្វេងជ្រុល និងនិយមជ្រុលរបស់វា។ ខ្លឹមសារនៃបដិវត្តន៍ប្រជាជាតិនាពេលនេះ ខុសពីពេលមុននៅត្រង់មិនប្រមូលផ្តុំមុខព្រួញប្រឆាំងការឈ្លានពានបរទេសឡើយ តែប្រមូលផ្តុំមុខព្រួញវាយទៅលើរបបគ្រប់គ្រងផ្តាច់ការប្រល័យពូជសាសន៍ ដែលមានចិននៅពី ក្រោយដើម្បីសង្គ្រោះជាតិ ។ មិនមែនជាការរំដោះជាតិចេញពីការកាន់កាប់របស់បរទេសឡើយ តែជាការសង្គ្រោះជាតិពីរលំរលាយនៃការប្រល័យពូជសាសន៍ ដែលមានបរទេសនៅពីក្រោយ។ ដូចនេះ ជាតុពិតនៃបដិវត្តន៍ប្រជាជាតិនៅពេលនេះគឺការ «សង្គ្រោះជាតិ»។ ឯខ្លឹមសារនៃបដិវត្តន៍ប្រជាធិបតេយ្យប្រជាជន គឺការលុប

បំបាត់ចោលនឹមត្រួតត្រារបស់ ប៉ុល ពត បែបផែនផលិតកម្មរបៀបទាសភាព បង្កើតឡើងរបបនយោបាយ និងបែបផែនផលិតកម្មថ្មីមួយជឿនលឿន។ តាមនិយមន័យនេះ ចរិតនៃបដិវត្តន៍ប្រជាជាតិ និងចរិតនៃបដិវត្តន៍ប្រជាធិបតេយ្យប្រជាជនមានខ្លឹមសារតែមួយ ហើយត្រូវដោះស្រាយក្នុងពេលជាមួយគ្នា សង្គ្រោះជាតិបាន និងបំបាត់ចោលបានក្បាលម៉ាស៊ីនត្រួតត្រាប្រតិកិរិយា បំបាត់ចោលបាននូវឥទ្ធិពលមនោគមវិជ្ជា «មហាបដិវត្តន៍វប្បធម៌អធន» របស់ចិន បំបាត់ចោលបាននូវទំនាក់ទំនងផលិតកម្មបែបទាសភាពរបស់ ប៉ុល ពត។ វាខុសពីដំណាក់កាលប្រជាជាតិប្រជាធិបតេយ្យនាពេលមុន ដែលប្រមូលផ្តុំដោះស្រាយបញ្ហាប្រជាជាតិមុន ហើយដំណើរការប្រជាធិបតេយ្យជាបណ្តើរៗ តែពេលនេះ គឺដោះស្រាយស្របគ្នាក្នុងពេលជាមួយគ្នា។

តាមស្ថានភាពទំនាស់នៃសង្គម ខ្លឹមសារនៃបដិវត្តន៍ត្រូវដំណើរការតាមរបៀបនេះឯង ប៉ុន្តែបញ្ហាចោទឡើង តើត្រូវដំណើរការរបៀបណា។ កំហឹងរបស់ប្រជាជន ចំពោះរបបប្រល័យពូជសាសន៍ ប៉ុល ពត ប្រៀបដូចគ្រាប់បែកមួយដែលរង់ចាំតែផ្ទុះ ក្រោយពេលដកគន្លឹះ វានៅខ្វះតែអ្នកដកគន្លឹះ ពោលគឺនៅខ្វះតែមាគ៌ា និងអ្នកដឹកនាំ។ បដិវត្តន៍នៅពេលនេះមានការលំបាកដូចពោលខាងលើ ប៉ុន្តែមានចំណុចងាយស្រួលនៅត្រង់ប្រជាជនជាទូទៅចងកំហឹងជាមួយពួក ប៉ុល ពត ចង់ផ្តួលរំលំរបបប្រល័យពូជសាសន៍នេះ និងងាយស្រួលដោយពួក ប៉ុល ពត បានអនុវត្តនយោបាយអត្តឃាតខ្លួនឯង តាមរយៈនៃការសំរិតសំរាំងផ្ទៃក្នុង តាមការដុតបញ្ឆេះកំហឹងរបស់ប្រជាជន និងតាមរយៈនៃការអនុវត្តន៍

នយោបាយបរទេសប្រតិកិរិយា សំខាន់គឺការឈ្លានពានទៅលើប្រទេសវៀតណាម។

ស្ថិតក្នុងកាលៈទេសៈ ដែលបដិវត្តន៍មួយត្រូវបំផ្លិញបំផ្លាញទាំងស្រុង ទាំងមាគ៌ា ក៏ដូចជាអង្គការចាត់តាំង ការបង្រ្កាប រាតត្បាត កាប់សម្លាប់មានកំរិតកាន់តែធំ ។ ការជ្រើសរើសល្អបំផុត ដែលអាចធ្វើបាននាពេលនោះ គឺការផ្តាច់ខ្លួនដោយឡែកជាបុគ្គល ជាពួក ជាក្រុម ហើយធ្វើសកម្មភាពប្រឆាំងជាមួយ ប៉ុល ពត ។ ការធ្វើរបៀបនេះ អនុគ្រោះសំរាប់តែតំបន់ជាប់ព្រំដែនវៀតណាម និងឡាវប៉ុណ្ណោះ ព្រោះប្រទេសទាំងពីរ ជាប្រទេសសង្គមនិយម ហើយរងគ្រោះដោយការវាយប្រហាររបស់ ប៉ុល ពត ដែរ ។ ចំណែក នៅព្រំដែនថៃ ជួបការលំបាកច្រើន ម៉្យាងដោយថៃ ត្រូវបានប្រែក្លាយទៅជាសមរភូមិបង្អែក ក្រោយខ្នងរបស់ពួក ប៉ុល ពត បន្ទាប់ពីពួកនេះ បានវាយទៅលើវៀតណាម ម៉្យាងទៀត ថៃមិនត្រូវការជួយកុម្មុយនិស្តឡើយ គេអាចជួយតែពួកខ្មែរសេរី ដែលជាកម្លាំងខាងស្តាំប៉ុណ្ណោះ។ ឯកម្លាំងបដិវត្តដែលភៀសខ្លួនទៅប្រទេសថៃ ហើយមិនព្រមចូលរួមជាមួយខ្មែរសេរី ក៏កម្លាំងនេះស្ថិតក្នុងសភាពការណ៍ដ៏លំបាក។

ការផ្តាច់ខ្លួនចេញ និងការប្រឆាំងជាមួយ ប៉ុល ពត ជាបុគ្គល ជាពួក ជាក្រុម បានកើតមានឡើងជាបន្តបន្ទាប់ មួយចំនួនបានត្រូវ ប៉ុល ពត កំទេច មួយចំនួនបានទៅដល់ប្រទេសវៀតណាម និងឡាវ ហើយការក្រោកឈរឡើងប្រឆាំង ប៉ុល ពត ដែលមានទ្រង់ទ្រាយធំ គឺចលនាបះបោររបស់កងកម្លាំងប្រដាប់អាវុធ និងប្រជាជននៅភូមិភាគបូព៌ាទិស

នាខែ ឧសភា ១៩៧៨។ ការបះបោររបស់កម្លាំងប្រដាប់អាវុធ និងប្រជាជននៅភូមិភាគបូព៌ាទិស រួមមាន ខេត្តស្វាយរៀង ព្រៃវែង មួយផ្នែកនៃខេត្ត កំពង់ចាម និងមួយផ្នែកនៃខេត្តក្រចេះ គួបផ្សំជាមួយកម្លាំងមានស្រាប់ មួយចំនួននៃខេត្តកោះកុង ភូមិភាគឦសាន ពីឆ្នាំ ១៩៧៤ និងកម្លាំងផ្សេងទៀតដែលបានកសាងឡើងនៅក្នុងទឹកដីវៀតណាម នាឆ្នាំ ១៩៧៧-១៩៧៨ គួបផ្សំជាមួយកម្មាភិបាល បក្ខជន មួយចំនួន ដែលបានទៅរៀនសូត្រ នៅភាគខាងជើង វៀតណាម ដែលបានផ្ដាច់ខ្លួនចេញពី ប៉ុល ពត តាំងពីឆ្នាំ ១៩៧៣-១៩៧៤ ឬ ១៩៧៥ ព្រមទាំងប្រជាជនរាប់ម៉ឺននាក់ដែលបានភៀសខ្លួនទៅវៀតណាម និងឡាវ បានក្លាយទៅជាមូលដ្ឋាននៃកម្លាំងបដិវត្តនាពេលក្រោយនេះ។ មានកម្លាំងប៉ុន្តែគ្មានអង្គការចាត់តាំងឯកភាព គ្មានមាគ៌ានយោបាយឯកភាព បញ្ហានេះបានក្លាយជាចំណោទដ៏សំខាន់មួយ ប៉ុន្តែគេបានឃើញនូវចំណុចងាយស្រួលនៅត្រង់កម្លាំងភាគច្រើន ត្រូវដឹកនាំដោយកម្មាភិបាលបដិវត្តពីពេលមុន ហើយមានគោលដៅស្របគ្នា គឺផ្ដួលរំលំរបប ប៉ុល ពត ហើយកសាងប្រទេសតាមមាគ៌ានៃលទ្ធិសង្គមនិយម និងដើរតាមលទ្ធិម៉ាក្ស-ឡេនីនដូចគ្នា។ ប្រការនេះ គឺជាកត្តាងាយស្រួលក្នុងការឯកភាពកម្លាំងទាំងនេះ មិនគ្រាន់តែកម្លាំងដែលមានក្នុងប្រទេសវៀតណាម និងឡាវប៉ុណ្ណោះទេ កម្លាំងបដិវត្តដែលនៅថៃ ក៏មានបំណងដូចនេះដែរ។

ប្រសិនបើធ្វើការប្រៀបធៀប រវាងរណសិរ្ស ដែលបង្កើតឡើងនាខែធ្នូ ឆ្នាំ ១៩៧៨ ជាមួយនឹងរណសិរ្សរបស់ពួកខ្មែរប្រតិកិរិយា ដែលបានបង្កើតឡើងនូវរដ្ឋាភិបាលចម្រុះត្រីភាគី ខែមិថុនា ១៩៨២ នៅកូឡាឡាំ

*ពួរ ប្រទេសម៉ាឡេស៊ី គេឃើញថា មានការខុសគ្នាទាំងស្រុងៗ រណសិរ្ស សាមគ្គីសង្គ្រោះជាតិកម្ពុជា បង្កើតឡើងនាខែធ្នូ ១៩៧៨ គឺបង្កើតឡើង លើមូលដ្ឋានបញ្ចភាគី «៥ ភាគី» ពិតមែនតែភាគីមួយនៅថៃ មិនទាន់ ចេញមុខ អាស្រ័យដោយត្រូវរក្សាការសម្ងាត់ ដើម្បីការពារកម្លាំងៗ ប្រាំ ភាគីនៅទីនេះ គឺជាចលនាតស៊ូដោយឡែកៗពីគ្នា នៅតំបន់ផ្សេងពីគ្នា នៅពេលវេលាខុសគ្នា តែស្ថិតក្នុងគោលដៅដូចគ្នាៗ គេគ្មានផល ប្រយោជន៍អ្វីផ្សេង ក្រៅពីសង្គ្រោះជាតិអោយចេញផុតពីរបបប្រល័យ ពូជសាសន៍ ប៉ុល ពត ហើយកសាងប្រទេសឈានតាមមាគ៌ាសង្គម និយមបរិសុទ្ធនោះឡើយ ដូច្នេះគេគ្មានការលំបាកនៅក្នុងការឯកភាព កម្លាំងទាំងនេះ ក្រោមអង្គការចាត់តាំងឯកភាពតែមួយ និងមាគ៌ាតែមួយ នោះឡើយៗ ការងាយស្រួលម៉្យាងទៀត គឺការជួយឧបត្ថម្ភរបស់បក្ស កុម្មុយនិស្តវៀតណាមក្នុងការជួយកសាងកម្លាំង បង្កលក្ខណៈអោយ កម្លាំងទីទៃៗ ពីគ្នា បានជួបគ្នានៅលើទឹកដីវៀតណាម ជួយដល់ជន ភៀសខ្លួន និងជួយកសាងកម្លាំង ពិសេសកម្លាំងដឹកនាំ និងកម្លាំង ប្រដាប់អាវុធ ធ្វើអោយកម្លាំងនេះបានឯកភាពគ្នាយ៉ាងឆាប់ ហើយរីក ចំរើនយ៉ាងឆាប់ លើគ្រប់វិស័យៗ*

*ខែ ធ្នូ ១៩៧៨ ជាដំណាក់កាលប្រវត្តិសាស្ត្រថ្មីមួយ នៃការរីកចំរើន របស់កម្លាំងបដិវត្តកម្ពុជា តាមរយៈនៃការបង្កើតឡើងនូវរណសិរ្សសាមគ្គី សង្គ្រោះជាតិកម្ពុជាៗ តាមរយៈនៃគោលនយោបាយរណសិរ្សសាមគ្គី សង្គ្រោះជាតិកម្ពុជា គេអាចពិនិត្យឃើញយ៉ាងច្បាស់លាស់នូវ <u>ចរិត បដិវត្តប្រជាជាតិប្រជាធិបតេយ្យប្រជាជន</u> ហើយតាមរយៈនៃគោល*

នយោបាយនេះ វាបានផ្តល់នូវលទ្ធភាពដ៏ធំធេងសំរាប់ការប្រមូលកម្លាំងប្រឆាំងរបបប្រល័យពូជសាសន៍ ប៉ុល ពត។ ការបដិវត្តន៍មួយ ត្រូវបានធ្វើឡើងវិញ ដោយចាប់ផ្តើមពីកម្លាំងតូចៗ ខ្វះមាគ៌ា និងអង្គការចាត់តាំង ទៅជាកម្លាំងដែលមានអង្គការចាត់តាំង និងមានមាគ៌ាដឹកនាំត្រឹមត្រូវ។ ការបង្កើតបានអង្គការចាត់តាំងរណសិរ្ស និងគោលនយោបាយរណសិរ្សនាពេលនោះ គឺជាដំណាក់កាលរីកចំរើនដ៏ឆាប់រហ័សមួយ។ វាមិនគ្រាន់តែក្លាយជាកម្លាំងនយោបាយ និងយោធាដ៏មានអត្ថន័យសំរាប់ការតស៊ូរបស់ប្រជាជនកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែវាបង្កើតបាននូវភាពស្របច្បាប់សំរាប់ការទទួលស្គាល់ និងការគាំទ្រពីសំណាក់អន្តរជាតិ និងភាពស្របច្បាប់ សំរាប់ការអំពាវនាវអោយសហគមន៍អន្តរជាតិជួយឧបត្ថម្ភ ពិសេសផ្តល់ភាពស្របច្បាប់អោយការស្នើសុំរបស់ប្រជាជនកម្ពុជា ចំពោះការជួយឧបត្ថម្ភរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត។ មានអង្គការចាត់តាំងរណសិរ្ស និងមានគោលនយោបាយរណសិរ្ស គឺមានសារៈសំខាន់សំរាប់ការតស៊ូសង្គ្រោះជាតិ ប៉ុន្តែការបដិវត្តន៍មួយ មិនស្ថិតនៅមួយកន្លែង ត្រង់ការរំដោះជាតិនោះឡើយ គឺត្រូវមានគោលដៅចុងក្រោយដ៏ច្បាស់លាស់ គឺ ការកសាងសង្គមនិយមនៅកម្ពុជា។ ដូច្នេះភាពចាំបាច់ត្រូវមានបក្សនយោបាយមួយដឹកនាំ មានមាគ៌ាយុទ្ធសាស្ត្រ យុទ្ធវិធីក្នុងដំណាក់កាលនីមួយៗ។ និយាយដល់បក្សនយោបាយ បក្សបានត្រូវ ប៉ុល ពត បំផ្លិចបំផ្លាញដល់ឫសគល់ ទាំងមាគ៌ា និងអង្គការចាត់តាំង។ ការកសាងបក្សនយោបាយមួយ មិនមែនជាបញ្ហាដ៏សាមញ្ញនោះឡើយ វាមានការលំបាកជាងការបង្កើតឡើងនូវអង្គការរណសិរ្ស ទាំងចាត់តាំង ទាំង

មាគ៌ា និងគោលការណ៍។ បញ្ហាចោទឡើង តើត្រូវកសាងបក្សតាមរបៀបណា ហើយលើមូលដ្ឋានណាដើម្បីកសាងបក្ស ហើយកសាងនៅពេលណា។ ចំណុចនេះ ទាក់ទងសំខាន់ថា <u>តើត្រូវបង្កើតបក្សថ្មី ឬត្រូវកសាងបក្សឡើងវិញ</u>។ ប្រសិនជា <u>ត្រូវបង្កើតបក្សថ្មី មានន័យថា បក្សប្រជាជនបដិវត្តខ្មែរត្រូវអស់ជីវិតទៅហើយ ដូច្នេះប្រការសមស្របបំផុតនាពេលនោះ គឺការកសាងបក្សឡើងវិញ</u>។ ដោយឈរលើមូលដ្ឋាននៃការប្រមែប្រមូលបក្ខជនរបស់បក្ស ដែលបាននិងកំពុងធ្វើការតស៊ូប្រឆាំងពួក ប៉ុល ពត ចូលក្នុងអង្គការចាត់តាំងឯកភាពមួយ ហើយរៀបចំឡើងនូវមាគ៌ាគោលនយោបាយសំរាប់ដំណាក់កាលថ្មី ដូច្នេះបក្សប្រជាជនបដិវត្តខ្មែរត្រូវបានបន្តជីវិត ទាំងនយោបាយសតិអារម្មណ៍ទាំងចាត់តាំង តាមរយៈនៃមហាសន្និបាតកសាងបក្សឡើងវិញដែលបានដំណើរការ ពីថ្ងៃ ៥-៧ មករា ១៩៧៩ ដែលមានសមាជិកបក្ស ៦២ នាក់ ចូលរួម។ មហាសន្និបាតនេះ ត្រូវបានចាត់ទុកជាមហាសន្និបាតលើកទី ៣ របស់បក្ស ដែលបានរៀបចំឡើងនូវមាគ៌ាគោលនយោបាយរបស់បក្សលក្ខន្តិកៈ និងរបៀបរបបធ្វើការងាររបស់បក្ស បង្កើតឡើងនូវអង្គការដឹកនាំទូទាំងប្រទេសមួយមានឈ្មោះថា គណៈកសាងបក្សឡើងវិញដែលក្រោយនេះក្លាយទៅជាមជ្ឈិមបក្ស។

ដូចនេះ កម្លាំងបដិវត្តកម្ពុជា បានមានរចនាសម្ព័ន្ធមួយសមស្របមានបក្សដឹកនាំទាំងអង្គការចាត់តាំង ទាំងមាគ៌ា មានរណសិរ្សធំទូលាយមួយ និងមានកងកម្លាំងប្រដាប់អាវុធ ដើម្បីបំរើអោយការតស៊ូ។ គេអាចនឹងលើកថា បក្សមិនបានចូលរួមដឹកនាំរំដោះប្រទេសទេ អាស្រ័យ

ដោយពេលរំដោះប្រទេសថ្ងៃ ៧ មករា ១៩៧៩ បក្សកំពុងដំណើរការមហាសន្និបាតនៅឡើយ។ គេអាចនិយាយបានយ៉ាងដូចនេះ ប្រសិនបើគេមិនបានគិតដល់ចរិតបក្សក្នុងគោលនយោបាយរណសិរ្ស និងតួនាទីបក្ខជន កម្មាភិបាលរបស់បក្សក្នុងរណសិរ្ស និងក្នុងកម្លាំងប្រដាប់អាវុធ។ ទោះមិនទាន់បានដំណើរការមហាសន្និបាត ដើម្បីរៀបចំអង្គការដឹកនាំ និងមាគ៌ា ប៉ុន្តែបក្ខជន កម្មាភិបាលរបស់បក្ស គឺជាអ្នកមានតួនាទីសំខាន់ក្នុងការបង្កើតនូវរណសិរ្ស ទាំងអង្គការចាត់តាំងទាំងគោលនយោបាយ។ ដូច្នេះហើយ បានជាក្រោយមហាសន្និបាតកសាងបក្ស គេពិនិត្យឃើញនូវមាគ៌ារបស់បក្ស និងគោលនយោបាយរណសិរ្ស មានភាពស្របគ្នាទាំងស្រុង។ តាមការវិវត្តន៍របៀបនេះ គេអាចសន្និដ្ឋានបានថា <u>ការបដិវត្តន៍មួយត្រូវបានធ្វើឡើងវិញ ដោយចាប់ផ្តើមពីការកសាងឡើងវិញនូវកម្លាំងបដិវត្តដែលនៅសេសសល់ពីការកាប់សម្លាប់របស់ ប៉ុល ពត</u>។ ដូច្នេះការបដិវត្តន៍ត្រូវធ្វើឡើងវិញ ឯកម្លាំងបដិវត្ត គឺជាការបន្តចលនារបស់បក្សប្រជាជនបដិវត្តខ្មែរ។ នោះជាការតស៊ូមិនដាច់រយៈនៃបដិវត្តន៍កម្ពុជា ក្រោមការដឹកនាំរបស់បក្សម៉ាក្ស-ឡេនីន។ ចំណុចនេះ វាមានឡូហ្ស៊ីក (ត្រឹមត្រូវតាមតក្កវិជ្ជា) នៅត្រង់បក្សបន្តយកថ្ងៃ ២៨ មិថុនា ១៩៥១ ជាថ្ងៃកំណើតរបស់បក្ស នាពេលបច្ចុប្បន្ននេះ។

ក្នុងដំណើររីកចំរើននៃកម្លាំងបដិវត្តកម្ពុជា ឈានទៅផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត គេឃើញនូវកត្តាដ៏សំខាន់មួយគឺ <u>ការគួបផ្សំរវាងកម្លាំងបដិវត្តជាតិ និងកម្លាំងបដិវត្តអន្តរជាតិ នោះគឺតួនាទីរបស់បដិវត្តន៍វៀតណាម ក្នុងការជួយឧបត្ថម្ភចំពោះបដិវត្តន៍ និងប្រជាជន</u>

<u>កម្ពុជា</u>។ នេះជាចំណុចសំខាន់មួយ ដែលត្រូវបានបញ្ជាក់នៅក្នុងសម្ព័ន្ធភាព មានចរិតចាប់បង្ខំនិងចរិតស្ម័គ្រចិត្ត ដែលចរិតទាំងពីរនេះមានលក្ខណៈយុទ្ធសាស្ត្រយូរអង្វែង (លើកឡើងក្នុងជំពូក ១ នៃសៀវភៅនេះ)។ ការបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យទាំងពីរលើក នាពេលមុនក៏បានកើតឡើងនូវបញ្ហានេះ ហើយការបដិវត្តន៍ដើម្បីផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ក៏កាន់តែត្រូវការជាងទៀតនូវសម្ព័ន្ធភាពនេះ។ <u>ដូច្នេះការបដិវត្តន៍កម្ពុជាទាំងបីដំណាក់កាល គឺសុទ្ធតែបានប្រើប្រាស់កម្លាំងពីរគួបផ្សំគ្នា គឺកម្លាំងបដិវត្តកម្ពុជាផ្ទាល់ និងការជួយឧបត្ថម្ភរបស់បដិវត្តន៍វៀតណាម។ ការគួបផ្សំពិសេសរវាងកម្លាំងបដិវត្តកម្ពុជាផ្ទាល់ និងកម្លាំងជួយឧបត្ថម្ភរបស់បដិវត្តវៀតណាមមានតួនាទីកំណត់សំរេចនូវជ័យជំនះ ដែលមានអត្ថន័យជារបត់ប្រវត្តិសាស្ត្រ នាថ្ងៃ ៧ មករា ១៩៧៩</u>។

អាចសន្និដ្ឋានបានថា ប្រសិនបើគ្មានប្រទេសវៀតណាមមួយសង្គមនិយម គ្មានបក្សកុម្មុយនិស្តវៀតណាម ដែលប្រកាន់ខ្ជាប់នូវលទ្ធិម៉ាក្ស-ឡេនីន មានស្មារតីអន្តរជាតិអធនបរិសុទ្ធទេ បដិវត្តន៍កម្ពុជាមិនអាចដណ្តើមបានជ័យជំនះ នាថ្ងៃ ៧ មករា ១៩៧៩ នេះឡើយ។ ដោះស្រាយបញ្ចប់បានរបប ប៉ុល ពត នាខែមករា ១៩៧៩ គឺតាមរយៈនៃសម្ព័ន្ធភាពរវាងបក្សបដិវត្ត ប្រជាជនបដិវត្តនៃប្រទេសមួយជាមួយបក្សបដិវត្ត ប្រជាជនបដិវត្តនៃប្រទេសមួយផ្សេងទៀត គឺ<u>សម្ព័ន្ធភាពកម្ពុជា-វៀតណាមក្នុងក្របខ័ណ្ឌបដិវត្ត</u>។ ប្រសិនជាវៀតណាមមិនមែនជាប្រទេសសង្គមនិយម គឺវាពិតជាមានបញ្ហាខុសពីនេះ។ ថែក៏ជាប្រទេសមួយជាប់

ជាមួយកម្ពុជា ហើយក៏មានកម្លាំងបដិវត្តមួយចំនួនរត់ទៅជ្រកកោននៅប្រទេសថៃដែរ តែថៃមិនជួយកម្លាំងនេះឡើយ។ ផ្ទុយទៅវិញ ថៃបានប្រែក្លាយទៅជាសមរភូមិក្រោយអោយពួក ប៉ុល ពត បន្ទាប់ពីចិនបានជួយផ្សះផ្សាជម្លោះរវាងពួក ប៉ុល ពត និងថៃ ហើយបន្ទាប់ពីពួក ប៉ុល ពត បានបង្វែរមុខព្រួញសំខាន់មកវាយវៀតណាម ដែលតម្រូវអោយពួក ប៉ុល ពត ត្រូវតែសម្រុះសម្រួលជាមួយថៃ ។ ក្នុងពេលជាមួយគ្នា ថៃក៏បានអនុវត្តនយោបាយមុខពីរ គឺសម្រុះសម្រួលជាមួយ ប៉ុល ពត ផង និងជួយពួកខ្មែរសេរី ដើម្បីម៉្យាងការពារព្រំដែនអោយខ្លួន និងម៉្យាងទៀតសំរាប់ធ្វើជាកូនជញ្ជីងសំរាប់ឧត្តមភាព ក្នុងទំនាក់ទំនងជាមួយរបប ប៉ុល ពត ផង។ ដូច្នេះ ពិតប្រាកដណាស់ ថៃមិនអាចជួយក្នុងការផ្តួលរំលំរបប ប៉ុល ពត ឡើយ ទោះជាកម្លាំងណាក៏ដោយ។

ផ្អែកលើចំណុចពិសេសនៃសភាពការណ៍កម្ពុជា ការប្រើប្រាស់កម្លាំងពីរគួបផ្សំគ្នា គឺជាការចាំបាច់ខានមិនបាន គ្មានការជ្រើសរើសណាផ្សេងពីនេះឡើយ។ កម្លាំងផ្ទាល់របស់បដិវត្តន៍កម្ពុជា ទោះស្ថិតក្នុងប្រៀប និងកម្លាំងតិច ឬច្រើនក៏មានតួនាទីសំរេចកំណត់ ព្រោះថា បើគ្មានចលនាតស៊ូនៅខាងក្នុងទេ គ្មានប្រទេសណាមួយអាចជួយបានឡើយ។ ការជួយឧបត្ថម្ភពីបរទេស ត្រូវចេញពីសំណូមពរនៃបដិវត្តន៍ក្នុងប្រទេស វាមិនគ្រាន់តែជាបញ្ហាឯករាជ្យ អធិបតេយ្យ ប៉ុណ្ណោះទេ ប៉ុន្តែវាជាក្រឹត្យក្រមសត្យានុម័តនៃការបដិវត្តន៍ពិតប្រាកដមួយ ដែលជានិច្ចកាលត្រូវផ្តើមចេញពីជាតិរបស់ខ្លួន ដែលជនជាតិផ្សេងមិនអាចធ្វើជំនួសបាន។ ខាងក្រៅអាចជួយបាន តែពេលណាមានសំណូមពរពីខាងក្នុង។ បដិវត្តន៍

*កម្ពុជា ស្ថិតក្នុងសភាពការណ៍នេះឯង កម្លាំងគ្រប់ផ្នែក ពិតមែនតែមាន ការរីកចំរើន ទាំងមុន និងក្រោយពេលបង្កើតរណសិរ្សសាមគ្គីសង្គ្រោះ ជាតិកម្ពុជា ប៉ុន្តែពុំមានលទ្ធភាពនឹងផ្តួលរំលំរបប ប៉ុល ពត ក្នុងរយៈ ពេលខ្លីនោះបានឡើយ។ ប៉ុន្តែទោះជាកម្លាំងពុំទាន់ខ្លាំង តែវាបានក្លាយ ទៅជា កត្តាសំរេចកំណត់ អាស្រ័យដោយកម្លាំងនេះជាម្ចាស់របស់ បដិវត្តន៍ តំណាងអោយឆន្ទៈរបស់ប្រជាជនកម្ពុជា ហើយដោយផ្តើម ចេញពីភាពជាម្ចាស់នេះហើយ ដែលបង្កើតឡើងនូវភាពស្របច្បាប់សំ រាប់ការអំពាវនាវសុំជំនួយបរទេស។ ការជួយរបស់បដិវត្តន៍វៀតណាម មានភាពចាំបាច់ និងមានសារសំខាន់ខ្លាំងណាស់ ក្នុងការផ្តួលរំលំរបប ប៉ុល ពត។ បើគ្មានការជួយរបស់កងទ័ពស្ម័គ្រចិត្តវៀតណាមទេ ពិតជា មិនអាចផ្តួលរំលំរបប ប៉ុល ពត ក្នុងខែមករា ១៩៧៩ បានឡើយ។ ការ ជួយរបស់វៀតណាមនាលើកទីបីនេះ មានភាពចាំបាច់ និងបន្ទាន់ជាង ពេលណាៗ ទាំងអស់។ បន្ទាន់នៅត្រង់ថា ប្រជាជនកម្ពុជាមិនមែន គ្រាន់តែស្ថិតនៅក្នុងការជិះជាន់សង្កត់សង្កិនជម្មតានោះទេ ប៉ុន្តែកំពុង ស្ថិតនៅក្នុងការប្រល័យពូជសាសន៍ ប្រៀបដូចជាជំងឺមួយ ដែលត្រូវ សង្គ្រោះបន្ទាន់ មិនអាចពន្យារបានតទៅទៀតឡើយ។ ប្រសិនបើប្រើ ប្រាស់តែកម្លាំងបដិវត្តកម្ពុជាតែម្នាក់ឯងគឺនឹងបន្តជីវិតរបស់របប ប៉ុល ពត តទៅទៀត ហើយវិនាសកម្មចំពោះជាតិ និងប្រជាជនកម្ពុជា មាន កាន់តែច្រើន ហើយផ្នែកណានោះ ប្រជាជនវៀតណាមនៅតាមព្រំដែន ជាមួយកម្ពុជា ក៏នឹងជួបប្រទះវិនាសកម្មដែរ។*

*ដំណើរការវិវត្តន៍បញ្ច្រាសទិសគ្នា រវាងបដិវត្តន៍ និងក្បត់បដិវត្តន៍*

បង្កើតឡើងនូវឧត្តមភាពយ៉ាងដាច់ខាតដោយកម្លាំងបដិវត្តន៍ ដើម្បីផ្តួលរំលំរបប ប៉ុល ពត។ ក្នុងពេលដែលកម្លាំងបដិវត្តន៍កម្ពុជាកំពុងរីកចំរើន ហើយរកបាននូវការជួយឧបត្ថម្ភរបស់បដិវត្តន៍វៀតណាម ពួក ប៉ុល ពត បានបន្តអនុវត្តនយោបាយអត្តឃាតខ្លួនកាន់តែខ្លាំង ឯកោខ្លួនកាន់តែខ្លាំង។ នយោបាយក្នុងប្រទេស និងនយោបាយក្រៅប្រទេសប្រតិកិរិយា គឺជាវត្ថុធាតុពីរគួបផ្សំគ្នា ដើម្បីបញ្ចប់ជីវិតរបប ប៉ុល ពត។

ការបង្កើតឡើងនូវរណសិរ្សសាមគ្គីសង្គ្រោះជាតិ និងការរីកចំរើននៃកម្លាំងប្រដាប់អាវុធបដិវត្តកម្ពុជា បានកើតមានឡើងចំពេលដែលវៀតណាមបានវាយបំបាក់កងពលសំខាន់ៗ របស់ ប៉ុល ពត ដែលចូលឈ្លានពានវៀតណាម។ ការវាយបំបាក់របស់វៀតណាមទៅលើកម្លាំងឈ្លានពានរបស់ ប៉ុល ពត បានបង្កឡើងនូវតុល្យភាពកម្លាំងមានភាពអនុគ្រោះអោយបដិវត្តន៍ និងបង្កើតឡើងនូវឱកាសយុទ្ធសាស្ត្រសំរាប់ការវាយលុករបស់បដិវត្តន៍ទៅលើរបប ប៉ុល ពត។ តាំងពីយូរមកហើយកំហឹងរបស់ប្រជាជនចំពោះរបប ប៉ុល ពត ប្រៀបដូចជាគ្រាប់បែកមួយដែលរង់ចាំពេលផ្ទុះ ក្រោយពេលដកគន្លឹះ តែខ្វះអ្នកដកគន្លឹះ។ ក្រោយការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា គឺជាឱកាសសំខាន់បំផុតសំរាប់ការក្រោកឈរឡើងរបស់ប្រជាជន ដូច្នេះ ការវាយលុករបស់កងកម្លាំងប្រដាប់អាវុធបដិវត្តកម្ពុជា ដោយមានការជួយឧបត្ថម្ភដោយទ្រង់ទ្រាយធំពីកងទ័ពស្ម័គ្រចិត្តវៀតណាម ត្រូវបានការចូលរួមពីប្រជាជននៅគ្រប់ទីកន្លែង ធ្វើអោយជំហានរុលទៅមុខនៃកម្លាំងប្រដាប់អាវុធទាំងពីរកម្ពុជា-វៀតណាម លឿន និងឆាប់រហ័សហួសពីការគ្រោងទុក។

នយោបាយក្នុងប្រទេសក្រៅប្រទេសរបស់ ប៉ុល ពត គឺជានយោបាយអត្តឃាតខ្លួនវា នេះគឺជាកត្តាសំខាន់បំផុតបង្កើតឡើងនូវកត្តាផ្សេងទៀត។ ចរន្តបដិបក្ខដ៏ជ្រាលជ្រៅក្នុងបែបផែនផលិតកម្ម ជាមូលហេតុសំខាន់បំផុត បង្កើតឡើងនូវការតស៊ូបដិវត្តន៍របស់ប្រជាជន ដែលជាតុពិតជាការតស៊ូ ដើម្បីលុបបំបាត់ចោលបែបផែនផលិតកម្មបែបទាសភាពរបស់ ប៉ុល ពត បង្កើតឡើងនូវបែបផែនផលិតកម្មថ្មី។ ការឈ្លានពានរបស់ពួក ប៉ុល ពត ទៅលើវៀតណាម បង្កើតបានជាចំណុចខ្សោយសំខាន់មួយទៀត សំរាប់ការដួលរលំនៃរបបនេះ។ ដូច្នេះ ការដួលរលំដ៏ឆាប់រហ័សនៃរបប ប៉ុល ពត មិនមែនជាការចៃដន្យឡើយ។ វាជាក្រឹត្យក្រមដែលជៀសវាងមិនផុត។ ប៉ុន្តែក៏គួរបញ្ជាក់ផងដែរថា បើសិនជាគ្មានការវាយលុកដ៏ខ្លាំងរបស់កងទ័ពកម្ពុជា និងកងទ័ពវៀតណាមទេ ក៏មិនអាចបញ្ចប់ជីវិតរបប ប៉ុល ពត បានឆាប់រហ័សនោះដែរ តែក៏ត្រូវឃើញថា បើគ្មានការចូលរួមពីប្រជាជនទេ យើងមិនអាចបើកទូលាយតំបន់រំដោះ និងឈានទៅបង្កើតរដ្ឋអំណាចគ្រប់ថ្នាក់បានឆាប់រហ័សដែរ ព្រោះថាពេលនោះ កងទ័ពទាំងកម្ពុជាទាំងវៀតណាម មានភារកិច្ចសំខាន់វាយរុលទៅមុខ សូម្បីតែរំដោះភ្នំពេញហើយក្តី ក៏ត្រូវបន្តវាយបោសសំអាតខ្មាំង។ ដូច្នេះអាស្រ័យដោយការចូលរួមរបស់ប្រជាជន ទើបបង្កើតឡើងនូវចលនាបំផ្លាញចោលរដ្ឋអំណាចប្រតិកិរិយា កសាងឡើងនូវរដ្ឋអំណាចថ្មីរបស់ប្រជាជននៅមូលដ្ឋាន ដែលពេលនោះហៅថា គណៈកម្មាធិការគ្រប់គ្រងខ្លួនឯង ព្រោះកន្លែងជាច្រើនកងទ័ព ឬកម្មាភិបាលបដិវត្តមិនបានទៅដល់ ឬទៅដល់ តែមិនបានចាត់តាំង។ ប្រជាជនគេចាត់តាំងរដ្ឋអំណាចគ្រប់គ្រងដោយខ្លួនឯង ហើយ

ជារដ្ឋអំណាចបដិវត្តរបស់ប្រជាជន។ ប្រជាជនបានម្ចាស់ការបំបាត់ចោលនូវបែបផែនផលិតកម្មបែបទាសភាព របបធ្វើរួមស៊ីរួម រស់នៅរួម ពលកម្មដោយចាប់បង្ខំ បង្កើតឡើងនូវទំនាក់ទំនងផលិតកម្មថ្មីមួយ។

ដូច្នេះការចូលរួមរបស់ប្រជាជន ជាកត្តាសំខាន់បំផុតក្នុងការបំបាត់ចោលរដ្ឋអំណាចមូលដ្ឋានចាស់ បែបផែនផលិតកម្មចាស់ បង្កើតឡើងនូវរដ្ឋអំណាចបដិវត្តនៅមូលដ្ឋាន និងបែបផែនផលិតកម្មថ្មីជាកត្តាជំរុញដ៏សកម្ម ដើម្បីកងទ័ពវាយកំទេចកម្លាំងរស់ និងក្បាលម៉ាស៊ីនត្រួតត្រារបស់ ប៉ុល ពត នៅគ្រប់ថ្នាក់។

កម្លាំងទាំងពីរ កម្ពុជា-វៀតណាម ជាធាតុពីរមិនអាចខ្វះណាមួយបានឡើយ។ កម្លាំងផ្ទាល់របស់បដិវត្តន៍កម្ពុជា មានតួនាទីសំរេចកំណត់ តែការសំរេចកំណត់នៅពេលនោះនៃកត្តាផ្ទៃក្នុង មុនបង្អស់គឺលើផ្នែកនយោបាយ ព្រោះវាជាធាតុនៃកម្លាំងខាងក្នុង បង្កើតជាមូលដ្ឋានស្របច្បាប់ អោយការស្នើសុំជំនួយឧបត្ថម្ភពីអន្តរជាតិ។ ឯការជួយឧបត្ថម្ភរបស់វៀតណាម មានតួនាទីសំខាន់ តែមាន<u>ចរិតកំណត់សំខាន់ចាំបាច់លើផ្នែកយោធា</u> ព្រោះថាកម្លាំងប្រដាប់អាវុធផ្ទាល់ របស់បដិវត្តន៍កម្ពុជា មានបរិមាណ និងគុណភាព មិនគ្រប់គ្រាន់សំរាប់ការផ្តួលរំលំរបប ប៉ុល ពត ដែលមានកម្លាំងយោធារហូត ១៨០.០០០ នាក់នោះឡើយ។ ដូច្នេះតួនាទីរបស់កងទ័ពវៀតណាមមានចរិតកំណត់អំពីផ្នែកយោធា។ តាមរបៀបនេះ គេឃើញនូវចំណងទាក់ទងជះឥទ្ធិពលអោយគ្នា បង្កើតឡើងនូវកម្លាំងសរុបមានអត្ថន័យដើម្បីសំរេចជោគជ័យ ក្នុងការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត។ <u>កត្តាផ្ទៃក្នុងបង្កើតឡើង នូវមូល</u>

ដ្ឋាននយោបាយ សំរាប់កត្តាអន្តរជាតិ ហើយកត្តាអន្តរជាតិ មានសារសំខាន់លើច្រើនវិស័យ តែដើរតួនាទីជាកំណត់សំខាន់ចាំបាច់លើផ្នែកយោធា។ ការដែលកងទ័ពវៀតណាម មានតួនាទីសំរេចកំណត់ខាងយោធា ក្នុងការផ្តួលរំលំរបប ប៉ុល ពត បានបង្កើតអោយ មានការមួលបង្កាច់ពីសត្រូវ អំពីរបស់ដែលហៅថាវៀតណាមឈ្លានពានកម្ពុជា ហើយចេញពីនោះ មនុស្សមួយចំនួនក៏បានចាត់ទុកថា បដិវត្តន៍កម្ពុជា ដើរមិនត្រូវតាមក្រឹត្យក្រម ព្រោះបដិវត្តន៍នេះត្រូវបានវៀតណាមធ្វើអោយស្មើរទាំងស្រុង។

តាមរយៈនៃការវិវត្តន៍សភាពការណ៍នៅពេលនោះ គេសន្និដ្ឋានបានថា បដិវត្តន៍កម្ពុជា បានដើរត្រឹមត្រូវតាមក្រឹតក្រម ហើយវៀតណាមចូលមកជួយកម្ពុជា គឺស្របច្បាប់ទាំងស្រុង ។ បដិវត្តន៍កម្ពុជា ដើរត្រូវតាមក្រឹត្យក្រមនៅត្រង់បដិវត្តន៍នេះ ផុសចេញពីប្រជាជនកម្ពុជាខ្លួនឯង ហើយដែលមានមូលហេតុគ្រប់គ្រាន់ដើម្បីដំណើរការបដិវត្តន៍។ អាស្រ័យដោយមានការតស៊ូរបស់ប្រជាជនកម្ពុជា ដែលមានអង្គការចាត់តាំងខាងនយោបាយយោធាត្រឹមត្រូវនេះហើយ ទើបផ្តល់ភាពស្របច្បាប់ អោយការស្នើសុំជំនួយបរទេស និងការគាំទ្រពីបរទេស នេះជាទម្លាប់ធម្មតា។

ការជួយឧបត្ថម្ភរបស់កងទ័ពស្ម័គ្រចិត្តវៀតណាម គឺមានភាពស្របច្បាប់ទាំងស្រុង អាស្រ័យដោយចេញពីសំណូមពររបស់ប្រជាជនកម្ពុជា។ នេះក៏ជាទម្លាប់ធម្មតា មិនមែនគ្រាន់តែសំរាប់ការបដិវត្តន៍ប៉ុណ្ណោះទេ ប្រទេសជាច្រើននៅពេលដែលកាលៈទេសៈចាប់បង្ខំ និងក្នុងករណី

សមស្របបានហៅកងទ័ពបរទេសចូលមកជួយ គេតែងនិយាយពីភាព ស្របច្បាប់ដែរ។ នៅមានចំណុចមួយទៀត វៀតណាមក៏អាចវាយ ប៉ុល ពត បានដែរ ប្រសិនបើមិននិយាយដល់ការដែលវៀតណាមមិនជួយ បដិវត្តន៍ និងប្រជាជនកម្ពុជា ក្នុងស្មារតីអន្តរជាតិអធននោះទេ នោះគឺ ការអនុវត្តន៍សិទ្ធិវាយតបរបស់ប្រជាជនវៀតណាម ទៅលើការឈ្លាន ពានរបស់ពួក ប៉ុល ពត។ សិទ្ធិវាយតបរបស់វៀតណាម គឺជាសិទ្ធិស្រប ច្បាប់។ ប្រការនេះ គេបានឃើញនូវទម្លាប់ ដែលបានកើតមានឡើងនៅ ក្នុងសង្គ្រាមលោកលើកទី២ គឺកងទ័ពសម្ព័ន្ធមិត្តដែលមានសហភាពសូ វៀត សហរដ្ឋអាមេរិក បារាំង អង់គ្លេស វាយលុកចូលប្រទេសអាល្លឺម៉ង់ ដើម្បីផ្តួលរំលំពួកហ្វាស៊ីស្តហ៊ីត្លែរ ក្រោយពេលប្រទេសនេះ ទៅឈ្លាន ពានប្រទេសផ្សេងទៀត ឬសហភាពសូវៀត និងសហរដ្ឋអាមេរិក វាយ ពួកហ្វាស៊ីស្តជប៉ុន ក្រោយពេលជប៉ុន ដើរឈ្លានពានប្រទេសដទៃ។

ការជួយរបស់វៀតណាមស្ថិត ក្នុងស្មារតីអន្តរជាតិអធនទាំងស្រុង ក្នុងគោលបំណងជួយសង្គ្រោះប្រជាជនកម្ពុជា អោយចេញផុតពីរបប ប្រល័យពូជសាសន៍ ប៉ុល ពត។ មានមតិមួយចំនួន បានលើកឡើងថា វៀតណាមមានការចាំបាច់ក្នុងការផ្តួលរំលំរបប ប៉ុល ពត ដើម្បីរក្សា សន្តិសុខរបស់ខ្លួននៅភាគខាងត្បូង ដើម្បីបន្ធូរកម្លាំងសង្កត់នៅភាគ ខាងជើងពីសំណាក់ចិន។ មតិនេះ ជាហេតុផលមួយ ប៉ុន្តែមិនត្រឹមត្រូវ តាមចរិតពិតប្រាកដនៃបំណងរបស់បក្ស រដ្ឋាភិបាល និងប្រជាជនវៀត ណាមឡើយ។ ប្រសិនបើវៀតណាមគិតត្រឹមតែសន្តិសុខរបស់ខ្លួន ការ ធ្វើសកម្មភាពវាយបក និងការប្រើប្រាស់សិទ្ធិវាយតបទៅលើការឈ្លាន

ពានរបស់ ប៉ុល ពត ល្មមគ្រប់គ្រាន់ ដើម្បីកាច់បំបាក់ ប៉ុល ពត បន្ថយ ឬរាំងស្កាត់បានអំពើឆ្កួតលេលារបស់វាទៅលើឯករាជ្យ អធិបតេយ្យរបស់វៀតណាម ។ ដូច្នេះការចូលមកកម្ពុជារបស់កងទ័ពស្ម័គ្រចិត្តវៀតណាម មិនមែនជាការឈ្លានពាន ឬជាផលប្រយោជន៍ផ្ទាល់របស់វៀតណាមនោះឡើយ តែវាជាផលប្រយោជន៍ជាអាយុជីវិតរបស់ប្រជាជនកម្ពុជា។ ពិតមែនហើយ វៀតណាមមានផលប្រយោជន៍ខាងសន្តិសុខរបស់ខ្លួន តែផលប្រយោជន៍ជាបឋមចេញមកពីផលប្រយោជន៍ប្រជាជនកម្ពុជា។ ការដែលវៀតណាមជួយកម្ពុជា វាយរំលំរបប ប៉ុល ពតគឺដើម្បីការរស់រានមានជីវិតរបស់ប្រជាជនកម្ពុជា សន្តិសុខរបស់វៀតណាមនៅតាមព្រំដែនជាមួយកម្ពុជាក៏ត្រូវបានធានា មិត្តភាពរវាងកម្ពុជា-វៀតណាម ដែលត្រូវបាន ប៉ុល ពត បំផ្លាញ ត្រូវបានស្តារឡើងវិញ។

គួររំលឹកថា វៀតណាមបានសំរេចចិត្ត ដើម្បីជួយបដិវត្តន៍កម្ពុជា ក្នុងសភាពការណ៍នាពេលនោះមានការលំបាកយ៉ាងធំធេង ម៉្យាង វៀតណាមទើបចេញពីសង្គ្រាម ទើបឯកភាពទឹកដីឡើងវិញ ត្រូវប្រមូលផ្តុំកម្លាំងដើម្បីកសាងប្រទេសឡើងវិញ ម៉្យាងទៀត ការលើកកងទ័ពពីប្រទេសមួយចូលមកប្រទេសមួយទៀត ពិតជាបង្កើតអោយមានប្រតិកម្មអន្តរជាតិមិនអនុគ្រោះ ទោះជាការចូលមកនេះ ក្នុងទិសដៅជួយប្រជាជនកម្ពុជាសុទ្ធសាធ ក៏សត្រូវពិតជាឆ្លៀតប្រើព្រឹត្តិការណ៍នេះ ដើម្បីប្រឆាំងបដិវត្តន៍វៀតណាម និងបដិវត្តន៍កម្ពុជាដែរ។ ដូច្នេះមិនមែនជាបញ្ហាដ៏សាមញ្ញទេ ដើម្បីធ្វើការសំរេចចិត្តលើបញ្ហាដ៏សំខាន់មួយរបៀបនេះ។ បើវៀតណាមឈរតែលើផលប្រយោជន៍ជាតិ ហើយគ្មានគោល

ដំហារអន្តរជាតិអធន ប្រជាជនកម្ពុជានឹងបន្តស្លាប់ ក្រោមរបបប្រល័យពូជសាសន៍ ហើយមិនប្រាកដថា កម្ពុជាអាចចេញផុតពីរបបប្រល័យពូជសាសន៍បានទេ ប្រសិនជាប្រើប្រាស់តែកម្លាំងបដិវត្តន៍កម្ពុជាផ្ទាល់។

គេអាចដាក់សំណួរថា ប្រសិនជាវៀតណាមមិនជួយសង្គ្រោះប្រជាជនកម្ពុជា ដោយស្មារតីអន្តរជាតិអធនទេ តែបែរជាធ្វើសម្ព័ន្ធមិត្តជាមួយ ប៉ុល ពត ឬអព្យាក្រឹតចំពោះពួក ប៉ុល ពត ឬវាយ ប៉ុល ពត តែក្នុងកំរិតអនុវត្តសិទ្ធិវាយតបដើម្បីការពារឯករាជ្យ អធិបតេយ្យរបស់ខ្លួន តើមានប្រទេសណាខ្លះ នឹងជួយប្រជាជនកម្ពុជា ហើយបើរបបប្រល័យពូជសាសន៍ ប៉ុល ពត បន្តជីវិតរហូតដល់សព្វថ្ងៃ តើគេនឹងបានឃើញអ្វីខ្លះនៅលើទឹកដីកម្ពុជាដ៏អភ័ព្វនេះ។ ទោះជាអ្នកប្រឆាំងវៀតណាម ប្រឆាំងកម្ពុជាដល់កំរិតណា ក៏មិនអាចរកចម្លើយបានឡើយ សូម្បីតែនរោត្តម សីហនុ ដែលជាសម្ព័ន្ធមិត្តរបស់ ប៉ុល ពត តាំងពីដើមដល់ចប់ ក៏បាននិយាយច្រើនលើកច្រើនសា ក្នុងឱកាសចរចាសីហនុ-ហ៊ុន សែន ថា បើគ្មានកងទ័ពឯកឧត្តម ហ៊ុន សែន គ្មានកងទ័ពវៀតណាម វាយ ប៉ុល ពត ទេ ខ្ញុំ (សីហនុ) ក៏នឹងស្លាប់ដែរ។ កូន និងចៅរបស់សម្តេច សីហនុ ជាច្រើនត្រូវបាន ប៉ុល ពត សម្លាប់ ហើយផ្ទាល់ខ្លួនសម្តេច ក៏ត្រូវជាប់ឃុំនៅមួយកន្លែង។ អ្នកមានកិត្តិយស ហើយបានរួមដំណើរ ធ្វើការជាមួយ ប៉ុល ពត ត្រូវ ប៉ុល ពត សម្លាប់កូនចៅ និងធ្វើទារុណកម្មទៅបាន ចុះប្រជាជនសាមញ្ញ តើ ប៉ុល ពត នឹងធ្វើយ៉ាងណាចំពោះពួកគេ។ ក្រោយពេលវៀតណាមបានដកកងទ័ពចេញពីកម្ពុជា ប្រទេសជាច្រើនក្នុងនោះ មានទាំងសហរដ្ឋអាមេរិក និងលោកខាងលិចផង បានព្រួយ

បារម្ភពីការវិលត្រឡប់នៃរបបប្រល័យពូជសាសន៍ ប៉ុល ពត ដូច្នេះមានន័យថា គេទទួលស្គាល់ថា វៀតណាម ជួយផ្ដួលរំលំរបប ប៉ុល ពត និងជួយរាំងស្កាត់កុំអោយបង្កើតឡើងវិញនូវរបបប្រល័យពូជសាសន៍ ប៉ុល ពត គឺជាការចាំបាច់ក្នុងផ្លូវច្បាប់ និងសីលធម៌ ហើយទទួលស្គាល់ថា វៀតណាមចូលមកកម្ពុជា ក្នុងបំណងជួយប្រជាជនកម្ពុជា ដោយពិតប្រាកដ។ បើគេមិនទទួលស្គាល់ប្រការនេះ តើចាំបាច់ព្រួយបារម្ភពីការវិលត្រឡប់នៃរបបប្រល័យពូជសាសន៍ ប៉ុល ពត ធ្វើអ្វី? ជាង ១០ ឆ្នាំក្រោយការដួលរលំនៃរបប ប៉ុល ពត គេនៅព្រួយបារម្ភពីការវិលត្រឡប់នៃរបប ប៉ុល ពត ដូច្នេះការវាយរំលំរបប ប៉ុល ពត នាខែមករា ១៩៧៩ វាជាការចាំបាច់ខានមិនបាន។

របបប្រល័យពូជសាសន៍ ប៉ុល ពត ត្រូវបានដួលរលំ សករាជថ្មីមួយបានចាប់ផ្ដើម សំរាប់ប្រជាជនកម្ពុជា។

ផ្នែកទី ៣

# ការរស់ឡើងវិញរបស់ជាតិក្នុងស្ថានភាព មានសន្តិភាពផង និងមានសង្គ្រាមផង

***ដើម្បី****ពិនិត្យឃើញគ្រប់គ្រាន់ អំពីការរស់ឡើងវិញរបស់ជាតិ ចាំបាច់ត្រូវឃើញអំពីចំណុចពិសេសនៃការចេញដំណើរ និងចំណុចពិសេសនៃសភាពការណ៍ដែលបានឆ្លងកាត់។ <u>នោះគឺផលវិបាកនៃរបប ប៉ុល ពត និងសង្គ្រាមបន្ត</u>។*

*ប្រទេសមួយដែលបានឆ្លងកាត់សង្គ្រាម ហើយជាពិសេសឆ្លងកាត់របបប្រល័យពូជសាសន៍ ផលវិបាករបស់វា បន្សល់ទុក គឺជាផលវិបាកធ្ងន់ធ្ងរបំផុត ដែលបណ្តាប្រទេសលើសកលលោក មិនដែលជួបប្រទះរាប់ទាំងប្រទេស ដែលបានឆ្លងកាត់សង្គ្រាមលោកទាំងពីរលើកផង។ ដូចបានលើកឡើងក្នុងសៀវភៅនេះ អំពីធាតុពិតនៃរបប ប៉ុល ពត ការបំផ្លិចបំផ្លាញនៃរបបនេះ មានទំហំនិងកំរិតធ្ងន់ធ្ងរបំផុត។ ប្រជាជនជាង ៣ លាននាក់ ក្នុងចំណោមប្រជាជនជិត ៨ លាននាក់ ត្រូវបានស្លាប់ ។ អ្នកដែលនៅសេសសល់ ត្រូវបាក់កម្លាំង ព្រាត់ប្រាសបែកបាក់គ្រួសារ កុមារកំព្រា រាប់ម៉ឺននាក់ មនុស្សម្នាគ្មានទីពំនាក់ មានច្រើនសន្ធឹកសន្ធាប់។ មូលដ្ឋានផលិតកម្ម មូលដ្ឋានសំភារៈបច្ចេកទេស ត្រូវ*

*បំផ្លិចបំផ្លាញស្មើរគ្មានសល់ គឺជាការបំផ្លាញត្រង់ទៅលើកម្លាំងផលិតកម្មរបស់ប្រទេសជាតិ។ សាលារៀន មន្ទីរពេទ្យ វត្តអារាម វប្បធម៌ប្រពៃណី ទីក្រុង ទីប្រជុំជន ប្រាក់កាស ទីផ្សារ ការលក់ដូរ ។ល។ សុទ្ធតែត្រូវបំផ្លិចបំផ្លាញ។ ដូច្នេះចំណុចចេញដំណើរសំរាប់ប្រជាជនកម្ពុជា កសាងសង្គមថ្មី គឺ <u>ចេញពីលេខសូន្យ ឬពីបាតដៃទទេ ជាមួយនឹងផលវិបាករាប់មិនអស់</u> ហើយផលវិបាកដែលធ្ងន់ធ្ងរជាងគេ គឺគ្រោះអត់ឃ្លាន បានគំរាមកំហែងនៅទូទាំងប្រទេស។ ជាមួយនឹងផលវិបាកយ៉ាងធ្ងន់ធ្ងរលើវិស័យសេដ្ឋកិច្ច និងសង្គម គ្រោះថ្នាក់នៃការវិលត្រឡប់នៃរបប ប៉ុល ពត មិនទាន់បានបញ្ចៀសទាំងស្រុងនៅឡើយ។ ពិតមែនតែរបប ប៉ុល ពត ត្រូវបានដួលរលំ ប៉ុន្តែកម្លាំងរបស់វា នៅសេសសល់ដោយមានការជួយឧបត្ថម្ភរបស់អានុភាពចក្រពត្តិ និងប្រតិកិរិយាខាងក្រៅ។ តាមរយៈនៃការជួយឧបត្ថម្ភពីអានុភាពចក្រពត្តិ និងប្រតិកិរិយាខាងក្រៅ គេបានប្រមូលពួកប្រតិកិរិយាឆ្វេងបំផុត និងស្តាំបំផុត អោយស្ថិតក្នុងរណសិរ្សជាមួយគ្នា ប្រឆាំងនឹងការរស់ឡើងវិញ របស់ជាតិ។ ដូច្នេះសភាពការណ៍កម្ពុជាតាំងពីពេលបានរំដោះមក គឺស្ថិតក្នុង <u>ស្ថានភាព និងកាលៈទេសៈ មានសន្តិភាពផង និងមានសង្គ្រាមផង</u>។ ពិតមែនតែសន្តិភាពបានកើតមានលើចំណែកភាគច្រើននៃដែនដី និងពេលវេលា ហើយសង្គ្រាមបានកើតមានដោយដាច់ដោយដុំ និងពេលវេលាខ្លះ ក៏សង្គ្រាមនេះ វាបានរាំងស្ទះនូវដំណើរការកសាងប្រទេសឡើងវិញ បំផ្លិចបំផ្លាញនូវទ្រព្យសម្បត្តិ អាយុជីវិតប្រជាជនកម្ពុជា ជាបន្តទៀត។*

*អាស្រ័យដោយមិនទាន់បានបញ្ចៀសផុតទាំងស្រុង នូវគ្រោះថ្នាក់នៃការវិលត្រឡប់នៃរបប ប៉ុល ពត ទើបបដិវត្តន៍កម្ពុជា បានបន្តប្រើប្រាស់ កម្លាំងពីរគួបផ្សំគ្នា គឺកម្លាំងបដិវត្តន៍កម្ពុជាផ្ទាល់ និងការជួយឧបត្ថម្ភ របស់កងទ័ពវៀតណាមរហូតមកដល់ខែកញ្ញា ឆ្នាំ ១៩៨៩។ នេះជាចំណុចពិសេសនៃការចេញដំណើរនៃបដិវត្តន៍កម្ពុជា ក្រោយពេលដណ្ដើមបានរដ្ឋអំណាច។ អាស្រ័យដោយលក្ខណៈពិសេសនៃសភាពការណ៍ បដិវត្តន៍កម្ពុជា ត្រូវប្រឈមមុខជាមួយនឹងរណសិរ្សពីរក្នុងពេលជាមួយគ្នា។ នោះគឺភារកិច្ចការពារ ដោយរឹងមាំនូវឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី ទប់ស្កាត់ការវិលត្រឡប់នៃរបប ប៉ុល ពត និងស្ដារឡើងវិញសេដ្ឋកិច្ចសង្គម សំខាន់ការដោះស្រាយការអត់ឃ្លានដែលកំពុងគំរាមកំហែងជីវិតប្រជាជន នៅទូទាំងប្រទេស។ វាបានក្លាយទៅជា ភារកិច្ចយុទ្ធសាស្ត្រពីរ គឺការពារប្រទេស និងកសាងប្រទេសដែលត្រូវធ្វើក្នុងពេលជាមួយគ្នា។ អាស្រ័យហេតុនេះ តាំងពីគ្រាដំបូងបក្សបានដាក់ចេញនូវចលនាបដិវត្តទាំងបីរបស់មហាជន គឺចលនាវាយខ្លាំង និងចលនាអូសទាញខ្មាំង ចលនាកសាងកម្លាំងពិតបដិវត្តលើគ្រប់ផ្នែក ចលនាបង្កបង្កើនផលដោះស្រាយ និងធ្វើអោយមានស្ថេរភាពជីវភាពប្រជាជន។ ចលនាបដិវត្តទាំងបី ជាខ្លឹមសារស្នូលសំខាន់នៃចលនាបដិវត្តរបស់មហាជន មិនត្រឹមតែត្រឹមត្រូវនាគ្រាដំបូងប៉ុណ្ណោះទេ ប៉ុន្តែវាត្រឹមត្រូវក្នុងរយៈពេលឆ្លងកាត់ និងកំពុងត្រឹមត្រូវពេលបច្ចុប្បន្ន ក៏ដូចជាពេលខាងមុខ។*

*ក្នុងក្របខ័ណ្ឌនៃភារកិច្ចការពារប្រទេស ដែលបក្សប្រជាជនបដិវត្ត*

កម្ពុជា បានដាក់ចេញតាំងពីគ្រាដំបូងនូវគោលការណ៍ដ៏ត្រឹមត្រូវ នោះគឺ ខឿនការពារប្រទេសរបស់ប្រជាជនទាំងមូល។ នេះជាមាគ៌ាសង្គ្រាមប្រជាជន ដើម្បីអនុវត្តភារកិច្ចការពារជាតិ។ អាស្រ័យដោយមាគ៌ាយោជាត្រឹមត្រូវនេះ ការចូលរួមរបស់ប្រជាជន បានក្លាយទៅជាចលនាដ៏ទូលំទូលាយ បង្កើតឡើងនូវលក្ខណៈសម្បត្តិងាយស្រួលសំរាប់ការកសាងកងទ័ពទាំងបីប្រភេទ (ស្រួច-តំបន់-ឃុំ) នគរបាលប្រជាជន និងបង្កើតឡើងនូវចលនាវាយខ្មាំង អូសទាញខ្មាំងយ៉ាងសកម្មផុសផុល។ ការរីកចំរើននូវកម្លាំងការពារជាតិរបស់ប្រជាជនកម្ពុជាផ្ទាល់ បានបង្កលក្ខណសម្បត្តិអោយកងទ័ពស្ម័គ្រចិត្តវៀតណាមដកជាបណ្តើរៗ តាំងពីឆ្នាំ ១៩៨២ និងឈានទៅដកទាំងស្រុង នាខែកញ្ញា ១៩៨៩ ដែលជាដំណាក់កាលផ្ទេរពីការប្រើប្រាស់កម្លាំងពីរគួបផ្សំគ្នា មកកាន់ដំណាក់កាលប្រើប្រាស់កម្លាំងបដិវត្តន៍កម្ពុជាផ្ទាល់ ដើម្បីរ៉ាប់រងភារកិច្ចការពារជាតិ។ រយៈពេលដែលកងទ័ពវៀតណាមជួយបដិវត្តន៍កម្ពុជា មានជាង ១០ ឆ្នាំ។ ជាង ១០ ឆ្នាំ គឺជារយៈពេលដ៏យូរ ប៉ុន្តែបើប្រៀបធៀបជាមួយប្រទេសនានា ដែលមានសេដ្ឋកិច្ចរីកចំរើន គ្មានសង្គ្រាមបំផ្លិចបំផ្លាញដូចជាកូរ៉េខាងត្បូង ជប៉ុន បណ្តាប្រទេសអឺរ៉ុបខាងលិច ឬប្រទេសមួយចំនួនទៀត ហើយដែលត្រូវការកងទ័ពបរទេសជួយការពាររាប់សិបឆ្នាំ ឃើញថា វត្តមានកងទ័ពវៀតណាមនៅកម្ពុជាមានរយៈពេលខ្លី។ ប្រការនេះបង្ហាញពីការរីកចំរើននៃកម្លាំងផ្ទាល់របស់បដិវត្តន៍កម្ពុជា ពីសុទ្ធិៈពីលក្ខណ៍ការណ៍ស្ម័គ្រចិត្តនៃសម្ព័ន្ធភាពរវាងប្រទេសទាំងពីរកម្ពុជា-វៀតណាម។

ក្នុងក្របខ័ណ្ឌនៃភារកិច្ចស្តារ និងកសាងជាតិ គឺជាភារកិច្ចដ៏លំបាក

បំផុត សំរាប់បដិវត្តន៍កម្ពុជា។ ក្នុងការកិច្ចការពារប្រទេស មានកងទ័ពវៀតណាមជួយឧបត្ថម្ភ តែក្នុងការកិច្ចស្តារ និងកសាងប្រទេស ពិតមែនតែមានការជួយឧបត្ថម្ភរបស់វៀតណាម សហភាពសូវៀត បណ្តាប្រទេសសង្គមនិយម តែនេះជាកិច្ចការដ៏លំបាក អាស្រ័យដោយលក្ខណៈពិសេសនៃស្ថានភាពសង្គម-សេដ្ឋកិច្ចរបស់កម្ពុជាផ្ទាល់។

សង្គមមួយដែលប្រឬកប្រុបល់ក្រឡាប់ចាក់ទាំងស្រុង ការចាប់ផ្តើមពិតជាមិនដូចបដិវត្តន៍ប្រទេសនានា ដែលបានផ្តួលរំលំរបបចាស់ ហើយកសាងលើមូលដ្ឋានមានស្រាប់ ដើម្បីកែប្រែអោយរីកចំរើននោះទេ។ បដិវត្តន៍កម្ពុជា ត្រូវធ្វើឡើងវិញទាំងស្រុង ក្នុងសភាពការណ៍ដ៏សែនលំបាក និងច្របូលច្របល់។ ប៉ុន្តែក៏មានចំណុចងាយស្រួល ដែលធ្វើអោយមានស្ថេរភាពបានឆាប់ កសាងបានឆាប់ មុនបង្អស់ការបដិវត្តន៍នេះស្របនឹងក្រឹត្យក្រមសត្យានុម័ត នៃការបដិវត្តន៍របស់សង្គមមនុស្ស។ មានបក្ស មានរដ្ឋអំណាច មានកម្លាំងប្រដាប់អាវុធ មានការជួយឧបត្ថម្ភរបស់វៀតណាម និងបណ្តាប្រទេសសង្គមនិយម វាផ្តល់នូវភាពងាយស្រួលមួយជាមូលដ្ឋានរួចទៅហើយ ប៉ុន្តែបណ្តា កត្តាទាំងនេះ បានក្លាយទៅជាបច្ច័យដ៏ធំធេង នាំមកនូវជ័យជំនះដ៏អស្ចារ្យ អាស្រ័យដោយមានសកម្មភាពស្របនឹងក្រឹត្យក្រមសត្យានុម័ត ឆ្លើយតបទៅនឹងការទាមទារដ៏ចាំបាច់របស់មហាជន ហេតុនេះហើយ ប្រមូលផ្តុំបានយ៉ាងឆាប់រហ័សនូវកម្លាំងមហាជនដ៏កុះករ។ របប ប៉ុល ពតបានប្រើប្រាស់នូវនយោបាយ និងហិង្សាសុទ្ធសាធ ដើម្បីបង្កើតឡើងនូវបែបផែនផលិតកម្មមួយ ផ្ទុយទាំងស្រុងទៅនឹងក្រឹត្យក្រមរីកចំរើននៃ

*សង្គមមនុស្ស។ ដូច្នេះ វាបង្កើតឡើងដោយឯកឯង នូវទំនាស់ដ៏ជ្រាលជ្រៅក្នុងទំនាក់ទំនងផលិតកម្ម។ នេះជាទំនាស់របស់មនុស្សគ្រប់ស្រទាប់វណ្ណៈ ក្នុងសង្គមជាមួយរបប ប៉ុល ពត។ ការទាមទារជាបឋមនៃការបដិវត្តន៍ គឺលុបបំបាត់ទាំងស្រុងកាកសំណល់នៃប្រព័ន្ធរដ្ឋអំណាច ប៉ុល ពត កសាងរដ្ឋអំណាចបដិវត្ត លុបបំបាត់ចោលនូវបែបផែនផលិតកម្មបែបទាសភាពរបស់ ប៉ុល ពត បង្កើតឡើងនូវបែបផែនផលិតកម្មថ្មីដែលនេះជាក្រឹត្យក្រមសត្យានុម័តមិនអាចជៀសវាងបាន។ ដូច្នេះហើយបានជាមានការចូលរួមពីគ្រប់ស្រទាប់ប្រជាជន។ ការចូលរួមរបស់ប្រជាជននេះហើយ ដែលជាកត្តាផ្តល់ភាពងាយស្រួលដល់ការវាយរំលំរបប ប៉ុល ពត អនុវត្តភារកិច្ចការពារប្រទេស បំផ្លាញចោលជាស្វ័យប្រវត្តិនូវបែបផែនផលិតកម្មចាស់ កសាងឡើងនូវបែបផែនផលិតកម្មថ្មី។ ដូច្នេះហើយបានជាក្រោយពេលរំដោះភ្លាម ប្រជាជនមិនត្រឹមតែបានចាត់តាំងគណៈកម្មាធិការគ្រប់គ្រងខ្លួនឯង ដែលជារដ្ឋអំណាចប្រជាជនប៉ុណ្ណោះទេ ប៉ុន្តែម្ចាស់ការរៀបចំឡើងនូវទំនាក់ទំនងផលិតកម្មថ្មី ដែលទំនាក់ទំនងផលិតកម្មនោះ ស្របនឹងការចង់បានរបស់បក្សនិងរដ្ឋ ហើយស្របជាមួយសមត្ថភាពជាក់ស្តែងនៃកម្លាំងផលិតកម្មនាពេលនោះ។*

*ប្រសិនបើធ្វើការប្រៀបធៀបជាមួយបដិវត្តន៍ប្រទេសនានា ដែលក្រោយការដណ្តើមបានរដ្ឋអំណាចហើយ ហើយត្រូវដំណើរការជាបណ្តើរៗក្នុងការរៀបចំទំនាក់ទំនងផលិតកម្មថ្មី ដែលត្រូវចំណាយពេលវេលាយ៉ាងយូរនោះ ឃើញថា បដិវត្តន៍កម្ពុជាមានភាពអនុគ្រោះច្រើន ក្នុង*

ការរៀបចំទំនាក់ទំនងផលិតកម្មថ្មី អាស្រ័យដោយបែបផែនផលិតកម្មរបស់ ប៉ុល ពត ដើរផ្ទុយទាំងស្រុងជាមួយក្រឹត្យក្រម ដូច្នេះប្រជាជនគ្មានរួញរាក្នុងការបំផ្លាញវាចោល ហើយបង្កើតឡើងនូវបែបផែនផលិតកម្មថ្មីមួយជឿនលឿនឡើយ។

ថ្ងៃ ១ មករា ១៩៧៩ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានចេញនូវគោលនយោបាយ ៨ ខ ចំពោះមុខក្នុងតំបន់រំដោះ ដែលក្នុងនោះមាន និយាយដល់ការចាត់តាំងក្រុមសាមគ្គីបង្កបង្កើនផលកសិកម្ម ប៉ុន្តែអាស្រ័យពេលវេលារំដោះទូទាំងប្រទេសមានរយៈពេលខ្លី ហើយខ្វះកម្មាភិបាល ដូច្នេះស្ទើរជាទូទៅ ប្រជាជនបានម្ចាស់ការរៀបចំទំនាក់ទំនងផលិតកម្មថ្មី និងរបៀបរកស៊ីដោយខ្លួនឯង។ ទោះជាការរៀបចំដោយខ្លួនឯង ដោយគ្មានគំរូ និងទ្រឹស្តីឯកភាព ប៉ុន្តែវាស្របបំផុតជាមួយសភាពការណ៍នាពេលនោះ សំខាន់បំផុតគឺការស្របគ្នារវាងទំនាក់ទំនងផលិតកម្មជាមួយកម្លាំងផលិតកម្ម។ អាស្រ័យហេតុនេះបានជាប្រជាជនសាមគ្គីជួយទំនុកបំរុងគ្នាបាន ជំរុញផលិតកម្មដោះស្រាយជីវភាពបាន។

មានចំណុចពិសេសមួយ នៅក្នុងការរៀបចំទំនាក់ទំនងផលិតកម្មនាគ្រាដំបូង គឺ <u>ក្នុងពេលដែលប្រជាជនបំផ្លាញចោលនូវរបៀបធ្វើការស៊ីចុក ជាសមូហភាពមកកាន់របបកម្មសិទ្ធិវិញក៏ដោយ ក៏ប្រជាជននៅបានម្ចាស់ការរៀបចំឡើងនូវរបៀបរកស៊ីជាសមូហភាព ក្នុងកំរិតមួយដែលទាំងអស់គ្នាអាចទទួលយកបាន សំខាន់ក្នុងវិស័យកសិកម្ម ដោយចាត់តាំងក្រុម សាមគ្គីបង្កបង្កើនផល ឬក្រុមប្រវាស់ដៃ</u>។ គេអាច

សន្និដ្ឋានបានថា ការម្ចាស់ការរៀបចំរបស់ប្រជាជនផ្អែកលើកត្តាពីរជាសំខាន់គឺ៖

ទីមួយ៖ មធ្យោបាយ និងឧបករណ៍ផលិតកម្ម ទោះបីជាទាប និងស្តួចស្តើងក៏ដោយ ប៉ុន្តែអាស្រ័យដោយហេតុនេះហើយ ទើបទាមទារអោយប្រើធ្វើជារបស់រួមមិនអាចធ្វើផ្សេងបានឡើយ។ តាមទ្រឹស្តី ហើយតាមទម្លាប់ដែលធ្លាប់កើតមាន ក្នុងដំណើររីកចំរើននៃផលិតកម្ម កម្លាំងផលិតកម្មខ្ពស់មានចរិតសង្គមូបនីយកម្ម តម្រូវអោយរៀបចំទំនាក់ទំនងផលិតកម្មនៃរបបកម្មសិទ្ធិរួមសង្គមនិយម ទើបស្របនឹងកម្លាំងផលិតកម្ម ប៉ុន្តែនៅកម្ពុជា កម្លាំងផលិតកម្មទាបបំផុតតែបែរជាទាមទារអោយមានរូបភាពកម្មសិទ្ធិរួមមួយជាកំណត់។ មូលហេតុសំខាន់នៅទីនេះ អាស្រ័យដោយរបប ប៉ុល ពត បានរឹបអូសយកអស់នូវកម្មសិទ្ធិរបស់ប្រជាជន បំផ្លាញស្ទើរទាំងស្រុងនូវឧបករណ៍ និងមធ្យោបាយផលិតកម្ម ដូច្នេះក្រោយពេលរំដោះ ឧបករណ៍ផលិតកម្មដែលនៅសេសសល់តិចតួចនេះ វាក្លាយទៅជាកត្តាប្រមូលផ្តុំប្រជាជនអោយរួមគ្នាជុំវិញឧបករណ៍ផលិតកម្មនេះ។ ដោយគេមិនអាចចែកគ្រប់គ្នាបានដូច្នេះ គេត្រូវប្រើប្រាស់មធ្យោបាយ និងឧបករណ៍នេះរួមគ្នា។ ចេញពីនេះ គេសម្រុះសម្រួលរករូបមន្តដ៏សមស្របអំពីការចែកចាយផល។ ប្រការនេះបញ្ជាក់ថា ប្រជាជនបានអនុវត្តត្រឹមត្រូវតាមក្រឹត្យក្រម ដោយយកកម្លាំងផលិតកម្មកំណត់ទំនាក់ទំនងផលិតកម្ម។ គេពុំទាន់យល់ស្របប្រការនេះ តាមរបៀបវិទ្យាសាស្ត្រទេ តែការជាក់ស្តែងក្នុងជីវភាពរស់នៅ បានបង្ហាញអោយគេនូវវិធីដ៏សមស្របនេះ។

ទីពីរ៖ ប្រពៃណីដ៏ល្អក្នុងការជួយឧបត្ថម្ភគ្នា ក្នុងប្រជាជនកម្ពុជា ប្រការនេះ បានក្លាយជាចំណុចងាយស្រួលក្នុងការកសាងឡើងនូវទំនាក់ទំនងផលិតកម្មថ្មីដែលគ្មានការជិះជាន់ ជួយសង្គ្រោះគ្នា ធ្វើអោយកុមារកំព្រា ជនគ្មានទីពឹងពំនាក់ដ៏ច្រើន បានរស់រានមានជីវិត សម្រាលនូវបន្ទុកដ៏ធ្ងន់ធ្ងររបស់សង្គម។

ក្រៅពីទំនាក់ទំនងក្នុងវិស័យកសិកម្ម វិស័យផ្សេងទៀត ក៏បានចាប់ផ្តើមមានចរិតជារដ្ឋ ជាសមូហភាព ជាឯកជន។ ការផ្លាស់ប្តូរទំនិញបានចាប់ផ្តើមឡើងភ្លាម តាំងពីមិនទាន់មានក្រដាសប្រាក់ប្រើប្រាស់ ដោយប្រើប្រាស់ទំនិញសំភារៈ ផ្លាស់ប្តូរជាមួយគ្នា ហើយវារីកចំរើនយ៉ាងឆាប់រហ័ស បន្ទាប់ពីរដ្ឋបោះផ្សាយនូវក្រដាសប្រាក់។ តាមរយៈនៃការផ្លាស់ប្តូរទំនិញ ទំនាក់ទំនងរវាងរូបិយវត្ថុ និងទំនិញ ការរីកចំរើននៃទីផ្សារ បានជំរុញយ៉ាងខ្លាំងដល់ផលិតកម្មលើគ្រប់ផ្នែក។

អាស្រ័យដោយការប្រឹងប្រែងផ្ទាល់របស់ប្រជាជនកម្ពុជា និងដោយការជួយឧបត្ថម្ភពីអន្តរជាតិ កម្ពុជាបានឆ្លងផុតនូវដំណាក់កាលដែលពិបាកបំផុត ហើយដែលជ័យជំនះធំបំផុត គឺបំបាត់បាននូវគ្រោះអត់ឃ្លានបន្សល់ទុកពីរបប ប៉ុល ពត ធ្វើអោយមានស្ថេរភាពជីវភាពប្រជាជនបានឆាប់រហ័ស ធ្វើអោយគ្រប់ផ្នែកបានរស់រានមានជីវិតឡើងវិញ ហើយកំពុងស្ថិតក្នុងដំណាក់កាលស្តារ និងអភិវឌ្ឍន៍លើគ្រប់វិស័យ។ ប្រៀបធៀបសភាពការណ៍ពេលចេញដំណើរ ដោយបូកបន្ថែមនឹងសភាពការណ៍ដ៏លំបាកដែលបានឆ្លងកាត់ ជាមួយសភាពការណ៍នាពេលក្រោយនេះ គេអាចមើលឃើញថា កម្លាំងរស់របស់ជាតិមានកំរិត

ខ្លាំងក្លា ទូលំទូលាយ និងស៊ីជំរៅ គឺការរស់ឡើងតាំងពីបុគ្គលម្នាក់ៗ គ្រួសារនីមួយៗ ភូមិ ឃុំ នីមួយៗ រហូតដល់ទូទាំងប្រទេសលើគ្រប់ផ្នែក (*)។

អំពីការកសាងកម្លាំងពិតលើគ្រប់ផ្នែក ពិសេសការកសាងបក្សដឹកនាំ ពិតមែនតែមានចំណុចពិសេសដោយឡែក ដែលបក្សមួយត្រូវកសាងឡើងវិញ ហើយកសាងពីលើចុះក្រោម តែជំហានរីកចំរើនបានធ្វើអោយបក្សត្រួតត្រា និងដឹកនាំបានសភាពការណ៍លើគ្រប់វិស័យ ក្លាយជាកម្លាំងដឹកនាំ សំរេចកំណត់ជោគជ័យរបស់បដិវត្តន៍ (**)។

ការរស់ឡើងវិញលើគ្រប់ផ្នែករបស់ជាតិ គឺជាមោទនភាពរបស់ប្រជាជនកម្ពុជាផ្ទាល់ របស់មិត្តភក្តិ ដែលបានជួយកម្ពុជា ពិសេសវៀតណាម ឡាវ សហភាពសូវៀត និងបណ្តាប្រទេសសង្គមនិយមៗ ប៉ុន្តែទន្ទឹមនឹងគុណសម្បត្តិ ក៏គួរពិនិត្យនូវការខ្វះខាតជាអត្តនោម័ត ដើម្បីជាមេរៀនពិសោធន៍នាពេលខាងមុខៗ ការខ្វះខាតសំខាន់គឺការមិនគោរពក្រឹត្យក្រមសេដ្ឋកិច្ចសត្យានុម័តៗ ចេញពីនេះ ការកំណត់ដំណាក់កាលបដិវត្តមិនបានត្រឹមត្រូវតាមការជាក់ស្តែងនៃស្ថានភាពសង្គម ភាពគំនិតនិយម អត្តនោម័ត ឆន្ទនិយម សតិអារម្មណ៍តក់ក្រហល់បានគ្របដណ្តប់លើគោលការណ៍ និងការអនុវត្តន៍អស់មួយរយៈកាល ក្នុងក្របខ័ណ្ឌផលិតកម្ម និងរចនាសម្ព័ន្ធគ្រប់គ្រងៗ មនុស្សមិនតិចទេ ដែលចាត់ទុកថា បដិវត្តន៍កម្ពុជាបានស្ថិតក្នុងដំណាក់កាលសង្គមនិយម ដូច្នេះហើយ

(*) ១០ ឆ្នាំនៃដំណើរកម្ពុជា ១៩៧៩/១៩៨៩ ទំព័រ ២២៧/៣៣៣ សរសេរដោយ ហ៊ុន សែន បោះពុម្ព ថ្ងៃ ០១ ធ្នូ ១៩៨៨ រោងពុម្ព ណុប បូផាន់។

(**) ១០ ឆ្នាំនៃដំណើរកម្ពុជា ១៩៧៩/១៩៨៩ ទំព័រ ៤០៧/៤២៧ សរសេរដោយ ហ៊ុន សែន បោះពុម្ព ថ្ងៃ ០១ ធ្នូ ១៩៨៨ រោងពុម្ព ណុប បូផាន់។

បានជាយកចិត្តទុកដាក់តែលើចរិតវណ្ណៈនៃគោលនយោបាយ ដោយមិនបានគិតដល់ចរិតអន្តរកាល ហើយ <u>ចរិតវណ្ណៈត្រូវបានគេយល់តាមរបៀបសាមញ្ញ ឆ្វេងនិយមក្មេងខ្ចី</u> អនុវត្តមិនបានត្រឹមត្រូវនូវក្រឹត្យក្រមនៃទំនាក់ទំនងផលិតកម្ម ដែលត្រូវតែស្របជាមួយនឹងចរិត និងកំរិតនៃកម្លាំងផលិតកម្ម ចង្អៀតចង្អល់ ចំពោះសមាសភាពសេដ្ឋកិច្ចផ្សេងទៀត ក្រៅពីសមាសភាពសេដ្ឋកិច្ចរដ្ឋ សមូហភាព ប្រើប្រាស់វិធានការនយោបាយ សតិអារម្មណ៍ ធ្វើជាកម្លាំងចលករសំខាន់ខាងសេដ្ឋកិច្ច ហើយមិនយកចិត្តទុកដាក់អោយបានពេញលេញ ចំពោះកម្លាំងចលករខាងក្នុងនៃសេដ្ឋកិច្ច។ ការកែសម្រួលនូវទំនាក់ទំនងសេដ្ឋកិច្ច ក្នុងវិស័យកសិកម្ម ធ្វើដោយយឺតយ៉ាវនៅពេលដែលទំនាក់ទំនងទាំងនេះលែងសមស្របនឹងសភាពការណ៍ដែលបានផ្លាស់ប្តូរ។ ការខ្វះខាតនេះ ពុំមានន័យថា មានចរិតទំនាស់រហូតដល់ត្រូវបំផ្លាញចោលបែបផែនផលិតកម្មនោះទេ ប៉ុន្តែផ្នែកណាមួយនោះវាបន្ថយល្បឿននៃផលិតកម្ម ដែលទាមទារអោយមានការកែទម្រង់ លើចំណុចដែលលែងសមស្របជាមួយសភាពការណ៍។

ក្រោយការកែទម្រង់ ហើយដោយមានការជះឥទ្ធិពលមិនល្អពីការប្រែប្រួលនៅបណ្តាប្រទេសអឺរ៉ុបខាងកើត ការអនុវត្តន៍បាន<u>ចេញពីឆ្វេងទៅស្តាំ ដោយមើលធ្ងន់តែលើចរិតអន្តរកាល ហើយមើលស្រាលចរិតវណ្ណៈនៃគោលនយោបាយ</u> ដែលមានផ្នែកខ្លះ ការកែទម្រង់ចង់ចេញផុតពីរង្វង់ដឹកនាំ និងត្រួតត្រារបស់បក្ស និងរដ្ឋ បង្កើតជានិន្នាការឱកាសនិយមខាងនយោបាយ ទាមទារការកែទម្រង់ខាងនយោបាយលឿនជាងការ

កែទម្រង់ខាងសេដ្ឋកិច្ច ហើយឈានរហូតដល់ការទាមទារពហុនិយម ខាងនយោបាយ ដោយភ្លេចគិតដល់ស្ថានភាពពិតប្រាកដរបស់ប្រទេសជាតិ។

ការកែទម្រង់នេះជាបញ្ហាមួយ ក្នុងបញ្ហាផ្សេងៗទៀត ដែលកំពុង តែចោទឡើង។ តាំងពីពេលបានរំដោះចេញពីរបប ប៉ុល ពត បដិវត្តន៍ កម្ពុជា បាននិងកំពុងស្ថិតលើផ្លូវកែទម្រង់ជាបន្តបន្ទាប់ ពិសេសលើវិស័យ សេដ្ឋកិច្ច។ ជំហានបន្តនៃការកែទម្រង់ខាងសេដ្ឋកិច្ច គឺជាដំណើរសត្យា នុម័តដើម្បីការរីកចំរើនរបស់ប្រទេសជាតិ និងសុខមាលភាពប្រជាជន។ ការរិះរកផ្លូវអភិវឌ្ឍសេដ្ឋកិច្ចសង្គមអោយបានឆាប់រហ័ស គឺជាការកិច្ច បដិវត្តមួយ។ ប៉ុន្តែត្រូវកំណត់ច្បាស់ថា ការកែទម្រង់ខាងសេដ្ឋកិច្ច ត្រូវ ចេញដំណើរពីស្ថេរភាពខាងនយោបាយ ការបាត់ស្ថេរភាពខាងនយោ បាយ មិនត្រឹមតែមិនអាចធ្វើអោយសេដ្ឋកិច្ចរីកចំរើនប៉ុណ្ណោះទេ តែនឹង ធ្វើអោយសេដ្ឋកិច្ច មានការធ្លាក់ចុះដូចប្រទេសមួយចំនួន បានធ្វើកន្លង ទៅ។ មតិមួយចំនួន ពិសេសបណ្តាប្រទេសលោកខាងលិច ទាមទារ អោយកម្ពុជា កែទម្រង់ខាងនយោបាយ ដែលផ្តោតសំខាន់លើពហុបក្ស ពហុខាងនយោបាយ។ សភាពការណ៍កម្ពុជា ខុសប្លែកពីបណ្តាប្រទេស នៅអឺរ៉ុបខាងកើត នៅត្រង់ប្រទេសនេះ នៅមានគ្រោះគំរាមកំហែង នៃ របបប្រល័យពូជសាសន៍ ប៉ុល ពត នៅមានសង្គ្រាម។ ជាក់ស្តែងនៅ កម្ពុជាកំពុងមានពហុបក្ស ពហុខាងនយោបាយ ដែលកំពុងតស៊ូជាមួយ គ្នាលើវិស័យនយោបាយផង និងយោធាផង។ ពេលមានដំណោះ ស្រាយនយោបាយ បណ្តាបក្សដែលមានជម្លោះនឹងស្ថិតស្ថេរជាមួយគ្នា ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងមួយ។ មុនពេលមានដំណោះស្រាយ

នយោបាយ គេមិនគួរប្រឈមមុខនឹងទិសពីរក្នុងពេលជាមួយគ្នាទេ មិនគួរបង្វែរទិស ពីការទប់ទល់ជាមួយពួក ប៉ុល ពត និងសម្ព័ន្ធមិត្ត ទៅទប់ទល់ជាមួយគ្នាឯង នៅផ្ទៃក្នុងឡើយ ហើយមិនគួរបំបែកនូវការឯកភាពកម្លាំង ក្នុងការទប់ស្កាត់របបប្រល័យពូជសាសន៍ ប៉ុល ពត ដែរ។ ធ្វើយ៉ាងនេះ គឺដូចជាបើកច្រកអោយពួក ប៉ុល ពត វិលត្រឡប់មកកាន់អំណាចវិញយ៉ាងងាយស្រួល។ ប្រទេសជាច្រើនលើសកលលោក មានបក្សតែមួយដឹកនាំ ក្នុងនោះមានប្រទេសដែលជាសម្ព័ន្ធមិត្តអាមេរិក និងលោកខាងលិចផង។ ហើយក៏មានប្រទេសមួយចំនួន បានប្រកាសដាក់ប្រទេសជាតិក្នុងគ្រាអាសន្ន ឬប្រើប្រាស់ច្បាប់កំណែនទូទៅ ឬប្រើប្រាស់ច្បាប់អាជ្ញាសឹក ដើម្បីទប់ទល់ជាមួយសង្គ្រាមបំផ្លិចបំផ្លាញ។ កម្ពុជាមិនចាំបាច់ដាក់ប្រទេសក្នុងគ្រាមានអាសន្ន ឬកំណែនទូទៅ ឬច្បាប់អាជ្ញាសឹក ដែលប៉ះពាល់ចំពោះសិទ្ធិប្រជាជននោះឡើយ តែក៏មិនចាំបាច់បង្កើតបក្សច្រើននៅផ្ទៃក្នុង ដែលនាំអោយបាក់បែកកម្លាំង ប្រឆាំងនឹងការបង្កើតឡើងវិញ នូវរបបប្រល័យពូជសាសន៍នោះដែរ។

បណ្តាប្រទេសនៅអឺរ៉ុបខាងកើត មានសភាពការណ៍ផ្សេង ឯនៅកម្ពុជាមានសភាពការណ៍ផ្សេង មិនអាចអនុវត្តដូចគ្នាបានឡើយ។ បញ្ហាមានប្រជាធិបតេយ្យ ឬគ្មានប្រជាធិបតេយ្យ មិនស្ថិតនៅត្រង់ពហុបក្សនោះឡើយ វាស្ថិតនៅត្រង់បក្សកាន់អំណាច ស្តាប់យោបល់ប្រជាជន បំរើប្រជាជនដោយស្មោះឬទេ? ពង្រីកប្រជាធិបតេយ្យនៅក្នុងបក្ស និងក្នុងប្រជាជនឬទេ? ប្រជាជនកម្ពុជា ធ្លាប់បានជួបប្រទះនូវរបស់ដែលហៅថា ប្រជាធិបតេយ្យពហុបក្ស ពីឆ្នាំ ១៩៥៤-១៩៧០ និងពីឆ្នាំ

*១៩៧០-១៩៧៥ រួមមកហើយៗ ក៏ធ្លាប់ជួបប្រទះនូវប្រជាធិបតេយ្យពីឆ្នាំ ១៩៧៥-១៩៧៨ ហើយដែរ។ គេធ្លាប់បានស្លាប់ បានជាប់គុកច្រវាក់ខ្នោះឃ្នាង ពីពួកអ្នកប្រើផ្លាកប្រជាធិបតេយ្យ។ គ្រាប់បែករាប់លានតោនបានធ្លាក់លើក្បាលប្រជាជាតិនៅឥណ្ឌូចិន ពីអ្នកមានឈ្មោះថាប្រជាធិបតេយ្យសេរីនិយម។ គោលដៅរបស់បដិវត្តន៍ គឺសិទ្ធិសេរីភាព ប្រជាធិបតេយ្យពិតប្រាកដគ្មានក្លែងក្លាយ ទោះមាន ឬគ្មានពហុបក្ស ពហុខាងនយោបាយក៏ដោយ។ មិនត្រូវផ្សងព្រេងទៅតាមអ្វីដែលជាការស្រមើស្រមៃ គេត្រូវប្រាកដនិយមចំពោះបញ្ហានេះ។*

*រួមមក ការបេះគួបផ្សំដោយឈ្លាសវៃនូវបណ្តាកត្តាវិជ្ជមាន ការក្តាប់ជាប់នូវលក្ខណ៍ការណ៍ជាសារវ័ន្ត និងការអនុវត្តន៍យុទ្ធវិធីដោយរស់រវើកទន់ភ្លន់ គឺជាកត្តាចាំបាច់របស់បដិវត្តន៍កម្ពុជានាពេលនេះ។ ត្រូវក្តាប់ជាប់នូវលក្ខណ៍ការណ៍ និងគោលដៅចុងក្រោយរបស់បក្ស។ ជាមួយនោះ ត្រូវប្រើប្រាស់អោយអស់លទ្ធភាពនូវបណ្តាកត្តាវិជ្ជមានដែលអាចធ្វើបាន ដើម្បីនាំបដិវត្តន៍ឈានឡើង៕*

## ឯកសារពិចារណា


1. **ឡេនីន** - ប្រជុំស្នាដៃ - ក្បាលទី ១១ - រោងពុម្ព វឌ្ឍនភាព មូស្គូ ១៩៧៨ (ភាសាវៀតណាម)
2. **ឡេនីន** - ប្រជុំស្នាដៃ - ក្បាលទី ២៩ - រោងពុម្ព វឌ្ឍនភាព មូស្គូ ១៩៧៩ (ភាសាវៀតណាម)
3. **ឡេនីន** - ប្រជុំស្នាដៃ - ក្បាលទី ៣៤ - រោងពុម្ព វឌ្ឍនភាព មូស្គូ ១៩៧៦ (ភាសាវៀតណាម)
4. **ឡេនីន** - ប្រជុំស្នាដៃ - ក្បាលទី ៤១ - រោងពុម្ព វឌ្ឍនភាព មូស្គូ ១៩៧៨ (ភាសាវៀតណាម)
5. **ហូ ជីមិញ** - សង្គ្រាមប្រជាជនវៀតណាម - រោងពុម្ពកងទ័ពប្រជាជន, ហាណូយ ១៩៨០
6. **ហ៊ុន សែន** - ១០ ឆ្នាំនៃដំណើរកម្ពុជា «១៩៧៩ - ១៩៨៩» រោងពុម្ព ណុប បូជាន់ ភ្នំពេញ ១៩៨៨
7. **សេចក្តីព្រាងប្រវត្តិសាស្រ្តបក្សប្រជាជនបដិវត្តន៍កម្ពុជា** ភាគទី១ «១៩៣០-១៩៥៤» និងភាគទី២ «១៩៥៥-១៩៧៩» គណៈស្រាវជ្រាវប្រវត្តិសាស្រ្តមជ្ឈិមបក្ស (មិនទាន់បោះពុម្ពផ្សាយ)
8. **របាយការណ៍នយោបាយ** នៃមហាសន្និបាតបក្សប្រជាជនបដិវត្តន៍កម្ពុជា លើកទី ៥  - ១៩៨៥
9. **សេចក្តីសំរេចចិត្ត** សន្និបាតកម្មាភិបាលទូទាំងប្រទេសលើកទី ២ - ១៩៨៩
10. **យ.យ. មីហេយ៉េវ** - ប្រវត្តិសាស្រ្តសង្ខេបនៃប្រទេសកម្ពុជា រោងពុម្ព

វឌ្ឍនភាព មូស្គូ ១៩៨៥ (ភាសាខ្មែរ)

11. **សម សារី** - អំពីកិច្ចព្រមព្រៀងនៃក្រុងហ្សឺណែវ និងការបោះឆ្នោតនៅប្រទេសខ្មែរ ក្នុងសន្និសីទសាធារណៈ ថ្ងៃ ២២ សីហា ១៩៥៥ - រោងពុម្ពរាជវាំង ភ្នំពេញ ១៩៥៥
12. **សារពត៌មានប្រជាជន** «ច្បាប់ចាស់» លេខ ៩៤ - ថ្ងៃ ៨ មករា ១៩៥៧ - ភ្នំពេញ
13. **រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា** ខែ កុម្ភៈ ១៩៦២ រោងពុម្ព ក្រសួងឃោសនាការ ភ្នំពេញ
14. **រដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ** នាថ្ងៃ ១០ ឧសភា ១៩៧២ ភ្នំពេញ
15. **អំពីបដិវត្តន៍សង្គមនិយម** -ទស្សនាវដ្តីទង់បដិវត្ត - លេខពិសេស «កញ្ញា - តុលា ១៩៧៦» (ឯកសារ ប៉ុល ពត)
16. **បទឧទ្ទេសនាមរបស់ ប៉ុល ពត** ក្នុងឱកាសខួបទី ៣ នៃជ័យជំនះ ១៧ មេសា - ទស្សនាវដ្តីទង់បដិវត្ត -លេខ ៤ មេសា ១៩៧៨
17. **អំពីលទ្ធផលនៃផែនការឆ្នាំ** ១៩៧៦ (ឯកសារ ប៉ុល ពត)
18. **សរុបលទ្ធផលវគ្គរៀនសូត្រ** ឆ្នាំ ១៩៧៦ (ឯកសារ ប៉ុល ពត)
19. **របាយការណ៍សកម្មភាពរបស់មជ្ឈិមបក្ស** តាមភារកិច្ចនយោបាយរួមឆ្នាំ ១៩៧៦ (ឯកសារ ប៉ុល ពត)
20. **កំណត់ហេតុប្រជុំមជ្ឈិម** ពីថ្ងៃ ២១.៨.៧៦ - ២៣.៨.៧៦ ដើម្បីពិនិត្យជាលើកទីមួយ អំពីគំរោងផែនការ ៤ ឆ្នាំ កសាងសង្គមនិយមរបស់បក្ស ឆ្នាំ ១៩៧៧ - ១៩៨០ (ឯកសារ ប៉ុល ពត)
21. **រ៉េមី ព្រុយដូម** - សេដ្ឋកិច្ចនៃប្រទេសកម្ពុជា - សកលវិទ្យាល័យ បារាំង - ប៉ារីស ១៩៦៩ (ភាសាបារាំង)៕